# លក្ខណៈនៃសេចក្តីបរិសុទ្ធ

កម្មសិទ្ធិរបស់៖
ក្រុមជំនុំមេត្តាករុណាព្រែកអំបិល

**បកប្រែដោយ៖**

លោក អ៊ុច អភិរិន
លោក ហេល ប៉ៀល

**ផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធខ្មែរដោយ៖**

លោក អ៊ុច អភិរិន
លោក ឃុត ភារុន
លោក គៀត ចាន់ឡុន
លោក វៀម សាវឿត

រក្សាសិទ្ធិគ្រប់យ៉ាង

Copyright 2016

With thanks to God for the life and memory of

**DAVID C. HOOS SR. (1935 - 2013)**

David was a man full of faith by the grace of God. His love, support and commitment to advancing the Gospel in Cambodia is truly treasure stored in heaven. To God be the glory forever and ever. *Galatians 1:5*

**Contact Information:**

www.thechurchofmercy.org

info@thechurchofmercy.org

Cambodia:

Pastor Chheng Nuon

chhengnuon@gmail.com

(+855) 12 662 710

USA:

Pastor Bill Hale

hale.bill@live.com

(+1) 972 977 82 61

**Church of Mercy Books**

Road 21 Prek Talay, Prek Ambel Saang, Kandal Cambodia

# មាតិកា

**សេចក្តីផ្តើម**
១. អំពើបាប
២. ការញែកចេញជាបរិសុទ្ធ
៣. សេចក្តីបរិសុទ្ធ
៤. ចម្បាំង
៥. តម្លៃ
៦. ការធំចម្រើនឡើង
៧. សេចក្តីសង្ឃឹមដ៏ជាក់លាក់មួយ
៨. ចូរឲ្យដូចជាលោក ម៉ូសេ
៩. លោក ឡុត - ការព្រមាន
១០. ស្ត្រីដែលត្រូវចងចាំ
១១. ព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះគ្រីស្ទ
១២. ការស្គាល់ព្រះយេស៊ូវគ្រីស្ទ
១៣. ពួកជំនុំពិតរបស់ព្រះគ្រីស្ទ
១៤. ព្រះគ្រីស្ទតម្រូវ ឲ្យពួកជំនុំបានបរិសុទ្ធ
១៥. សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ គឺជាផ្នែកនៃសេចក្តីបរិសុទ្ធ
១៦. ការដាច់ចេញពីព្រះគ្រីស្ទ
១៧. ការលែងស្រេក !
១៨. កំណប់ទ្រព្យដែលប្រមាណមិនបាន
១៩. អ្វីដែលតម្រូវឲ្យគ្រីស្ទានមាននៅសម័យនេះ
២០. ព្រះគ្រីស្ទជាគ្រប់ទាំងអស់

# សេចក្ដីផ្ដើម

ដោយលោកគ្រូគង្វាល **ចេ ស៊ី រ៉ាល** (J.C. Ryle)

អស់រយៈពេលជាច្រើនឆ្នាំ (នៅក្នុងឆាកជីវិតរបស់លោកគ្រូ J.C. Ryle) ខ្ញុំមានជំនឿថា ភាពបរិសុទ្ធ និងការញែកខ្លួនជាបរិសុទ្ធពេញលេញមនុស្សជាច្រើនកំពុងតែធ្វេសប្រហែសចំពោះព្រះជាម្ចាស់ ។ ការកោតខ្លាចដល់ព្រះត្រូវបានគ្របដណ្ដប់ដោយសេចក្ដីខាងលោកិយ រីឯសេចក្ដីស្រឡាញ់ស្មោះត្រង់ចំពោះព្រះគ្រីស្ទវិញមិនសូវមាន ហើយខ្នាតនៃការរស់នៅជាគ្រីស្ទានបានធ្លាក់ចុះ ។ គេភ្លេចសារៈសំខាន់នៃការតាក់តែងសេចក្ដីបង្រៀនអំពីព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះ ឲ្យកាន់តែមានការចាប់អារម្មណ៍ (ទីតុស ២:១០) ។

ការប្រកាសពីគោលលទ្ធិល្អរបស់យើងគឺជាការឥតប្រយោជន៍ ប្រសិនបើជីវិតរបស់យើងមិនបានឆ្លុះបញ្ចាំងពីគោលលទ្ធិនោះ។ ការប្រកាសខ្លួនដោយមិនស្មោះត្រង់ថា ខ្លួនជាគ្រីស្ទានដែលជឿលើព្រះគម្ពីរហើយមានជីវិតបរិសុទ្ធ មិនយូរប៉ុន្មាននឹងត្រូវបានគេកត់សំគាល់ឃើញថា ជាសេចក្ដីអាម៉ាសមួយ ដែលនាំទៅរកសេចក្ដីអាប់អោនដល់សេចក្ដីជំនឿរបស់យើង ។

ការនោះពិតជាមានសារៈសំខាន់ណាស់ ប៉ុន្តែយើងគួរតែយល់ប្រធានបទទាំងមូលនៅក្នុងពន្លឺនៃការបង្រៀនរបស់ព្រះគម្ពីរវិញ ។ គោលបំណងរបស់ខ្ញុំនៅក្នុងសៀវភៅនេះ គឺព្យាយាមពន្យល់ពីអ្វីដែលបទគម្ពីរបង្រៀនពីសេចក្ដីបរិសុទ្ធ

នេះ។ ហើយដោយសារមានអ្នកខ្លះកំពុងតែបង្រៀនគំនិតខុសឆ្គងជាច្រើនអំពីប្រធានបទនេះ បានជាខ្ញុំចាប់ផ្ដើមរំលឹកដាស់តឿនឲ្យបងប្អូនប្រុងប្រយ័ត្នចំពោះគំនិតខុសឆ្គងទាំងអស់នេះ ។

## ១. តើជាការឆ្លាតវៃដែរឬទេ ដែលអ្នកខ្លះបង្រៀនថា ភាពបរិសុទ្ធរបស់អ្នកជឿ កើតមកដោយសារតែសេចក្តីជំនឿប៉ុណ្ណោះ មិនមែនដោយការខំប្រឹងប្រែងផ្ទាល់ខ្លួនរបស់អ្នកជឿនោះទេ ?

គ្មានគ្រីស្ទានដែលមានការយល់ដឹងណានឹងបដិសេធថា សេចក្តីជំនឿក្នុងព្រះគ្រីស្ទ គឺជាការចាប់ផ្តើមនៃគ្រប់ទាំងសេចក្តីបរិសុទ្ធឡើយ ។ ប្រសិនបើយើងមិនជឿដល់ទ្រង់ នោះយើងគ្មានសេចក្តីបរិសុទ្ធអ្វីទាំងអស់ ។ ជាការពិតណាស់ បទគម្ពីរបានបង្រៀនយើងថា អ្នកជឿត្រូវការការខំប្រឹងប្រែងទាំងកំលាំងកាយចិត្ត រួមទាំងសេចក្តីជំនឿ ដើម្បីសេចក្តីបរិសុទ្ធនេះ ។ សាវកដដែលនោះបានសរសេរថា «*ដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយសេចក្តីជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះ*» (កាឡាទី ២:២០) ។ ហើយគាត់បានសរសេរទៀតថា «*ខ្ញុំវាយដំរូបកាយខ្ញុំទាំងបង្ខំឲ្យចុះចូល*» (១កូរិនថូស ៩:២៧) ។ នៅត្រង់កន្លែងផ្សេងទៀតបានសរសេរថា «*ត្រូវឲ្យយើងរាល់គ្នាសំអាតខ្លួនយើង...ត្រូវឲ្យយើងរាល់គ្នាសង្វាត...ត្រូវឲ្យយើងចោលអស់ទាំងបន្ទុក*» (២កូរិនថូស ៧:១; ហេព្រើរ ៤:១១, ១២:១) ។

យោងតាមការបង្រៀនរបស់ព្រះគម្ពីរ មានភាពខុសគ្នាមួយរវាង របៀបដែលសេចក្តីជំនឿរាប់យើងជាសុចរិត និង របៀបដែលសេចក្តីជំនឿញែកយើងជាបរិសុទ្ធ ។ សេចក្តីជំនឿដែលរាប់ជាបរិសុទ្ធ គឺជាព្រះគុណមួយដែលទុកចិត្ត សំរាកពឹងលើព្រះគ្រីស្ទ (រ៉ូម ៤:៥) ។ អស់អ្នកដែលគ្រាន់តែជឿ បានរាប់ជាសុចរិត ។

សេចក្តីជំនឿដែលបានរាប់ជាបរិសុទ្ធ គឺជាព្រះគុណមួយដូចជា រ៉ឺស័រដ៏សំខាន់របស់នាឡិកាអញ្ចឹង ដែលវារុញច្រានអ្នកជឿទៅកាន់សេចក្តីបរិសុទ្ធ *មានប្រយោជន៍តែសេចក្តីជំនឿ ដែលប្រព្រឹត្តិដោយសេចក្តីស្រឡាញ់ប៉ុណ្ណោះ* (កាឡាទី ៥:៦)។ គ្មានកន្លែងណាមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែលនិយាយពី «សេចក្តីបរិសុទ្ធដោយសេចក្តីជំនឿ»ទេ។ ព្រះគម្ពីរបានប្រាប់ថា យើងត្រូវបានរាប់ជាសុចរិតដោយសេចក្តីជំនឿដោយគ្មានការប្រព្រឹត្តិតាមក្រិត្យវិន័យ តែគ្មានកន្លែងណាមួយដែលប្រាប់ថា យើងត្រូវបានរាប់ជាបរិសុទ្ធ ដោយគ្មានការប្រព្រឹត្តិតាមក្រិត្យវិន័យនោះឡើយ។ ផ្ទុយទៅវិញ យើងដឹងថា សេចក្តីជំនឿក៏បែបដូច្នេះដែរ បើគ្មានការប្រព្រឹត្តិតាមទេ នោះក៏ស្លាប់នៅតែឯង (យ៉ាកុប ២:១៧)។

## ២. តើជាការឆ្លាតវៃដែរឬទេដែលអ្នកខ្លះគិតថា ការលើកទឹកចិត្តឲ្យមានសេចក្តីបរិសុទ្ធនៅក្នុងសេចក្តីអធិប្បាយនៅលើភ្នំ និងផ្នែកខាងចុងនៃសំបុត្ររបស់សាវកប៉ុល ជារឿងមិនសូវសំខាន់?

គ្មានអ្នកជឿដែលមានការយល់ដឹងណាប្រឆាំងនឹងសេចក្តីត្រូវការនៃការដើរជាទៀងរាល់ថ្ងៃជាមួយនឹងព្រះទេ ហើយក៏មិនប្រឆាំងនឹងសេចក្តីត្រូវការនៃទម្លាប់ទៀងទាត់មួយក្នុងសេចក្តីអធិស្ឋាន និងការសញ្ជឹងគិត អំពីការយាងមកវិញរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទដែរ។ ព្រះគម្ពីរសញ្ញាថ្មីមិនមែនជាគំនិតដែលបង្រៀនយើងរាល់គ្នាជាពាក្យទូទៅនោះទេ ប៉ុន្តែយើងបានរកឃើញថា ព្រះគម្ពីរសញ្ញាថ្មីបានចែងពីសេចក្តីលំអិត និងសេចក្តីជាក់លាក់ជាច្រើនវិញ។

អំពីការប្រើប្រាស់អណ្តាតរបស់យើង អំពីអារម្មណ៍របស់យើង អាកប្បកិរិយារបស់យើងក្នុងនាមជាឪពុកម្តាយឬកូន អំពីចៅហ្វាយ ឬបាវបំរើ អំពីប្តី

ប្រពន្ធ អ្នកគ្រប់គ្រង ប្រធានបទនានា ឥរិយាបថនៅពេលឈឺ នៅពេលមានសុខភាពល្អ មានឬក្រ។ ទាំងអស់នេះសុទ្ធតែជាអ្វីដែលព្រះគម្ពីរបានថែងយ៉ាងលំអិត។ សេចក្ដីបរិសុទ្ធលើសជាងទឹកភ្នែក និងការដកដង្ហើមធំ ការរំភើបខាងរូបកាយ សេចក្ដីស្រឡាញ់ដល់អ្នកអធិប្បាយណាមួយ ឬពួកជំនុំណាមួយ ខ្លាំងណាស់។ សេចក្ដីបរិសុទ្ធកំពុងតែឲ្យបានត្រឡប់ដូច ជារូបអង្គនៃព្រះរាជបុត្រាទ្រង់ (រ៉ូម ៨: ២៩)។ សេចក្ដីបរិសុទ្ធជាអ្វីដែលអាចបង្ហាញឲ្យអ្នកដទៃទៀតបានឃើញ តាមរយៈឥរិយាបថ ទម្លាប់ និងអាកប្បកិរិយាប្រចាំថ្ងៃរបស់យើង។

## ៣. តើជាការវ័យឆ្លាតដែរឬទេ ដែលគេបង្រៀនថា វាអាចទៅរួច ដែលអ្នកជឿម្នាក់បានពេញខ្នាតនៃសេចក្ដីបរិសុទ្ធនៅក្នុងជីវិតនេះ?

ជាការពិតណាស់ នៅក្នុងបទគម្ពីរ អ្នកជឿត្រូវបានដាស់តឿនឥតឈប់ឈរក្នុង*គោលបំណងឲ្យមានសេចក្ដីគ្រប់លក្ខណ៍* (២កូរិនថូស ១៣:១)។ ប៉ុន្តែខ្ញុំមិនដែលឃើញបទគម្ពីរមួយដែលបង្រៀនថា ការរួចពីអំពើបាបទាំងស្រុងគឺអាចទៅរួច ឬមានគេធ្លាប់ទៅដល់ នៅក្នុងជីវិតនេះដោយអ្នកជឿណាមួយនោះឡើយ។ សេចក្ដីគ្រប់លក្ខណ៍ដែលមានកំរិតខ្ពស់មួយអាចទៅរួច ប៉ុន្តែសេចក្ដីគ្រប់លក្ខណ៍ដ៏ពិតប្រាកដវិញ គ្មានអ្នកបរិសុទ្ធណាម្នាក់របស់ព្រះនៅជំនាន់ណាមួយ ធ្លាប់អះអាងពីវាទេ។ ហើយពួកបរិសុទ្ធល្បីៗក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរដូចជា៖ ស្តេចដាវីឌ សាវ៉កប៉ុល សាវ៉ក យ៉ូហាន បានប្រកាសដោយគ្មានការស្ទាក់ស្ទើរថា ពួកគេមានសេចក្ដីកម្សោយ និងអំពើបាប នៅក្នុងចិត្តរបស់ពួកគេ។

ខ្ញុំត្រូវតែគិតថា ពួកអ្នកដែលប្រកាសពី សេចក្ដីគ្រប់លក្ខណ៍ឥតមានបាបសោះនៅក្នុងជីវិតនេះ ស្គាល់ពីលក្ខណៈនៃអំពើបាប ឬពីសេចក្ដីបរិសុទ្ធរបស់ព្រះ

តិចណាស់ ។ ខ្ញុំប្រឆាំងដាច់ខាតពីការបង្រៀនដែលមិនទៅតាមព្រះគម្ពីរនេះ ដ្បិតវាជាជំនឿដែលខុសឆ្គងដ៏មានគ្រោះថ្នាក់ ។ វាធ្វើឲ្យអ្នកដែលមានសុភនិច្ឆ័យល្អ មិនអាចទទួលយកបាន ហើយធ្វើឲ្យពួកគេអាក់អន់ស្រពន់ចិត្តពីសេចក្តីជំនឿ ដោយព្រោះតែពួកគេឃើញថា គំនិតនោះមិនត្រឹមត្រូវ ។ វាធ្វើឲ្យកូនសំណប់របស់ព្រះមួយចំនួនមិនសប្បាយរីករាយ ដែលពួកគេមានអារម្មណ៍ថា ពួកគេនៅឆ្ងាយពីការទៅដល់សេចក្តីគ្រប់លក្ខណ៍នោះ ហើយវាធ្វើឲ្យអ្នកដែលមានជំនឿខ្សោយៗមានអំនួតនៅពេលដែលពួកគេស្រមើស្រមៃថា ពួកគេជាអ្វីម្យ៉ាង នៅខណៈដែលពួកគេមិនជាអ្វីសោះនោះ។

## **៩. តើជាភាពវៃឆ្លាតដែរឬទេ ដែលគេអះអាងយ៉ាងម៉ឺងម៉ាត់ថា គម្ពីររ៉ូម ជំពូក៧ មិនពិពណ៌នាពីបទពិសោធន៍នៃពួកបរិសុទ្ធ តែពីបទពិសោធន៍នៃអ្នកដែលមិនបានកើតជាថ្មីវិញ ?**

នេះជាចំនុចមួយដែលមាននៅក្នុងការវែកញែក តាំងពីសម័យសាវក ប៉ុល ។ ប៉ុន្តែគេច្បាស់ជានិយាយថា ពួកកែទំរង់ ពួកសមាជិកប្រូតេស្តង់ទាំងអស់ព្រមទាំងសិស្សជាច្រើនដទៃទៀត សុទ្ធតែយល់ព្រមថា នៅត្រង់នេះសាវក ប៉ុលពិពណ៌នាពីបទពិសោធន៍នៃអ្នកជឿ។ (លោក រ៉ាល (Ryle) ចង្អុលបង្ហាញបញ្ជីឈ្មោះមួយ ដែលមានរាប់បញ្ចូលទាំង ហាលឌេន (Haldane) និង អូវិន (Owen) ជាអ្នកការពារគោលជំហរដែលថា សាវក ប៉ុល គឺកំពុងសរសេរពីបទពិសោធន៍បច្ចុប្បន្នរបស់គាត់)។ ប្រសិនបើពួកកែទំរង់ និងពួកប្រូតេស្តង់ ទាត់ចោលគំនិតនេះមានន័យថាពួកគេល្ងង់ខ្លៅ។

**៥. តើជាការឆ្លាតវៃឬទេ បើយើងផ្តោតយកចិត្តទុកដាក់ខ្លាំងពេកលើពាក្យថា "ព្រះគ្រីស្ទនៅក្នុងយើង" មិនទៅតាមសេចក្តីបង្រៀននៃព្រះគម្ពីរនោះ?**

ពិតមែនហើយ ពាក្យនេះមាននៅក្នុងបទគម្ពីរៈ (រ៉ូម ៨:១០; កាឡាទី ២:២០; អេភេសូរ ៣:១៧; កូល៉ុស ៣:១១)។ ហើយអ្នកខ្លះលើកឡើងថា យើងត្រូវយល់សេចក្តីពិតនេះក្នុងន័យមួយដែលថា អ្នកជឿមិនទទួលខុសត្រូវចំពោះអ្វីដែលខ្លួនធ្វើទេ ពីព្រោះគេមានព្រះគ្រីស្ទនៅក្នុងពួកគេហើយ ដែលទ្រង់ធ្វើអ្វីៗគ្រប់យ៉ាង។ ការយល់បែបនេះមិនមែនជាការត្រឹមត្រូវទេ។

ការដែលអះអាងបែបនេះគឺជាការដែលមិនយកចិត្តទុកដាក់ចំពោះសេចក្តីពិតដែលថា វត្តមានរបស់ព្រះគ្រីស្ទនៅក្នុងអ្នកជឿ តាមរយៈវត្តមានព្រះវិញ្ញាណបរិសុទ្ធ។ ព្រះគ្រីស្ទដ៏ជាសង្ឃដែលរស់ពីសុគតឡើងវិញ ទ្រង់គង់នៅខាងស្តាំព្រះជាម្ចាស់ កំពុងតែអង្វរជំនួសរាស្ត្រទ្រង់ រហូតទាល់តែទ្រង់យាងត្រឡប់មកវិញជាថ្មីម្តងទៀត។ *គឺជាព្រះវិញ្ញាណបរិសុទ្ធដែលជាព្រះដ៏ជាជំនួយ...បានគង់នៅជាមួយនៅអស់កល្បរៀងទៅ*(យ៉ូហាន ១៤:១៦) ដើម្បីសំរេចកិច្ចការដ៏ពិសេសរបស់ទ្រង់ក្នុងការរំលឹកដាស់តឿនយើងនៅក្នុងការញែកជាបរិសុទ្ធ។ ចូរកុំភ្លេចថា សេចក្តីពិតដែលត្រូវគេបានបំផ្លែង ដូចជាអ្នកខ្លះបានបំផ្លែងសេចក្តីពិតអំពី "ព្រះគ្រីស្ទគង់នៅក្នុងយើង" នេះ គឺជាចំនុចចាប់ផ្តើមនៃជំនឿខុសឆ្គងដ៏គ្រោះថ្នាក់។

**៦. តើជាការឆ្លាតវៃដែរឬទេ ដែលអ្នកខ្លះបានបំបែក ការផ្លាស់ប្រែ និងការញែកជាបរិសុទ្ធ ឬ "ជីវិតដែលកាន់តែបរិសុទ្ធ" ចេញពីគ្នានោះ ?**

មានទស្សនៈមួយពោលថា គ្រីស្ទានមានពីរប្រភេទ គឺពួកអ្នកដែលបានផ្លាស់ប្រែ ហើយនិងពួកអ្នកដែលរីករាយនឹងជីវិតដែលកាន់តែបរិសុទ្ធនៃការញែក

ជាបរិសុទ្ធ ។ គេវែកញែកថា អាចនឹងមានការលោតផ្លោះលឿនរហ័សពីការផ្លាស់ប្រែ ទៅកាន់ការញែកជាបរិសុទ្ធ គឺប្រៀបដូចជា អ្នកជឿត្រូវការការផ្លាស់ប្រែជាលើកទីពីរអ៊ីចឹង ។ ខ្ញុំគិតថា អ្នកដែលប្រើប្រាស់ភាសាបែបនោះ មានទស្សនៈទាបអំពីការផ្លាស់ប្រែ។

មានតែមួយផ្នែកប៉ុណ្ណោះដែលនិយាយតាមព្រះបន្ទូលនៃព្រះ គឺ រវាងអ្នកជឿ និងអ្នកមិនជឿ ហើយនិងរវាងអ្នកដែលមានជីវិតខាងព្រលឹងវិញ្ញាណ និងអ្នកដែលស្លាប់ខាងព្រលឹងវិញ្ញាណ ។ នៅក្នុងក្របខ័ណ្ឌក្រុមទាំងពីរនេះ បង្ហាញយ៉ាងច្បាស់ពីភាពខុសគ្នានៃអំពើបាប និងព្រះគុណ ។ ហើយសម្រាប់អ្នកជឿ ត្រូវតែមានការធំចម្រើនឡើងជាលំដាប់ នៅក្នុងព្រះគុណ ចំណេះដឹង និងគំនិតខាងព្រលឹងវិញ្ញាណ ។ ប៉ុន្តែការលោតផ្លោះលឿនរហ័សពីការផ្លាស់ប្រែ ទៅកាន់ការញែកចេញជាបរិសុទ្ធវិញ ខ្ញុំមិនបានឃើញមាននៅក្នុងព្រះគម្ពីរទេ ។

ខ្ញុំពិតជាឆ្ងល់ណាស់ថា តើមនុស្សម្នាក់អាចទទួលបានការផ្លាស់ប្រែឬទេ ប្រសិនបើគាត់មិនបានរាប់ជាបរិសុទ្ធនៅចំពោះព្រះផងនោះ ។ គេកាន់តែបរិសុទ្ធឡើងៗរហូត នៅពេលដែលព្រះគុណរបស់ព្រះធំចម្រើនឡើងនៅក្នុងពួកគេ ។ ប៉ុន្តែដែលគេលើកឡើងថា មនុស្សម្នាក់អាចមានបទពិសោធន៍នឹងកំណើតថ្មី តែមិនត្រូវបានញែកជាបរិសុទ្ធ ចំពោះខ្ញុំ គិតថា ការលើកឡើងនេះ គឺជាយល់ដឹងដ៏កំសោយពីអត្ថន័យនៃការផ្លាស់ប្រែ ។

**៧. តើជាការវៃឆ្លាតឬទេ ដែលបង្រៀនអ្នកជឿថា ពួកគេមិនត្រូវគិតពីការតស៊ូប្រឆាំងនឹងអំពើបាប ប៉ុន្តែត្រូវប្រគល់ខ្លួនទៅព្រះវិញ ?**

ឃ្លាថា *ប្រគល់ខ្លួន* កើតឡើងតែម្តងប៉ុណ្ណោះនៅក្នុងគម្ពីរសញ្ញាថ្មី (រ៉ូម ៦:១៣-១៩)។ នៅក្នុងខទាំងនោះពាក្យថា *ការប្រគល់ខ្លួន* គឺនិយាយពីកាតព្វកិច្ចជាអ្នកជឿ ។ ប៉ុន្តែពាក្យថា "ប្រគល់" មិនមានន័យថាប្រគល់ខ្លួនដោយអសកម្មទៅក្នុងកណ្តាប់ដៃអ្នកណាម្នាក់នោះទេ ។ តែវាមានន័យថា ជាការប្រគល់ខ្លួនយ៉ាងសកម្មសំរាប់ការប្រើប្រាស់ដល់អ្នកដទៃ ទុកដូចជា*ប្រគល់ខ្លួនទៅព្រះ* (រ៉ូម ៦:១៣)។

ទោះជាយ៉ាងណាក៏ដោយ មានបទគម្ពីរចំនួន២០ ឬ៣០ កន្លែងដែលបង្រៀនថា អ្នកជឿមិនមែនអង្គុយតែមួយកន្លែងទេ ប៉ុន្តែត្រូវងើបឡើង ហើយធ្វើការ ។ សង្គ្រាម ចម្បាំង ជីវិតទាហាន ការបោកចំបាប់ សុទ្ធតែនិយាយអំពីលក្ខណៈនៃជីវិតគ្រីស្ទាន ។ តើមានមូលហេតុអ្វីទៀត ដែល*យើងគួរពាក់គ្រឿងសឹករបស់ព្រះ ?* (អេភេសូរ ៦:១០-១៨) ។

មនុស្សនឹងបន្តការភាន់ច្រឡំការពីរដែលខុសគ្នា ។ នៅក្នុងការរាប់ជាសុចរិត ព្រះគម្ពីរប្រាប់យើងឲ្យជឿ យើងគ្រាន់តែជឿ រីឯនៅក្នុងការញែកជាបរិសុទ្ធវិញ ព្រះគម្ពីរប្រាប់យើងឲ្យចាំយាម អធិស្ឋាន និងតស៊ូ។

ខ្ញុំបញ្ចប់សេចក្តីផ្តើមរបស់ខ្ញុំនៅត្រង់នេះដោយចិត្តថប់បារម្ភខ្លាំង។ មានឥរិយាបថមួយក្នុងចំណោមអ្នកដែលប្រកាសថាខ្លួនជាគ្រីស្ទាននៅសម័យនេះ (ឧះដូចជានៅសតវត្សទី១៩) ធ្វើឲ្យខ្ញុំពេញដោយការព្រួយបារម្ភសម្រាប់អនាគត ។ គួរឲ្យភ្ញាក់ផ្អើលណាស់ មនុស្សជាច្រើនមិនមានការយល់ដឹងពីបទគម្ពីរ នោះដោយព្រោះតែខ្វះសេចក្តីជំនឿពិត ។ មានរស់ជាតិបន្ថែមថ្មីដែលធ្វើឲ្យមានការរំជើបរំជួលផ្នែកអារម្មណ៍។ មានមនុស្សមូលគ្នាច្រើនកុះករដើម្បីមកស្តាប់សម្លេងថ្មី និងការបង្រៀនថ្មី ដោយមិនបានគិតពិចារណាពីអ្វីដែលពួកគេឮថាតើត្រឹមត្រូវឬយ៉ាងណានោះទេ ។ មានតែហ្វូងមនុស្សកុះករ សម្រែកបោកព្រៀវ និងការរំភើបឥតឈប់ឈរខាង

អារម្មណ៍ប៉ុណ្ណោះដែលមនុស្សជាច្រើនយកចិត្តទុកដាក់។ ដរាបណាគ្រូអធិប្បាយនោះមាន «ភាពឆ្លាតវៃ» និង «ភាពម៉ឺងម៉ាត់» មនុស្សជាច្រើនហាក់ដូចជាគិតថា វាមិនមានបញ្ហាអ្វីទេ ។

បំណងចិត្តនិងសេចក្តីអធិស្ឋានជាប្រចាំថ្ងៃរបស់ខ្ញុំគឺថា សូមឲ្យសេចក្តីបរិសុទ្ធផ្ទាល់ខ្លួនរបស់ខ្ញុំបានចម្រើនឡើងកាន់តែខ្លាំងឡើង នៅក្នុងចំណោមបងប្អូនដែលប្រកាសខ្លួនថាជាពួកគ្រីស្ទាន ។ ហើយខ្ញុំទុកចិត្តថា អស់អ្នកដែលខំព្យាយាមធ្វើឲ្យសេចក្តីបរិសុទ្ធផ្ទាល់ខ្លួនកាន់តែចម្រើនឡើង បានជាប់ជិតស្និតនឹងអ្វីដែលបទគម្ពីរបង្រៀន ហើយបែងចែកយ៉ាងប្រុងប្រយ័ត្នពីសេចក្តីបង្រៀនដែលខុសគ្នាគឺថា *បើឯងនឹងញែករបស់ថ្លៃវិសេសចេញពីរបស់ស្មោកគ្រោក* នោះឯងនឹងបានដូចជាមាត់អញ នេះគឺអ្វីដែលព្រះយេហូវ៉ាមានបន្ទូល (យេរេមា ១៥:១៩) ។

## ជំពូក ១

## អំពើបាប

*អំពើបាបជាការរំលងក្រឹត្យវិន័យ* (១យ៉ូហាន ៣:៤)

ការស្គាល់អំពើបាប គឺជាមូលដ្ឋានគ្រឹះនៃការយល់ដឹងដ៏ពិតប្រាកដមួយអំពីជំនឿលើព្រះគ្រីស្ទ។ ប្រសិនបើគ្មានសេចក្ដីពិតដូចជា ការរាប់ជាសុចរិត ការផ្លាស់ប្រែ និងការញែកជាបរិសុទ្ធទេ ការទាំងនោះគ្រាន់តែជាពាក្យ និងឈ្មោះប៉ុណ្ណោះ។ ការដំបូងដែលព្រះធ្វើ នៅពេលដែលទ្រង់ទាញមនុស្សមកឯទ្រង់ គឺជាការដែលទ្រង់ប្រទានឲ្យពួកគេនូវការភ្ញាក់រលឹកខាងក្នុងមួយថា ពួកគេជាមនុស្សបាបដែលមានទោស ។ ការបង្កើតពិភពលោក បានចាប់ផ្ដើមជាមួយនឹងការមកនៃពន្លឺ (លោកុប្បត្តិ ១:៣) ដូចគ្នានឹងការភ្ញាក់រលឹកនៃអំពើបាប គឺជាការចាប់ផ្ដើមការបង្កើតមនុស្សខាងឯវិញ្ញាណម្នាក់ដែរ។ ព្រះជាម្ចាស់បំភ្លឺចិត្តរបស់យើង ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបន្ទាប់មកជីវិតខាងឯវិញ្ញាណក៏បានចាប់ផ្ដើមឡើង (២កូរិនថូស ៤:៦) ។

## ១. អត្ថន័យនានានៃអំពើបាប

អំពើបាប ជាជំងឺខាងសីលធម៌ដ៏ធំមួយដែលធ្វើឲ្យប៉ះពាល់ដល់មនុស្សជាតិទាំងមូល ។ អំពើបាប មាននៅក្នុងទង្វើ ការនិយាយ ការគិត ឬការស្រមើស្រមៃដល់

អ្វីមួយដែលមិនទៅតាមគំនិតនិងតាមក្រឹត្យវិន័យរបស់ព្រះ ឲ្យបានមួយរយភាគរយ។ ការប្តូរផ្លាស់ខាងក្រៅ ឬខាងក្នុងតែបន្តិចដែលខុសពីព្រះហឫទ័យ និងចរិតលក្ខណៈដែលបើកសំដែងរបស់ព្រះ នោះជាអំពើបាប ហើយ អំពើបាបនោះ ធ្វើឲ្យយើងមានទោសនៅចំពោះព្រះ មួយរំពេច។ ជាការងាយស្រួលណាស់ ក្នុងការរំលងក្រឹត្យវិន័យរបស់ព្រះនៅក្នុងគំនិត និងសេចក្តីប៉ងប្រាថ្នារបស់យើង ទោះបីជាយើងមិនអាចមើលឃើញពីសកម្មភាពនៃសេចក្តីអាក្រក់នោះក៏ដោយ ។ ព្រះអម្ចាស់របស់យើងបានមានបន្ទូលអំពីចំណុចនេះយ៉ាងច្បាស់ នៅក្នុងការអធិប្បាយរបស់ទ្រង់នៅលើភ្នំ (ម៉ាថាយ ៥:២១-២៨) ។

ជាការងាយស្រួលផងដែរ ក្នុងការរំលងក្រឹត្យវិន័យរបស់ទ្រង់ដោយការមិនបានធ្វើអ្វីមួយដែលព្រះតម្រូវឲ្យធ្វើ ។ ព្រះយេស៊ូវបានបញ្ជាក់ការនេះយ៉ាងច្បាស់ម្តងទៀតថា៖ *អញបានឃ្លាន តែឯងរាល់គ្នាមិនបានឲ្យបរិភោគទេ អញបានស្រេក តែឯងរាល់គ្នាមិនបានឲ្យផឹកទេ* (ម៉ាថាយ ២៥:៤១-៤៣) ។ ហើយខ្ញុំត្រូវតែរំលឹកអ្នកថា ការនោះអាចទៅរួចដែលយើងប្រព្រឹត្តិអំពើបាប ដោយព្រោះតែការមិនអើពើ។ ព្រះជាម្ចាស់បានបង្រៀនដល់ប្រជាជនអ៊ីស្រាអែលថា មានអំពើបាបនៃការមិនអើពើ (លេវីវិន័យ ៤)។ ទ្រង់បានបញ្ជាក់ការនោះដោយមានបន្ទូលថា *អ្នកណាដែលមិនបានស្គាល់ តែបានប្រព្រឹត្តិ គួរនឹងត្រូវវំពាត់* (លូកា ១២:៤៨)។ យើងត្រូវចងចាំឲ្យច្បាស់ថា ចំណេះដឹងមិនគ្រប់លក្ខណ៍របស់យើង មិនមែនជារបៀបនៃការវាយតម្លៃអំពើបាបរបស់យើងនោះទេ!

## ២. ដើមកំណើត និងប្រភពនៃអំពើបាប

អំពើបាបរបស់យើង មិនបានចាប់ផ្តើមពីផ្នែកខាងក្រៅរបស់យើងនោះទេ ប៉ុន្តែពីផ្នែកខាងក្នុងរបស់យើងវិញ ។ អំពើបាបមិនមែនជាលទ្ធផលនៃការបង្ហាត់បង្រៀនកាលពីយើងនៅក្មេងនោះទេ។ វាមិនមែនទើបតែកើតពីអ្នកជិតខាងអាក្រក់ និងគំរូអាក្រក់នានានោះដែរ ។ ទេ ! វាគឺជាជំងឺតពូជដែលយើងមានតាំងពីកំណើតមកម្ល៉េះ ដែលយើងបានទទួលមរតកពីឪពុកម្តាយដើមដំបូងរបស់យើង គឺលោកអ័ដាម និងនាងអេវ៉ា ។ *បាបបានចូលមកក្នុងលោកិយដោយសារមនុស្សតែម្នាក់*...(រ៉ូម ៥:១២) ។ ទារកដ៏ស្រស់ស្អាតបំផុតដែលកើតមកនៅក្នុងឆ្នាំនេះ មិនមែនជា "របស់តូចមួយដែលអត់មានបាប" នោះទេ តែគឺជាមនុស្សមានបាបម្នាក់វិញ ។ ចូរអ្នកមើលវានៅពេលវាកំពុងលូតលាស់ ហើយមិនយូរប៉ុន្មាន អ្នកនឹងឃើញមានមេរោគនានានៅក្នុងក្មេងនោះជាមិនខាន ដូចជា កុបាក កំហឹង អាត្មានិយម ចង់ធ្វើតាមតែចិត្ត រឹងរូស លោភ ច្រណែន ងប់ងុល -- ការទាំងអស់នេះនឹងរីកដុះដាលយ៉ាងលឿនដូចជាស្រមៃនៅក្នុងស្រែ ប្រសិនបើបណ្តែតបណ្តោយ និងទុកចោលឲ្យនៅម្នាក់ឯង ។ តើអ្នកណាបានបង្រៀនការទាំងអស់នេះ ? មានតែព្រះគម្ពីរប៉ុណ្ណោះដែលអាចឆ្លើយនឹងសំនួរនេះបាន ! *ដ្បិតនៅពីខាងក្នុង ពីក្នុងចិត្តរបស់មនុស្ស មានចេញអស់ទាំងគំនិតអាក្រក់យ៉ាងនេះ គឺ សេចក្តីកំផិត សហាយស្មន់ កាប់សម្លាប់គេ លួចប្លន់ លោភា ខិលខូច ឧបាយកល អាសអាភាស ភ្នែកអាក្រក់ ជេរប្រមាថ ឆ្មើងឆ្មៃ និងសេចក្តីចំកួត គឺសេចក្តីអាក្រក់ទាំងនេះហើយ ដែលចេញពីខាងក្នុងមក ហើយធ្វើឲ្យមនុស្សស្មោកគ្រោកវិញ* (ម៉ាកុស ៧:២១-២៣) ។

**៣. អំពីទំហំនៃអំពើបាប**

យើងមិនត្រូវធ្វើខុសត្រង់ចំនុចនេះទេ គឺថា កន្លែងដែលមានសុវត្ថិភាពតែមួយសម្រាប់ការយល់ដឹងរបស់យើង គឺជាអ្វីដែលព្រះគម្ពីរបានបង្រៀន។ *អស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ច* (លោកុប្បត្តិ ៦:៥)។ *ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់* (យេរេមា ១៧:៩)។ អំពើបាបជាជំងឺមួយដែលជ្រាបចូលគ្រប់ទាំងផ្នែកនៃគំនិតយើងដូចជា ការយល់ដឹង, និងសេចក្ដីស្រឡាញ់ ការត្រិះរិះពិចារណា ឆន្ទៈ ទាំងអស់នេះសុទ្ធតែបានឆ្លងរាលដាល។ សូម្បីតែបញ្ញាចិត្តក៏ត្រូវបានធ្វើឲ្យខ្វាក់ ដូច្នេះហើយបានជាយើងមិនអាចយកវាជាទីពឹង ក្នុងរបៀបមួយជាអ្នកនាំផ្លូវបានទេ លើកលែងតែព្រះវិញ្ញាណបរិសុទ្ធបានបំភ្លឺមកប៉ុណ្ណោះ។

ការទាំងអស់នេះអាចនឹងត្រូវបានលាក់បាំងដោយការបង្ហាញភាពគួរសមខាងក្រៅ។ ជាការពិតដែលមនុស្សមានសមត្ថភាពពិសេស ហើយពូកែខាងបង្ហាញសមត្ថភាពផ្នែកសិល្បៈ វិទ្យាសាស្ត្រ និងអក្សរសិល្ប៍។ ប៉ុន្តែសេចក្ដីពិតនោះ នៅតែថា យើងជា «មនុស្សស្លាប់» ក្នុងសេចក្ដីខាងឯវិញ្ញាណវិញ។ ជានិច្ចជាកាល យើងគ្មានសេចក្ដីកោតខ្លាច ឬសេចក្ដីស្រឡាញ់ដល់ព្រះនៅក្នុងចិត្តរបស់យើងទេ។ អ្វីដែលប្រសើរបំផុតនៅក្នុងយើង គឺត្រូវបានលាយឡំនឹងអំពើពុករលួយដែលបំរើសម្រាប់តែបង្ហាញពីទំហំនៃអំពើបាបនៅក្នុងយើងតែប៉ុណ្ណោះ។

អំណាចនៃអំពើបាបគឺយ៉ាងដូច្នេះឯង សូម្បីតែបន្ទាប់ពីយើងមានបទពិសោធន៍ការផ្លាស់ប្រែដោយកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធក៏ដោយ ក៏គង់តែយើងមានអារម្មណ៍ដឹងពីកំលាំងរបស់វានៅក្នុងយើងដដែល។ យើងមិនដែលនឹងដកខ្លួនយើងចេញពីឫសនៃអំពើបាបដែលនៅក្នុងយើងបានទេ។ កន្លែងដែលអ្នកជឿត្រូវយកចិត្តទុកដាក់ គឺ យើងទាំងអស់គ្នា អាចដឹងប្រាកដច្បាស់ថា អំពើបាបកាន់តែខ្សោយទៅៗ និងត្រូវបានពិនិត្យដោយសារព្រះគុណរបស់ព្រះដែលនៅក្នុងយើង។

ប៉ុន្តែចម្បាំងដែលយើងត្រូវតែច្បាំងជារៀងរាល់ថ្ងៃរវាងសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម និងសេចក្តីប៉ងប្រាថ្នាខាងព្រលឹងវិញ្ញាណ ធ្វើបន្ទាល់ពីអំណាច និងកំលាំងដ៏ធំនៃអំពើបាប ។

ខ្ញុំនឹងថា គ្មានភស្តុតាងណាទៀតក្នុងបទគម្ពីរអំពីប្រភពរបស់មនុស្សជាតិ ដែលខ្លាំងជាងសាកលភាពនៃអំពើបាបនេះទេ។ ប្រសិនបើយើងទទួលស្គាល់ថា មនុស្សជាតិជាពូជរបស់មនុស្សពីរនាក់ ហើយមនុស្សពីរនាក់នោះបានបះបោរប្រឆាំងនឹងព្រះ នោះគេអាចវិនិច្ឆ័យសណ្ឋាននៃនិស្ស័យរបស់មនុស្សបានយ៉ាងងាយស្រួល ។ ប្រសិនបើយើងបដិសេធរឿងរ៉ាវនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ដូចជាអ្នកខ្លះនោះមានន័យថា យើងមានការលំបាកក្នុងការពន្យល់ពីភាពធំធេងនិងអំណាចនៃអំពើបាបសព្វថ្ងៃនេះណាស់ ។

មានពរហើយអស់អ្នកជឿណាដែលយល់ពីសេចក្តីពិតនៃអំពើបាបហើយអាចនិយាយថា “អរព្រះគុណដល់ព្រះ ដែលទ្រង់ប្រទានជ័យជំនះដល់យើង តាមរយៈព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់របស់យើង” ក្នុងខណៈដែលមិនភ្លេចការចាំយាម និងអធិស្ឋាន ដើម្បីកុំឲ្យធ្លាក់ទៅក្នុងសេចក្តីល្បួង(១កូរិនថូស ១៥:៥៧)។

## ៤. អំពីសេចក្តីអាក្រក់នៃអំពើបាប

ខ្ញុំគិតថា យើង (ដែលមានគំនិតមិនគ្រប់គ្រាន់អំពីបាប) មិនអាចនឹងយល់ពីភាពអាក្រក់ដ៏ក្រៃលែងរបស់អំពើបាបនៅក្នុងព្រះនេត្រដ៏បរិសុទ្ធរបស់ព្រះ ជាយ៉ាងណានោះបានឡើយ។ មនុស្សខ្វាក់ម្នាក់មិនអាចប្រាប់ពីភាពខុសគ្នារវាងស្នាដៃសិល្បៈដ៏អស្ចារ្យមួយ និងរបស់សាមញ្ញមួយបានទេ ។ អ្នកថ្លង់ម្នាក់ក៏មិនអាចប្រាប់ពីភាពខុសគ្នារវាងសំឡេងកញ្ចែធម្មតាមួយ និងសំឡេងព្យាណូដ៏ពីរោះបានទេ ។

ចូរយើងដោះស្រាយនៅក្នុងគំនិតរបស់យើងយ៉ាងដូច្នេះវិញថា ព្រះនេត្របរិសុទ្ធក្រៃលែងនឹងទតមើលការអាក្រក់មិនបាន ក៏នឹងពិនិត្យ *មើលការទុច្ចរិតមិនបានដែរ* (ហាបាគុក ១:១៣) ដូច្នេះ *ព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់វិញ* (អេសេគាល ១៨:៤) ។ យើងក៏មានព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះយេស៊ូវដែរថា *ពួកអ្នកទាំងនោះនឹងថយទៅ មានទោសអស់កល្បជានិច្ច* (ម៉ាថាយ ២៥:៤៦) ។ ទាំងនេះគឺជាព្រះបន្ទូលដ៏គួរឲ្យខ្លាច នៅពេល យើងពិចារណាវា នៅក្នុងបទគម្ពីររបស់ព្រះដ៏ពេញដោយសេចក្តីមេត្តាករុណា !

ប៉ុន្តែលើសជាងអ្វីៗទាំងអស់ គ្មានភស្តុតាងនៃសេចក្តីអាក្រក់របស់អំពើបាបណា ដែលធំពេក ហើយគ្មានចម្លើយ ដូចជាឈើឆ្កាង និងសម្រែកយំរបស់ព្រះអម្ចាស់យើង *ឱព្រះអង្គៗនៃទូលបង្គំអើយ! ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ* (ម៉ាថាយ ២៧:៤៦) នោះដែរ ។ ព្រះគ្រីស្ទមិនទាន់យាងមកជាលើកទីពីរផង នោះយើងនឹងស្គាល់យ៉ាងពេញលេញពី «ភាពពោរពេញនៃអំពើបាប» ហើយ។

## ៥. អំពីការបោកបញ្ឆោតរបស់អំពើបាប

ការបោកបញ្ឆោតរបស់អំពើបាប អាចបង្ហាញឲ្យឃើញតាមរយៈ ត្រៀមខ្លួនជាស្រេចដើម្បីដោះសារឲ្យវា ហើយនិងធ្វើឲ្យទោសរបស់វាកាន់តែតូចឡើង ។ យើងនិយាយថា «វាគ្រាន់តែជាបាបដ៏តូចតាចប៉ុណ្ណោះ...ព្រះពោរពេញដោយសេចក្តីមេត្តាករុណា...យើងមានបំណងល្អ...មនុស្សម្នាក់មិនអាចនឹងច្បាស់លាស់ពេកបានទេ...តើការគ្រោះថ្នាក់នៅឯណា ?» តើនេះមានន័យយ៉ាងដូចម្តេច? គឺមានន័យថា យើងកំពុងព្យាយាមបោកបញ្ឆោតខ្លួនឯង ដោយជឿថា អំពើបាបមិនសូវ

អាក្រក់នោះទេ ។ ខ្ញុំខ្លាចក្រែងថា យើងមិនយល់ពីល្បិចដ៏ប៉ិនប្រសប់អស្ចារ្យនៃអំពើបាប ។ ជាដំបូង វាកម្របង្ហាញខ្លួនវាជាអំពើបាបណាស់ ។

អ្វីដែលជាហេតុផលពិតដែលយើងមានសម្រាប់ការបន្ទាបខ្លួន និងការគិតថាខ្លួនឯងអន់ជាងអ្នកដទៃ ហើយជាហេតុផលដើម្បីពិចារណាពីតម្រូវការនៃការប្រែចិត្ត គឺជាការប្រែចិត្តដែលព្រះគម្ពីរហៅថា ការកើតជាថ្មី គឺជាកំណើតថ្មីហើយនិងការផ្លាស់ប្រែ។ លើសពីនេះទៅទៀត យើងគួរអរគុណដល់ដំណឹងល្អដែលបានផ្សាយប្រាប់យើងអំពីថ្នាំព្យាបាល សម្រាប់ជំងឺរបស់យើង ។ យើងមិនគួរខ្លាចនឹងសិក្សាពីនិស្ស័យ ប្រភព អំណាច វិសាលភាព និងភាពអាក្រក់នៃអំពើបាបនោះទេ ប្រសិនបើយើងសំឡឹងមើលទៅឯសេចក្ដីសង្គ្រោះ ដែលព្រះគ្រីស្ទបានប្រទានមកយើងហើយនោះ ។ *កន្លែងណាដែលមានបាបចម្រើនជាបរិបូរឡើង នោះព្រះគុណក៏ចម្រើនជាបរិបូរលើសទៅទៀត* (រ៉ូម ៥:២០)។

## ៦. ការប្រើប្រាស់ជាប្រយោជន៍មួយចំនួន របស់គោលលទ្ធិនៃអំពើបាប

ក) ជាដំបូង គំនិតមួយនៃបទគម្ពីរដែលបានចែងអំពីអំពើបាប គឺជាឱសថព្យាបាលដ៏ប្រសើរមួយ ចំពោះការសិក្សាវិជ្ជាព្រះដែលមិនមានលក្ខណៈច្បាស់លាស់ និងខ្វះការពន្យល់លម្អិតត្រឹមត្រូវដូចជាគ្រាន់តែនិយាយ “អ្វីមួយអំពីព្រះគ្រីស្ទ, អ្វីមួយអំពីព្រះគុណ, អ្វីមួយអំពីសេចក្ដីជំនឿ”តាមតែគំនិតរបស់ពួកគេ។ ការសិក្សាវិជ្ជាព្រះគម្ពីរដែលពុំមានលក្ខណៈច្បាស់លាស់បែបនេះ មិនបានប្រើប្រាស់អំណាចលើជីវិតប្រចាំថ្ងៃ និងដើម្បីផ្ដល់សេចក្ដីមេត្រីនៅក្នុងសេចក្ដីស្លាប់ទេ ។ អស់អ្នកដែលចុះចូលចំពោះការសិក្សាវិជ្ជាព្រះគម្ពីរបែបនោះ ជាញឹកញាប់តែងតែដឹងខ្លួនយឺតពេលថា គ្មានភាពពិតប្រាកដអ្វីទាំងអស់អំពីសេចក្ដីជំនឿរបស់ពួកគេ ។

មនុស្សមិនដែលព្យាយាមធ្វើការសម្រេចចិត្តដើម្បីឲ្យបានទៅឯនគរស្ថានសួគ៌ ហើយរស់នៅដូចជាពួកអ្នកដែលស្វែងរកព្រះទេ ទាល់តែពួកគេដឹងខ្លួនថា ពួកគេកំពុងស្ថិតនៅក្នុងការគ្រោះថ្នាក់នៃការធ្លាក់ទៅក្នុងស្ថាននរកដោយព្រោះអំពើបាបរបស់ពួកគេ ទើបពួកគេបែរមករកព្រះ។ យើងអាចនឹងពឹងលើការនោះបានជាប្រាកដមែន។ មនុស្សនឹងមិនដែលមកឯព្រះយេស៊ូវ ក៏មិនដែលស្នាក់នៅជាមួយហើយរស់នៅសម្រាប់ទ្រង់ដែរ ទាល់តែពួកគេដឹងពីមូលហេតុដែលពួកគេត្រូវការមក ទើបពួកគេមក។ អស់អ្នកដែលព្រះវិញ្ញាណបរិសុទ្ធបានទាញមកឯព្រះគ្រីស្ទ ជាពួកអ្នកដែលទ្រង់បានធ្វើឲ្យស្គាល់ពីភាពពោរពេញនៃអំពើបាបរបស់ខ្លួនហើយ។

ខ) គំនិតមួយនៃបទគម្ពីរអំពីអំពើបាប គឺជាឱសថព្យាបាលដ៏ប្រសើរបំផុត សម្រាប់ការសិក្សាវិជ្ជាព្រះគម្ពីរតាមបែបសម័យទំនើបដែលមិនជាក់លាក់។ និន្នាការនៃការសិក្សាវិជ្ជាព្រះគម្ពីរនេះនឹងបដិសេធសេចក្ដីត្រឹមត្រូវនៃសេចក្ដីពិត ហើយនឹងព្យាយាមធ្វើឲ្យយើងជឿថា អ្វីគ្រប់យ៉ាងគឺត្រឹមត្រូវ គឺថា មនុស្សគ្រប់គ្នាទាំងអស់សុទ្ធតែត្រឹមត្រូវ ហើយនៅទីបំផុត ពួកគេនឹងទទួលសេចក្ដីសង្គ្រោះគ្រប់ៗគ្នា។ ការធ្វើឲ្យធួននឹងបាបនៃព្រះគ្រីស្ទ, បុគ្គលិកលក្ខណៈនៃអារក្សសាតាំង, ការអស្ចារ្យដែលព្រះគម្ពីរបានចែង, ភាពពិតប្រាកដ និងភាពអស់កល្បនៃទណ្ឌកម្មនៅពេលអនាគត -- សេចក្ដីពិតទាំងអស់នេះត្រូវបានច្រានចោលទៅម្ខាងនៅក្នុងជំនឿខុសឆ្គង ដែលការនោះធ្វើឲ្យសេចក្ដីជំនឿលើព្រះគ្រីស្ទកាន់តែអាចទទួលយកនូវគំនិតសម័យទំនើបនេះ។

គ) គំនិតមួយនៃបទគម្ពីរអំពីអំពើបាប គឺជាឱសថព្យាបាលដ៏ប្រសើរបំផុតចំពោះពិធីមួយនៃសេចក្ដីជំនឿគ្រីស្ទាន។ កុមារម្នាក់សប្បាយរីករាយនឹងល្បែងដែលគាត់កំពុងលេង ឯរាបណាគាត់មិនទាន់ឃ្លាន។ យើងក៏ដូចគ្នាក្នុងករណីហ្នឹងដែរខាងឯ

ព្រលឹងវិញ្ញាណ។ នៅពេលដែលមនុស្សម្នាក់ដឹងថាខ្លួនមានអំពើបាបធ្ងន់ ហើយត្រូវការអ្នកសង្គ្រោះម្នាក់សម្រាប់ខ្លួនគេ ពេលនោះបទភ្លេង ផ្កា ទាន ធូប ផ្លាកបដារ ហើយនិងពិធីនានាដែលមនុស្សធ្វើ នឹងហាក់ដូចជាការខ្ជះខ្ជាយពេលវេលាគួរឲ្យអាណិតមួយ។

ឃ) គំនិតមួយនៃបទគម្ពីរអំពីអំពើបាប គឺជាឱសថព្យាបាលដ៏ប្រសើរបំផុតចំពោះទ្រឹស្ដីនៃសេចក្ដីគ្រប់លក្ខណ៍ដែលគ្មានបាបសោះ។ ដោយរបៀបណាក៏ដោយ ចូរឲ្យយើងធ្វើឲ្យអស់ពីសមត្ថភាពបំផុត។ ប៉ុន្តែបើគេពិតចង់ប្រាប់យើងថា នៅក្នុងលោកិយនេះ អ្នកជឿអាចរស់នៅអស់រយៈពេលយ៉ាងយូរនៅក្នុងការប្រកបគ្នាដ៏មិនចេះបាក់បែកបានជាមួយនឹងព្រះ ខ្ញុំត្រូវនិយាយថា គំនិតនេះពិតជាមិនតាមបទគម្ពីរទេ ហើយវាថែមទាំងមានគ្រោះថ្នាក់ទៀត។ *បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្ដីពិតមិនស្ថិតនៅក្នុងយើងទេ* (១យ៉ូហាន ១:៨)។

ង) គំនិតមួយនៃបទគម្ពីរអំពីអំពើបាប គឺជាឱសថព្យាបាលដ៏ប្រសើរបំផុតចំពោះគំនិតដ៏អន់ថយអំពីសេចក្ដីបរិសុទ្ធផ្ទាល់ខ្លួន។ វាជាគំនិតដ៏សោកសង្រេងរបស់ខ្ញុំតាំងពីយូរយារមកហើយ គឺថា ខ្នាតនៃជីវិតប្រចាំថ្ងៃក្នុងចំណោមពួកគ្រីស្ទានកំពុងតែត្រូវបានធ្លាក់ចុះបន្តិចម្ដងៗ។ វាប្រហែលជាអាចមកពីការកើនឡើងនៃទ្រព្យសម្បត្តិ ដែលនាំទៅរកគ្រោះកាចនៃភាពជាលោកិយ និងសេចក្ដីស្រឡាញ់នៃភាពស្រណុកសុខស្រួល។ វាប្រហែលជាអាចមកពីការមិនឯកភាពគ្នាខាងជំនឿ ដែលការនោះធ្វើឲ្យជីវិតខាងព្រលឹងវិញ្ញាណរបស់យើងក្រៀមស្វិត។ ទោះជាហេតុផលណាក៏ដោយ ជាច្រើនឆ្នាំចុងក្រោយនេះ (ឧ៖ សតវត្សទី១៩) ខ្នាតនៃសេចក្ដីបរិសុទ្ធផ្ទាល់ខ្លួនគឺមានកម្រិតទាបជាងកាលពីនៅក្នុងសម័យឪពុករបស់យើង។ ខ្ញុំជឿជាក់

ថា ជំហានដំបូងទៅរកការទទួលបានខ្នាតនៃសេចក្តីបរិសុទ្ធខ្ពស់ជាងនេះ គឺត្រូវដឹង
ស្គាល់ឲ្យច្បាស់ពីភាពពោរពេញដ៏អាក្រក់របស់អំពើបាបរបស់យើង។

# ជំពូក ២

## ការញែកចេញជាបរិសុទ្ធ

*សូមញែកគេចេញជាបរិសុទ្ធដោយសារសេចក្ដីពិតរបស់ទ្រង់ ឯសេចក្ដីពិតគឺជាព្រះបន្ទូលរបស់ទ្រង់* (យ៉ូហាន ១៧:១៧)

*ដ្បិតព្រះទ្រង់សព្វព្រះបាហ្ទ័យ ឲ្យអ្នករាល់គ្នាបានញែកជាបរិសុទ្ធ* (១ថែស្សាឡូនិច ៤:៣)។

នេះគឺជាប្រធានបទដែលសំខាន់ជាងគេបំផុត។ ប្រសិនបើយើងមិនបានញែកចេញជាបរិសុទ្ធ នោះព្រះគម្ពីរចែងថា យើងនឹងមិនបានទទួលសេចក្ដីសង្គ្រោះបានទេ។ មានការចាំបាច់បីយ៉ាងចំពោះសេចក្ដីសង្គ្រោះរបស់យើងគឺ ការរាប់ជាសុចរិត ការកើតជាថ្មី និងការញែកចេញជាបរិសុទ្ធ។ មនុស្សម្នាក់ដែលខ្វះការណាមួយក្នុងចំណោមទាំងបីនេះ នោះមានន័យថា អ្នកនោះមិនមែនជាអ្នកជឿពិតប្រាកដទេ នៅក្នុងព្រះនេត្ររបស់ព្រះ។ គ្មានអ្នកណាដែលស្លាប់នៅក្នុងករណីនេះបានទៅស្ថានសួគ៌ទេ។ ដូច្នេះការពិនិត្យដ៏ប្រុងប្រយ័ត្ននៃប្រធានបទដែលជាគោលលទ្ធិដ៏អស្ចារ្យនៃដំណឹងល្អនេះ គឺពិតជាចាំបាច់ណាស់សម្រាប់សុខមាលភាពខាងព្រលឹងវិញ្ញាណរបស់យើង។

## ១. និស្ស័យពិតនៃការញែកចេញជាបរិសុទ្ធ

ការញែកចេញជាបរិសុទ្ធ គឺជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងអស់អ្នកណាដែលព្រះបានត្រាស់ហៅឲ្យក្លាយជាអ្នកជឿ។ ព្រះវិញ្ញាណធ្វើការដើម្បីបង្កើតការភ្ញាក់រលឹកមួយអំពីអំពើបាប ហើយបន្ទាប់មកបង្កើតការភ្ញាក់រលឹកអំពីសេចក្តីល្អរបស់ព្រះ នៅក្នុងការជូតសម្អាតទោសរបស់យើងដោយកិច្ចការរបស់ព្រះគ្រីស្ទ។ ព្រះវិញ្ញាណធ្វើការតាមរយៈព្រះបន្ទូល ដើម្បីញែកពួកអ្នកជឿចេញពីការស្រឡាញ់អំពើបាប និងសេចក្តីខាងឯលោកិយ ហើយនិងដើម្បីបង្កើតពួកគេឲ្យមានលក្ខណៈដូចព្រះគ្រីស្ទក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

ព្រះយេស៊ូវមិនត្រឹមតែបានរស់នៅ បានសុគត និងបានមានព្រះជន្មរស់ឡើងវិញ ដើម្បីប្រទានការរាប់ជាសុចរិតនិងការអត់ទោសបាបសម្រាប់រាស្ត្ររបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ថែមទាំងបានសន្យានឹងផ្តល់អ្វីៗគ្រប់យ៉ាង ដែលជីវិតខាងព្រលឹងវិញ្ញាណរបស់រាស្ត្រទ្រង់ត្រូវការផងដែរ។ ទ្រង់ចាត់ព្រះវិញ្ញាណបរិសុទ្ធមកឯចិត្តរបស់ពួកគេ ដើម្បីមកជំនួសសេចក្តីប៉ងប្រាថ្នាខាងអំពើបាប មកឯសេចក្តីប៉ងប្រាថ្នាខាងឯសេចក្តីបរិសុទ្ធវិញ ។ ព្រះគ្រីស្ទបានមានបន្ទូលថា *ឯទូលបង្គំក៏ញែកខ្លួនចេញជាបរិសុទ្ធដោយយល់ដល់គេ ដើម្បីឲ្យគេបានញែកចេញជាបរិសុទ្ធដោយសារសេចក្តីពិតដែរ* (យ៉ូហាន ១៧:១៩) ហើយសាវក ប៉ុល បានសរសេរដែរថា *ព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គជំនួយផង ដើម្បីឲ្យទ្រង់បានញែកពួកជំនុំជាបរិសុទ្ធ ដោយសារបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល* (អេភេសូរ ៥:២៥-២៦)។ អ្នកជឿដែលកំពុងអានហើយយល់ខទាំងនេះ នឹងភ្ញាក់ដឹងថា ព្រះគ្រីស្ទរាប់យើងជាសុចរិតផង ហើយញែកយើងចេញជាបរិសុទ្ធផង

ង។ ហើយឥឡូវនេះ ខ្ញុំចង់និយាយពីការមួយចំនួនដល់បងប្អូន ដែលការទាំងនោះនឹងកំណត់និយមន័យពីនិស្ស័យពិតនៃការញែកចេញជាបរិសុទ្ធ ។

ក) ការញែកចេញជាបរិសុទ្ធ គឺជាលទ្ធផលដែលមិនចេះប្រែប្រួលនៃការនៅជាប់នឹងព្រះគ្រីស្ទ ដែលសេចក្ដីជំនឿផ្ដល់ឲ្យអ្នកជឿពិតប្រាកដគ្រប់រូប ។ ព្រះគ្រីស្ទបានមានបន្ទូលថា *ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន* (យ៉ូហាន ១៥:៥)។ អស់អ្នកណាដែលគ្មានផលផ្លែខាងព្រលឹងវិញ្ញាណនៅក្នុងជីវិតប្រចាំថ្ងៃ គឺអ្នកនោះមិននៅក្នុងព្រះគ្រីស្ទទេ។ ការគេស្មានថានៅជាប់នឹងព្រះគ្រីស្ទ តែមិនបង្កើតលទ្ធផលនៅក្នុងជីវិតប្រចាំថ្ងៃសោះ។ *តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ (ព្រះគ្រីស្ទ)ក៏គង់ក្នុងពន្លឺដែរ* (១យ៉ូន ១:៧) ។

ខ) ការញែកចេញជាបរិសុទ្ធ គឺជាលទ្ធផលដែលមិនអាចបំបែកបាននៃការកើតជាថ្មី ។ អស់អ្នកដែលកើតជាថ្មី ត្រូវបានក្លាយជាមនុស្សថ្មីដែលរស់នៅក្នុងជីវិតថ្មី។ កន្លែងណាគ្មានជីវិតបរិសុទ្ធ កន្លែងនោះគ្មានកំណើតថ្មីទេ។ កន្លែងណាដែលគ្មានការញែកចេញជាបរិសុទ្ធ កន្លែងនោះគ្មានការកើតជាថ្មីទេ។ *អស់អ្នកណាដែលប្រព្រឹត្តតាមសេចក្ដីសុចរិតនោះ គេបានកើតពីទ្រង់មកដែរ* (១យ៉ូន ២:២៩) ។ *អស់អ្នកណាដែលកើតពីព្រះ នោះមិនដែលប្រព្រឹត្តអំពើបាបទេ ពីព្រោះពូជព្រះនៅក្នុងអ្នកនោះឯង បានជាពុំអាចនឹងធ្វើបាបឡើយដ្បិតបានកើតពីព្រះមក* (១យ៉ូន ៣:៩) ។

គ) ការញែកចេញជាបរិសុទ្ធ គឺជាភស្តុតាងជាក់លាក់តែមួយគត់ពីព្រះវិញ្ញាណដែលគង់នៅក្នុងដែលការនោះមានសារសំខាន់សម្រាប់សេចក្ដីសង្គ្រោះនៃអ្នកជឿពិតប្រាកដ។ *បើអ្នកណាគ្មានព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ* (រ៉ូម ៨:៩)។ព្រះវិញ្ញាណមិនដែលជាឥតប្រយោជន៍នោះទេ ប៉ុន្តែ

តែងតែធ្វើឲ្យគេស្គាល់ពីវត្តមានរបស់ទ្រង់ដោយ "ផលផ្លែ" ដែលទ្រង់បានធ្វើឲ្យរីកចម្រើនឡើងនៅក្នុងអាកប្បកិរិយា និងជីវិតវិញ(កាឡាទី ៥:២២,២៣)។ ប្រសិនបើមិនឃើញមានផ្លែនេះទេនោះវត្តមាននៃជីវិតខាងឯវិញ្ញាណច្បាស់ជាស្ថិតនៅក្នុងការសង្ស័យហើយ។ ដូចជាយើងដឹងថា មានខ្យល់ដោយព្រោះលទ្ធផលនានាដែលវាបង្កើត ដូច្នេះយើងអាចដឹងព្រះវិញ្ញាណនៅក្នុងបុគ្គលម្នាក់ ដោយសារលទ្ធផលដែលទ្រង់បានបង្កើតនៅក្នុងជីវិតអ្នកនោះផងដែរ។ *អស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ* (ហើយមានតែពួកគេប៉ុណ្ណោះ) *អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ* (រ៉ូម ៨:១៤)។

ឃ) ការញែកចេញជាបរិសុទ្ធ គឺជាសញ្ញាសំគាល់តែមួយគត់នៃពួកអ្នកដែលជារាស្ត្រជ្រើសរើសរបស់ព្រះ។ ឈ្មោះ និងចំនួននៃរាស្ត្រជ្រើសរើសរបស់ព្រះគឺជាការអាថ៌កំបាំង មានតែទ្រង់ប៉ុណ្ណោះដែលជ្រាប។ ប៉ុន្តែមានការដឹងច្បាស់មួយនៅក្នុងបទគម្ពីរថា រាស្ត្រជ្រើសរើសទាំងបុរសនិងស្ត្រី ត្រូវបានញែកចេញពីគេដោយជីវិតបរិសុទ្ធ។ *ទ្រង់* (ព្រះ) *បានរើសយើងរាល់គ្នាក្នុងព្រះគ្រីស្ទ តាំងពីមុនកំណើតលោកីយមក ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់* (អេភេសូរ ១:៤)។ ជាការពិតណាស់ អស់អ្នកណាដែលបង្កើតការបង្ហាញសមរម្យមួយនៃសេចក្តីជំនឿ អាចនឹងត្រឡប់ទៅជាមនុស្សកំពុតនៅទីបំផុត។ ប៉ុន្តែកន្លែងណាដែលគ្មានលក្ខណៈនៃការញែកចេញជាបរិសុទ្ធខ្លះសោះ យើងអាចនឹងដឹងជាប្រាកដថា នោះគ្មានការជ្រើសរើសទេ។

ង) ការញែកចេញជាបរិសុទ្ធ ជាការមួយដែលគេតែងតែឃើញ។ គេស្គាល់ដើមឈើមួយដើមដោយសារតែផ្លែរបស់វា។ អ្នកជឿដែលបានញែកជាបរិសុទ្ធម្នាក់នឹងត្រូវបានប្រដាប់ដោយការបន្ទាបខ្លួន ទោះបីអ្នកនោះ អាចនឹងដឹងពីសេចក្តី

កម្សោយនៅក្នុងជីវិតខាងព្រលឹងវិញ្ញាណរបស់ខ្លួនក៏ដោយ ។ «អ្នកបរិសុទ្ធ» ម្នាក់មានតែឈ្មោះ មិនអាចឃើញអ្វីនៅក្នុងជីវិតរបស់គាត់ទាល់តែសោះ ក្រៅពីសេចក្តីស្រើបស្រាលខាងលោកិយដ៏គួរឲ្យខ្លាច ដែលព្រះគម្ពីរមិនទទួលស្គាល់។

ច) ការញែកចេញជាបរិសុទ្ធ គឺជាអ្វីម្យ៉ាងដែលអ្នកជឿគ្រប់រូបត្រូវទទួលខុសត្រូវ ។ អ្នកជឿដែលជាកូនរបស់ផងព្រះ មានចំណេះដឹងអំពីព្រះបន្ទូលនៃដំណឹងល្អ និងជីវិតថ្មីមួយ ព្រមទាំងសេចក្តីសង្ឃឹមដែលមាននៅក្នុងពួកគេ។ *ដ្បិតព្រះចេស្តានៃព្រះបានផ្តល់ឲ្យយើងរាល់គ្នាមានគ្រប់របស់ទាំងអស់ ខាងឯជីវិត និងសេចក្តីគោរពប្រតិបត្តិដល់ព្រះ ដោយយើងបានស្គាល់ព្រះអង្គ ដែលទ្រង់ហៅយើងរាល់គ្នាមកដោយសារសិរីល្អ និងសគុណរបស់ទ្រង់* (២ពេត្រុស ១:៣) ។ ប៉ុន្តែប្រសិនបើពួកគ្រីស្ទានមិនបរិសុទ្ធ នោះវាជាកំហុសរបស់អ្នកឯទៃក្រៅពីពួកគេផ្ទាល់ឬ? ប្រសិនបើពួកគេមិនបានញែកចេញជាបរិសុទ្ធ តើពួកគេអាចទម្លាក់កំហុសនោះទៅលើអ្នកណា ក្រៅពីខ្លួនគេ? ប្រសិនបើព្រះអង្គសង្គ្រោះនៃមនុស្សមានបាប ប្រទានព្រះគុណថ្មីដល់យើងហើយ តើយើងអាចមិនប្រាកដថា ទ្រង់តម្រូវឲ្យយើងប្រើអំណោយទានរបស់ទ្រង់ទេឬអី? បើមិនធ្វើយ៉ាងដូច្នេះទេ អ្នកទាំងនោះច្បាស់ជានៅក្នុងចំណោម ពួកដែលធ្វើឲ្យព្រះវិញ្ញាណព្រួយព្រះហឫទ័យហើយ។

ឆ) ការញែកចេញជាបរិសុទ្ធ គឺជាការមួយដែលអាចធ្វើឲ្យធំចម្រើនឡើង ហើយឲ្យកាន់តែរីកចម្រើនឡើង។ គ្រីស្ទានមិនអាចទទួលការអត់ទោស និងការរាប់ជាសុចរិតបន្ថែមទៀត ច្រើនជាងនៅពេលពួកគេទើបតែចាប់ផ្តើមជឿជាលើកដំបូងនោះទេ។ គ្រីស្ទានមិនអាចយ៉ាងដូច្នេះបានឡើយ។ អ្នកជឿអាចនឹងដឹងប្រាកដច្បាស់ថា ខ្លួនបានទទួលការញែកចេញជាបរិសុទ្ធថែមទៀត។ អ្នកបរិសុទ្ធរបស់ព្រះទាំងអស់សុទ្ធតែយល់ព្រមថា ពួកគេឃើញថែមទៀត ហើយពួកគេដឹងថែមទៀត

ហើយមានអារម្មណ៍ថែមទៀត ហើយធ្វើថែមទៀត ប្រែចិត្តថែមទៀត ហើយជឿថែមទៀត នៅពេលដែលពួកគេបន្តរស់នៅក្នុងជីវិតខាងព្រលឹងវិញ្ញាណ ហើយដើរកាន់តែជិតស្និទ្ធជាមួយនឹងព្រះ។ យើងរាល់គ្នាត្រូវបាន *ចម្រើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់* (២ពេត្រុស ៣:១៨)។

ជ) ការញែកចេញជាបរិសុទ្ធ គឺជាការមួយដែលពឹងលើការប្រើប្រាស់ដ៏ឧស្សាហ៍ព្យាយាមនៃមធ្យោបាយខាងបទគម្ពីរ ជួនកាលគេហៅការនោះថាជា «មធ្យោបាយនៃព្រះគុណ»។ នៅពេលខ្ញុំនិយាយពី «មធ្យោបាយ» គឺសំដៅ ការអានព្រះគម្ពីរ ពេលអធិស្ឋានផ្ទាល់ខ្លួន និងជាសាធារណៈ ការគោរពថ្វាយបង្គំ ស្តាប់ព្រះបន្ទូល ពិធីលៀងព្រះអម្ចាស់ដ៏ទៀងទាត់។ ខ្ញុំមិនអាចរកឃើញការកត់ត្រាណាមួយដែលនិយាយពីអ្នកបរិសុទ្ធដ៏ល្បីៗ ធ្លាប់ធ្វេសប្រហែសនឹងការទាំងនេះទេ។ ខ្ញុំគួររំពឹងថា ដើម្បីឲ្យបានភោគផលជាទីពេញចិត្តពីការសាបព្រោះក្នុងចំការ មិនដែលកសិករណាម្នាក់ មិនមើលថែដំណាំ របូតទាល់តែដល់ពេលប្រមូលផលនោះឡើយ ដូចជាអ្នកជឿម្នាក់ដែលរំពឹងថានឹងទទួលបានសេចក្តីបរិសុទ្ធយ៉ាងដូច្នេះដែរ ពួកគេមិនដែលប្រហែសក្នុងការយកចិត្តទុកដាក់ចំពោះមធ្យោបាយទាំងនេះនោះទេ។

ឈ) ការញែកចេញជាបរិសុទ្ធ គឺជាអ្វីមួយដែលមិនមានការរារាំងក្នុងការតស៊ូខាងព្រលឹងវិញ្ញាណ។ ដោយការតស៊ូខាងព្រលឹងវិញ្ញាណ ខ្ញុំចង់សំដៅថា *សាច់ឈាមតែងតែប៉ងប្រាថ្នាទាស់នឹងព្រះវិញ្ញាណ ឯព្រះវិញ្ញាណទ្រង់ក៏ទាស់នឹងសាច់ឈាមដែរ សេចក្តីទាំងពីរនោះប្រឆាំងនឹងគ្នា* (កាឡាទី ៥:១៧)។ ការតស៊ូខាងព្រលឹងវិញ្ញាណ និងការលំបាកខាងគំនិត មិនមែនជាភស្តុតាងដែលថាមនុស្សម្នាក់មិនបានទទួលការញែកចេញជាបរិសុទ្ធនោះទេ តែផ្ទុយទៅវិញ ការទាំងនោះបង្ហាញថា អ្នកនោះកំពុងតែមានជីវិតរស់នៅខាងព្រលឹងវិញ្ញាណវិញ។ អ្នកជឿម្នាក់នឹងអាចមាន

បញ្ញាចិត្តសន្តិភាព នៅខណៈពេលមានសង្គ្រាមមួយកំពុងតែពិបាកគ្រប់គ្រងដែលនៅខាងក្នុង! ខ្ញុំជឿថា អ្វីដែលខ្ញុំនិយាយ ត្រូវបានបញ្ជាក់ដោយភាសាដែលសាវកប៉ុលនិយាយនៅក្នុងគម្ពីររ៉ូមជំពូក៧។ ខ្ញុំពិតជាពេញចិត្តណាស់ ដែលគាត់មិនបានពិពណ៌នាពីបទពិសោធន៍នៃមនុស្សមិនប្រែចិត្តម្នាក់ ឬគ្រីស្ទានវ័យក្មេងម្នាក់ ប៉ុន្តែគាត់និយាយពីអ្នកបរិសុទ្ធចាស់ទុំដែលមានទំនាក់ទំនងជិតស្និតជាមួយនឹងព្រះវិញ។ (នេះក៏ជាគំនិតនៃពួកកែទម្រង់ផងដែរ គឺពួកប្រ៉ូតេស្តង់ រួមទាំងលោកបាលខេន និងលោក អូវិន និងអ្នកប្រាជ្ញខាងព្រះគម្ពីរជាច្រើនទៀត)។

យើងអាចទន្ទឹងរង់ចាំពេលមួយដែលយើងនឹងមិនមានការតស៊ូ នៅក្នុងនគរស្ថានសួគ៌ ប៉ុន្តែយើងតែងតែមានការតស៊ូនៅក្នុងជីវិតនេះវិញ។ សូម្បីតែបន្ទាប់ពីការកើតជាថ្មីហើយក៏ដោយ ព្រលឹងវិញ្ញាណរបស់យើងនៅតែឆ្លងរាលដាលដដែល ដោយសារតែការសេសសល់នៃអំពើបាប។

៣) ការញែកចេញជាបរិសុទ្ធ មិនអាចរាប់មនុស្សម្នាក់ជាសុចរិតបានឡើយ ប៉ុន្តែការនោះបានធ្វើឲ្យព្រះជាម្ចាស់បានគាប់ព្រះហឫទ័យ។ ការប្រព្រឹត្តិដ៏បរិសុទ្ធបំផុតនៃមនុស្សដែលបរិសុទ្ធបំផុត នឹងទទួលការរងទុក្ខដោយសារសេចក្តីមិនគ្រប់លក្ខណ៍ដូច្នេះការប្រព្រឹត្តិនោះក៏មានបាបដែរ ទោះបីជាមានបាបបន្តិចបន្តួចក៏ដោយ។ បើកម្លាំងជំរុញពីខាងក្នុងខុស នោះការប្រព្រឹត្តិនឹងខូចទទេ។ មានតែសេចក្តីសុចរិតដោយការដែលយើងអាចថ្វាយខ្លួនយើងដល់ព្រះប៉ុណ្ណោះ ទើបជាសេចក្តីសុចរិតដ៏គ្រប់លក្ខណ៍។ ហើយសេចក្តីគ្រប់លក្ខណ៍នេះ មាននៅក្នុងព្រះអម្ចាស់របស់យើងតែមួយប៉ុណ្ណោះ។ សេចក្តីគ្រប់លក្ខណ៍របស់ទ្រង់ដែលមិនមែនជាសេចក្តីគ្រប់លក្ខណ៍របស់យើង កិច្ចការរបស់ទ្រង់ដែលមិនមែនជាកិច្ចការរបស់យើង គឺជាការ

រាប់ជាសុចរិតរបស់យើង ហើយជាសិទ្ធិតែមួយរបស់យើងដែលធានាឲ្យយើងទៅឯនគរស្ថានសួគ៌បាន!

នៅពេលជំណាលគ្នានោះ យើងដឹងយ៉ាងច្បាស់ថា ការប្រព្រឹត្តិដ៏សុចរិតនៃពួកអ្នកជឿ គឺជាការដែលគាប់ព្រះហឫទ័យដល់ព្រះ ទោះបីជាការប្រព្រឹត្តិរបស់យើងមិនគ្រប់លក្ខណ៍ក៏ដោយ ។ ទោះជាមិនគ្រប់លក្ខណ៍យ៉ាងណា ដែលកូនខិតខំប្រឹងប្រែងផ្គាប់ចិត្តឪពុកម្តាយ ឪពុកម្តាយនៅតែពេញចិត្តនឹងការរបស់កូន ដូចជាព្រះវរបិតាដែលទ្រង់សព្វព្រះហឫទ័យ ចំពោះការខិតខំប្រឹងប្រែងរបស់កូនៗរបស់ទ្រង់យ៉ាងដូច្នេះដែរ ទោះជាការនោះមិនបានគ្រប់លក្ខណ៍ដ៏ដោយ។ ទ្រង់ទតមើលពីបំណងចិត្តនៃការប្រព្រឹត្តិរបស់ពួកយើង មិនមែនគ្រាន់តែទតមើលពីបរិមាណ និងគុណភាពនៃការប្រព្រឹត្តិទាំងនោះទេ។

ង) ការញែកចេញជាបរិសុទ្ធ គឺជាការមួយដែលត្រូវការចាំបាច់បំផុត នៅថ្ងៃជំនុំជំរះដ៏ធំនោះ។ នៅពេលដែលទ្រង់បានហៅយើងមកឯការជំនុំជំរះចុងក្រោយ ភស្តុតាងពីសេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទរបស់យើង គឺពិតប្រាកដ ហើយការនោះជាការតែមួយគត់ដែលនឹងសង្គ្រោះយើងឲ្យរួចពីការផ្តន្ទាទោសនោះបាន។ បញ្ហាមិនមែនអំពីរបៀបដែលយើងនិយាយយ៉ាងណា យើងអះអាងយ៉ាងណានោះទេ តែជារបៀបដែលយើងបានរស់នៅយ៉ាងណា ហើយពីអ្វីដែលយើងបានធ្វើវិញ។ *ដ្បិតយើងទាំងអស់គ្នាត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រីស្ទ ដើម្បីឲ្យគ្រប់គ្នាបានទទួលតាមការដែលបានធ្វើពីកាលនៅក្នុងរូបកាយរៀងខ្លួន ទោះល្អឬអាក្រក់ក្តី* (២កូរិនថូស ៥: ១០)។

ច) ការញែកចេញជាបរិសុទ្ធ គឺជាការមួយដែលត្រូវការចាំបាច់ ដើម្បីរៀបចំយើងសម្រាប់នគរស្ថានសួគ៌។ មនុស្សជាច្រើនសង្ឃឹមថាបានទៅស្ថានសួគ៌ នៅពេល

ដែលពួកគេស្លាប់ទៅ ប៉ុន្តែមនុស្សមួយក្តាប់តូចគិតថា តើពួកគេនឹងពេញចិត្តរស់នៅទីនោះដែរឬទេ! ស្ថានសួគ៌គឺកន្លែងដ៏បរិសុទ្ធបំផុត ពោលគឺ អ្នករស់នៅទីនោះសុទ្ធតែបរិសុទ្ធ ការងារសុទ្ធតែបរិសុទ្ធ។ ដើម្បីឲ្យបានសប្បាយរីករាយនៅក្នុងនគរស្ថានសួគ៌ យើងគួររៀបចំខ្លួនសម្រាប់រស់នៅទីនោះ ខណៈពេលដែលកំពុងនៅលើផែនដីនេះនៅឡើយ។ នៅពេលដែលសត្វឥន្ទ្រីមួយបានសប្បាយរីករាយនៅក្នុងទ្រុងដែកមួយ នៅពេលដែលសត្វចៀមមួយកំពុងតែសប្បាយនៅក្នុងទឹក នៅពេលដែលសត្វទីទុយមួយកំពុងតែសប្បាយនៅក្នុងពន្លឺថ្ងៃត្រង់ នៅពេលដែលត្រីមួយកំពុងតែសប្បាយនៅលើដីស្ងួតហួតហែង យ៉ាងនោះតើខ្ញុំអាចអះអាងថា មនុស្សដែលមិនបានញែកចេញជាបរិសុទ្ធ អាចនឹងសប្បាយនៅក្នុងស្ថានសួគ៌យ៉ាងដូចម្តេចបាន។

## ២. តើមានសញ្ញាសំគាល់ដែលអាចមើលឃើញអ្វីខ្លះនៃមនុស្សដែលបានញែកចេញជាបរិសុទ្ធម្នាក់?

ក) ការញែកចេញជាបរិសុទ្ធ លើសជាជាងពីការជជែកអំពីសេចក្តីជំនឿ។ អ្នកខ្លះចេះពាក្យ និងឃ្លានៃដំណឹងល្អជាច្រើន ហើយនិយាយពាក្យ និងឃ្លាទាំងនោះយ៉ាងស្ទាត់ជំនាញ ហើយពួកគេប្រាប់អ្នកដទៃទៀតថា ពួកគេជាអ្នកជឿ។ ព្រះមិនសព្វព្រះហឫទ័យឲ្យរាស្ត្ររបស់ទ្រង់គ្រាន់តែជាធុងអត់ទឹកនោះទេ ដែលឮទូងដូចជាឃឹងនោះឡើយ។ *យើងមិនត្រូវស្រឡាញ់ដោយពាក្យសំដី ឬដោយបបូរមាត់ឡើយ គឺដោយការប្រព្រឹត្ត និងសេចក្តីពិតវិញ* (១យ៉ូហាន ៣:១៨)។

ខ) ការញែកចេញជាបរិសុទ្ធ គឺមិនគ្រាន់តែពេញចិត្តខាងអារម្មណ៍ខាងសេចក្តីជំនឿតែមួយភ្លែតនោះទេ។ ការបម្រើពិសេស និងការជួបជុំគ្នាជាសាធារណៈដើម្បីប្រកាស

ដំណឹងល្អ អាចនឹងទាក់ទាញការយកចិត្តទុកដាក់ជាច្រើន ហើយយើងគួរសរសើរដល់ព្រះ នៅពេលដែលពួកគេប្រកាសដំណឹងល្អទៅដល់មនុស្សជាច្រើន។ ប៉ុន្តែការទាំងនេះធ្វើឲ្យអ្នកចូលរួមមានគ្រោះថ្នាក់ផងនិងមានប្រយោជន៍ផង។ កន្លែងណាក៏ដោយ ដែលគេព្រោះពូជស្រូវ អារក្សក៏ព្រោះស្រងែរបស់វាដែរ។ យើងត្រូវមានការប្រុងប្រយ័ត្ននឹងការរំភើបខាងសេចក្ដីជំនឿដែលបណ្ដាលឲ្យមនុស្សចាប់អារម្មណ៍ទៅឯព្រះអម្ចាស់តែមួយភ្លែត។ បន្តិចក្រោយមក ពួកគេនឹងត្រឡប់ដូចដើមវិញ ហើយពួកគេកាន់តែរឹងរូស និងអាក្រក់ជាងមុនទៅទៀត។ ចូរយើងដាស់តឿនដល់អស់អ្នកដែលបង្ហាញចំណាប់អារម្មណ៍ថ្មីក្នុងជំនឿគ្រីស្ទបរិស័ទ កុំឲ្យស្កប់ចិត្តតែមួយភ្លែតនឹងកិច្ចការញែកចេញជាបរិសុទ្ធដ៏ជ្រៅមួយនៃព្រះវិញ្ញាណបរិសុទ្ធនោះឡើយ ។

គ) ការញែកចេញជាបរិសុទ្ធ គឺមិនមែនគ្រាន់តែសំដែងពីការប្រព្រឹត្តិសុចរិតម្ដងម្កាលនោះទេ។ មនុស្សស្មោះត្រង់ជាច្រើនដែលសប្បាយរីករាយក្នុងការធ្វើអ្វីមួយតាមតែអារម្មណ៍ ជួនកាលគឺជាសកម្មភាពខាងជំនឿ។ ប៉ុន្តែខ្ញុំក្រែងថា នៅក្នុងករណីជាច្រើន ការសំដែងសេចក្ដីជំនឿតែខាងក្រៅ មិនអាចនឹងជំនួសសេចក្ដីបរិសុទ្ធដែលនៅខាងក្នុងបានទេ។ ខ្ញុំមានអារម្មណ៍ថា មានភាពចាំបាច់ក្នុងការនិយាយពីប្រធានបទនេះឲ្យបានច្បាស់ ។ អាចនឹងមាន “រូបកាយបម្រើ” ជាច្រើន ក្នុងខណៈដែលមិនមានការញែកចេញជាបរិសុទ្ធពិតប្រាកដ។

ឃ) ការញែកចេញជាបរិសុទ្ធមិនមែនជាការផ្ដាច់ខ្លួន ពីជីវិតប្រចាំថ្ងៃក្នុងលោកិយនោះទេ។ គ្រប់សម័យទាំងអស់ មានពួកអ្នកជឿថា ការផ្ដាច់ខ្លួនចេញពីលោកិយ គឺជាផ្លូវធំមួយទៅកាន់ការញែកចេញជាបរិសុទ្ធ។ ប៉ុន្តែកន្លែងណាដែលយើងទៅ យើងតែងតែយកប្រភពនៃសេចក្ដីអាក្រក់ទៅជាមួយ--គឺជាចិត្តរបស់យើងនោះឯ

ង។ សេចក្តីបរិសុទ្ធ មិនមែនជារុក្ខជាតិដែលខ្សោយ ដែលអាចរស់បានតែនៅក្នុងថ្នាលនោះទេ ប៉ុន្តែគឺជាអ្វីមួយដែលខ្លាំងហើយរឹងមាំ ដែលអាចចម្រើនលូតលាស់នៅក្នុងជីវិតប្រចាំថ្ងៃធម្មតាវិញ។ សេចក្តីបរិសុទ្ធពិតប្រាកដមិនធ្វើឲ្យគ្រីស្ទានម្នាក់ត្រូវរត់គេចពីការលំបាកនោះទេ តែត្រូវប្រឈមមុខ និងប្រឹងយកឈ្នះវាវិញ។

ង) ការញែកចេញជាបរិសុទ្ធ នឹងបង្ហាញខ្លួនវានៅក្នុងការគោរពឥតឈប់ឈរមួយដែលព្រះទាមទារពីយើង។ អ្នកដែលធ្វើពុតជាអ្នកបរិសុទ្ធ ដោយសើចចំអកដាក់ក្រឹត្យវិន័យទាំង១០ប្រការ ហើយមិនគិតថាខ្លួនល្មើសនឹងក្រិត្យវិន័យទាំងនោះ គឺជាការបោកបញ្ឆោតយ៉ាងធ្ងន់ធ្ងរ ហើយពិបាកនឹងបញ្ជាក់ថា អ្នកនោះជាអ្នកបរិសុទ្ធនៅថ្ងៃចុងក្រោយណាស់!

ច) ការញែកចេញជាបរិសុទ្ធ នឹងបង្ហាញខ្លួនវានៅក្នុងការខំប្រឹងប្រែងធ្វើតាមព្រះបាបន្ទូលព្រះគ្រីស្ទដ៏ឥតឈប់ឈរមួយ។ ការទាមទារដ៏ត្រឹមត្រូវរបស់ទ្រង់មាននៅក្នុងគម្ពីរដំណឹងល្អ ហើយនិងនៅក្នុងសេចក្តីអធិប្បាយនៅលើភ្នំ។ ព្រះអម្ចាស់របស់យើងបាននៅតែបន្តបង្រៀនពីអ្វីដែលពួកសាវករបស់ទ្រង់គួរធ្វើ។ *បើអ្នករាល់គ្នាធ្វើតាមសេចក្តីដែលខ្ញុំបានបង្គាប់ នោះអ្នករាល់គ្នាជាពួកសំឡាញ់ខ្ញុំហើយ* (យ៉ូហាន ១៥:១៤) ជាព្រះបន្ទូលរបស់ទ្រង់។ យើងនៅតែបម្រើព្រះអម្ចាស់ដដែលនេះ។

ឆ) ការញែកចេញជាបរិសុទ្ធ នឹងបង្ហាញខ្លួនវានៅក្នុងការប្រាថ្នាចង់រស់នៅមួយ ទៅតាមខ្នាតដែលសាវក ប៉ុលបានដាក់នៅចំពោះពួកជំនុំ។ យើងអាចរកខ្នាតនោះឃើញនៅក្នុងជំពូកចុងក្រោយ ស្ទើរតែគ្រប់សំបុត្រទាំងអស់របស់គាត់។ ខ្ញុំមិនជឿថា អ្នកដែលអានសំបុត្ររបស់សាវក ប៉ុល ដោយយកចិត្តទុកដាក់ មិនបានរកឃើញការចង្អុលបង្ហាញងាយយល់ដ៏មានប្រយោជន៍ អំពីកាតព្វកិច្ចរបស់គ្រីស្ទាននៅក្នុងគ្រប់ទាំងទំនាក់ទំនងនៃជីវិតនោះទេ។ ការចង្អុលបង្ហាញទាំងនេះត្រូវបានសរ

សេរឡើងដោយការបណ្ដាលនៃព្រះ ទុកសម្រាប់ជាការនាំផ្លូវដល់ពួកអ្នកជឿពិតប្រាកដ។

ជ) ការញែកចេញជាបរិសុទ្ធ នឹងបង្ហាញខ្លួនរបស់វានៅក្នុងការយកចិត្តទុកដាក់ស្ដាប់និងមើលទៅគ្រប់ទាំងព្រះគុណខាងវិញ្ញាណ ដែលព្រះអម្ចាស់របស់យើងបង្ហាញឲ្យឃើញ ប្រកបដោយសោភ័ណភាព។ *ឲ្យអ្នករាល់ស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ* (យ៉ូហាន ១៣:៣៤,៣៥)។ សាវក ពេត្រុស បានសរសេរទៅកាន់អ្នកជឿ ក្នុងអត្ថន័យដូចគ្នាដែរថា *បើអ្នកបានប្រព្រឹត្តិល្អហើយទ្រាំឲ្យគេធ្វើទុក្ខដោយអត់ទ្រាំវិញ...ដ្បិតទ្រង់បានហៅអ្នករាល់គ្នាមកឯសេចក្ដីនោះឯង ពីព្រោះព្រះគ្រីស្ទក៏បានរងទុក្ខជំនួសយើងដែរ ទាំងទុកដំរាប់ឲ្យយើងរាល់គ្នាដើរតាមលំអានដាននៃទ្រង់* (១ពេត្រុស ២:២០, ២១)។ សាវក ប៉ុល និយាយពីព្រះគុណចំនួន ៩នៅក្នុងបញ្ជីនៃផលផ្លែនៃព្រះវិញ្ញាណនៅក្នុងគម្ពីរកាឡាទី ៥:២២-២៣។ ប្រសិនបើយើងមិនបានបង្ហាញសេចក្ដីទាំងនេះនៅក្នុងជីវិតរបស់យើងទេ នោះគ្មានប្រយោជន៍សោះដែលយើងធ្វើពុតជាបានរាប់ជាបរិសុទ្ធនោះ។ មិនមែនអ្នកជឿទាំងអស់សុទ្ធតែបង្ហាញសញ្ញាសំគាល់ទាំងនេះស្មើៗគ្នានោះទេ ប៉ុន្តែសញ្ញាសំគាល់ទាំងនេះជាខ្នាតតាមព្រះគម្ពីរដែលពួកអ្នកជឿគួរបាញ់ឆ្ពោះទៅ។

**៣. ជាចុងក្រោយ ខ្ញុំចង់ពិចារណាពីភាពផ្សេងគ្នារវាងការរាប់ជាសុចរិត និងការញែកចេញជាបរិសុទ្ធ ដោយបង្ហាញពីរបៀបដែលការទាំងពីរនេះឯកភាពគ្នា និងពីរបៀបដែលការទាំងពីរខុសគ្នា។**

*(i) តើការទាំងពីរនេះឯកភាពគ្នាយ៉ាងដូចម្តេច?*

ក) ការទាំងពីនេះមានប្រភពជាអំណោយទានដែលមកពីព្រះ ដល់ពួកអ្នកជឿ។

ខ) ការរាប់ជាបរិសុទ្ធ និងការញែកចេញជាបរិសុទ្ធ សុទ្ធតែហូរចេញមកពីលទ្ធផលនៃកិច្ចការរបស់ព្រះគ្រីស្ទ។

គ) ការទាំងពីរនេះសុទ្ធតែបានរកឃើញនៅក្នុងអ្នកជឿតែមួយ មានន័យថាពួកអ្នកដែលបានរាប់ជាសុចរិត គឺជាពួកអ្នកដែលបានញែកចេញជាបរិសុទ្ធ ហើយពួកអ្នកដែលបានញែកចេញជាបរិសុទ្ធ ក៏ជាពួកអ្នកដែលបានរាប់ជាសុចរិតដែរ។

ឃ) ការទាំងពីរនេះចាប់ផ្តើមក្នុងពេលដំណាលគ្នា។ ខណៈពេលដែលមនុស្សម្នាក់ត្រូវបានរាប់ជាសុចរិត គាត់ក៏ចាប់ផ្តើមត្រូវបានញែកចេញជាបរិសុទ្ធដែរ។

ង) ការទាំងពីរនេះចាំបាច់ដូចគ្នាចំពោះសេចក្តីសង្គ្រោះ។ គ្មានអ្នកណាម្នាក់ទៅដល់នគរស្ថានសួគ៌ ដោយគ្មានសេចក្តីបរិសុទ្ធ និងការអត់ទោសបាបបានទេ។

*(ii) តើការទាំងពីរនេះខុសគ្នាដោយរបៀបណា?*

ក) ការរាប់ជាសុចរិត គឺជាការកំពុងវាយតម្លៃថា មនុស្សម្នាក់សុចរិតដោយយល់ដល់ព្រះគ្រីស្ទយេស៊ូវ ។ វាគឺជាអ្វីម្យ៉ាងដែលត្រូវបានធ្វើឡើង*សម្រាប់*អ្នកជឿ។ ការញែកចេញជាបរិសុទ្ធ គឺជាការដែលកំពុងធ្វើឲ្យមនុស្សម្នាក់បានសុចរិតផ្នែកខាងក្នុងដោយព្រះវិញ្ញាណបរិសុទ្ធ។ វាគឺជាអ្វីម្យ៉ាងដែលត្រូវបានធ្វើឡើង*ក្នុង*អ្នកជឿ។

ខ) សេចក្តីសុចរិត ដែលអ្នកជឿមាននៅក្នុងការញែកចេញជាបរិសុទ្ធមិនមែនជារបស់ពួកគេផ្ទាល់ឡើយ ប៉ុន្តែជារបស់ព្រះគ្រីស្ទវិញ។ សេចក្តីសុចរិតនៃការញែកចេញជាបរិសុទ្ធ គឺជារបស់អ្នកជឿផ្ទាល់។

គ) នៅក្នុងការរាប់ជាសុចរិត កិច្ចការខាងជំនឿដែលយើងធ្វើ គ្មានន័យសោះ។ ការដែលមានជំនឿលើព្រះគ្រីស្ទនោះគ្រប់គ្រាន់។ រីឯនៅក្នុងការញែកចេញជាបរិសុទ្ធវិញ យើងធ្វើ យើងតស៊ូ ចាំយាម អធិស្ឋាន ប្រឹងប្រែង និងខំធ្វើការងារ!

ឃ) ការរាប់ជាសុចរិត គឺជាអ្វីម្យ៉ាងដែលពេញលេញ ហើយចប់សព្វគ្រប់។ ការញែកចេញជាបរិសុទ្ធមិនទាន់បញ្ចប់ទេ ទាល់តែយើងបានចូលទៅដល់នគរស្ថានសួគ៌សិន។

ង) ការរាប់ជាសុចរិត មិនវិវឌ្ឍន៍ ឬរីកចម្រើនថែមទៀតឡើយ។ អ្នកជឿត្រូវបានរាប់ជាសុចរិតកាលពីដំបូងប៉ុណ្ណា ទៅមុខទៀតក៏នៅតែរាប់ជាសុចរិតប៉ុណ្ណឹងដែរ។ ការញែកចេញជាបរិសុទ្ធ គឺជាចលនាមួយនៅក្នុងវិញ្ញាណរបស់យើង ហើយវាវិវឌ្ឍន៍ និងរីកចម្រើនឡើងនៅក្នុងជីវិតនៅលើលោកិយនេះ។

ច) ការរាប់ជាសុចរិត ពាក់ព័ន្ធនឹងជំហររបស់យើងនៅក្នុងព្រះនេត្ររបស់ព្រះ រីឯការញែកចេញជាបរិសុទ្ធ ពាក់ព័ន្ធនឹងសភាពនៃចិត្តរបស់យើង។

ឆ) ការរាប់ជាសុចរិត ផ្តល់អំណាចដល់យើងក្នុងចូលទៅឯនគរស្ថានសួគ៌ រីឯការញែកចេញជាបរិសុទ្ធវិញ រៀបចំយើងឲ្យបានរីករាយនឹងជីវិតក្នុងនគរស្ថានសួគ៌។

ជ) ការរាប់ជាសុចរិត គឺជាកិច្ចការរបស់ព្រះនៅខាងក្រៅយើង គេមិនអាចមើលឃើញវាបានទេ។ រីឯការញែកចេញជាបរិសុទ្ធវិញ គឺជាកិច្ចការរបស់ព្រះនៅក្នុងយើង ហើយមនុស្សនៅជុំវិញខ្លួនយើង អាចមើលឃើញ។

ខ្ញុំសូមណែនាំភាពខុសគ្នាទាំងនេះដល់មិត្តអ្នកអានរបស់ខ្ញុំ។ សូមកុំឲ្យមានការយល់ច្រឡំនឹងពាក្យទាំងពីរនេះទៀត ហើយក៏កុំឲ្យភ្លេចពីភាពខុសគ្នារវាងពាក្យទាំងពីរនេះដែរ។ ការរាប់ជាសុចរិត និងការញែកចេញជាបរិសុទ្ធជាការពីរផ្សេងគ្នា ប៉ុន្តែអ្នកណាដែលមានមួយ ត្រូវតែមានទាំងពីរ។

**៩. នៅពេលយើងគិតពីការញែកចេញជាបរិសុទ្ធ នឹងមានប្រយោជន៍អ្វីខ្លះដល់យើង?**

*បើអ្នកណាគ្មានសេចក្តីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ* (ហេព្រើរ ១២:១៤)។

ក) ចូរយើងភ្ញាក់រលឹកពីបញ្ហាគ្រោះថ្នាក់នៃការមិនបរិសុទ្ធ! បើគ្មានការញែកចេញជាបរិសុទ្ធទេ ក៏គ្មានសេចក្តីសង្គ្រោះដែរ។ អ្វីដែលធ្វើឲ្យសាសនាត្រឡប់ជាឥតប្រយោជន៍ នោះគឺជាការខ្វះសេចក្តីបរិសុទ្ធពិតប្រាកដហ្នឹងឯង! តើអ្វីទៅជាការវិនិច្ឆ័យរបស់យើង ជម្រើសរបស់យើង បំណងប្រាថ្នារបស់យើងនោះ? នេះគឺជាសំណួរធ្វើតេស្តដ៏សំខាន់។

ខ) ប្រសិនបើយើងចង់បានភាពស្កប់ស្កល់ យើងត្រូវតែទៅឯព្រះគ្រីស្ទ ក្នុងនាមយើងជាមនុស្សមានបាប ហើយទូលប្រាប់ទ្រង់ពីសេចក្តីត្រូវការដ៏ចាំបាច់របស់យើង ។

គ) យើងត្រូវតែបន្តនៅពេលដែលយើងបានចាប់ផ្តើមហើយ មានន័យថា យើងត្រូវតែមកឯព្រះគ្រីស្ទម្តងហើយម្តងទៀត។ អវយវៈនៃរូបកាយរបស់ទ្រង់ត្រូវការឲ្យទ្រង់ដែលជាព្រះសិរសាបានផ្គត់ផ្គង់ឲ្យ។ អ្នកជឿដែលហាក់ដូចជាគាំងនៅមួយកន្លែងក្នុងការញែកចេញជាបរិសុទ្ធ ជាទូទៅគាត់កំពុងតែធ្វេសប្រហែសនឹងការប្រកបជាមួយនឹងព្រះគ្រីស្ទ។

ឃ) យើងមិនត្រូវសង្ឃឹមច្រើនពេកពីចិត្តរបស់យើងនៅក្នុងជីវិតនេះទេ។ នៅពេលយើងបានចាប់ផ្តើមផ្លូវនេះ យើងជាមនុស្សមានបាបទៅហើយ ហើយយើងនៅតែជាមនុស្សមានបាប នៅខណៈពេលដែលយើងកំពុងតែបន្តទទួលការកែជាថ្មី ការ

ទទួលការអត់ទោស ការទទួលការរាប់ជាសុចរិត មានន័យថា យើងជាមនុស្សមានបាបរបួតដល់ទីបំផុត។

ង) ប៉ុន្តែ ចូរយើងខិតខំឲ្យបានខ្ពាតខ្ពស់បំផុតនៃសេចក្ដីបរិសុទ្ធចុះ។ សេចក្ដីបរិសុទ្ធគឺជាសុភមង្គល ហើយអស់អ្នកណាដែលទទួលបានការនេះច្រើនជាងគេនៅក្នុងជីវិត គឺជាពួកអ្នកជឿដែលត្រូវបានញែកចេញជាបរិសុទ្ធ។ *ពួកអ្នកដែលស្រឡាញ់ក្រិត្យវិន័យទ្រង់ នោះមានសេចក្ដីសុខដ៏លើសលប់ ហើយគ្មានហេតុនឹងជំពប់ដួលឡើយ*(ទំនុកដំកើង ១១៩:១៦៥)។

# ជំពូក ៣

## សេចក្ដីបរិសុទ្ធ

*បើអ្នកណាគ្មានសេចក្ដីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ* (ហេព្រើរ ១២:១៤)។

តើយើងបរិសុទ្ធដែរឬទេ? តើយើងនឹងឃើញព្រះដែរឬទេ? ស្ដេចសាឡូម៉ូន ប្រាប់យើងថា មានពេលយំ និងពេលសើច...មានពេលដែលគួរនៅស្ងៀមហើយមានពេលសម្រាប់និយាយ (សាស្តា ៣:៤, ៧) ។ ប៉ុន្តែឥឡូវនេះជាពេលដែលត្រូវឲ្យបានបរិសុទ្ធ! ទោះបីយើងជានរណា ឬជាអ្វីក៏ដោយ យើងត្រូវតែឲ្យបានបរិសុទ្ធឥឡូវនេះភ្លាម។ នៅក្នុងលោកិយដ៏ប្រញាប់ប្រញាល់និងមមាញឹកនេះ សូមឲ្យបងប្អូនបានស្ដាប់អំពីរឿងនេះបន្តិចសិន។

### ១. តើអ្វីទៅជាសេចក្ដីបរិសុទ្ធនិងប្រភេទមនុស្សដ៏ពិតប្រាកដ ដែលព្រះត្រាស់ហៅឲ្យបានបរិសុទ្ធ?

ក) សេចក្ដីបរិសុទ្ធ គឺជាទម្លាប់នៃការឯកភាពជាមួយនឹងព្រះហឫទ័យរបស់ព្រះ។ វាជាការស្រឡាញ់នូវអ្វីដែលព្រះស្រឡាញ់ ហើយការស្អប់នូវអ្វីដែលព្រះស្អប់។ វាជាការវាស់វែងពីអ្វីៗគ្រប់យ៉ាងនៅក្នុងជីវិតនេះ ដោយខ្នាតនៃព្រះបន្ទូលរបស់ព្រះ គឺជា

ព្រះគម្ពីរ។ អ្នកណាដែលឯកភាពជាមួយព្រះបានច្រើនជាងគេ អ្នកនោះជាអ្នកបរិសុទ្ធជាងគេ។

ខ) នៅពេលមនុស្សម្នាក់ ខំប្រឹងប្រែងជៀសវាងចេញពីសេចក្ដីអាក្រក់ ហើយខំធ្វើតាមការទាមទាររបស់ព្រះ នោះហើយជាសេចក្ដីបរិសុទ្ធ។ សេចក្ដីបរិសុទ្ធ ត្រូវតែមានគំនិតស្រឡាញ់ផ្លូវរបស់ព្រះ។ សេចក្ដីបរិសុទ្ធ គឺត្រូវមានអារម្មណ៍ដូចស្ដេចដាវីឌអញ្ចឹង នៅពេលគាត់បាននិយាយថា *ទូលបង្គំរាប់អស់ទាំងបញ្ញត្តទ្រង់ថាជាត្រឹមត្រូវគ្រប់ប្រការ តែទូលបង្គំ ស្អប់ដល់គ្រប់ទាំងផ្លូវកំភូតវិញ* (ទំនុកដំកើង ១១៩:១២៨)។ ហើយសាវក ប៉ុលក៏បាននិយាយដែរថា *តាមប៉ែកខាងក្នុង ខ្ញុំត្រេកអរចំពោះក្រិត្យវិន័យរបស់ព្រះ* (រ៉ូម ៧:២២)។

គ) សេចក្ដីបរិសុទ្ធ គឺជាការខំព្យាយាមឲ្យបានដូចជាព្រះយេស៊ូវ គឺជាការរស់នៅក្នុងជីវិតនៃសេចក្ដីជំនឿដល់ព្រះយេស៊ូវ ដោយទាញសេចក្ដីសុខសាន្ត និងកម្លាំងចេញពីទ្រង់ជារៀងរាល់ថ្ងៃ។ សេចក្ដីបរិសុទ្ធ គឺត្រូវមាន*គំនិតជារបស់ផងព្រះគ្រីស្ទវិញ* (១កូរិនថូស ២:១៦) ហើយ*ឲ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់* (រ៉ូម ៨:២៩)។ ព្រះគ្រីស្ទពោរពេញទៅដោយការអត់ទោស សប្បុរស សេចក្ដីស្រឡាញ់ ការបន្ទាបខ្លួន ហើយនិងស្ដាប់បង្គាប់ដល់ព្រះ។ ព្រះគ្រីស្ទ គឺជាស្មបន្ទាល់ដ៏ស្មោះត្រង់ពីសេចក្ដីពិត បដិសេធខ្លួនឯងដើម្បីបម្រើអ្នកដទៃ។ ទ្រង់ស្លូតត្រង់ ហើយអត់ធ្មត់ក្រោមដំនៀលរបស់អ្នកដទៃ។ ទ្រង់មានសេចក្ដីក្លាហានក្នុងការលះកាត់ចេញពីអំពើបាប យាងទៅមកដើម្បីធ្វើការល្អ ហើយអធិស្ឋានជាញឹកញាប់។ ទាំងអស់នេះជាតម្លៃគុណធមិដែលមានលក្ខណៈដូចព្រះគ្រីស្ទ ដែលយើងត្រូវយកតម្រាប់តាមសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់យើង។ *បើសិនយើងរាល់គ្នាថា យើងមានសេចក្ដីប្រកបនឹងទ្រង់ តែដើរក្នុងសេចក្ដីងងឹតវិញ នោះឈ្មោះថាយើងកុហក* (១

យ៉ូហាន ១:៦)។ គេអាចនឹងចំណេញពេលវេលា ហើយនិងអាចការពារខ្លួនពីអំពើបាបបានច្រើន ប្រសិនបើគេសួរជារឿយៗថា តើព្រះគ្រីស្ទអាចនឹងមានបន្ទូលថាម៉េច ឬក៏អាចនឹងធ្វើអ្វី នៅក្នុងស្ថានភាពនេះ?

ឃ) មនុស្សបរិសុទ្ធ ជាមនុស្សស្លូតត្រង់ ទន់ភ្លន់ អត់ធ្មត់ ក្រនឹងនិយាយពី "សិទ្ធិរបស់ខ្លួន"។ យើងអាចឃើញពីគំរូល្អទាំងនេះ នៅក្នុងលោកម៉ូសេ នៅពេលដែលលោក អើរ៉ុន និងម៉ារាម និយាយប្រឆាំងនឹងលោក ម៉ូសេ (ជន ១២:៣) ហើយនៅក្នុងស្តេចដាវីឌ នៅពេល ស៊ីម៉ាយដែលប្រទេចផ្តាសាដល់ទ្រង់ (២សាំ ១៦:១០)។

ង) មនុស្សបរិសុទ្ធជាមនុស្សដែលមិនបណ្តែតបណ្តោយខ្លួន។ ពួកគេនឹងមិនបណ្តោយឲ្យសេចក្តីប៉ងប្រាថ្នា សេចក្តីស្រឡាញ់បែបអាក្រក់ ឬក៏អារម្មណ៍ស្រើបស្រាល មកគ្រប់គ្រងក្នុងជីវិតរបស់ពួកគេឡើយ។ ដូចជាព្រះយេស៊ូវផ្ទាល់បានរលឹកដាស់តឿនដល់ពួកអ្នកដែលដើរតាមទ្រង់ហើយនៅគម្ពីរលូកា ២១:៣៤ថា *ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន! ក្រែងចិត្តអ្នករាល់គ្នាកំពុងតែផ្ទុកនូវសេចក្តីវក់នឹងស៊ីផឹក ហើយនឹងមានសេចក្តីខ្វល់ខ្វាយនៅជីវិត*។ (ហើយពេលបច្ចុប្បន្ន ការរំលឹកដាស់តឿននេះ សំដៅទៅលើ ការញៀនស្រី ស្រា ថ្នាំញៀន ឬអ្វីផ្សេងទៀតដែលធ្វើឲ្យញៀន)។

ច) មនុស្សបរិសុទ្ធជាមនុស្សដែលមានពេញដោយសេចក្តីស្រឡាញ់ --គឺជាសេចក្តីស្រឡាញ់ដែលព្រះយេស៊ូវបានមានបន្ទូលនៅក្នុងការអធិប្បាយនៅលើភ្នំ ដែលសាវក ប៉ុលបានពិពណ៌នានៅក្នុង១កូរិនថូស ជំពូក ១៣។ កន្លែងណាដែលមានសេចក្តីស្រឡាញ់ នោះការកុហក ការបោកប្រាស់ ការលួចប្លន់ និងការធ្វើបាបអ្នកដទៃ មិនអាចកើតឡើងបានឡើយ!

ឆ) សេចក្តីបរិសុទ្ធ គឺជាសេចក្តីស្រឡាញ់ដ៏សកម្ម។ នេះមិនគ្រាន់តែជាការមិនធ្វើឲ្យមាននូវសេចក្តីអន្តរាយនោះទេ គឺត្រូវធ្វើល្អផង។ នាងក្តាន់ *បានធ្វើគុណ ហើយដាក់ទានជាច្រើន* (កិច្ចការ ៩:៣៦)។ សាវក ប៉ុល បានសរសេរផ្ញើទៅកាន់អ្នកជឿនៅក្នុងក្រុងកូរិនថូសថា *ខ្ញុំសុខចិត្តនឹងចែកចាយ ហើយនិងត្រូវហិនអស់របើងទៅចុះ* (១កូរិនថូស ១២:១៥)។

ជ) សេចក្តីបរិសុទ្ធ តែងស្វែងរកភាពបរិសុទ្ធនៃចិត្តនិងគំនិត។ មនុស្សប្រភេទនេះគឺជាអ្នកដែលខ្លាចមិនចង់ឲ្យមាននូវសេចក្តីសៅហ្មងខាងព្រលឹងវិញ្ញាណរបស់ខ្លួន ហើយជៀសវាងនូវអ្វីៗដែលអាចនឹងនាំឲ្យគេធ្លាក់ទៅក្នុងសេចក្តីមិនបរិសុទ្ធ។ តើអ្នកណាមិនប្រុងប្រយ័ត្នអំពីការនេះបាន ដ្បិតស្តេចដាវីឌ ជាអ្នកសំណព្វរបស់ព្រះ (២ សាំយូអែល ១១) បានប្រព្រឹត្តអំពើបាបនេះរួចទៅហើយនោះ? នៅក្រោមច្បាប់នៃពិធីផ្សេងៗនៃពួកអ៊ីស្រាអែល អស់អ្នកណាដែលគ្រាន់តែប៉ះឆ្អឹងមួយ ឬក៏មនុស្សស្លាប់ នោះបានត្រឡប់ជាមិនបរិសុទ្ធភ្លាមនៅចំពោះព្រះ។ មានពួកគ្រីស្ទានតិចណាស់ដែលធ្លាប់មានការប្រុងប្រយ័ត្នអំពីសេចក្តីបរិសុទ្ធនៃចិត្តនិងគំនិត!

ឈ) សេចក្តីបរិសុទ្ធត្រូវតែមានសេចក្តីគោរពដ៏ជ្រាលជ្រៅចំពោះព្រះ និងផ្លូវរបស់ទ្រង់។ ដូចជាកុមារម្នាក់ដែលចង់ប្រព្រឹត្តិអាកប្បកិរិយាទៅតាមរបៀបដែលផ្គាប់ចិត្តឪពុកម្តាយ ដូច្នេះអ្នកជឿត្រូវស្រឡាញ់ព្រះ ហើយផ្គាប់ដល់ព្រះហឫទ័យព្រះក្នុងរបៀបយ៉ាងដូច្នោះដែរ។ លោក នេហេមា បានផ្តល់ជាឧទាហរណ៍ដ៏ល្អមួយសម្រាប់យើង នៅពេលដែលគាត់បានបដិសេធទៅនឹងការប្រព្រឹត្តិមួយ ដោយនិយាយថា *ខ្ញុំមិនបានធ្វើដូច្នោះទេ ដោយមានសេចក្តីកោតខ្លាចដល់ព្រះវិញ*(នេហេមា ៥:១៥)។

ញ) មនុស្សបរិសុទ្ធជាមនុស្សបន្ទាបខ្លួន ជាអ្នកដែលតែងតែគោរពនិងកោតសរសើរអ្នកដទៃជាជាងខ្លួនឯង។ មនុស្សបែបនេះនឹងតែងតែឃើញសេចក្តីអាក្រក់

នៅក្នុងចិត្តរបស់ខ្លួនឯងច្រើនជាងនៅក្នុងជីវិតរបស់ឯទៃ។ គេដឹងពីអ្វីដែលលោក អាប្រាហាំ ចង់និយាយសំដៅ នៅពេលដែលគាត់បាននិយាយថា *ទូលបង្គំជាធូលីដី ហើយជាផេះទទេ* (លោកុប្បត្តិ ១៨:២៧) ហើយនៅពេល លោក យ៉ាកុប និយាយថា *ទូលបង្គំមិនគួរឲ្យបានអស់ទាំងអស់សេចក្ដីសប្បុរស និងអស់ទាំងសេចក្ដីស្មោះត្រង់ដែលទ្រង់បានផ្ដល់មកទូលបង្គំជាអ្នកបំរើទ្រង់ទេ* (លោកុប្បត្តិ ៣២:១០) ឬសាវក ប៉ុល នៅពេលដែលគាត់បាននិយាយថា *ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកិយ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ ១ ក្នុងពួកគេ* (១ធីម៉ូថេ ១:១៥)។

ង) មនុស្សបរិសុទ្ធជាមនុស្សស្មោះត្រង់ និងគួរឲ្យទុកចិត្តបាន នៅក្នុងកាតព្វកិច្ច និងទំនាក់ទំនងរបស់ពួកគេ។ សាវក ប៉ុល បានសរសេរទៅកាន់ពួកជំនុំនៅក្រុងកូល៉ុសថា *ការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ* (កូល៉ុស ៣:២៣) ។ មនុស្សបរិសុទ្ធគួរផ្ដោតលើអ្វីដែលខ្លួនធ្វើ គឺធ្វើអ្វីៗទាំងអស់ឲ្យបានល្អ ដូចជា ធ្វើជាប្ដីល្អ ជាប្រពន្ធល្អ ជាឪពុកម្ដាយល្អ ជាកូនល្អ ល្អក្នុងជីវិតឯកជន ល្អក្នុងសបាគមន៍ ល្អនៅកន្លែងការងារ ល្អនៅផ្ទះ។ សេចក្ដីបរិសុទ្ធរបស់អ្នកមានតម្លៃតិចវិញ ប្រសិនបើអ្នកមិនផ្ដោតយកចិត្តទុកដាក់លើការទាំងអស់នេះ នោះ។

ច) ចំណុចចុងក្រោយ មនុស្សបរិសុទ្ធជាមនុស្សដែលជំហាររឹងមាំខាងវិញ្ញាណ។ ពួកគេយល់ថាជីវិតនេះជាការរៀបចំមួយសម្រាប់ជីវិតនៅឯនគរស្ថានសួគ៌។ នេះមានន័យថា ពួកគេអាចទទួលយកតែអ្វីដែលជាតំលៃពិតនៅក្នុងលោកិយនេះប៉ុណ្ណោះ ដែលសមនឹងយើងសម្រាប់ជីវិតនោះពេលខាងមុខ។

យើងបានមើលពីលក្ខណៈមនុស្សដែលគេហៅថា "បរិសុទ្ធ" រួចហើយ។ ប៉ុន្តែ ចូរឲ្យអ្នកមិនជឿស្រយុតចិត្តដោយសារសេចក្ដីដែលបានរៀបរាប់ខាងលើនេះចុះ។ សេចក្ដីបរិសុទ្ធទទួលបានមកដោយសារមានការខិតខំប្រឹងប្រែងប៉ុណ្ណោះ។ ការរីកចម្រើននៅក្នុងសេចក្ដីបរិសុទ្ធ នាំមកនូវការធ្វើឲ្យដឹងពីអំពើបាបកាន់តែច្រើនឡើង។ ការញែកចេញជាបរិសុទ្ធ តែងតែជាកិច្ចការដែលនៅតែបន្តការរីកចម្រើនមួយ វាមិនមែនជាកិច្ចការដែលគ្រប់លក្ខណ៍មួយនោះទេ។ អ្នកដែលបរិសុទ្ធបំផុតអាចនឹងមានស្លាកស្នាមជាច្រើននៅចំពោះព្រះ។ ពន្លឺមិនដែលរះដោយគ្មានពពកខ្លះនោះទេ ហើយសូម្បីតែព្រះអាទិត្យផ្ទាល់ក៏មានស្លាកស្នាមនៅលើមុខរបស់វាដែរ! ទោះជាអ្នកជឿទទួលយកផ្នែកកម្សោយ និងអំពើបាបនៃនិស្ស័យមនុស្សក៏ដោយ តែរូបភាពនៃសេចក្ដីបរិសុទ្ធដែលបានផ្ដល់មកនៅទីនេះ អាចនៅតែជាគោលដៅរបស់អ្នកជឿទាំងអស់ដដែល។ វាជាអ្វីដែលពួកគេខិតខំប្រឹងប្រែងឲ្យបាន ប្រសិនវាមិនមែនជាអ្វីដែលពួកគេមាននៅឡើយ។

## ២. ហេតុផលដែលសេចក្ដីបរិសុទ្ធមានសារៈសំខាន់

ក) យើងត្រូវតែបរិសុទ្ធ ពីព្រោះនៅក្នុងព្រះគម្ពីរ ព្រះបង្គាប់ឲ្យយើងបានបរិសុទ្ធ។ ព្រះអម្ចាស់យេស៊ូវមានបន្ទូលដល់ពួកសាវករបស់ទ្រង់ថា *ខ្ញុំប្រាប់អ្នករាល់គ្នាថា បើសេចក្ដីសុចរិតរបស់អ្នករាល់គ្នាមិនលើសពីសេចក្ដីសុចរិតនៃពួកអាចារ្យ និងពួកផារិស៊ីទេ នោះអ្នករាល់គ្នានឹងចូលទៅក្នុងនគរស្ថានសួគ៌ពុំបានឡើយ* (ម៉ាថាយ ៥:២០)។ ហើយនៅគម្ពីរម៉ាថាយ ៥:៤៨ ជាថ្មីម្ដងទៀតថា *"ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍"*។ សាវក ពេត្រុស ក៏បានសរសេរទៅកាន់ពួកអ្នកជឿផងដែរថា *ចូរឲ្យអ្នករាល់គ្នាបាន*

*បរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ ដ្បិតមានសេចក្តីចែងទុកមកថា "ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ"* (១ពេត្រុស ១:១៥-១៦)។

២) យើងត្រូវតែបរិសុទ្ធ ពីព្រោះព្រះគ្រីស្ទបានយាងមកក្នុងពិភពលោកនេះ ដើម្បីញែកយើងជាបរិសុទ្ធ។ សាវក ប៉ុល បានសរសេរថា *ព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គជំនួយផង ដើម្បីឲ្យទ្រង់បានញែកពួកជំនុំជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល* (អេភេសូរ ៥:២៥,២៦)។ ព្រះគ្រីស្ទបានសុគតមិនត្រឹមតែដើម្បីសង្គ្រោះយើងពីទោសនៃអំពើបាបប៉ុណ្ណោះទេ តែថែមទាំងសង្គ្រោះយើងចេញពីអំណាចនៃអំពើបាបទៀតផង។ តើពួកអ្នកជឿជា «ពួកជ្រើសរើស» ឬ? នោះគឺដោយសារកិច្ចការញែកជាបរិសុទ្ធរបស់ព្រះវិញ្ញាណ។ តើពួកគេត្រូវបាន"តម្រូវទុកជាមុន"ឬ? នោះគឺដើម្បី*ឲ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់* (រ៉ូម ៨:២៩)។ តើព្រះបានជ្រើសរើសពួកគេឬ? នោះគឺ*ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់* (អេភេសូរ ១:៤)។ តើព្រះបានជ្រើសរើសពួកគេឬ? នោះគឺ*បានហៅយើងមកក្នុងការងារបរិសុទ្ធ* (២ធីម៉ូថេ ១:៩)។ តើពួកគេទទួលនូវការទុក្ខលំបាកឬទេ? វាជាករណីមួយដែលព្រះវាយផ្ចាល សម្រាប់ជាប្រយោជន៍ដល់យើងវិញទេ ដើម្បីឲ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់ (ហេព្រើរ ១២:១០)។ ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះដ៏ពេញលេញ ដែលមិនគ្រាន់តែយកទោសនៃអំពើបាបរបស់អ្នកជឿចេញប៉ុណ្ណោះទេ ថែមទាំងបំផ្លាញអំណាចរបស់វាចេញពីអ្នកជឿ ហើយព្រមទាំងធ្វើឲ្យអ្នកជឿបានបរិសុទ្ធទៀតផង។

គ) សេចក្តីបរិសុទ្ធគឺជាភស្តុតាងដែលបង្ហាញពី សេចក្តីជំនឿដ៏ពិតប្រាកដនៅក្នុងព្រះគ្រីស្ទ។ លោក យ៉ាកុប បានព្រមានថា មានការមួយដែលជាជំនឿស្លាប់។ ជំនឿពិតនឹងបង្កើតផលផ្លែ។ នោះវានឹងធ្វើឲ្យយើងបានបរិសុទ្ធ (យ៉ាកុប ២:១៧,១៨)។ ខ្ញុំសង្ស័យថា មានមនុស្សស្លាប់នៅក្នុងលក្ខខណ្ឌដូចជាពួកគេបានរស់នៅ។ អស់អ្នកណាដែលរស់នៅក្នុងជីវិតដ៏បរិសុទ្ធមួយ គឺជាពួកអ្នកដែលស្លាប់នៅក្នុងសេចក្តីសុចរិតដែរ។

ឃ) សេចក្តីបរិសុទ្ធនៃជីវិតបង្ហាញថាសេចក្តីស្រឡាញ់របស់យើងចំពោះព្រះ គឺជាសេចក្តីស្រឡាញ់ស្មោះត្រង់។ ព្រះបន្ទូលរបស់ព្រះយេស៊ូវបានបង្ហាញយ៉ាងច្បាស់ថា៖ *«បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ»* (យ៉ូហាន ១៤:១៥)។ *អ្នកណាដែលស្រឡាញ់ខ្ញុំនោះជាទីស្រឡាញ់នៃព្រះវរបិតាខ្ញុំហើយ ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសំដែងខ្លួនឲ្យអ្នកនោះស្គាល់ផង* (យ៉ូហាន ១៤:២១)។ *ដូចជាព្រះវរបិតាទ្រង់ស្រឡាញ់ខ្ញុំដែរ ចូរនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំចុះ* (យ៉ូហាន ១៥:៩)។ ពិបាករកពាក្យណាទៀតដែលងាយស្រួលស្តាប់ជាងពាក្យទាំងនេះណាស់!

ង) សេចក្តីបរិសុទ្ធជាភស្តុតាងបង្ហាញថាយើងជាកូនរបស់ផងព្រះ។ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកយូដា ដែលអះអាងថាខ្លួនជាកូនរបស់ព្រះថា៖ *បើព្រះជាព្រះវរបិតានៃអ្នករាល់គ្នាមែន នោះអ្នកនឹងបានស្រឡាញ់ខ្ញុំ* (យ៉ូហាន ៨:៤២)។ សកម្មភាពរបស់យើងត្រូវតែបង្ហាញថា យើងពិតជាសមាជិកនៃគ្រួសារព្រះប្រាកដមែន។

ច) ដោយសេចក្តីបរិសុទ្ធ យើងជួយអ្នកដទៃទៀតដើម្បីស្វែងរកសេចក្តីបរិសុទ្ធដែរ។ ជីវិតរបស់យើងតែងតែជាគំរូល្អ ឬអាក្រក់ ដែលវាជាសេចក្តីអធិប្បាយដ៏មិនពូ

សំឡេងមួយដែលពួកគេអាន។ វាគួរឲ្យសោកស្តាយប្រសិនបើសេចក្តីអធិប្បាយរបស់យើងសម្រាប់តែបុព្វហេតុរបស់អារក្សសាតាំង មិនសម្រាប់បុព្វហេតុរបស់ព្រះ។ យ៉ាងហោចណាស់វាជាប្រយោជន៍ដល់អ្នកដទៃ ប្រសិនបើមិនមានហេតុផលអ្វីផ្សេងទៀតនោះ ចូរយើងរាល់គ្នាខិតខំឲ្យបានបរិសុទ្ធចុះ! *បើមានអ្នកណាដែលមិនព្រមស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះ នោះប្រពន្ធនឹងទាញចិត្តមកបានដោយសារកិរិយាល្អក្រៅពីព្រះបន្ទូល...ដោយអ្នកឃើញកិរិយាបរិសុទ្ធដែលប្រពន្ធប្រព្រឹត្តិយ៉ាងកោតខ្លាចដល់ព្រះ* (១ពេត្រុស ៣:១)។

ឆ) ការកម្សាន្តចិត្តនៅពេលបច្ចុប្បន្នរបស់យើង ពឹងលើសេចក្តីបរិសុទ្ធរបស់យើង។ ជាញឹកញាប់យើងតែងតែភ្លេចពីចំណងរវាងអំពើបាបនិងការទុក្ខព្រួយ។ យើងភ្លេចពីផែនការរបស់ព្រះថា សេចក្តីសុខសាន្តរបស់យើងពឹងលើរបៀបដែលធ្វើតាមព្រះហឫទ័យរបស់ទ្រង់។ *យើងមិនត្រូវស្រឡាញ់ដោយពាក្យសំដី ឬដោយបបូរមាត់ប៉ុណ្ណោះឡើយ គឺដោយការប្រព្រឹត្តិនិងសេចក្តីពិតវិញ...យើងនឹងបានកំឡាចិត្តនៅចំពោះទ្រង់* (១យ៉ូហាន ៣:១៨, ១៩)។ នៅពេលដែលពួកសាវ័ក រត់ចោលព្រះគ្រីស្ទ ហើយពួកគេបានរត់គេចពីការគ្រោះថ្នាក់ ប៉ុន្តែពួកគេបានកើតទុក្ខជាខ្លាំងវិញ។ ក្រោយមកនៅពេលដែល ពួកគេបានលន់តួដោយសេចក្តីក្លាហានដល់ព្រះនៅចំពោះមនុស្ស ពួកគេមានសេចក្តីអំណរអរសប្បាយ *ពីព្រោះព្រះបានរាប់ជាអ្នកគួរនឹងទ្រាំសេចក្តីដំនៀលដោយព្រោះព្រះនាមទ្រង់* (កិច្ចការ ៥:៤១)។

ជ) ប្រសិនបើគ្មានសេចក្តីបរិសុទ្ធនៅផែនដីនេះទេ យើងនឹងមិនដែលត្រៀមខ្លួនរួចជាស្រេចសម្រាប់សេចក្តីបរិសុទ្ធនៅនគរស្ថានសួគ៌ឡើយ។ អត្តចរិតរបស់យើងមិនត្រូវបានផ្លាស់ប្តូរដោយព្រោះសេចក្តីស្លាប់ទេ។ យើងនឹងរស់ឡើងវិញនៅថ្ងៃជំនុំជំរះ ដោយមានអត្តចរិតដដែលដូចគ្នានឹងអត្តចរិតនៅពេលយើងបានស្លាប់ដែ

រ។ មានតែពួកអ្នកដែលបានត្រៀមខ្លួនជាស្រេចសម្រាប់នគរស្ថានសួគ៌ប៉ុណ្ណោះដែលនឹងបានសេចក្ដីរីករាយនៅឯនគរស្ថានសួគ៌។ ឧបមាថា យើងត្រូវបានអនុញ្ញាតិឲ្យចូលទៅក្នុងនគរស្ថានសួគ៌ដោយមិនបាច់មានសេចក្ដីបរិសុទ្ធ។ តើយើងនឹងធ្វើអ្វីនៅទីនោះ? សេចក្ដីបរិសុទ្ធនៅគ្រប់ទីកន្លែងក្នុងនគរស្ថានសួគ៌ តើមានសេចក្ដីរីករាយណាមួយដែលយើងអាចរកបាននៅទីនោះ?

សូមឲ្យខ្ញុំរំលឹកដល់បងប្អូនពីខដែលនៅខាងដើមនៃជំពូកនេះថា *បើអ្នកណាគ្មានសេចក្ដីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ*។ ជាការពិតណាស់ពាក្យខាងលើនេះជំរុញយើងឲ្យមានការពិនិត្យមើលលើខ្លួនឯងម្នាក់ៗ។ តើយើងបរិសុទ្ធឬទេ? តើយើងគិត មានអារម្មណ៍ ហើយនិងប្រព្រឹត្តិដូចជាព្រះគ្រីស្ទដែរឬទេ? *អស់អ្នកណាដែលមានសេចក្ដីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជំរះសំអាតចិត្តខ្លួន ឲ្យដូចទ្រង់* (ព្រះគ្រីស្ទ) *ដែលស្អាតដែរ* (១យ៉ូហាន ៣:៣)។ ការធ្វើឲ្យខ្លួនយើងរាល់គ្នាឲ្យបានបរិសុទ្ធគឺជាការដ៏លំបាកមួយ ប៉ុន្តែវាជាការចាំបាច់ដែលខានមិនបាន។ ខ្ញុំមិនសួរថា "តើបងប្អូនទៅព្រះវិហារទៀតទាត់ដែរឬទេ? តើបងប្អូនទទួលពិធីជ្រមុជទឹកហើយឬនៅ? តើបងប្អូនហៅខ្លួនឯងជាគ្រីស្ទានដែរឬទេ?" ខ្ញុំក៏មិនសួរថាតើបងប្អូនគាំទ្រឬមិនគាំទ្រជីវិតបរិសុទ្ធរបស់អ្នកដទៃដែរ។ ហើយខ្ញុំក៏មិនសួរថាបងប្អូនអាចជជែកអំពីសេចក្ដីខាងឯភាពបរិសុទ្ធទេ តែខ្ញុំសួរលើសពីនោះគឺ "តើបងប្អូនខ្លួនឯងបានបរិសុទ្ធនៅថ្ងៃនេះដែរឬទេ?"

## ៣. ដំបូន្មានខ្លះសម្រាប់អ្នកដែលចង់បានបរិសុទ្ធ

ក) ចូរចាប់ផ្ដើមជាមួយព្រះគ្រីស្ទ។ ជួលកាល មនុស្សព្យាយាមធ្វើឲ្យខ្លួនឯងបានបរិសុទ្ធ ហើយនិងលទ្ធផលដ៏គួរឲ្យអាណិតមួយដែលពួកគេទទួលបាន។ អ្វីដែល

យើងរាល់គ្នាត្រូវធ្វើគឺ បែរទៅរកព្រះគ្រីស្ទ គឺមកឯទ្រង់ដោយសេចក្ដីជំនឿ ហើយរួមសហភាពជាមួយទ្រង់។ *ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ* (យ៉ូហាន ១៥:៥) នេះជាអ្វីដែលព្រះយេស៊ូវផ្ទាល់បានមានបន្ទូល។

ខ) សេចក្ដីបរិសុទ្ធគឺជាអំណោយទានពិសេសរបស់ព្រះគ្រីស្ទ ដែលទ្រង់ប្រទានមករាស្ត្ររបស់ទ្រង់។ សេចក្ដីបរិសុទ្ធគឺជាលទ្ធផលនៃការរួមសហភាពជាមួយទ្រង់ ។ ប្រសិនបើនោះជាសេចក្ដីបរិសុទ្ធដែលអ្នកចង់បាន អញ្ចឹងខ្ញុំសូមទូន្មានអ្នកថា កុំរង់ចាំអ្វីឬអ្នកណាមួយឲ្យសោះ ចូរទៅឯព្រះគ្រីស្ទទៅ។

គ) ដើម្បីបន្តនៅក្នុងសេចក្ដីបរិសុទ្ធ យើងត្រូវតែនៅជាប់នឹងព្រះគ្រីស្ទ។ ទ្រង់គឺជាគ្រូពេទ្យ ដែលអ្នកត្រូវទៅជួបជារៀងរាល់ថ្ងៃ ប្រសិនបើអ្នកចង់រក្សាសុខភាពខាងព្រលឹងវិញ្ញាណ។ ទ្រង់គឺជានំម៉ាណាដែលយើងត្រូវតែបរិភោគជារៀងរាល់ថ្ងៃ ហើយទ្រង់ជាថ្មដាផ្ដល់ទឹកដែលយើងត្រូវផឹកជារៀងរហូត។ សាវ័ក ប៉ុល បានសរសេរថា *«ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទ ដែលទ្រង់ចម្រើនកំឡាំងដល់ខ្ញុំ»* (ភីលីព ៤:១៣)។

សូមឲ្យបងប្អូនដែលបានអានអត្ថបទក្នុងទំព័រទាំងនេះ បានស្គាល់សេចក្ដីទាំងអស់នេះ ដោយបទពិសោធន៍ចុះ គឺមិនមែនដោយគ្រាន់តែឮគេថានោះទេ។

# ជំពូក ៤

## ការតស៊ូ

*ចូរប្រឹងតស៊ូ ដោយការតយ៉ាងល្អនៃសេចក្ដីជំនឿ* (១ធីម៉ូថេ ៦:១២)

អស់អ្នកណាដែលប្រាថ្នាចង់យល់ពីនិស្ស័យនៃសេចក្ដីបរិសុទ្ធ ត្រូវតែយល់ថា គ្រីស្ទានផ្សារភ្ជាប់នៅក្នុងការតស៊ូ។ វាគឺជាសង្គ្រាមខាងព្រលឹងវិញ្ញាណមួយដែលសាវក ប៉ុល បាននិយាយសំដៅ នៅពេលដែលគាត់សរសេរទៅកាន់ធីម៉ូថេ «*ចូរប្រឹងតស៊ូ ដោយការតយ៉ាងល្អនៃសេចក្ដីជំនឿ*»។

## ១. សេចក្ដីជំនឿលើព្រះគ្រីស្ទដ៏ពិតប្រាកដ គឺជាការតស៊ូមួយ

ខ្ញុំនិយាយអំពី ជំនឿលើព្រះគ្រីស្ទ «ពិត»។ មានមនុស្សជាច្រើនហៅខ្លួនឯងថាជាគ្រីស្ទាន តែមិនស្គាល់អ្វីទាំងអស់ពីការតស៊ូ ជម្លោះ និងការលះកាត់ខ្លួនឯងខាងព្រលឹងវិញ្ញាណ។ ប្រហែលជាពួកគេរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារ កប់សពនៅក្នុងព្រះវិហារ ហើយហៅខ្លួនឯងថាជា «ពួកគ្រីស្ទាន» ប៉ុន្តែអ្នកមិនដែលឃើញ «ការតស៊ូ» ណាមួយទាល់តែសោះនៅក្នុងសេចក្ដីជំនឿរបស់ពួកគេ។ សេចក្ដីជំនឿរបស់ពួកគេ គឺមិនមែនជាសេចក្ដីជំនឿ ដែលព្រះយេស៊ូវគ្រីស្ទបានបង្កើតឡើង ហើយពួកសាវកបានប្រកាសនោះទេ។ វាមិនមែនជាសេចក្ដីជំនឿដែលបង្កើតឲ្យមានសេចក្ដីបរិសុទ្ធទេ។

តើពួកគ្រីស្ទានតស៊ូជាមួយអ្នកណា? មិនមែនជាមួយអ្នកជឿងទៃទៀតទេ! ជាទូទៅ នៅពេលណាដែលពួកគ្រីស្ទានចំណាយកម្លាំងឥតប្រយោជន៍ ក្នុងការឈ្លោះប្រកែកគ្នា នោះវាជួយដល់បុព្វហេតុនៃអំពើបាបវិញទេ។ គ្រីស្ទានពិតប្រាកដតស៊ូនឹងចម្បាំងដ៏ឥតឈប់ឈរមួយប្រឆាំងនឹងលោកិយ សាច់ឈាម និងអារក្សសាតាំង ។ ទាំងអស់នេះគឺជាសត្រូវដ៏សំខាន់របស់ពួកគ្រីស្ទានពិតប្រាកដ ដ្បិតដោយចិត្តពុករលួយ អារក្សសាតាំងដ៏មមាញឹក ហើយនិងលោកិយដែលតែងតែព្យាយាមធ្វើឲ្យពួកគេជាប់អន្ទាក់ នោះគ្រីស្ទានត្រូវតែច្បាំង បើមិនដូច្នោះទេនោះនឹងចាញ់ជាពុំខាន ។

ក) ពួកគ្រីស្ទានត្រូវតែច្បាំងនឹង «សាច់ឈាម»។ សូម្បីតែបន្ទាប់ពីការផ្លាស់ប្រែក៏ដោយ ពួកគ្រីស្ទានទាំងអស់នៅតែយកជាមួយនូវនិស្ស័យតស៊ូនឹងសេចក្តីអាក្រក់ និងអារម្មណ៍រំជើបរំជួល ដែលនាំឲ្យពួកគេវង្វេង។ ដើម្បីដោះស្រាយជាមួយនឹងសេចក្តីល្បួងនេះ ត្រូវមានការតស៊ូខាងព្រលឹងវិញ្ញាណ និងសេចក្តីអធិស្ឋានដ៏ស្មោះត្រង់រៀងរាល់ថ្ងៃ។ ដូចជាសាវក ប៉ុល បានសរសេរផ្ញើទៅកាន់អ្នកជឿនៅកូល៉ុសថា ៖ *«ចូរសម្លាប់និស្ស័យសាច់ឈាមរបស់អ្នករាល់គ្នា ដែលនៅផែនដីនេះចេញ គឺជាការសហាយស្មន់ ស្មោកគ្រោក សម្រើបសម្រាលប៉ងប្រាថ្នាអាក្រក់ និងសេចក្តីលោភ ដែលរាប់ទុកដូចជាការថ្វាយបង្គំរូបព្រះ»* (កូល៉ុស ៣:៥)។ (ហើយគេអាចនឹងបន្ថែមការផ្សេងៗដែលធ្វើឲ្យញៀនដូចជា ល្បែងស៊ីសង ថ្នាំញៀន។ល។)

ខ)គ្រីស្ទានត្រូវតែតស៊ូច្បាំងនឹង «លោកិយ»។ឥទ្ធិពលនៃសេចក្តីស្រឡាញ់របស់លោកិយនៃសម្ភារៈនិយម គឺពិបាកទប់ទល់ណាស់។ ពួកគ្រីស្ទានអាចនឹងខ្លាចការសើចចំអក ឬការស្តីបន្ទោសរបស់លោកិយដែលមិនជឿ ឬក៏អាចនឹងចង់ធ្វើត្រាប់

តាមឥរិយាបថនៃអ្នកមិនជឿ ឬខ្លាចចេញមុខនៅចំពោះភ្នែករបស់លោកិយ។ ប៉ុន្តែទាំងនេះជាសត្រូវខាងព្រលឹងវិញ្ញាណ ដែលពួកគេត្រូវតែច្បាំង។

*ឱពួកកំផិតទាំងប្រុសទាំងស្រីអើយ តើមិនដឹងទេឬអីថា ដែលស្រឡាញ់ដល់លោកិយ នោះគឺជាស្អប់ដល់ដល់ព្រះវិញ ដូច្នេះអ្នកណាដែលចូលចិត្តធ្វើជាមិត្តសម្លាញ់នឹងលោកិយ នោះឈ្មោះថា បានតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ* (យ៉ាកុប ៤:៤)។ ពួកគ្រីស្ទានត្រូវតែច្បាំងនឹងលោកិយ!

គ) ពួកគ្រីស្ទានត្រូវតែច្បាំងនឹងអារក្សសាតាំង។ យើងមិនត្រូវសង្ស័យនឹងភាពពិតរបស់អារក្សសាតាំងនោះទេ។ វានៅរស់ វាមិនដែលដេកលក់ទេ ហើយវាជាខ្មាំងសត្រូវដ៏មើលមិនឃើញរបស់ពួកគ្រីស្ទាន។ *សាតាំងបានសូមចង់បានអ្នករាល់គ្នាប្រយោជន៍នឹងរែងអ្នករាល់គ្នាដូចជារែងអង្ករ* (លូកា ២២:៣១)។ សត្រូវនេះគឺជាសត្រូវដែលយើងត្រូវតទល់រៀងរាល់ថ្ងៃ ប្រសិនបើយើងចង់បានទទួលសេចក្តីសង្គ្រោះ។ ចូរគ្រប់គ្រងខ្លួនឯង និងប្រុងប្រយ័ត្ន។ *ចូរដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន។ ចូរតស៊ូនឹងវា ដោយមានចិត្តជឿមាំមួន...*(១ពេត្រុស ៥:៨-៩)។

ចម្បាំងនេះពិតជាចាំបាច់ណាស់ ចំពោះការបែបនេះ យើងមិនអាចឈរនៅកណ្តាលនៃបញ្ហាបានឡើយ។ យើងគ្មានជម្រើសទេ។ បើយើងមានសន្តិភាពជាមួយលោកិយ សាច់ឈាម អារក្សសាតាំង នោះមានន័យថា យើងកំពុងទាស់ប្រឆាំងនឹងព្រះហើយ។ យើងត្រូវតែច្បាំងជាដាច់ខាត មិនដូច្នេះទេយើងនឹងចាញ់!

ចម្បាំងនេះគឺសម្រាប់គ្រីស្ទានគ្រប់រូប ទោះជាជាតិសាសន៍ អាយុ ឬឋានៈអ្វីក៏ដោយ។ ពួកគ្រីស្ទានទាំងអស់សុទ្ធតែកំពុងរស់នៅក្នុងលោកិយមួយដែលពេញ

ទៅដោយអន្ទាក់ និងកន្លែងបញ្ឆោតឲ្យធ្លាក់ជង្ហុក។ ពួកគ្រីស្ទានទាំងអស់ សុទ្ធតែមានអារក្សដ៏រស់នៅក្បែរខ្លួន។ ពួកគ្រីស្ទានទាំងអស់សុទ្ធតែមានឥទ្ធិពលនៃនិស្ស័យចាស់មុនពេលផ្លាស់ប្រែរបស់ពួកគេ។ ពួកគ្រីស្ទានទាំងអស់ ត្រូវតែចម្បាំងជាដាច់ខាត!

ចម្បាំងនេះ គឺជាចម្បាំងដែលមិនចេះឈប់ រហូតទាល់តែយើងស្លាប់ទៅ។ ពួកសត្រូវរបស់គ្រីស្ទាន មិនឈប់សំរាកនៅថ្ងៃឈប់សំរាកទេ ហើយក៏មិនដែលអស់កម្លាំងហើយដេកដែរ។ ជម្លោះនេះតែងតែនៅជាប់នឹងអស់អ្នកណាដែលចង់បានបរិសុទ្ធជានិច្ច។ វាជាការដែលគួរឲ្យសោកស្តាយនៅពេលដែលមនុស្សម្នាក់ដែលហៅថាជាគ្រីស្ទាន មិនបានស្គាល់ពីចម្បាំងខាងវិញ្ញាណនេះ ។

នៅពេលដែលនោះពួកគ្រីស្ទានអាចនឹងបានទទួលសេចក្តីកម្សាន្តដោយដឹងថា បទពិសោធន៍នៃចម្បាំងខាងក្នុងនេះ គឺជាសញ្ញាដ៏ល្អ ដ្បិតវាអាចជាភស្តុតាងដែលបង្ហាញថា ពួកគេកំពុងស្ថិតនៅលើផ្លូវត្រឹមត្រូវដើម្បីទៅដល់សេចក្តីបរិសុទ្ធនៃជីវិត។ ដូច្នេះ ខ្ញុំសូមនិយាយម្តងទៀតថា ចូរយើងទទួលការកម្សាន្តចិត្តពីការតស៊ូនេះចុះ។ មានសញ្ញាសំគាល់សំខាន់ៗពីរដែលបង្ហាញថាជាគ្រីស្ទានពិតប្រាកដ គឺចម្បាំងខាងក្នុងខាងវិញ្ញាណ និងវិញ្ញាណនៃសេចក្តីសុខសាន្តខាងក្នុង! នៅត្រង់នេះពួកយើងមានការព្រួយបារម្ភត្រង់ចំណុចទីមួយនៃចំណុចទាំងពីរខាងលើនេះ ។

## ២. សេចក្តីជំនឿលើព្រះគ្រីស្ទ គឺជាចម្បាំងនៃសេចក្តីជំនឿ

នៅក្នុងផ្នែកនេះ សង្គ្រាមគ្រីស្ទាន ខុសគ្នាពីសង្គ្រាមរបស់លោកិយ។ វាមិនពឹងលើកម្លាំងខាងរូបកាយ ហើយវាមិនប្រើគ្រឿងសព្វាវុធទេ។ ជោគជ័យក្នុងសង្គ្រាមខាងព្រលឹងវិញ្ញាណនេះ គឺពឹងលើសេចក្តី ជំនឿខាងព្រលឹងវិញ្ញាណវិញ។

ក) ជោគជ័យពឹងទាំងស្រុងលើជំនឿជឿដល់ព្រះបន្ទូលនៃព្រះ គឺព្រះគម្ពីរនេះឯង។ ទាហានគ្រីស្ទាន ធ្វើអ្វីដែលពួកគេធ្វើ គិតនៅពេលដែលពួកគេគិត សង្ឃឹមលើអ្វីដែលពួកគេសង្ឃឹម សម្រាប់ហេតុផលតែមួយប៉ុណ្ណោះគឺ ពួកគេជឿលើអ្វីដែលព្រះបានបង្រៀននៅក្នុងព្រះគម្ពីរ។សេចក្ដីជំនឿគឺជាឆ្អឹងខ្នងនៃការរស់នៅរបស់ពួកគេ។ គ្មានការរស់នៅត្រឹមត្រូវទេ បើគ្មានជំនឿត្រឹមត្រូវនោះ។

ខ)ត្រូវតែមានសេចក្ដីជំនឿពិសេសមួយនៅក្នុងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយនិងអ្វីដែលទ្រង់បានធ្វើ។ ប្រសិនបើអ្នកជឿមើលតែសេចក្ដីកម្សោយរបស់ខ្លួនហើយនិងភាពខ្លាំងក្លារបស់លោកិយទាស់នឹងខ្លួនឯង នោះពួកគេ អាចនឹងអស់សង្ឃឹមមែនទែន។ ប៉ុន្តែផ្ទុយទៅវិញ ពួកគេមានព្រះអង្គសង្គ្រោះដ៏មានអំណាចព្រះចេស្ដាមួយអង្គ ដែលដោយសារយញ្ញបូជាព្រះជន្មរបស់ទ្រង់ ពួកគេបានទទួលសេចក្ដីប្រោសលោះ ហើយនឹងដោយការអង្វរជំនួសរបស់ទ្រង់ ពួកគេបានទទួលការថែរក្សា ហើយដោយសារទ្រង់ នាំឲ្យពួកគេបានមានកម្លាំងឡើង។

គ្រីស្ទានច្បាំងយ៉ាងល្អ ឬមិនល្អ គឺយោងទៅតាមកម្រិតនៃសេចក្ដីជំនឿនេះឯង។ អ្នកណាដែលមានកម្រិតនៃសេចក្ដីជំនឿខ្លាំងបំផុត នឹងក្លាយជាទាហានគ្រីស្ទានដែលសប្បាយជាងគេបំផុត។ មានសេចក្ដីជំនឿកាន់តែខ្លាំង មានជ័យជំនះកាន់តែច្រើន! ខ្ញុំគិតថា គ្មានអ្វីទៀតមានតម្លៃនិងមានសារៈសំខាន់លើសជាងសេចក្ដីជំនឿនេះទេ។ ចូរអានជំពូក១១នៃសំបុត្រនេះរហូតដល់កណ្ឌគម្ពីរហេព្រើរនៅក្នុងព្រះគម្ពីរ ហើយនិង មើលពីរបៀបដែលពួកគ្រីស្ទានកាលសម័យមុនខ្ជាប់ខ្ជួននឹងសេចក្ដីជំនឿរបស់ពួកគេក្នុងគ្រប់ស្ថានភាព។ ការជឿលើព្រះយេស៊ូវដ៏មើលមិនឃើញមួយអង្គ គឺជាកំលាំងរបស់ពួកគេ។ ព្រះអម្ចាស់អើយ *"សូមទ្រង់ចម្រើនសេចក្ដីជំនឿដល់យើងខ្ញុំទៀតផង!"*

## ៣. សេចក្តីជំនឿលើព្រះគ្រីស្ទ គឺជាចម្បាំងដ៏ល្អមួយ

វាហាក់ដូចចម្លែកដែលប្រើពាក្យថា “ល្អ” អំពីសង្គ្រាម។ ការតយុទ្ធរបស់គ្រីស្ទាន គឺល្អពីព្រោះគ្មានសេចក្តីអាក្រក់នៅក្នុងការតយុទ្ធនេះទេ។ ខ្ញុំមិនត្រូវពួនពីអ្នកណាម្នាក់ឡើយ ការពិតនោះគឺថា ប្រសិនបើពួកគេចង់បានបរិសុទ្ធ ពួកគេត្រូវតែតយុទ្ធ។ ប៉ុន្តែខ្ញុំក៏ចង់ឲ្យអ្នកអានរបស់ខ្ញុំដឹងដែរថា ព្រះគម្ពីរហៅការតយុទ្ធរបស់គ្រីស្ទានថា “ល្អ” សម្រាប់ហេតុផលពិតប្រាកដ។

ក) វាគឺជាការតយុទ្ធដ៏ល្អ ពីព្រោះវាជាការតយុទ្ធក្រោមការដឹកនាំរបស់មេទ័ពលើសអស់ទាំងមេទ័ព! អ្នកដឹកនាំនិងជាមេបញ្ជាការនៃពួកគ្រីស្ទានពិតប្រាកដ គឺព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។ មិនតែប៉ុណ្ណោះ ទ្រង់មានប្រាជ្ញាញាណដ៏គ្រប់លក្ខណ៍ សេចក្តីស្រឡាញ់ និងអំណាចព្រះចេស្តាដ៏គ្មានព្រំខណ្ឌ។ទ្រង់មិនដែលមានកំហុសក្នុងការវិនិច្ឆ័យ ហើយក៏មិនដែលធ្វើឲ្យអ្វីមួយកើតឡើងជាឥតប្រយោជន៍ដែរ។ អស់អ្នកដែលទ្រង់បានប្រោសលោះរួចហើយ មានតម្លៃវិសេសណាស់ ទ្រង់មិនខ្ជះខ្ជាយបោះពួកគេចោលទេ។ ពិតមែនហើយ តើការនេះមិនមែនជាការល្អទេឬអី?

ព្រះវរបិតាថែរក្សាអ្នកជឿទាំងអស់។ ព្រះរាជបុត្រាអធិស្ឋានសម្រាប់អ្នកជឿទាំងអស់។ ព្រះវិញ្ញាណបរិសុទ្ធនាំផ្លូវ និងបង្រៀនអ្នកជឿទាំងអស់។ នោះជាជំនួយដែលមានរហូតដល់ទៅបីតង់ដែលធ្វើឲ្យយើងមិនដែលចាញ់។ ពិតមែនហើយ តើការនេះមិនមែនជាការល្អទេឬអី?

គ) វាគឺជាការតយុទ្ធដ៏ល្អ ពីព្រោះវាជាការតយុទ្ធដោយមានសេចក្តីសន្យាដ៏ល្អបំផុត។ *ដ្បិតអំពើបាបមិនត្រូវមានអំណាច លើអ្នករាល់គ្នាទៀតឡើយ...ឯព្រះនៃសេចក្តីសុខសាន្ត នៅ បន្តិចទៀតទ្រង់នឹងកិនអារក្សសាតាំង នៅក្រោមជើងអ្នករាល់គ្នា...ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឲ្យ*

*កាន់តែពេញខ្នាតឡើង ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ (រ៉ូម ៦:១៩; ១៦:២០; ភីលីព១:៦)*។ ពិតមែនហើយ តើការទាំងនោះមិនមែនជាសេចក្ដីសន្យាដ៏ល្អទេឬអី?

ឃ) វាគឺជាការតយុទ្ធដ៏ល្អ ពីព្រោះវាជាការតយុទ្ធដែលមានលទ្ធផលដ៏ល្អបំផុត។ គ្មានទាហានរបស់ព្រះគ្រីស្ទណាម្នាក់ធ្លាប់បាត់បង់ ឬស្លាប់នៅក្នុងសមរភូមិនេះឡើយ។ ដោយគ្មានការលើកលែងអ្នកណាម្នាក់ គ្រប់អ្នកជឿទាំងអស់សុទ្ធតែ *វិសេសលើសជាងអ្នកជ័យជំនះទៅទៀត ដោយសារព្រះអង្គដែលទ្រង់ស្រឡាញ់យើង* (រ៉ូម ៨:៣៧)។ គ្មានទាហានរបស់ព្រះគ្រីស្ទណាម្នាក់នឹងបាត់ពីនគរស្ថានសួគ៌ឡើយ។ ពិតមែនហើយ តើនេះពិតជាការល្អណាស់មែនទេ?

ង) ការតយុទ្ធរបស់គ្រីស្ទាន ល្អ ពីព្រោះវាធ្វើការល្អចំពោះពួកអ្នកដែលប្រយុទ្ធក្នុងការតយុទ្ធនេះ។ សង្គ្រាមខាងលោកិយនាំមកនូវសេចក្ដីអាក្រក់បំផុតដល់និស្ស័យមនុស្ស។ វាធ្វើឲ្យបញ្ញាចិត្តរឹងរូស និងបំផ្លាញសីលធម៌។ ប៉ុន្តែសង្គ្រាមខាងព្រលឹងវិញ្ញាណវិញ នាំមកនូវសេចក្ដីដ៏ប្រសើរបំផុតនៅក្នុងអ្នកជឿ។ វានាំមកនូវការបន្ទាបខ្លួន កាត់បន្ថយភាពអាត្មានិយម និងសេចក្ដីរំជួលខាងលោកិយ ហើយទាញឲ្យអ្នកជឿគិតយ៉ាងច្រើនពីសេចក្ដីខាងព្រលឹងវិញ្ញាណវិញ។ ពិតមែនហើយ តើនេះពិតជាការល្អណាស់មែនទេ?

ឆ) ការតយុទ្ធនេះគឺជាការល្អ ពីព្រោះនៅទីបញ្ចប់ អ្នកដែលច្បាំងទាំងអស់នឹងបានទទួលរង្វាន់ដ៏មានសិរីរុងរឿងមួយ។ តើអ្នកណាមួយអាចស្មានការល្អទាំងនេះថាជាអ្វីបាន ដែលមេបញ្ជាការរបស់យើងទុកសម្រាប់ទាហានស្មោះត្រង់ទាំងអស់របស់ទ្រង់ហើយនោះ? អ្វីក៏ដោយដែលទ្រង់នឹងប្រទានមកយើងនឹងស្ថិតស្ថេរនៅជារៀងរហូត ដ្បិតវាលើសពីការមកដល់នៃសេចក្ដីស្លាប់ទៅទៀត។ អ្នកជឿនឹងទទួលបាន

*ភួងជ័យដែលមិនចេះស្រពោន* (១ពេត្រុស ៥:៤)។ ពិតមែនហើយ តើនេះពិតជាការល្អណាស់មែនទេ?

ដូច្នេះខ្ញុំសូមទូន្មានបងប្អូនថា ប្រសិនបើបងប្អូនមិនទាន់ជាទាហានរបស់ព្រះគ្រីស្ទនៅឡើយ ចូរធ្វើឥឡូវនេះចុះ! ចូរតយុទ្ធនឹងចម្បាំងនៃសេចក្តីជំនឿដ៏ល្អនេះ ដើម្បីឲ្យយើងបានសប្បាយរីករាយ និងមានសុវត្ថិភាព។ ហេតុអ្វីបានជាបងប្អូនធ្វើជាទាសកររបស់លោកិយ ហើយធ្វើតាមរបៀបរបស់លោកិយនេះ? មានកន្លែងទំនេរសម្រាប់បងប្អូននៅក្នុងកងទ័ពរបស់ព្រះគ្រីស្ទ-- ចូរជ្រើសរើសសេរីភាព ហើយតយុទ្ធដើម្បីឲ្យបានស្ថិតស្ថេរនៅ។ សូមកុំឲ្យយើងភ្លេចថា បើគ្មានការតយុទ្ធទេ នោះក៏មិនអាចមានសេចក្តីបរិសុទ្ធ នៅពេលដែលយើងរស់នៅ ហើយក៏គ្មានភួងជ័យនៅពេលដែលយើងស្លាប់ដែរ!

# ជំពូក ៥

## តម្លៃ

*ក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាចង់សង់ផ្ទះពីថ្ម តើមិនអង្គុយលៃលកមើលជាមុនទេឬអី? ដើម្បីឲ្យដឹងជាមានល្មមនឹងធ្វើបង្ហើយបានឬមិនបាន?* (លូកា ១៤: ២៨)។

ជាសញ្ញាល្អ ប្រសិនបើអ្នកចង់បានបរិសុទ្ធ ដូចជាយើងអាចនឹងអរព្រះគុណដល់ព្រះ ដោយទ្រង់បានដាក់សេចក្តីប្រាថ្នានេះនៅក្នុងចិត្តយើង។ នៅពេលដដែលនេះយើងគួរគិតដោយយកចិត្តទុកដាក់ថា តើភាពជាគ្រីស្ទានម្នាក់ នឹងមានឥទ្ធិពលលើជីវិតរស់នៅរបស់យើងយ៉ាងណា។ ផ្លូវដែលឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ចរបស់ព្រះគ្រីស្ទ គឺជាផ្លូវមួយដែលមានសេចក្តីកម្សាន្តដ៏អស្ចារ្យ ប៉ុន្តែវាក៏តូចចង្អៀតផងដែរ ដែលតាមផ្លូវនោះឈើឆ្កាងមកមុនមកុដ!

## ១. ខ្ញុំនឹងបង្ហាញថាអ្វីទៅជាតម្លៃដើម្បីធ្វើជាគ្រីស្ទាន

ខ្ញុំមិនកំពុងតែពិភាក្សាពីតម្លៃ ដើម្បីសង្គ្រោះព្រលឹងគ្រីស្ទានម្នាក់នោះទេ។ ខ្ញុំដឹងថា ការនោះគ្មានតម្លៃអ្វីទាំងអស់ក្រៅពីព្រះលោហិតជីវិតរបស់ព្រះរាជបុត្រានៃព្រះ ដែលបានប្រទានមកទុកជាទីសណ្តោសប្រោសសម្រាប់អំពើបាប ហើយនឹងដើម្បីប្រោសលោះមនុស្សម្នាក់ឲ្យរួចពីស្ថាននរក។ ខ្ញុំចង់ពិចារណាពីអ្វីដែលពួកអ្នក

ជឿត្រូវត្រៀមខ្លួនជាស្រេចក្នុងការលះបង់ ដើម្បីជីវិតមួយនៃការបម្រើដល់ព្រះគ្រីស្ទវិញ។ ខ្ញុំទទួលស្គាល់ថា វាមានតម្លៃតិចណាស់ បើគ្រាន់តែធ្វើជាគ្រីស្ទានដែលមានតែឈ្មោះនោះ។ ការមកឯកន្លែងមួយដើម្បីថ្វាយបង្គំនៅថ្ងៃអាទិត្យ ហើយការនឹងខុសត្រូវខាងសីលធម៌កំឡុងពេលមួយសប្តាហ៍នោះ គ្មានតម្លៃហើយងាយស្រួលណាស់ក្នុងសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ ព្រោះមិនមានការលះកាត់និងការលះបង់ខ្លួនឯងនៅក្នុងសេចក្តីជំនឿនោះសោះ។ ប៉ុន្តែដើម្បីឲ្យក្លាយជាគ្រីស្ទានពិតប្រាកដ ត្រូវតែលះបង់អ្វីម្យ៉ាងដូចជា មានខ្មាំងសត្រូវដែលយើងត្រូវយកជ័យជំនះសមរភូមិដែលត្រូវច្បាំង ការលះបង់ដែលត្រូវធ្វើ សេចក្តីល្បួងដែលត្រូវទប់ទល់។ នោះហើយជាមូលហេតុសំខាន់សម្រាប់យើង ដើម្បីរាប់តម្លៃនៃការលះបង់ ។

ក) មានការលះបង់ចំពោះសេចក្តីសុចរិតផ្ទាល់ខ្លួនរបស់យើង។ យើងត្រូវតែដោះចោលគ្រប់ទាំងសេចក្តីអំនួត និងគំនិតខ្ពស់អំពីអ្វីដែលយើងគិតថា ជាសេចក្តីល្អរបស់យើង។ យើងរាល់គ្នាបានទទួលសេចក្តីសង្គ្រោះដោយសារតែសេចក្តីល្អ និងគុណបំណាច់របស់អ្នកដទៃប៉ុណ្ណោះ គឺជាព្រះយេស៊ូវគ្រីស្ទតែម្តង។ បើគ្មានទ្រង់ សីលធម៌របស់យើង ការអធិស្ឋានរបស់យើង ការសិក្សាព្រះគម្ពីររបស់យើង ការជួបជុំគ្នាថ្វាយបង្គំរបស់យើង នោះនឹងត្រឡប់ជាឥតប្រយោជន៍ទទេ។ យើងត្រូវនឹងថា នៅក្នុងយើង យើងគ្រាន់តែជាមនុស្សមានបាបដ៏កំសត់ និងឥតទីពឹងប៉ុណ្ណោះ។ ដូច្នេះ ដើម្បីឲ្យបានក្លាយជាគ្រីស្ទានពិតប្រាកដ យើងត្រូវធ្វើការលះបង់សេចក្តីសុចរិតផ្ទាល់ខ្លួនរបស់យើង។

ខ) មានការលះបង់ចំពោះអំពើបាបរបស់យើង។ យើងត្រូវតែបោះបង់ចោលរាល់សកម្មភាពទាំងឡាយណាដែលមិនត្រឹមត្រូវនៅចំពោះព្រះនេត្រព្រះជាម្ចាស់។ ទោះជាតូចឬធំក្តី ទោះជាគេដឹងជាសាធារណៈ ឬលាក់កំបាំងក្តី គ្រប់ទាំងអំពើបាបត្រូវតែ

លះកាត់ចោលចេញ។ *ចូរបំបាត់អំពើអាក្រក់ដែលឯងរាល់គ្នា ប្រព្រឹត្តពីភ្នែកអញចេញហើយលែងប្រព្រឹត្តអំពើអាក្រក់ទៅ ចូររៀនធ្វើការល្អវិញ* (អេសាយ ១: ១៦-១៧)។ ជាញឹកញាប់ អំពើបាបប្រៀបដូចជាកូនជាទីស្រឡាញ់របស់យើងអញ្ចឹង។ យើងស្រឡាញ់វា យើងឱបវា តោងវា ហើយមានសេចក្តីរីករាយនៅក្នុងវា! ព្រះគ្រីស្ទសព្វព្រះហឫទ័យទទួលមនុស្សមានបាប ប៉ុន្តែទ្រង់នឹងមិនទទួលពួកគេទេ ប្រសិនបើពួកគេនៅតែតោងជាប់អំពើរបស់ពួកគេនោះ។ ដើម្បីឲ្យបានក្លាយជាគ្រីស្ទានពិតប្រាកដ គឺត្រូវលះបង់អំពើបាបរបស់យើងចោល។

គ) មានការលះបង់ចំពោះសេចក្តីស្រឡាញ់ដល់ភាពសុខស្រួលរបស់យើង។ ប្រសិនបើ យើងចង់បានទទួលជោគជ័យក្នុងការធ្វើដំណើរឆ្ពោះទៅកាន់នគរស្ថានសួគ៌ ការខំប្រឹងប្រែងដ៏ឥតឈប់ឈរពិតជាមានភាពចាំបាច់ណាស់។ យើងត្រូវតែប្រុងប្រយ័ត្នក្នុងអាកប្បកិរិយារបស់យើងគ្រប់វិនាទីគឺ ប្រុងប្រយ័ត្នចំពោះគំនិតពាក្យសំដី និងទង្វើ។ យើងនឹងត្រូវការប្រុងប្រយ័ត្នពីសេចក្តីអធិស្ឋានរបស់យើង ការសិក្សាព្រះគម្ពីររបស់យើង ការប្រើប្រាស់ "មធ្យោបាយនៃព្រះគុណ" របស់យើង។ នេះក៏ស្តាប់ទៅហាក់ដូចជាការទូន្មានដ៏ពិបាកផងដែរ។ យើងមិនចូលចិត្តអ្វីដែលតម្រូវឲ្យមានការតស៊ូទេ។ ប៉ុន្តែយើងមិនអាចទទួលបាននូវអ្វីទាំងអស់ បើសិនគ្មានការឈឺចាប់។ ដើម្បីឲ្យក្លាយទៅជាគ្រីស្ទានពិតប្រាកដ យើងត្រូវលះបង់ការរស់នៅដ៏សុខស្រួលរបស់យើង។

ឃ) វាអាចនឹងធ្វើឲ្យយើងលះបង់ប្រជាប្រិយភាពជាមួយអ្នកជិតខាង។ ប្រសិនបើគោលបំណងសំខាន់របស់យើងគឺដើម្បីផ្គាប់ព្រះហឫទ័យព្រះ នោះយើងត្រូវតែទទួលនូវអារម្មណ៍មិនល្អពីអ្នកដទៃ។ មនុស្សអាចនឹងបដិសេធយើងទុកដូចជា

មនុស្សឆោតល្ងង់ ឬពួកជ្រុលនិយម។ ព្រះយេស៊ូវបានមានបន្ទូលថា *ចូរនឹកចាំពីពាក្យដែលខ្ញុំបានប្រាប់រួចហើយថា បាវមិនមែនធំជាងចៅហ្វាយទេ បើគេបៀតបៀនដល់ខ្ញុំ នោះគេនឹងបៀតបៀនដល់អ្នករាល់គ្នា* ដែរ (យ៉ូហាន ១៥:២០)។ នេះនឹងពិតជាពិបាកទ្រាំ។ វាតែងតែជាការដែលមិនសប្បាយដែលត្រូវគេនិយាយប្រឆាំង។ ប៉ុន្តែត្រូវតែទ្រាំនឹងការនោះ។ ដើម្បីក្លាយទៅជាគ្រីស្ទានពិតប្រាកដ អាចនឹងលះបង់អារម្មណ៍ល្អដោយព្រោះអ្នកជិតខាងដែលមិនមែនគ្រីស្ទានរបស់យើង។ ចូរយើងចងចាំថាសេចក្តីជំនឿមួយដែលគេមិនត្រូវលះបង់អ្វីទាំងអស់ គឺមិនមានតម្លៃអ្វីទាំងអស់។ គ្រីស្ទានដែលមិនប៊ានលះបង់ ហើយគ្មានឈើឆ្កាង នៅទីបំផុតនឹងត្រឡប់ជាគ្រីស្ទានដែលឥតប្រយោជន៍ ហើយគ្មានមកុដ!

## ២. ខ្ញុំនឹងបង្ហាញអ្នកពីមូលហេតុថាការរាប់តម្លៃនៃការលះបង់មានសារៈសំខាន់

មានមនុស្សមួយក្រុមកំពុងតែរាប់តម្លៃនៃការលះបង់ ក្នុងការធ្វើជាគ្រីស្ទានពិតប្រាកដម្នាក់ ថាជាការសំខាន់ណាស់។ គេមិនល្ងើល្ងើនៅក្នុងសេចក្តីជំនឿនោះទេ។ ពួកគេដឹងច្រើនពីសេចក្តីជំនឿនោះ ប៉ុន្តែសេចក្តីជំនឿរបស់គេមិនខ្លាំង។ ប្រហែលជាពួកគេមានចំណេះដឹងពី "បទពិសោធន៍ពួតាមគេ" មិនមែនពីបទពិសោធន៍ផ្ទាល់ខ្លួនឯង។ ប្រហែលជាពួកគេកើតមកក្នុងគ្រួសារដែលកាន់តាមជំនឿនោះ។ ប៉ុន្តែមនុស្សប្រភេទនោះកំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់ហើយ ដ្បិតសេចក្តីជំនឿរបស់ពួកគេតម្រូវឲ្យមានការប្រឹងប្រែងតិចតួចប៉ុណ្ណោះពីពួកគេ។ នៅពេលដែលពួកគេឈានចូលជិតចុងបញ្ចប់នៃជីវិត ពួកគេខំព្យាយាមធ្វើការប្រឹងប្រែងខ្លះជាចុងក្រោយ ដើម្បីបែរមកឯព្រះ ពេលនោះពួកគេនឹងមានអារម្មណ៍ថា ការប្រែចិត្តគឺមិនស្រួលដូចជាអ្វីដែលពួកគេបានគិតឡើយ។ មនុស្សទាំងអស់នេះត្រូវពិនិត្យមើលគំរូ

នានានៅក្នុងព្រះគម្ពីរ អំពីពួកអ្នកដែលមិនបានរាប់តម្លៃនៃការលះបង់ពេញលេញនូវអ្វីដែលព្រះទាមទារ ហើយនៅទីបំផុតពួកគេបានស្លាប់នៅក្នុងអំពើបាបរបស់ខ្លួន។

ក) កូនចៅអ៊ីស្រាអែលរាប់ពាន់នាក់ បានស្លាប់ក្នុងទីរហោស្ថាននៅចន្លោះប្រទេសអេហ្ស៊ីប និងទឹកដីកាណាន ដោយព្រោះពួកគេមិនបានរាប់តម្លៃនៃការលះបង់។ ពួកគេបានចាកចេញពីប្រទេសអេហ្ស៊ីប ដោយមានចិត្តចង់និងពោរពេញដោយថាមពល។ ពួកគេបានគិតថាទឹកដីសន្យានឹងជារបស់ពួកគេភ្លាម។ ប៉ុន្តែនៅពេលដែលពួកជួបការលំបាក ចិត្តដែលពោរពេញដោយថាមពលបានចេញពីពួកគេ ហើយសេចក្តីក្លាហានបានបាត់ទៅ។ ពួកគេមិនបានរាប់តម្លៃនៃការលះបង់ឡើយ។ ពួកគេបានបាត់សេចក្តីជំនឿហើយបានស្លាប់ក្នុងអំពើបាបរបស់ពួកគេ។

ខ) ដោយការចង់រាប់តម្លៃនៃការលះបង់ មនុស្សជាច្រើនដែលបានស្តាប់ព្រះអម្ចាស់យើងមួយរយៈ *ដកខ្លួនថយចេញមិនតាមទ្រង់ទៀត*(យ៉ូហាន ៦:៦៦)។ ពួកគេបានឃើញការអស្ចារ្យពីមុនមក ហើយគេគិតថា នគរព្រះនឹងលេចមកភ្លាម។ ប៉ុន្តែនៅពេលដែលពួកគេដឹងថា មានការបង្រៀនដ៏ពិបាកដែលត្រូវឲ្យពួកគេជឿ និងការពិបាកដែលត្រូវឲ្យពួកគេធ្វើ សេចក្តីជំនឿរបស់ពួកគេបានធ្លាក់ដួល។ ពួកគេមិនបានរាប់តម្លៃនៃការលះបង់។

គ) ដោយការចង់រាប់តម្លៃនៃការលះបង់ ស្តេច ហេរ៉ូឌ បានត្រឡប់ទៅរកអំពើបាបចាស់របស់គាត់វិញ ហើយការនោះក៏បានបំផ្លាញព្រលឹងគាត់ទៅ។ គាត់បានឮលោក យ៉ូហាន បាទីស្ទ ប្រកាស ហើយក៏បានចូលចិត្តនូវអ្វីដែលគាត់បានឮដែរ។ គាត់មានការចាប់អារម្មណ៍ ព្រមទាំងបានលើកដំកើងលោក យ៉ូហាន ជាមនុស្សបរិសុទ្ធម្នាក់។ ប៉ុន្តែសេចក្តីជំនឿរបស់គាត់មិនអាចគ្រប់គ្រងសេចក្តីស្រើបស្រាលរបស់គាត់

បានឡើយ ហើយក៏មិនព្រមទទួលយកការរិះគន់ពីភ្ញៀវរបស់គាត់ដែរ (ម៉ាកុស ៦: ១៩-២៨)។ គាត់មិនបានរាប់តម្លៃលះបង់នៃការរស់នៅ ទៅតាមសេចក្តីបង្រៀនដ៏បរិសុទ្ធរបស់លោក យ៉ូហានទេ។

ឃ) ដោយការចង់រាប់តម្លៃនៃការលះបង់ ដាម៉ាសបានចាកចេញពីសាវ៉ក ប៉ុល ពីព្រោះគាត់មិនចង់បោះបង់មិត្តភាពនៃលោកិយនេះ ដើម្បីឲ្យមានមិត្តភាពជាមួយនឹងព្រះទេ។ សាវ៉ក ប៉ុល បានសរសេរថា *ដ្បិតអ្នកដេម៉ាសបានលះចោលខ្ញុំហើយ ដោយគាត់ស្រឡាញ់លោកីយ៍នេះ* (២ធីម៉ូថេ ៤:១០)។ នេះគឺជាការច្បាស់ណាស់ថា ដេម៉ាស មិនបានរាប់តម្លៃ នៅពេលដែលគាត់ចូលមកក្នុងក្រុមការងាររបស់សាវ៉ក ប៉ុលទេ។

ង) ដោយព្រោះការចង់ឲ្យរាប់តម្លៃនោះ មនុស្សជាច្រើនដែលបានឮការអធិប្បាយដ៏មានអំណាច ហាក់ដូចជាត្រូវបានផ្លាស់ប្តូរមួយរយៈ។ ពួកគេឆេះឆួលក្នុងការប្រកាសពីបទពិសោធន៍ខាងព្រលឹងវិញ្ញាណមួយដែលពួកគេមិនស្គាល់ពិតប្រាកដ។ ហើយនៅពេលដែលប្រលោមលោកនេះចប់ទៅ គេក៏ចាកចេញពីពួកជំនុំនៃអ្នកជឿ (ម៉ាថាយ ១៣:២០, ២១)។ ពួកគេមិនបានរាប់តម្លៃនោះទេ។

ច) ដោយព្រោះការចង់ឲ្យរាប់តម្លៃនោះ មនុស្សជាច្រើនហាក់ដូចជាបានផ្លាស់ប្រែនៅឯមហាសន្និបាតហើយនិងព័ន្ធកិច្ចដំណឹងល្អធំៗ តែគេទទួលបរាជ័យក្នុងការរក្សាសេចក្តីជំនឿរបស់ពួកគេ។ គេមិនបានយល់ថា សេចក្តីជំនឿគឺលើសពីការដែលមានអារម្មណ៍ចង់ "មកឯព្រះគ្រីស្ទ" ទេ។ ពេលមួយ ពួកគេភ្ញាក់ខ្លួនថា មានឈើឆ្កាងមួយដែលពួកគេត្រូវលី (ដែលចិត្តរបស់យើងជាគ្រឿងបញ្ឆោត ហើយថាសាតាំងគឺតែងតែនៅជិតយើងជានិច្ច) ពួកគេបែរទៅរករបៀបរស់នៅដែលគ្មានព្រះគ្រីស្ទវិញ។ ពួកគេមិនដែលរាប់តម្លៃឡើយ (ម៉ាថាយ ១៣:២០, ២១)។

ឆ) ដោយព្រោះការចង់ឲ្យរាប់តម្លៃនោះ កូនៗជាច្រើនដែលមានឪពុកម្ដាយជាគ្រីស្ទាន ខកខានមិនបានរីកចម្រើនជាគ្រីស្ទានខ្លួនឯងផ្ទាល់ជារឿយៗ។ ពេលដែលគេនៅក្មេងគេស្គាល់ពីសេចក្ដីពិតនៃព្រះគម្ពីរ ប៉ុន្តែពួកគេគ្មានបទពិសោធន៍ជាមួយនឹងសេចក្ដីពិតទាំងនោះពិតប្រាកដទេ។ ហើយនៅពេលមួយដែលគេចេញទៅឆ្ងាយពីផ្ទះ គេចាប់ផ្ដើមស្វែងរកសេចក្ដីរីករាយខាងលោកិយវិញ ហើយគ្មានពេលសម្រាប់កិច្ចការខាងគ្រីស្ទានទៀតឡើយ។ ពួកគេមិនបានរាប់តម្លៃ--ប្រហែលជាពួកគេមិនបានរៀនថា មានតម្លៃមួយដែលត្រូវលះបង់ទេ!

ខ្ញុំអាចនឹងនិយាយដោយក្លាហានថា នឹងជាការប្រសើរ ប្រសិនបើកាតព្វកិច្ចនៃការរាប់តម្លៃត្រូវបានគេយកមកបង្រៀនញឹកញាប់ជាងនេះ។ គួរតែប្រាប់ដល់មនុស្សឯទៃដោយស្មោះត្រង់ពីអ្វីដែលពួកគេកំពុងចាប់ផ្ដើមធ្វើ ប្រសិនបើពួកបង្ហាញថាពួកគេមានចិត្តចង់បម្រើព្រះគ្រីស្ទ។ ចូរកុំឲ្យយើងដូចជាទាហានដែលមិនស្មោះត្រង់សម្រាប់កងទ័ពដែលនិយាយតែពីឯកសណ្ឋាន ប្រាក់ខែ និងបុណ្យសក្តិ ហើយមិននិយាយអ្វីទាំងអស់ពីខ្មាំងសត្រូវ សមរភូមិ និងរបួស។

## ៣. តើយើងអាចរាប់តម្លៃដោយត្រឹមត្រូវបានយ៉ាងដូចម្ដេច?

គ្មានអ្វីធ្វើឲ្យយើងខ្លាចទេ ប្រសិនបើយើងរាប់តម្លៃជាគ្រីស្ទានម្នាក់តាមរបៀបត្រឹមត្រូវនោះ។ តម្លៃណាដែលត្រូវទារពីយើង អាចនឹងចេញថ្លៃបាន ប្រសិនបើសេចក្ដីជំនឿរបស់យើងរឹងមាំ។ យើងត្រូវតែអានពីតួអង្គនៅក្នុងព្រះគម្ពីរដូចជា លោក ណូអេ ម៉ូសេ និងសាវក ប៉ុល ដើម្បីឲ្យដឹងថា បើគ្មានសេចក្ដីជំនឿរឹងមាំនៅក្នុងព្រះជាម្ចាស់ទេ នោះតម្លៃដែលទ្រង់ទាមទារនឹងធំពេកមិនអាចបង់ថ្លៃបានជាមិនខាន។ វាអាចនឹងមានតម្លៃច្រើនណាស់ដើម្បីឲ្យបានត្រឡប់ជាគ្រីស្ទានពិតប្រាកដម្នាក់ ប៉ុន្តែ

បើផ្ទុយពីនោះ យើងច្បាស់ជាដាក់ចោលរង្វាន់នៃសិរីល្អរបស់នគរស្ថានសួគ៌ហើយ។

ក) ដូច្នេះ ចូរយើងប្រៀបធៀបចំណេញ និងខាត។ យើងអាចនឹងខាតបង់របស់ដ៏បណ្ដោះអាសន្នខាងលោកិយនេះ ប៉ុន្តែយើងបានចំណេញសេចក្ដីសង្គ្រោះដ៏នៅអស់កល្បនៃព្រលឹងវិញ្ញាណរបស់ពួកយើងវិញ។

ខ) ចូរប្រៀបធៀបការសរសើរនិងការបន្ទោស។ អ្នកដទៃអាចនឹងបន្ទោសអ្នក ប៉ុន្តែក្នុងនាមយើងជាកូនរបស់ទ្រង់ យើងមានការសរសើរពីព្រះជាម្ចាស់!

គ) ចូរប្រៀបធៀបមិត្តនិងខ្មាំងសត្រូវ។ នៅម្ខាងដៃជាអារក្សសាតាំង និងមនុស្សអាក្រក់។ ប៉ុន្តែនៅម្ខាងទៀតគឺជាការគាំទ្រនិងមិត្តភាពជាមួយព្រះអម្ចាស់យេស៊ូវគ្រីស្ទដែលទ្រង់បានយកឈ្នះលើអារក្សសាតាំង។

ឃ) ចូរប្រៀបធៀបជីវិតបច្ចុប្បន្ននេះ និងជីវិតដែលត្រូវមក។ អាចនឹងមានការតស៊ូ និងការល្បួងលផ្សេងៗនៅបច្ចុប្បន្ននេះ ប៉ុន្តែមានរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។ តែមានជីវិតអស់កល្បនៃស្ថានសួគ៌ ជាកន្លែងដែលគ្មានបាប គ្មានការតស៊ូ និងគ្មានការល្បួងលវិញ។

ង) ចូរប្រៀបធៀបសេចក្ដីរីករាយនៃអំពើបាប និងព្រះពរនៃការបំរើព្រះ។ សេចក្ដីរីករាយខាងលោកិយនេះមិនដែលធ្វើឲ្យស្កប់ស្កល់បានទេ សេចក្ដីរីករាយនោះបំភ្លឺបានតែមួយភ្លែត ហើយក៏បាត់ទៅវិញ។ សេចក្ដីរីករាយទាំងនោះពឹងយ៉ាងខ្លាំងលើស្ថានភាពដែលសប្បាយៗ។ ប៉ុន្តែព្រះពររបស់ព្រះវិញគឺជារឿងរបូត ហើយមិនពឹងលើស្ថានភាពរបស់លោកិយឡើយ។

ច) ចូររាប់និងប្រៀបធៀបបញ្ហាដែលគ្រីស្ទានម្នាក់អាចនឹងមាន ហើយនិងបញ្ហាដែលស្ដុកទុកសម្រាប់ពួកទមិឡល្មើស។ យើងមិនអាចនិយាយថា ពួកគ្រីស្ទានត្រូវ

បានហៅមកសម្រាប់ការរងទុក្ខឡើយ បើប្រៀបធៀបនឹងសេចក្តីក្រោធដ៏អស់កល្ប របស់ព្រះលើពួកមនុស្សអាក្រក់នោះ។ ជាញឹកញាប់ការទាំងអស់មិនត្រូវបានបំពេញត្រឹមត្រូវ ឬក៏មិនបានធ្វើសោះ។ មនុស្សជាច្រើនមិនអាចសម្រេចចិត្តថា តើគួរបម្រើព្រះគ្រីស្ទឬយ៉ាងណា។ អាថិកំបាំងនៃការរាប់តម្លៃតាមរបៀបត្រឹមត្រូវ គឺត្រូវតែមានសេចក្តីជំនឿរឹងមាំ។ ខ្ញុំសូមទូន្មានដល់បងប្អូនអ្នកអាន សូមឲ្យពិចារណាថាតើសេចក្តីជំនឿរបស់អ្នកបច្ចុប្បន្ននេះធ្វើឲ្យអ្នកលះបង់អ្វីខ្លះ។ ខ្ញុំសូមទូន្មាន សូមឲ្យពិចារណាថា ព្រះជាម្ចាស់បានលះបង់អ្វីខ្លះដើម្បីនាំសេចក្តីសង្គ្រោះមកមនុស្សមានបាបក្នុងលោកិយនេះ។ សូមឲ្យពិចារណាពីរបៀបហើយនិងពេលដែលលោកអ្នកនៅក្នុងសិរីល្អនៃនគរស្ថានសួគ៌ ហើយលោកអ្នកមើលត្រឡប់ថយក្រោយ ហើយដែលលោកអ្នកនឹងឆ្ងល់ពីមូលហេតុដែលលោកអ្នកគិតថា តម្លៃនោះវាច្រើនលើសលប់ពេកសម្រាប់សងថ្លៃការឈឺចាប់របស់លោកអ្នក!

# ជំពូក ៦
## ការធំចម្រើនឡើង

*ចូរឲ្យអ្នករាល់គ្នាចម្រើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់* (២ពេត្រុស ៣:១៨)។

នេះគឺជាបញ្ហាដ៏សំខាន់ សម្រាប់អស់អ្នកដែលយកចិត្តទុកដាក់នឹងការប្ដេជ្ញាចំពោះសេចក្ដីបរិសុទ្ធ។ ពេលខ្លះពួកគេត្រូវការសួថា តើខ្ញុំកំពុងតែធំចម្រើនឡើងនៅក្នុងសេចក្ដីជំនឿរបស់ខ្ញុំដែរឬទេ? តើខ្ញុំរីកចម្រើនដែរឬទេ? ប្រហែលជា ថ្ងៃខួបកំណើត ថ្ងៃណូអែល ឬក៏មុនថ្ងៃចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ ជាឱកាសដ៏សមសួន សម្រាប់ការពិនិត្យមើលខ្លួនឯង។ មានបីចំនុចដែលខ្ញុំត្រូវនិយាយសង្កត់ធ្ងន់អំពីការធំចម្រើនឡើងខាងវិញ្ញាណ។

### ១. ភាពពិតនៃការរីកចម្រើនខាងព្រលឹងវិញ្ញាណ

ពិតជាមានការមួយដែលរីកចម្រើននៅក្នុងព្រះគុណប្រាកដមែន។ ដោយនិយាយយ៉ាងដូច្នេះ ខ្ញុំចង់ធ្វើវាឲ្យកាន់តែច្បាស់ឡើងថា ខ្ញុំមិនមានន័យថា ដោយការខំប្រឹងប្រែងរបស់យើង យើងអាចឲ្យការរាប់ជាសុចរិតរបស់យើង មានភាពខុសគ្នានៅចំពោះព្រះនោះទេ។ យើងមិនដែលត្រូវបានទទួលការអភ័យទោស ការអត់ទោស ការរាប់ជាសុចរិត លើសពីពេលដំបូងដែលយើងជឿនោះទេ។ ការរីកចម្រើនដែល

ខ្ញុំចង់និយាយសំដៅគឺជាការរីកចម្រើននៅក្នុងព្រះគុណដែលព្រះបានប្រទានមកយើងដោយព្រះវិញ្ញាណបរិសុទ្ធដូចជាការប្រែចិត្ត សេចក្ដីជំនឿ សេចក្ដីសង្ឃឹម សេចក្ដីស្រឡាញ់ ការបន្ទាបខ្លួន ការឧស្សាហ៍និងសេចក្ដីក្លាហាន។ យើងអាចហើយយើងគួរតែធ្វើឲ្យមានការរីកចម្រើនខាងព្រលឹងវិញ្ញាណជានិច្ច ដោយការរីកចម្រើននៅក្នុងព្រះគុណនីមួយៗទាំងអស់នេះ។

ការរីកចម្រើនក្នុងព្រះគុណត្រូវបានបង្រៀននៅក្នុងព្រះគម្ពីរ។ *សេចក្ដីជំនឿរបស់អ្នករាល់គ្នា កំពុងតែចម្រើនកាន់តែច្រើនឡើង ហើយអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ ដល់គ្នាទៅវិញទៅមក រឹតតែខ្លាំងឡើងដែរ* (២ថែស្សាឡូនិច ១:៣)។ *ឲ្យបានបង្កើតផលក្នុងគ្រប់ទាំងការល្អ ហើយឲ្យស្គាល់ព្រះកាន់តែច្បាស់ឡើង* (កូល៉ុស ១:១០)។ *ខ្ញុំក៏អធិស្ឋានសូមសេចក្ដីនេះ គឺឲ្យសេចក្ដីស្រឡាញ់របស់អ្នករាល់គ្នា បានចម្រើនកាន់តែច្រើនឡើង* (ភីលីព ១:៩)។ ហើយនឹងមានការទូន្មានដាស់តឿនបែបនេះជាច្រើនទៀត។

ប៉ុន្តែបទពិសោធន៍ផ្ទាល់ខ្លួនក៏បានបញ្ជាក់ផងដែរថា លទ្ធភាពនៃការរីកចម្រើននៅក្នុងព្រះគុណគឺជាការពិតប្រាកដមែន។ ភាពខុសគ្នារវាងកម្រិតនៃសេចក្ដីជំនឿ និងចំណេះដឹង នៅពេលដែលយើងបានត្រឡប់ជាអ្នកជឿនៅពេលដំបូង ហើយនិងបន្ទាប់ពីការដើរអស់រយៈពេលរាប់ឆ្នាំជាមួយនឹងព្រះ គឺជាភស្តុតាងដែលបង្ហាញថាមានការរីកចម្រើនពិតប្រាកដមែន។ ខ្ញុំចង់សង្កត់ធ្ងន់ថា ចំណាប់អារម្មណ៍ដ៏សំខាន់របស់យើងគឺនៅក្នុងបញ្ហានៃការរីកចម្រើន។ ឧទាហរណ៍៖

ក) ការរីកចម្រើននៅក្នុងព្រះគុណគឺជាភស្តុតាងដ៏សំខាន់បំផុតនៃសុខភាពខាងព្រលឹងវិញ្ញាណ។ អ្វីៗដែលនៅរស់សុទ្ធតែបង្ហាញពីសុខភាពរបស់ផងវា ដោយការ

ធំលូតលាស់ទៀងទាត់នៅក្នុងការរីកចម្រើន។ អ្វីដែលមិនលូតលាស់ នោះគឺមិនរស់ទេ។

ខ) ការរីកចម្រើននៅក្នុងព្រះគុណ គឺជារបៀបមួយដើម្បីឲ្យបានសប្បាយរីករាយនៅក្នុងសេចក្តីជំនឿរបស់យើង។ មានចំណងមួយរវាងសេចក្តីកម្សាន្តនិងភាពបរិសុទ្ធរបស់យើង។ អ្នកជឿដែលមានសេចក្តីអំណរនិងសេចក្តីសុខសាន្តច្រើននៅក្នុងសេចក្តីជំនឿ ហើយមាន "ទីបន្ទាល់នៃព្រះវិញ្ញាណ" នៅក្នុងចិត្តរបស់គាត់ (រ៉ូម ៨:១៦) គឺជាអ្នកជឿដែលកំពុងរីកចម្រើនខាងព្រលឹងវិញ្ញាណ។

គ) ការរីកចម្រើននៅក្នុងព្រះគុណ គឺជាអាថ៌កំបាំងមួយនៃជំនួយដ៏មានប្រយោជន៍មួយចំពោះអ្នកដទៃ។ ឥទ្ធិពលរបស់យើងលើអ្នកដទៃ ពឹងយ៉ាងខ្លាំងលើអ្វីដែលពួកគេឃើញនៅក្នុងយើង។ អ្នកជឿដែលធ្វើឲ្យលោកិយគិតគឺជាអ្នកជឿដែលកំពុងតែរីកចម្រើនទៅមុខឥតឈប់ឈរ។

ឃ) ការរីកចម្រើននៅក្នុងព្រះគុណ គាប់ព្រះទ័យដល់ព្រះជាម្ចាស់។ វាហាក់ដូចជាអស្ចារ្យដែលយើងអាចធ្វើអ្វីម្យ៉ាងដើម្បីផ្គាប់ព្រះហឫទ័យព្រះ។ ប៉ុន្តែព្រះយេស៊ូវបានមានបន្ទូលទៅពួកសិស្សរបស់ទ្រង់ថា *ព្រះវរបិតាខ្ញុំបានដំកើងឡើង ដោយសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាបង្កើតផលជាច្រើន យ៉ាងនោះអ្នករាល់គ្នានឹងធ្វើជាសិស្សខ្ញុំមែន* (យ៉ូហាន ១៥:៨)។ ព្រះអម្ចាស់រីករាយនៅក្នុងរាស្ត្ររបស់ទ្រង់គ្រប់ៗរូប ជាពិសេសអស់អ្នកដែលរីកចម្រើនខាងព្រលឹងវិញ្ញាណ។

ង) ប៉ុន្តែ លើសពីនោះទៅទៀត ចូរយើងដឹងថា ការរីកចម្រើននៅក្នុងព្រះគុណមិនត្រឹមតែអាចទៅរួចប៉ុណ្ណោះទេ តែថែមទាំងជាអ្វីម្យ៉ាងដែលយើងត្រូវទទួលខុសត្រូវទៀតផង។ តើជាកំហុសរបស់អ្នកណា ប្រសិនបើអ្នកជឿម្នាក់មិនរីកចម្រើន? ច្បាស់ណាស់ថា នោះមិនមែនជាកំហុសរបស់ព្រះឡើយ។ អ្នកជឿមានកាតព្វកិច្ចមួយ

ដើម្បីការរីកចម្រើន។ ការធ្វេសប្រហែសនៃការរីកចម្រើន ប្លន់អភ័យឯកសិទ្ធិពីអ្នកជឿ ធ្វើឲ្យព្រះវិញ្ញាណព្រួយព្រះហឫទ័យ ហើយធ្វើឲ្យអាប់ពន្លឺដល់ព្រលឹង។ ត្រូវទម្លាក់កំហុសលើខ្លួនយើងផ្ទាល់ មិនមែនលើអ្នកណាទៀតឡើយ ប្រសិនបើយើងមិនធំចម្រើនឡើងខាងឯព្រលឹងវិញ្ញាណ។

## ២. លទ្ធផលនៃការធំចម្រើនឡើងខាងព្រលឹងវិញ្ញាណ

តើយើងអាចនឹងដឹងថា យើងកំពុងតែរីកចម្រើន ឬមិនកំពុងរីកចម្រើននៅក្នុងព្រះគុណដោយរបៀបណា? ខ្ញុំសូមឆ្លើយថា មានលទ្ធផលជាក់លាក់នៃការធំចម្រើនឡើងយ៉ាងដូច្នេះ ហើយកន្លែងណាក៏ដោយដែលយើងឃើញលទ្ធផលទាំងនោះ យើងក៏ឃើញវិញ្ញាណដែលកំពុងតែរីកចម្រើនមួយដែរ។ សូមឲ្យខ្ញុំចង្អុលបង្ហាញលទ្ធផលខ្លះនៃលទ្ធផលទាំងនោះ។

ក) លទ្ធផលមួយនៃការរីកចម្រើននៅក្នុងព្រះគុណ គឺជាទ្រព្យសម្បត្តិនៃការបន្ទាបខ្លួន។ នៅពេលដែលចូលទៅឯព្រះកាន់តែជិត យើងស្គាល់ពីសេចក្ដីបរិសុទ្ធ និងសេចក្ដីគ្រប់លក្ខណ៍របស់ទ្រង់កាន់តែច្រើន ដូច្នេះបានជាយើងដឹងកាន់តែច្រើនពីភាពមិនស័ក្ដិសមរបស់យើងនៅក្នុងព្រះនេត្ររបស់ផងព្រះ។ យើងដឹងពីពាក្យសំដីរបស់មេទ័ពម្នាក់ (ម៉ាថាយ ៨:៨) អាចជាពាក្យសំដីរបស់ផងយើងដែរដែលថា *ព្រះអម្ចាស់អើយ ទូលបង្គំមិនគួរនឹងទទួលទ្រង់នៅក្នុងផ្ទះរបស់ទូលបង្គំទេ*។ ឬក៏ដូចជានៅក្នុងពាក្យសំដីរបស់កូនពៅវង្វេង (លូកា ១៥:១៩) *ខ្ញុំនេះមិនគួរឲ្យគេហៅជាកូនលោកឪពុកទៀតទេ*។ នៅពេលដែលអ្នកជឿម្នាក់កាន់តែមានភាពចាស់ទុំសម្រាប់សិរីល្អនៃនគរស្ថានសួគ៌ គឺប្រៀបដូចជាពោតដែលមានគ្រាប់កាន់តែច្រើនយ៉ាងដូច្នោះដែរ។

ខ) លទ្ធផលមួយទៀតនៃការរីកចម្រើននៅក្នុងព្រះគុណ គឺជាសេចក្តីស្រឡាញ់ ដែលកាន់តែកើនឡើងចំពោះព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដែលធ្វើឲ្យសេចក្តីជំនឿរបស់យើងកាន់តែជ្រាលជ្រៅឡើងនៅក្នុងទ្រង់។ ច្បាស់ណាស់ថា អ្នកជឿគិតច្រើនអំពីព្រះគ្រីស្ទនៅពេលគេជឿជាលើកដំបូង។ ប៉ុន្តែការរីកចម្រើននៅក្នុងព្រះគុណ ធ្វើឲ្យព្រះគ្រីស្ទកាន់តែជាទីចង់បាន។ នេះគឺជាលទ្ធផលមួយនៃការរីកចម្រើនដែលត្រូវស្វែងរក!

គ) លទ្ធផលមួយទៀតនៃការរីកចម្រើននៅក្នុងព្រះគុណ គឺជាការកើនឡើងនៃសេចក្តីបរិសុទ្ធនៅក្នុងជីវិត។ មានការប្រុងប្រយ័ត្នកាន់តែខ្លាំងឡើងមួយលើភាពកម្សោយនៅក្នុងចរិតលក្ខណៈរបស់យើង។ មានការតស៊ូកាន់តែខ្លាំងឡើងមួយប្រឆាំងនឹងអារក្សសាតាំង និងអំពើបាប។ វាជាសញ្ញាមួយនៃការមិនរីកចម្រើននៅក្នុងព្រះគុណ ប្រសិនបើយើងដឹងថាខ្លួនយើងមិនសូវខ្វល់ខ្វាយចំពោះអំពើបាប។

ឃ) លទ្ធផលមួយទៀតនៃការរីកចម្រើននៅក្នុងព្រះគុណ ជាការលូតលាស់ខាងសេចក្តីប៉ងប្រាថ្នា និងគំនិតខាងព្រលឹងវិញ្ញាណថែមទៀត។ អ្នកជឿដែលកំពុងតែរីកចម្រើននឹងមានទំនួលខុសត្រូវដោយស្មោះត្រង់ចំពោះផ្ទះសំបែង និងជីវិត។ ប៉ុន្តែសេចក្តីដែលគេស្រឡាញ់បំផុតគឺសេចក្តីខាងឯព្រលឹងវិញ្ញាណ។ សេចក្តីរីករាយ និងគំនិតដែលធ្លាប់គិតថាមានសារៈសំខាន់បំផុត នឹងហាក់ដូចជាបាត់តម្លៃ។ ការទាំងអស់នោះអាចនឹងមិនជាអំពើបាបនៅក្នុងគេទេ ប៉ុន្តែបន្តិចម្តងៗ វាហាក់ដូចជាសេចក្តីដែលមិនសំខាន់ចំពោះអ្នកជឿដែលកំពុងតែរីកចម្រើន។

ង) លទ្ធផលមួយទៀតនៃការរីកចម្រើននៅក្នុងព្រះគុណ គឺជាសេចក្តីស្រឡាញ់ធំជាងមុនចំពោះមនុស្សទាំងអស់ ជាពិសេសចំពោះអ្នកជឿឯទៃទៀត។ វិញ្ញាណដែលកំពុងតែរីកចម្រើន នឹងព្យាយាមដាក់នូវការបកស្រាយដ៏ល្អបំផុតលើឥរិយាបថ

របស់មនុស្សម្នាក់ទៀត។ សញ្ញាដ៏ច្បាស់បំផុតនៃការមិនរីកចម្រើននៅក្នុងព្រះគុណ គឺជាចិត្តមួយដែលចង់តែចាប់កំហុស និងសេចក្ដីកម្សោយរបស់មនុស្សឯទៀតទៀត។

ច) លទ្ធផលចុងក្រោយនៃការរីកចម្រើននៅក្នុងព្រះគុណដែលខ្ញុំនឹងនិយាយ គឺជាការរីកចម្រើនចំណាប់អារម្មណ៍ខាងការផ្សាយដំណឹងល្អ។ របៀបដែលយើងគិតហើយធ្វើការសម្រាប់បេសកកម្ម នៅក្នុងប្រទេសនិងក្រៅប្រទេស គឺជាសញ្ញាដ៏គួរឲ្យទុកចិត្តនៃការរីកចម្រើននៃព្រលឹងវិញ្ញាណរបស់យើង។ ប្រសិនបើយើងចង់ដឹងថាតើយើងរីកចម្រើនខាងព្រលឹងវិញ្ញាណឬយ៉ាងណា ចូរយើងមើលថា មានការព្រួយបារម្ភខាងឯការរីកចម្រើនសម្រាប់សេចក្ដីសង្គ្រោះនៃអ្នកឯទៀតដែរឬទេ។

## ៣. ធនធាននានាដែលត្រូវយកមកប្រើដើម្បីជួយដល់ការរីកចម្រើនខាងព្រលឹងវិញ្ញាណ

អ្នកណាដែលចង់រីកចម្រើននៅក្នុងព្រះគុណ ត្រូវតែប្រើមធ្យោបាយនៃការរីកចម្រើនដែលព្រះប្រទានឲ្យ។ *គ្រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក និងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍ នោះសុទ្ធតែមកពីស្ថានលើ* (យ៉ាកុប ១:១៧)។ នេះគឺជាធនធានពិតសម្រាប់ជំរុញឲ្យមានការរីកចម្រើន ដូចជាគ្រប់ទាំងអំណោយទានឯទៀតទៀតរបស់ព្រះដែរ។ ដោយព្រោះព្រះជាម្ចាស់បានធ្វើឲ្យមានធនធានទាំងអស់នេះ បានជាទំនួលខុសត្រូវរបស់គ្រីស្ទានគ្រប់រូបក្នុងការប្រើប្រាស់ធនធានទាំងអស់នោះ នាំឲ្យបានល្អបំផុត។

ក) ការអធិស្ឋានផ្ទាល់ខ្លួនរបស់យើង ការអានព្រះគម្ពីររបស់យើង ហើយនិងការសញ្ជឹងគិតផ្ទាល់ខ្លួនរបស់យើង ជាជំនួយដ៏ប្រសើរបំផុតចំពោះការរីកចម្រើនខាងឯព្រលឹងវិញ្ញាណ។ ការធ្វេសប្រហែលនិងខ្ជិលច្រអូសអំពីការទាំងអស់នេះ គឺខុស

ទាំងស្រុង! ខ្ញុំដឹងថា យើងរស់នៅក្នុងសម័យមួយដែលពេញទៅដោយការគ្រោះថ្នាក់ដូចជា មមាញឹកខ្លាំង ហើយនិងសកម្មភាពសប្បាយៗជាច្រើន។ ខ្ញុំគិតថា គ្រីស្ទានជនជាតិអង់គ្លេសកាលពីពីររយឆ្នាំមុនអានព្រះគម្ពីរច្រើនជាងពួកអ្នកដែលនៅសម័យនេះ (លោក រ៉ាល បានសរសេរនៅចុងសតវត្សទី១៩)។ សេចក្តីជំនឿផ្ទាល់ខ្លួនត្រូវតែទទួលការយកចិត្តទុកដាក់ជាទីមួយរបស់យើង ប្រសិនបើយើងចង់ឲ្យព្រលឹងវិញ្ញាណរបស់យើងបានរីកចម្រើន។

ខ) សារៈសំខាន់មួយទៀតចំពោះការរីកចំរើនខាងព្រលឹងវិញ្ញាណ គឺជាការប្រើប្រាស់ដ៏ប្រុងប្រយ័ត្ននៃមធ្យោបាយនៃព្រះគុណជាសាធារណៈ។ ការជួបជុំគ្នាទៀងទាត់សម្រាប់ការសរសើរ និងការថ្វាយបង្គំព្រះ ដោយចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ ដោយស្តាប់ការអធិប្បាយព្រះបន្ទូល។ ទាំងអស់នេះជាប្រភពសាធារណៈដើម្បីជួយឲ្យមានការរីកចម្រើននៅក្នុងព្រះគុណ។ ការគ្រោះថ្នាក់គឺថា ការស្គាល់ការទាំងអស់នេះ ជាទំនោរដែលធ្វើឲ្យយើងមានការធ្វេសប្រហែស។ ប្រសិនបើយើងរីកចំរើន យើងត្រូវតែចាំយាម ក្រែងលោ អ្វីដែលយើងធ្វើដដែលៗ ធ្វើឲ្យយើងបាត់បង់ការស្រេកឃ្លានដល់ការទាំងអស់នោះ។

គ) ការប្រុងប្រយ័ត្នចំពោះអាកប្បកិរិយារបស់យើងក្នុងការដ៏តូចមួយក្នុងជីវិត ពិតជាមានសារៈសំខាន់ណាស់។ ជីវិតគឺកើតពីការតូចៗនានាដូចជា អារម្មណ៍ប្រចាំថ្ងៃរបស់យើង ការបំពេញកាតព្វកិច្ចទៀងទាត់របស់យើង របៀបដែលយើងប្រើប្រាស់ពេលវេលារបស់យើង ទាំងអស់នេះសុទ្ធតែជាការសំខាន់។ យើងត្រូវតែផ្តោតការយកចិត្តទុកដាក់ ដើម្បីឲ្យមានជំនឿជឿដល់ព្រះគ្រីស្ទមួយដែលប្រៀបដូចជា ចរន្តទឹកក្នុងដើមឈើ ដែលហូរកាត់មែកនិងស្លឹកនៃចរិតលក្ខណៈរបស់យើង ហើយធ្វើឲ្យគ្រប់ទាំងអស់បានបរិសុទ្ធ។

ឃ) ត្រូវតែមានការប្រុងប្រយ័ត្នជាមួយមនុស្សដែលយើងសេពគប់ជាមួយ ហើយនិងមិត្តភាពដែលយើងបង្កើត។ ជំងឺអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ប៉ុន្តែសុខភាពវិញមិនអាចកើតឡើងយ៉ាងដូច្នេះបានឡើយ។ នៅក្នុងចំណោមមិត្តភ័ក្តិ ប្រសិនបើមិនមានអ្នកដែលជាមិត្តភ័ក្តិរបស់ព្រះជាម្ចាស់ផង តើគេអាចជួយដល់ការរីកចម្រើនខាងព្រលឹងវិញ្ញាណបានយ៉ាងដូចម្តេច? កំហុសក្នុងការបង្កើតមិត្តភាព និងអាពាហ៍ពិពាហ៍ ទាំងអស់នេះជាហេតុផលដែលអ្នកជឿមួយចំនួនមិនបានរីកចម្រើន។ *ពួកម៉ាកអាក្រក់តែងនឹងបង្ខូចកិរិយាល្អ* (១កូរិនថូស ១៥:៣៣)។

ង) មានការមួយទៀត ដែលខ្ញុំជឿថាមានសារៈសំខាន់។ ទំនាក់ទំនងទៀងទាត់ជាមួយព្រះអម្ចាស់ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះការរីកចម្រើនខាងព្រលឹងវិញ្ញាណ។ ខ្ញុំមិនចង់សំដៅ គ្រាន់តែការចូលរួមក្នុងមធ្យោបាយសាធារណៈនៃព្រះគុណប៉ុណ្ណោះទេ។ ខ្ញុំចង់និយាយពីការរីកចម្រើនក្នុងការយល់ដឹងពីទំនាក់ទំនងរវាងព្រះអម្ចាស់ និងខ្លួនយើងផ្ទាល់ដែលជាអ្នកជឿវិញ។ ទ្រង់ជាប្តីថ្មោងថ្មីរបស់យើង ដែលយើងជាប្រពន្ធថ្មោងថ្មីរបស់ទ្រង់។ ទ្រង់គឺជាសិរសារបស់យើង ដែលយើងជាអវយវៈរបស់ទ្រង់។ ទ្រង់គឺជាគ្រូពេទ្យរបស់យើង ដែលយើងជាអ្នកជំងឺរបស់ទ្រង់។ ទ្រង់គឺជាមេធាវីរបស់យើង ដែលយើងជាកូនក្តីរបស់ទ្រង់។ ទ្រង់គឺជាអ្នកគង្វាលរបស់យើង ដែលយើងជាចៀមរបស់ទ្រង់។ ទ្រង់គឺជាគ្រូរបស់យើង ដែលយើងជាសិស្សរបស់ទ្រង់។ ការចូលមកជិតព្រះអម្ចាស់ក្នុងទំនាក់ទំនងទាំងអស់នេះ ទើបជាសារៈសំខាន់ចំពោះការរីកចម្រើនខាងព្រលឹងវិញ្ញាណ។ យើងត្រូវតែដឹងពីអ្វីដែលសាវក ប៉ុលបាននិយាយសំដៅថា *ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសម្រាប់ព្រះគ្រីស្ទទេ* (ភីលីព ១:២១)។ យើងត្រូវតែដឹង ត្រូវបែរមករកទ្រង់ជាទីមួយក្នុងគ្រប់ទាំងសេចក្តីត្រូវការ ដើម្បីទូលដល់ទ្រង់ពីគ្រប់ទាំងសេចក្តីលំបាក

ដើម្បីសុំយោបល់ពីទ្រង់ពីគ្រប់ទាំងជំហាន និងដើម្បីចែកចាយសេចក្តីសោកសង្រេង និងសេចក្តីអំណរនៅចំពោះទ្រង់។

ជាចុងក្រោយ ប្រសិនបើយើងកំពុងរីកចម្រើននៅក្នុងព្រះគុណ ឬកំពុងតែស្វែងរកទ្រង់ឲ្យអស់ពីចិត្ត យើងត្រូវតែត្រៀមខ្លួនជាស្រេចសម្រាប់ការលំបាក។ យើងអាចនឹងត្រូវឆ្លងកាត់ការលំបាកនិងបញ្ហាជាច្រើននៅក្នុងជីវិតនេះ។ ព្រះបន្ទូលដ៏អស្ចារ្យមួយរបស់ព្រះអម្ចាស់របស់យើង អំពីទំនាក់ទំនងរវាងទ្រង់ផ្ទាល់និងសាវករបស់ទ្រង់គឺ *អស់ទាំងខ្នែងណាដែលបង្កើតផលផ្លែ នោះទ្រង់លួសខ្នែងនោះវិញ ដើម្បីឲ្យបានផលផ្លែជាច្រើនឡើង* (យ៉ូហាន ១៥:២)។ នៅពេលព្រះជាម្ចាស់បានកែតម្រង់យើងដោយកាលៈទេសៈខ្លះគឺដើម្បីជាការបង្ហាត់បង្រៀន ហើយធ្វើឲ្យយើងមានការរីកចម្រើន! *កាលណាយើងត្រូវសេចក្តីផ្ចាញ់ផ្ចាល នោះមើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ តែក្រោយមកនោះទើបបង្កើតផលដ៏សុខសាន្តនៃសេចក្តីសុចរិត ដល់អស់អ្នកណាដែលត្រូវរងទ្រាំនោះវិញ* (ហេព្រើរ ១២:១១)។ ដូច្នេះចូរយើងសួរខ្លួនឯងថា តើយើងកំពុងមានជីវិតមួយនៅក្នុងសេចក្តីជំនឿ នៅក្នុងអ្វីៗដែលជាសេចក្តីសុខសាន្តនៃចិត្តគំនិតរបស់យើង និងនៅក្នុងសេចក្តីបរិសុទ្ធរបស់យើងដែរឬទេ? ដូច្នេះតើយើងកំពុងតែរីកចម្រើនដែរឬទេ?

# ជំពូក ៧

## សេចក្តីសង្ឃឹមដ៏ពិតប្រាកដ

*ដ្បិតខ្ញុំកំពុងតែត្រូវច្រួចចេញ ឯពេលវេលាដែលខ្ញុំត្រូវលាទៅ ក៏បានមកដល់ហើយ ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច ខ្ញុំបានរក្សាសេចក្តីជំនឿទៅហើយ ពីនេះទៅមុខ នឹងមានមកុដនៃសេចក្តីសុចរិត បំរុងទុកឲ្យខ្ញុំ ដែលព្រះអម្ចាស់ដ៏ជាចៅក្រមសុចរិត ទ្រង់នឹងប្រទានមកខ្ញុំនៅថ្ងៃនោះ មិនមែនដល់ខ្ញុំតែម្នាក់ប៉ុណ្ណោះ គឺដល់អស់អ្នកណាដែលចូលចិត្តនឹងដំណើរទ្រង់យាងមកវិញនោះដែរ* (២ធីម៉ូថេ ៤:៦-៨) ។

នៅក្នុងខទាំងនេះ សាវក ប៉ុល និយាយដោយគ្មានស្ទាក់ស្ទើរឬក៏សង្ស័យអំពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលទេ។ គាត់គ្មានសេចក្តីខ្មាសអំពីភាពជាគ្រីស្ទានរបស់គាត់នៅអតីតកាល ហើយគាត់ក៏គ្មានសេចក្តីភ័យខ្លាចពីការចេញដំណើរពីជីវិតរបស់គាត់ដែលត្រូវមកឆាប់ៗនេះ ហើយគាត់ក៏គ្មានការសង្ស័យអំពីលទ្ធផលនៃការជំនុំជំរះបន្ទាប់ពីសេចក្តីស្លាប់នៅអនាគតដែរ។ ដោយព្រោះព្រះជាម្ចាស់បានទាញគាត់បែរទៅរកនគរស្ថានសួគ៌ នោះគាត់បានផ្ចង់អារម្មណ៍ក្នុងការបម្រើព្រះអម្ចាស់របស់គាត់ដោយមិនចេះប្រែប្រួល។ បញ្ញាចិត្តរបស់គាត់ពិតជាជ្រះថ្លា ទោះបីជាគ្មានអ្នកណាមួយចូលទៅនគរស្ថានសួគ៌ដោយការល្អនៃបញ្ញាចិត្តក៏ដោយ តែបញ្ញាចិត្តពិតជាបានផ្តល់ឲ្យយើងនូវការកំសាន្តចិត្តពេល

ដែលចាកចេញពីលោកិយនេះទៅកាន់បរ លោកនាយប្រាកដមែន។ ហើយគាត់អាចសំឡឹងមើលទៅថ្ងៃជំនុំជំរះដោយក្លាហានជាក់ច្បាស់។ គ្មានការស្ទាក់ស្ទើរអំពីពាក្យសំដីរបស់គាត់ទេ__ គ្មានពាក្យថា "ខ្ញុំសង្ឃឹមថា" ឬ "ប្រហែលជា" ឡើយ។ សាវ័ក ប៉ុល មានការដឹងប្រាកដច្បាស់*សេចក្តីសង្គ្រោះរបស់គាត់។

មានការ៤យ៉ាងដែលខ្ញុំចង់និយាយអំពីបញ្ហានេះដែលថា អ្នកជឿមានសេចក្តីសង្ឃឹមដ៏ពិតប្រាកដ និងការដឹងប្រាកដច្បាស់នៃសេចក្តីសង្គ្រោះ។ ហើយខ្ញុំនិយាយដោយបន្ទាបខ្លួនថា នោះគឺជាប្រធានបទដ៏ពិបាក។

**១. ការដឹងប្រាកដច្បាស់នេះ គឺជាការមួយដែលពិតហើយទៅតាមបទគម្ពីរ**

ការដឹងប្រាកដច្បាស់ គឺជាអំណោយទានមួយនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នកជឿនៅក្នុងព្រះគ្រីស្ទគួរស្វែងរក។ ចំពោះខ្ញុំវាហាក់ដូចជា ព្រះគម្ពីរបង្រៀនថា អ្នកជឿពិតអាចនឹងទៅដល់សណ្ឋានមួយនៃសេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទ ដែលពួកគេនឹងមានជំនឿទុកចិត្តទាំងស្រុងអំពីសុវត្ថិភាពចុងក្រោយនៃវិញ្ញាណរបស់ពួកគេ។ ប៉ុន្តែមានពួកជំនុំមួយចំនួន*បែរជាគិតថា មិនអាចទៅរួចទេដែលអ្នកជឿម្នាក់មានជំនឿទុកចិត្តយ៉ាងដូច្នេះនោះ ហើយថា ប្រសិនបើពួកគេមានជំនឿទុកចិត្តយ៉ាងដូច្នោះមែន នោះពួកគេត្រូវបញ្ឆោតទេ។

ជាការពិតដែលថា អ្នកខ្លះអាចនឹងស្មានថា សេចក្តីសង្គ្រោះរបស់ខ្លួនជាការពិត គឺជាអ្នកដែលគ្មានហេតុផលដើម្បីនឹងនិយាយដូច្នេះ។ ប៉ុន្តែពីខមួយទៅខមួយនៅក្នុងព្រះគម្ពីរទាមទារថា ការដឹងប្រាកដច្បាស់ គឺជាអំណោយទានដ៏ពិតនៃព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះការឆ្លើយតបរបស់ខ្ញុំចំពោះពួកអ្នកដែលបដិសេធពីវត្តមាន

នៃការដឹងប្រាកដច្បាស់ គឺសួរសំណួរងាយមួយថា តើព្រះគម្ពីរចែងយ៉ាងដូចម្តេច?

*ប៉ុន្តែ អ្នកដែលលោះខ្ញុំទ្រង់មានព្រះជន្មរស់នៅ ហើយដល់ជាន់ក្រោយ ទ្រង់នឹងមកឈរនៅលើផែនដី ហើយក្រោយដែលសំបកកាយខ្ញុំនេះត្រូវរលាយទៅ គឺក្រៅពីរាងកាយនោះខ្ញុំនឹងបានឃើញព្រះ* (យ៉ូប ១៩:២៥-២៦)។

*ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្តីស្លាប់ក៏ដោយ គង់តែមិនខ្លាចសេចក្តីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ ព្រនង់ ហើយនឹងដំបងរបស់ទ្រង់កំសាន្តចិត្តទូលបង្គំ* (ទំនុកដំកើង ២៣:៤)។

មានឧឃោងជាច្រើនអំពីមនុស្សដែលមានបទពិសោធន៍នឹងសេចក្តីសង្ឃឹមដ៏ជាក់លាក់នេះ ដូចជា អេសាយ ២៦:៣; ៣២:១៧; រ៉ូម ៨:២៨-៣៩; ២កូរិនថូស ៥:១, ៦; កូល៉ុស ២:២; ២ធីម៉ូថេ ១:១២; ហេព្រើរ ៦:១១; ១០:២២; ២ពេត្រុស ១:១០; ១យ៉ូហាន ៣:១៩; ៥:១៣។ នៅក្នុងបទគម្ពីរទាំងអស់នេះ យើងរកឃើញនូវការបន្ទាបខ្លួន និងការដឹងប្រាកដច្បាស់ ម្តងបន្តិចៗ។ ហើយការដឹងប្រាកដច្បាស់ដែលគេនិយាយនេះ គឺតែងតែជាការជឿជាក់នៅក្នុងព្រះជាម្ចាស់ មិនមែននៅក្នុងខ្លួនពួកគេទេ។ ចំពោះអ្នកដែលមិនចូលចិត្តគំនិតដែលថាអ្នកជឿមានការដឹងប្រាកដច្បាស់នោះមានន័យថា មិនបានដើរតាមគំរូរបស់លោកយ៉ូប អ្នកច្រៀងទំនុកដំកើង លោក អេសាយ លោក ប៉ុល លោក ពេត្រុស និងលោក យ៉ូហានទេ។ ពួកគាត់ជាមនុស្សដែលមានចិត្តបន្ទាប តែពួកគេបាននិយាយថាមានសេចក្តីសង្ឃឹមដ៏ជាក់លាក់មួយ។ តើការដឹងប្រាកដច្បាស់អាចជាការខុសឆ្គងដោយរបៀបណា បើព្រះជាម្ចាស់បានប្រទានសេចក្តីសន្យាដ៏ប្រាកដរបស់ទ្រង់មកយើងហើយនោះ?

## ២. អ្នកជឿម្នាក់នឹងមានសេចក្ដីជំនឿដែលបានសង្គ្រោះ តែមិនស្គាល់ពីការដឹងប្រាកដច្បាស់

ខ្ញុំជឿថា ជាការដ៏សំខាន់ណាស់ក្នុងការស្គាល់ពីភាពខុសគ្នារវាងសេចក្ដីជំនឿនិងការដឹងប្រាកដច្បាស់។ សេចក្ដីជំនឿគឺឫសនៃការជឿរបស់យើង ហើយការដឹងប្រាកដច្បាស់ជាផ្កា។ យើងមិនដែលអាចមានផ្កាដោយគ្មានឫសបានទេ ប៉ុន្តែជួនកាលអ្នកមានឫសតែគ្មានផ្កា។ សេចក្ដីជំនឿដ៏សាមញ្ញនៅក្នុងព្រះគ្រីស្ទនឹងសង្គ្រោះមនុស្សម្នាក់ជាមិនខាន ប៉ុន្តែពួកគេអាចនឹងមិនដែលមានសេរីភាពពីការព្រួយបារម្ភ និងការសង្ស័យ។ សេចក្ដីជំនឿនឹងនាំឲ្យព្រលឹងវិញ្ញាណមួយឲ្យបានទៅនគរស្ថានសួគ៌ ប៉ុន្តែការដឹងប្រាកដច្បាស់នឹងនាំនគរស្ថានសួគ៌មកឯវិញ្ញាណមួយវិញ។

សេចក្ដីជំនឿគឺជាការស្រែកឡើងរបស់ពេត្រុសថា *ព្រះអម្ចាស់អើយ សូមជួយសង្គ្រោះទូលបង្គំផង* (ម៉ាថាយ ១៤:៣០)។ ការដឹងប្រាកដច្បាស់គឺថា លោកពេត្រុសដដែលនោះបានប្រកាសនៅចំពោះពួកក្រុមប្រឹក្សាថា *ព្រះអង្គនោះ ជាថ្មដែលលោករាល់គ្នា ជាជាងសង់ផ្ទះបានមើលងាយ ប៉ុន្តែទ្រង់បានត្រឡប់ជាថ្មជ្រុងយ៉ាងឯកវិញ ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀត បានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ* (កិច្ចការ ៤:១១-១២)។ អ្នកណាដែលមានសេចក្ដីជំនឿធ្វើបានល្អហើយ ប៉ុន្តែអ្នកណាដែលមានការដឹងប្រាកដច្បាស់ទៀតនោះកាន់តែប្រសើរ!

## ៣. សេចក្ដីសង្ឃឹមដ៏ជាក់លាក់ ជាការមួយដ៏ជាទីចង់បានខ្លាំងណាស់

ខ្ញុំប្រាថ្នាចង់ឲ្យការដឹងប្រាកដច្បាស់ត្រូវបានស្វែងរកលើសពីហ្នឹងទៅទៀត។ អ្នកជឿជាច្រើនបានរស់នៅក្នុងការសង្ស័យ និងស្លាប់នៅក្នុងការសង្ស័យ ហើយទៅនគរស្ថានសួគ៌នៅក្នុងអ័ព្ទ ។

ក) ការដឹងប្រាកដច្បាស់គឺជាទីចង់បាន ពីព្រោះវាផ្តល់នូវការកម្សាន្តចិត្តនិងមេត្រីភាពក្នុងលោកិយនេះឲ្យយើង។ ការមិនដឹងប្រាកដច្បាស់នៅក្នុងបញ្ហានៃជីវិតនេះ ដូចជា ទំនាក់ទំនងក្នុងគ្រួសារ លុយកាក់និងការងារ អាចបំផ្លាញសុខភាពខាងផ្នែកកាយចិត្តរបស់យើង។ រីឯការមិនដឹងប្រាកដច្បាស់ខាងសេចក្តីងវិញ្ញាណវិញ អាចបំផ្លាញសុខភាពខាងព្រលឹងវិញ្ញាណរបស់យើងយ៉ាងដូច្នោះដែរ។

ការដឹងប្រាកដច្បាស់ នឹងជួយគាំទ្រអ្នកជឿ នៅពេលអ្នកដែលជាទីស្រឡាញ់ទទួលមរណភាព វានឹងជួយឲ្យយើងនៅតែអាចសរសើរព្រះបាន ទោះបីជាស្ថិតនៅក្នុងស្ថានភាពដ៏លំបាកក៏ដោយ ហើយបានរីករាយនៅពេលយើងរងទុក្ខដោយព្រោះព្រះគ្រីស្ទក៏ដោយ។ ការដឹងប្រាកដច្បាស់អាចធ្វើឲ្យទៅរួច ដែលសាវ័កពេត្រុសបានគេងលក់យ៉ាងស្កប់ស្កល់នៅយប់មុនថ្ងៃគាត់ត្រូវគេសម្លាប់ (កិច្ចការ ១២)។ ការដឹងប្រាកដច្បាស់ដកសេចក្តីភ័យខ្លាចចេញ ហើយវាធ្វើឲ្យអ្នកជឿដែលកំពុងតែជិតស្លាប់ឲ្យនិយាយថា *បើត្រសាលដែលជាទីលំនៅរបស់យើងខ្ញុំនៅផែនដីនេះ ត្រូវបំផ្លាញនៅវេលាណា នោះយើងខ្ញុំមានវិមាន១ ដែលមកពីព្រះ មិនមែនធ្វើនឹងដៃមនុស្សទេ គឺនៅលើស្ថានសួគ៌វិញ ជាវិមានដ៏នៅជាប់អស់កល្បជានិច្ច* (២ កូនរិនថូស ៥:១)។

ខ) ការមានសេចក្តីសង្ឃឹមដ៏ជាក់លាក់មួយជួយឲ្យអ្នកជឿមានថាមពលសម្រាប់កិច្ចការគ្រីស្ទាន។ ជាទូទៅ គ្មានអ្នកណាម្នាក់ធ្វើកិច្ចការដ៏ច្រើនសម្រាប់ព្រះគ្រីស្ទ ដូចជាពួកអ្នកដែលរីករាយដោយដឹងប្រាកដថានឹងបានចូលទៅកាន់នគរស្ថានសួគ៌

នោះទេ។ អ្នកជឿដែលខ្វះការដឹងប្រាកដច្បាស់ នឹងចំណាយពេលច្រើនក្នុងការស្វែងយល់ពីចិត្តរបស់ខ្លួនឯងអំពីស្ថានភាពខាងព្រលឹងវិញ្ញាណរបស់ខ្លួន។ ប៉ុន្តែអ្នកជឿដូចសាវ័កប៉ុលមានសេចក្តីជំនឿយ៉ាងមុតមាំមួយ ហើយនិងសេចក្តីសង្ឃឹមដ៏ពិតប្រាកដមួយ។ អ្នកយ៉ាងនោះមានសេរីភាពពីការរំខាននានា។ ការផ្តោតយកចិត្តទុកដាក់លើការងារដោយមិនបែកអារម្មណ៍ តែងតែនាំមកនូវភាពជោគជ័យដ៏ធំបំផុត ។

គ) ការដឹងប្រាកដច្បាស់កំចាត់នូវការមិនចេះសម្រេចចិត្តក្នុងបញ្ហាខាងព្រលឹងវិញ្ញាណ។ មនុស្សជាច្រើនដែលគ្រាន់តែសង្ឃឹមថាខ្លួនជាកូនព្រះ ប៉ុន្តែគេតែងតែយល់មិនច្បាស់ពីរបៀបដែលខ្លួនត្រូវប្រព្រឹត្តិបែបជាយ៉ាងណា។ តើពួកគេគួរធ្វើនេះ ឬធ្វើនោះឬទេ? តើពួកគេមិនត្រូវធ្វើនេះឬធ្វើនោះទេឬ? ហើយនេះពីព្រោះតែពួកគេមិនច្បាស់ថាពួកគេជាកូនរបស់ព្រះមួយរយភាគរយឬយ៉ាងណា? ប្រសិនបើគេថា កិច្ចការសង្គ្រោះរបស់ព្រះគ្រីស្ទពិតជាសម្រាប់ពួកគេមែន នោះពួកគេនឹងដឹងប្រាកដថាពួកគេជាកូនរបស់ព្រះ ហើយនឹងចេះសម្រេចចិត្តលើសកម្មភាពរបស់ពួកគេថាត្រូវធ្វើយ៉ាងណា។

ឃ) ការដឹងប្រាកដច្បាស់គួរជាទីចង់បាន ពីព្រោះវាធ្វើឲ្យគ្រីស្ទានបានបរិសុទ្ធបំផុត។ *អស់អ្នកណាដែលមានសេចក្តីសង្ឃឹមយ៉ាងនោះដល់ទ្រង់ នោះក៏តែងតែជំរះសំអាតចិត្តខ្លួន ឲ្យដូចទ្រង់ដែលស្អាតដែរ* (១យ៉ូហាន ៣:៣)។ សេចក្តីសង្ឃឹមមួយដែលមិនលាងសម្អាត គឺជាការល្ងីល្ងើ និងជំនឿខុសឆ្គង។

ពីអ្វីដែលខ្ញុំបាននិយាយរហូតមកដល់ពេលនេះ គួរតែត្រូវបានយល់ច្បាស់ថា ការធ្វេសប្រហែសពីការដឹងប្រាកដច្បាស់ អាចជាហេតុផលសំខាន់សម្រាប់គ្រប់ទាំងការបរាជ័យក្នុងជីវិតជាគ្រីស្ទាន។ ប្រសិនបើអ្នកមានបញ្ហាយ៉ាងនោះដែរ ដូច្នេះអ្នក

គួរយកយោបល់របស់ខ្ញុំនៅពេលនេះហើយ។ ទុកការសង្ស័យរបស់អ្នកមួយអន្លើ ហើយពឹងឲ្យកាន់តែខ្លាំងលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ចូរគ្រាន់តែចាប់ផ្ដើមដោយជឿទ្រង់ ហើយការដឹងប្រាកដច្បាស់នឹងបន្ថែមមកតាមក្រោយ។

## ៩. ការលំបាកដែលអាចទៅរួចមួយចំនួនក្នុងការដឹងប្រាកដច្បាស់

គេអាចនឹងពន្យល់ពីការខ្វះការដឹងប្រាកដច្បាស់របស់មនុស្សមួយចំនួន ដោយបុព្វហេតុមួយក្នុងបុព្វហេតុដូចខាងក្រោមនេះ។ មនុស្សជាច្រើនជឿ ប៉ុន្តែមនុស្សតិចណាស់ដែលសំរេចចិត្តធ្វើ។ មនុស្សជាច្រើនមានជំនឿ តែមានមនុស្សតិចតួចណាស់ដែលមានការជឿជាក់។ ហេតុអ្វីបានជាអញ្ចឹង?

ក) ប្រហែលជាមានទស្សនៈមិនត្រឹមត្រូវអំពីគោលលទ្ធិនៃការរាប់ជាសុចរិត។ ការដែលមិនយល់ថានោះជាកិច្ចការរបស់ព្រះគ្រីស្ទ (មិនមែនជាកិច្ចការរបស់យើងទេ) ដែលជាមូលដ្ឋានព្រះជាម្ចាស់ទទួលយើង នឹងឆក់យកការដឹងប្រាកដច្បាស់ពីយើង។ គ្មានអ្វីក្រៅពីសេចក្ដីជំនឿប៉ុណ្ណោះដែលតម្រូវឲ្យយើងមាន។ ការរាប់ជាសុចរិតគឺជាអំណោយទានមួយ គឺជាអ្វីមួយដែលមិនមែនជារបស់យើងទាល់តែសោះ។ និយាយឲ្យងាយស្ដាប់ទៅគឺ ការជឿគឺដើម្បីឲ្យបានរាប់ជាបរិសុទ្ធពេញលេញ។ អ្នកជឿដែលខ្សោយជាងគេបំផុតត្រូវរាប់ជាសុចរិតដូចជាអ្នកជឿដ៏ខ្លាំងបំផុតដែរ ដូចនេះហើយបានជាពួកគេអាចដឹងយ៉ាងប្រាកដច្បាស់បាន។

ខ) ប្រហែលជាមានការខ្ជិលច្រអូសមិនចង់ធំចម្រើននៅក្នុងព្រះគុណ។ មនុស្សជាច្រើនហាក់ដូចជាគិតថា ពួកគេអាចសម្រាកនិងសប្បាយរីករាយជាមួយនឹងជំនឿថ្មីដែលទើបតែរកឃើញរបស់ពួកគេ។ ពួកគេត្រូវបានរំលឹកថា ព្រះគុណនេះត្រូវបាន

ប្រទានមកពួកគេទុកជាប្រាក់ណែនដែលពួកគេត្រូវប្រើ។ អ្នកជឿត្រូវបន្ថែមសេចក្តីជំនឿរបស់ខ្លួនឥតឈប់ឈរ (២ពេត្រុស ១:៥)។

មានទំនាក់ទំនងដែលមិនអាចបំបែកបានមួយរវាងការឧស្សាហ៍ព្យាយាម និងការដឹងប្រាកដច្បាស់ (ហេព្រើរ ៦:១១; ២ពេត្រុស ១:១០)។ នៅក្នុងជីវិតខាងព្រលឹងវិញ្ញាណ ការដឹងប្រាកដច្បាស់មិនដែលមកដោយគ្មានសេចក្តីឧស្សាហ៍ព្យាយាមនោះទេ។ ការបង្រៀនមួយនៃពួក ព្យូរីតិន មានសារៈសំខាន់ណាស់គឺ សេចក្តីជំនឿនៃការប្រតិបត្តិដ៏តឹងរឹង (ឧទាហរណ៍៖ ការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ) មកដោយសារការឮ ប៉ុន្តែសេចក្តីជំនឿនៃការដឹងប្រាកដច្បាស់មិនមកដោយគ្មានការធ្វើអ្វីម្យ៉ាងនោះទេ។ "គ្រីស្ទានដែលខ្ជិលច្រអូសតែងតែខ្វះខាតការ៤យ៉ាងគឺ សេចក្តីកំសាន្តចិត្ត ការស្កប់ចិត្ត ការជឿជាក់ និងការដឹងប្រាកដច្បាស់។ ព្រះបានបង្កើតការញែកចេញពីគ្នាមួយរវាងសេចក្តីអំណរ និង ការមិនធ្វើការ, រវាងការដឹងប្រាកដច្បាស់ និងការខ្ជិលច្រអូស ដូច្នេះហើយមិនអាចទៅរួចទេ ដែលអ្នកយកអ្វីដែលព្រះជាម្ចាស់បានញែកចេញពីគ្នាទៅជាមួយនោះ។

គ) ហេតុផលមួយទៀតក្នុងការដែលខ្វះការដឹងប្រាកដច្បាស់ អាចជាជីវិតមួយដែលមិនខ្ជាប់ខ្ជួន។ ការមិនខ្ជាប់ខ្ជួននៅក្នុងជីវិត គឺជាការបំផ្លាញដល់សេចក្តីសុខសាន្តនៃបញ្ញាចិត្ត។ ប្រសិនបើអ្នកនឹងនៅតែមានទម្លាប់មិនល្អ ហើយមិនអាចធ្វើការសម្រេចចិត្តក្នុងការបោះបង់វាចោល នោះអ្នកនឹងមិនដែលមានការដឹងប្រាកដច្បាស់បានឡើយ។ *យើងរាល់គ្នាដឹងថា យើងស្គាល់ទ្រង់ដោយសារសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តទ្រង់* (១យ៉ូហាន ២:៣)។ សេចក្តីសង្គ្រោះរបស់យើងមិនពឹងផ្អែកលើការប្រព្រឹត្តិរបស់យើងទេ ប៉ុន្តែសេចក្តីកម្សាន្តចិត្តរបស់វាពិតជាពឹងលើការដើរខ្ជាប់ខ្ជួនជាគ្រីស្ទានរបស់យើងវិញ។

ខ្ញុំសូមទុកចំណុចទាំងនេះសម្រាប់ការពិចារណារបស់អ្នក។ គួរពិនិត្យមើលចំណុចទាំងនោះដោយប្រុងប្រយ័ត្នចុះ។

*ចំណាំ៖*

* ការដឹងប្រាកដច្បាស់ អ្នកជឿអាចនឹងដឹងដោយជាក់ច្បាស់ថា ពួកគេជាអ្នកជឿ កូនរបស់ព្រះ បានកើតជាថ្មី អ្នកមានជីវិតអស់កល្ប។ អ្នកជឿពឹងផ្អែកការដឹងប្រាកដច្បាស់របស់ពួកគេលើការមួយចំនួនដូចជា

១. សេចក្តីសន្យារបស់ព្រះ (ឧ៖ យ៉ូហាន ៦:៣៧)

២. ទីបន្ទាល់ខាងក្នុងរបស់ព្រះវិញ្ញាណបរិសុទ្ធ (រ៉ូម ៨:១៦)

៣. ភស្តុតាងនៃសេចក្តីសង្គ្រោះ (ម៉ាថាយ ៧:២០)

៤. តេស្តទាំងបីនៅក្នុងសំបុត្រទី១របស់សាវក យ៉ូហាន ដូចជា

ជំនឿត្រឹមត្រូវ ៣:២៣; ៤:២; ៥:៥, ១០

អាកប្បកិរិយាត្រឹមត្រូវ ១:៥, ៦; ២:៣; ៣:៦, ៩

សេចក្តីស្រលាញ់ ៤:៧, ៨

(ដកស្រង់ពីវចនានុក្រមវិជ្ជាព្រះគម្ពីរ -រោងពុម្ព Grace Publication)

* នេះអាចជាការពិតនៃការបង្រៀនរបស់ពួកជំនុំរ៉ូម៉ាំងកាតូលិក ហើយនឹងជាការបង្រៀនរបស់ពួកប្រូតិះស្តង់មួយចំនួនតូចផងដែរ ដែលពួកគេភ័យខ្លាចថា ការដឹងប្រាកដច្បាស់មិនអាចទៅរួចទេ បើគ្មានការប៉ាន់ស្មាន។

- ដកស្រង់ពីសំណេរដែលសរសេរដោយលោក Thomas Brookes ជាអ្នកអធិប្បាយ Puritan ម្នាក់នៅក្នុងទីក្រុងឡុងដុង ១៦៥៤។

- នៅត្រង់ចំណុចនេះលោក វ៉ាល ផ្តល់ការដកស្រង់៣០ចំណុចពីអ្នកអធិប្បាយដើម្បីគាំទ្រពីអ្វីដែលគាត់បាននិយាយនៅក្នុងជំពូកនេះ។ ចំណុចទាំងនេះត្រូវបានកាត់ចោលនៅក្នុងសៀវភៅបង្រួមតូចនេះ។

# ជំពូក ៨

## ចូរឲ្យបានដូចជាលោក ម៉ូសេ

*ដោយសារសេចក្ដីជំនឿ លុះលោកធំហើយ នោះលោកមិនព្រមឲ្យគេហៅខ្លួន ជាកូនបុត្រីផារ៉ោនទេ លោកស៊ូរងទុក្ខលំបាកជាមួយនឹងរាស្ត្ររបស់ព្រះ ជាជាងមានសេចក្ដីអំណរខាងអំពើបាប ដែលនៅតែមួយភ្លែតនោះវិញ ដោយបានរាប់សេចក្ដីដំនៀលដល់ព្រះគ្រីស្ទ ទុកជាទ្រព្យសម្បត្តិដ៏ប្រសើរជាងអស់ទាំងរបស់ថ្លៃវិសេសនៅស្រុកអេស៊ីព្ទ ដ្បិតលោកសំឡឹងចំទៅឯរង្វាន់វិញ* (ហេព្រើរ ១១:២៤-២៦)។

ចំពោះអស់អ្នកដែលស្វែងរកគំរូនៃសេចក្ដីបរិសុទ្ធ ខ្ញុំសូមផ្ដល់លោក ម៉ូសេ ជាគំរូ។ ចំពោះខ្ញុំ វាហាក់ដូចជា របៀបដែលសេចក្ដីជំនឿដល់ព្រះជាម្ចាស់សូនជីវិតរបស់លោក ម៉ូសេ បង្ហាញយើងពីរបៀបដែលវាអាចសូនជីវិតយើងយ៉ាងដូច្នោះដែរ។ សេចក្ដីជំនឿរបស់គាត់បណ្ដាលឲ្យគាត់មានអាកប្បកិរិយាក្នុងរបៀបជាក់លាក់នានាដូចជារបៀបដែលយើងត្រូវមានអាកប្បកិរិយា ប្រសិនបើយើងចង់រស់នៅជាជីវិតគ្រីស្ទានដ៏ខ្ជាប់ខ្ជួនមួយ។

### ១. អ្វីៗដែលលោក ម៉ូសេ បានបោះបង់ចោល

ក) គាត់បានបោះបង់ចោលឋានៈ និងភាពឧត្ដុង្គឧត្ដមនៃលោកិយនេះ។ គាត់បដិសេធមិនឲ្យគេស្គាល់ថា គាត់ជាកូនប្រុសរបស់បុត្រីផារ៉ោនទេ។ ដោយព្រោះព្រះ

នាងអេហ្ស៊ីប បានយកមកចិញ្ចឹម និងអប់រំគាត់ទុកដូចជាកូនប្រុសបង្កើត លោក ម៉ូសេអាចនឹងជាមនុស្សសំខាន់នៅក្នុងដំណាក់ស្តេចអេហ្ស៊ីប។ គាត់អាចនឹងមានឋានៈ អំណាច កិត្តិយស និងបុណ្យសក្តិ ដែលការទាំងអស់នេះមនុស្សជាច្រើនស្វែងរកចង់បានបំផុត! ប៉ុន្តែគាត់បានបដិសេធការទាំងនោះវិញ។

ខ) គាត់បដិសេធសេចក្តីសប្បាយរីករាយ។ នៅក្នុងដំណាក់ស្តេចអេហ្ស៊ីបមានការសប្បាយរីករាយជាច្រើនប្រភេទកំពុងរង់ចាំគាត់ដូចជា ការសប្បាយខាងឯសេចក្តីត្រេកត្រអាល ខាងសង្គម និងខាងប្រាជ្ញា។ ប្រទេសអេហ្ស៊ីបគឺជាមជ្ឈមណ្ឌលរៀនសូត្រ ជាមជ្ឈមណ្ឌលសិល្បៈ និងជាមជ្ឈមណ្ឌលវិទ្យាសាស្ត្រ។ សេចក្តីសប្បាយរីករាយគឺអ្វីម្យ៉ាងដែលមនុស្សជាច្រើនចំណាយពេលនៅក្នុងជីវិតដើម្បីអោយបានទទួលវា។ នេះជាសេចក្តីល្បួងដ៏ធំណាស់ហ្ន ដែលការទាំងអស់នេះត្រូវតែជារបស់គាត់!

គ) គាត់បានបដិសេធទ្រព្យសម្បត្តិ។ វត្ថុបាក់បែកបុរាណនៃប្រទេសអេហ្ស៊ីប ផ្តល់នូវការចង្អុលបង្ហាញពីទ្រព្យសម្បត្តិ និងភាពឧត្តុង្គឧត្តមនៃប្រទេសអេហ្ស៊ីប ដែលធ្លាប់ជារបស់ប្រទេសនោះ។ លោក ម៉ូសេ បានធំឡើងនៅក្នុងដំណាក់ស្តេចផារ៉ោន។ គាត់ផ្ទាល់មានបទពិសោធន៍ថា ជីវិតនឹងស្រណុកសុខស្រួលយ៉ាងណាក្នុងការដែលមានទ្រព្យសម្បត្តិនោះ។ សេចក្តីល្បួងនេះអាចនឹងផ្តល់សេចក្តីស្រណុកសុខស្រួលដល់គាត់។ ប៉ុន្តែនៅពេលវេលាបានមកដល់ គាត់បានរកឃើញកម្លាំងក្នុងការបែរចេញពីរបស់ទាំងអស់នោះវិញ។

## ២. អ្វីដែលលោក ម៉ូសេ បានជ្រើសរើស

ក) គាត់បានជ្រើសរើសការឈឺចាប់ និងរងទុក្ខ។ គាត់បានចូលរួមជាមួយប្រជាជនរបស់គាត់ដូចជា ប្រជាជនដែលជាអ្នករងគ្រោះនៃទាសភាព និងការបៀតបៀនសម្រាប់ពួកដែលហាក់ដូចជាគ្មានផ្លូវដែលត្រូវបានដោះលែងឲ្យរួចពីច្រវាក់ខ្នោះឃ្នាងនៃប្រទេសអេហ្ស៊ីប និងសម្រាប់ពួកអ្នកដែលនឹងទទួលបានប្រទេសដែលជាទីលំនៅ ដែលហាក់ដូចជាលើសហួសពីលទ្ធភាពរបស់ពួកគេ!

ជាធម្មតា យើងរុញរាពីការឈឺចាប់ ហើយជៀសវាងការរងទុក្ខ ប្រសិនបើយើងអាច។ នៅទីនេះ មានបុរសម្នាក់ដែលមានលក្ខណៈដូចជាយើងដែរ តែគាត់ជ្រើសរើសយកការរងទុក្ខ!

ខ) គាត់បានជ្រើសរើសចូលជាមួយក្រុមមនុស្សដែលគេស្អប់។ គាត់បានចាកចេញពីសង្គមដ៏អស្ចារ្យ និងប្រាជ្ញា ហើយសេពគប់ជាមួយពួកទាសករ និងពួកកម្មករ។ គាត់បានឃើញមនុស្សដែលគេស្អប់ ហើយបានជ្រើសរើសដើរជាមួយពួកគេ ជាជាងដើរជាមួយពួកអភិជននៅក្នុងទឹកដីនោះ!

គ) គាត់បានជ្រើសរើសទទួលការរិះគន់ និងការមើលងាយ។ ចូរគិតពីការឡូកឡំមួយ ដែលលោក ម៉ូសេ បានស៊ូទ្រាំ ក្នុងការដកខ្លួនចេញដំណាក់ផារ៉ោនទៅចូលរួមជាមួយនឹងពួកអ៊ីស្រាអែល។ មានការមួយចំនួនដែលយើងខំស៊ូទ្រាំយ៉ាងលំបាកលំបិន បែរទៅជាការឡូកឡំ និងការមើលងាយទៅវិញ។ ប៉ុន្តែនៅទីនេះមានបុរសម្នាក់ដែលមិនរុញរានឹងការល្បងនេះ។

ហើយចូរចងចាំក្នុងចិត្តដែរថា លោក ម៉ូសេមិនមែនជាមនុស្សកម្សោយហើយអវិជ្ជានោះទេ ហើយគាត់ក៏មិនត្រូវបានបណ្តេញចេញ បានជាគាត់ជ្រើសរើសធ្វើយ៉ាងដូច្នោះដែរ។ អ្វីដែលគាត់បានធ្វើគាត់ធ្វើដោយស្ម័គ្រពីចិត្តនិងមិនមាន

ការបង្ខិតបង្ខំ។ ពិតមែនហើយបានជាការនេះធ្វើឲ្យការសម្រេចចិត្តរបស់គាត់ អស្ចារ្យដូចជាការបដិសេធលះចោលរបស់អញ្ចឹងដែរ!

### ៣) អ្វីដែលធ្វើឲ្យលោក ម៉ូសេ បានធ្វើបែបនេះ

ហេតុផលសម្រាប់អាកប្បកិរិយាចំឡែករបស់គាត់ គឺជាសេចក្តីជំនឿរបស់គាត់។ គាត់បានបដិសេធគ្រប់ការទាំងអស់ដែលគាត់បដិសេធ ហើយជ្រើសរើសគ្រប់ការទាំងអស់ដែលគាត់ជ្រើសរើស ពីព្រោះគាត់បានជឿដល់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានបើកសំដែងដល់លោក ម៉ូសេថា នៅពេលអនាគតទៅមុខនឹងមានព្រះអង្គសង្គ្រោះមួយអង្គប្រសូតសម្រាប់ប្រជាជាតិអ៊ីស្រាអែល ហើយថា ផ្នែកដំបូងនៃដំណើរការនេះ នាំទៅរកការដែលត្រូវកើតឡើងនៅពេលបច្ចុប្បន្ននេះ តាមរយៈគាត់។ លោក ម៉ូសេ បានជឿថាព្រះជាម្ចាស់បានមានបន្ទូល។

ក) គាត់ជឿថា ព្រះជាម្ចាស់នឹងរក្សាសេចក្តីសន្យារបស់ទ្រង់ ហើយទ្រង់ធ្វើដូចជាអ្វីដែលទ្រង់បានមានបន្ទូល។

ខ) គាត់ជឿថា គ្មានអ្វីដែលព្រះធ្វើមិនកើតនោះទេ។ ហេតុផលមនុស្សអាចនឹងនិយាយថា ការរំដោះប្រជាជនអ៊ីស្រាអែលមិនអាចទៅរួចបានឡើយ ប៉ុន្តែសេចក្តីជំនឿរបស់គាត់បានប្រាប់គាត់ថា ព្រះជាម្ចាស់អាចធ្វើវាបាន។

គ) គាត់បានជឿថា ព្រះជាម្ចាស់មានគ្រប់ទាំងប្រាជ្ញាញាណ។ ហេតុផលមនុស្សអាចនឹងប្រាប់ លោក ម៉ូសេថា គាត់ជាមនុស្សល្ងីល្ងើដែលគាត់បោះបង់ចោលអត្ថប្រយោជន៍ដែលគាត់មាន ដោយចាកចេញពីដំណាក់របស់ផារ៉ោន ប៉ុន្តែដោយសេចក្តីជំនឿ លោកម៉ូសេ បានយល់ថា ព្រះជាម្ចាស់បានចង្អុលបង្ហាញនូវផ្លូវជាក់លាក់មួយ ដែលជាផ្លូវដ៏ល្អបំផុត។

ឃ) គាត់បានជឿថា ព្រះជាម្ចាស់មានពេញទៅដោយសេចក្តីមេត្តាករុណា។ ហេតុផលមនុស្សអាចនឹងលើកឡើងថា ព្រះជាម្ចាស់អាចធ្វើឲ្យជីវិតកាន់តែងាយស្រួលសម្រាប់ប្រជាជនអ៊ីស្រាអែល ប៉ុន្តែសេចក្តីជំនឿបានប្រាប់លោក ម៉ូសេថា ព្រះជាម្ចាស់ជាព្រះនៃសេចក្តីស្រលាញ់ ហើយនឹងមិនឲ្យរាស្ត្ររបស់ទ្រង់មានសេចក្តីជូរចត់មួយដំណាក់ណា ដែលលើសពីអ្វីដែលចាំបាច់ឡើយ។

ង) សេចក្តីជំនឿរបស់គាត់បានជួយគាត់ឲ្យយល់ពីស្ថានភាពពិតដែលមនុស្សកំពុងតែស្ថិតក្នុង។ គាត់បានដឹងថា ភាពឧត្តុង្គឧត្តមនៅក្នុងសង្គមមនុស្សគឺបណ្តោះអាសន្ន។ គាត់បានដឹងថា មានរង្វាន់មួយនៅឯនគរស្ថានសួគ៌ សម្រាប់អ្នកជឿដែលស្តាប់បង្គាប់ដែលច្រើនលើសជាងទ្រព្យសម្បត្តិនៃប្រទេសអេហ្ស៊ីបសន្ធឹកណាស់។ គាត់បានដឹងថា ការល្បងល និងការឈឺចាប់ អាចជាមធ្យោបាយមួយសម្រាប់បង្ហើកដល់ពួកអ្នកជឿខាងឯជីវិតព្រលឹងវិញ្ញាណ។ គាត់បានដឹងថា ការពិតទៅពួកអ៊ីស្រាអែលជារាស្ត្រនៃជំរើសរបស់ព្រះ។

តើគាត់មានអាកប្បកិរិយាបែបនោះ មិនត្រឹមត្រូវទេឬ? ឈ្មោះបុត្ររបស់ផារ៉ោន បានរលាយបាត់បង់។ ទីក្រុងនៃដំណាក់របស់ស្តេចផារ៉ោនមិនបានគេស្គាល់ទៀត ហើយទ្រព្យសម្បត្តិនៃប្រទេសអេហ្ស៊ីបក៏មិននៅទៀតដែរ ប៉ុន្តែឈ្មោះរបស់លោក ម៉ូសេ នៅតែគេស្គាល់ពេលណាគេអានព្រះគម្ពីរ។ គាត់ជាគំរូដ៏អស្ចារ្យមួយនៃការពិតដែលអស់អ្នកណាដែលរស់នៅដោយសារសេចក្តីជំនឿនឹងបានទទួលព្រះពរ!

## ៩. តើអ្វីទៅជាមេរៀនពិតប្រាកដ ដែលយើងអាចរៀនពីគំរូរបស់លោក ម៉ូសេ?

ក) ប្រសិនបើអ្នកចង់ធ្វើជាគ្រីស្ទានពិតប្រាកដ អ្នកត្រូវជ្រើសរើសផ្លូវរបស់ព្រះ មិនមែនជាផ្លូវរបស់លោកិយទេ។ អ្នកត្រូវតែត្រៀមខ្លួនជាស្រេចដើម្បីទទួលយកការលំបាក ហើយបដិសេធការដែលងាយនិងស្រណុកសុខស្រួល ដែលមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះវិញ។ លោកិយនៅសម័យនេះដូចជាលោកិយនៅសម័យលោក ម៉ូសេដែរ គឺចិត្តរបស់មនុស្សនៅតែរឹងរូសប្រឆាំងនឹងព្រះ ហើយរាស្ត្ររបស់ព្រះនៅតែគេស្អប់ខ្ពើម។ សំនួរដែលសំខាន់គឺតើអ្នកចង់បានសេចក្តីសង្គ្រោះដែរឬទេ? ដូច្នេះអ្នកត្រូវចងចាំថា អ្នកត្រូវជ្រើសរើសអ្នកណា ដែលអ្នកនឹងបម្រើ។ អ្នកត្រូវតែចាកចេញពីពួកកូននៃលោកិយនេះ។ អ្នកមិនអាចបម្រើព្រះជាម្ចាស់ផង ហើយលោកិយផងបានទេ។

តើអ្នកកំពុងតែធ្វើការលះបង់យ៉ាងដូច្នោះដែរឬទេ? តើជំនឿរបស់អ្នកត្រូវអោយអ្នកចំណាយអ្វីម្យ៉ាងដែរឬទេ? តើអ្នកចង់បោះបង់ចោលនូវអ្វីដែលរារាំងអ្នកពីព្រះជាម្ចាស់ដែរឬទេ? តើមានអ្វីមួយនៅក្នុងផ្លូវជីវិតរបស់អ្នកដែលប្រឆាំងនឹងជំនឿរបស់អ្នកឬទេ? ឬអ្នកបានដុសខាត់កែច្នៃអ្វីៗនៅក្នុងជំនឿរបស់អ្នកឲ្យបានសមទៅនឹងផ្លូវដែលអ្នករស់នៅដែរឬទេ? ចូរស្វែងរក ហើយពិនិត្យមើលចុះ!

ខ) មានការមួយដែលជួយអ្នកក្នុងការជ្រើសរើសព្រះជាម្ចាស់ជំនួសលោកិយនេះ គឺជាសេចក្តីជំនឿ។ ជំនឿមួយដែលត្រូវរស់នៅ ត្រូវតែមានគ្រឹះដ៏មានជីវិតមួយ ហើយគ្មានគ្រឹះណាផ្សេងឡើយក្រៅពីសេចក្តីជំនឿនេះ។ ត្រូវតែមានសេចក្តីជំនឿពិតមួយថា ត្រូវតែទុកចិត្តដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទោះជាព្រះបន្ទូលទាំងនោះអ្នកហាក់ដូចជាមិនសូវឯកភាពក៏ដោយ ហើយផ្លូវរបស់ទ្រង់ត្រឹមត្រូវ ក្រៅពីផ្លូវរបស់ទ្រង់សុទ្ធតែខុស។

អ្នកត្រូវដឹងថា សេចក្តីសន្យារបស់ទ្រង់វិសេសជាងទ្រព្យសម្បត្តិ ហើយអ្វីដែលមើលមិនឃើញប្រសើរជាងអ្វីដែលមើលឃើញ ហើយការសរសើរនៃព្រះប្រសើរជាងការសរសើររបស់មនុស្សប្រុសស្រី។ អ៊ីចឹង តើអ្នកនឹងសម្រេចជ្រើសរើសដូចជាលោក ម៉ូសេ ហើយចូលចិត្តព្រះជាម្ចាស់ជាជាងលោកិយឬទេ? តើលោក ណូអេ លោក អ័ប្រាហាំ នាងរស់ និងលោក ដានីយ៉ែល សុទ្ធតែបានធ្វើនិងប្រព្រឹត្តិយ៉ាងនោះ ពីព្រោះពួកគេបានជឿព្រះជាម្ចាស់ដូចជាលោក ម៉ូសេដែរ។

គ) ហេតុផលដែលមនុស្សជាច្រើនជាមនុស្សទមិឡល្មើស និងជាមនុស្សស្រើបស្រាលតាមលោកិយ គឺពីព្រោះតែពួកគេខ្វះជំនឿ។ ពួកគេមិនគិតថា អ្វីដែលព្រះជាម្ចាស់មានបន្ទូលជាការពិតនោះទេ។ មានមនុស្សជាច្រើនហៅខ្លួនឯងជាគ្រីស្ទាន ប៉ុន្តែគេមិនដែលគិតធ្វើអ្វីដូចដែលលោក ម៉ូសេ បានធ្វើនោះទេ។

មនុស្សបែបនោះមិនដែលជឿថាមានស្ថាននរកទេ បានជាពួកគេមិនរត់ចេញពីវា។ ពួកគេមិនជឿថា មានស្ថានសួគ៌ បានជាពួកគេមិនស្វែងរកវា។ ពួកគេមិនដែលជឿពីទោសកំហុសនៃអំពើបាបឡើយ បានជាគេមិនបែរចេញពីវា។ ពួកគេមិនដែលជឿថា ពួកគេត្រូវការព្រះគ្រីស្ទទេ បានជាគេមិនទុកចិត្តទ្រង់។ ពួកគេមិនមានការជឿជាក់នៅក្នុងព្រះជាម្ចាស់ទេ បានជាពួកគេមិនធ្វើអ្វីសោះ។ សេចក្តីជំនឿដែលមិនមានឥទ្ធិពលលើរបៀបនៃការរស់នៅ មិនមែនជាសេចក្តីជំនឿពិតប្រាកដទេ។

ឃ) អាថ៌កំបាំងនៃការធ្វើកិច្ចការដ៏ធំសម្រាប់ព្រះជាម្ចាស់ គឺជាការដែលយើងត្រូវមានសេចក្តីជំនឿ។ នៅក្នុងការដើរជាមួយព្រះជាម្ចាស់ អ្នកនឹងទៅដល់ត្រឹមដែលអ្នកជឿនោះឯង មិននៅឆ្ងាយជាងនេះទេ។ សេចក្តីមេត្រី ការអត់ធ្មត់ សេចក្តីក្លាហាន ការឧស្សាហ៍ និងការបម្រើព្រះ នឹងមិនធំជាងសេចក្តីជំនឿរបស់អ្នកនៅក្នុងទ្រង់ទេ។

នៅពេលដែលអ្នកអានពីជីវិតរបស់ពួកគ្រីស្ទានដ៏អស្ចារ្យនាសម័យមុន អ្នកនឹងឃើញថា សេចក្តីជំនឿរបស់ពួកគេ គឺជាការជំរុញទឹកចិត្តដល់សេចក្តីបរិសុទ្ធរបស់ពួកគេ។ ពួកគេពោរពេញទៅដោយសេចក្តីអធិស្ឋាន បានជាសេចក្តីអធិស្ឋាន គឺជាសេចក្តីជំនឿដែលពួកគេនិយាយជាមួយនឹងព្រះជាម្ចាស់។ ពួកគេឧស្សាហ៍ណាស់ ពីព្រោះសេចក្តីឧស្សាហ៍ជាសេចក្តីជំនឿក្នុងការធ្វើការងារ។ ពួកគេក្លាហានណាស់ ពីព្រោះសេចក្តីក្លាហានជាសេចក្តីជំនឿក្នុងការបំពេញកាតព្វកិច្ច។ ពួកគេបរិសុទ្ធ ពីព្រោះសេចក្តីបរិសុទ្ធ ជាសេចក្តីជំនឿដែលពួកគេបង្ហាញឲ្យមើលឃើញ។

តើអ្នកចង់យល់ច្បាស់លាស់ដូចជា លោក ម៉ូសេ ដែរឬទេ ក្នុងការជ្រើសរើសព្រះជាម្ចាស់ មិនជ្រើសរើសលោកិយ? បើអ៊ីចឹង ចូរទៅហើយស្រែករកព្រះអម្ចាស់យេស៊ូវគ្រីស្ទថា ព្រះអម្ចាស់អើយសូមឲ្យសេចក្តីជំនឿរបស់ទូលបង្គំបានកើនឡើងផង! សេចក្តីជំនឿគឺជាឫសគល់នៃចរិតលក្ខណៈរបស់គ្រីស្ទាន។ ចូរឲ្យឫសរបស់អ្នកបានត្រឹមត្រូវ ហើយអ្នកនឹងបង្កើតផ្លែផ្កា។ ការរីកចម្រើនខាងឯព្រលឹងវិញ្ញាណរបស់អ្នក នឹងតែងតែអស្ចារ្យដូចសេចក្តីជំនឿរបស់អ្នកយ៉ាងដូច្នោះដែរ។ ចូរយកគំរូតាមលោក ម៉ូសេចុះ!

# ជំពូក ៩

## លោក ឡុត គឺជាការព្រមានមួយ!

*គាត់នៅបង្អែបង្អង់...*(លោកុប្បត្តិ ១៩:១៦)

ព្រះគម្ពីរជាសៀវភៅដែលបានកត់ទុកនូវការចង្អុលបង្ហាញផ្លូវសម្រាប់យើងរាល់គ្នាហើយបង្ហាញយើងពីអ្វីដែលយើងគួរយកគំរូតាម ហើយបង្ហាញពីអ្វីដែលយើងមិនគួរយកគំរូតាម។ ប្រសិនបើយើងចង់បានបរិសុទ្ធ ព្រះគម្ពីរបង្ហាញយើងពីអ្វីដែលយើងត្រូវជៀសវាង និងអ្វីដែលយើងគួរស្វែងរក។ លោក ឡុត គឺជាឧទាហរណ៍ដែលគួរជៀសវាង។ ចរិតលក្ខណៈសរុបមកពីពាក្យគឺ គាត់បង្អែបង្អង់។ ទោះបីមានទេវតាពីររូបកំពុងតែដាស់តឿនគាត់ឲ្យចេញពីទីក្រុងសូដុំមក៏ដោយ ប៉ុន្តែគាត់នៅតែបង្អែបង្អង់!

### ១. តើលោកឡុតជាមនុស្សប្រភេទណា?

ប្រសិនបើខ្ញុំមិនបញ្ជាក់យ៉ាងច្បាស់ទេ ប្រហែលមនុស្សជាច្រើននឹងនិយាយថា "ហ្អា! លោក ឡុត ជាមនុស្សអាក្រក់ ជាមនុស្សដែលមិនប្រែចិត្តគួរឲ្យអាណិត ពីព្រោះច្បាស់ណាស់គាត់បានបង្អែបង្អង់"។ ប៉ុន្តែលោក ឡុត មិនមែនជាមនុស្សប្រភេទនោះទេ។ លោក ឡុត ជាកូនពិតប្រាកដរបស់ព្រះ ជាអ្នកជឿដែលត្រូវបានរាប់ជាសុចរិតម្នាក់។ គាត់*ជាអ្នកសុចរិត...*(២ពេត្រុស ២:៧)។ គាត់មានសេចក្តី

កម្សោយនៅក្នុងចរិតលក្ខណៈរបស់គាត់ ហើយគាត់បានរងការឈឺចាប់ដោយសារពួកគេ។ ចូរយើងកុំភ្លេចថា អ្នកជឿម្នាក់អាចនឹងមានសេចក្តីកម្សោយ តែនៅតែជាគ្រីស្ទានពិតម្នាក់ដូចជាឡុតដែរ។

ក) យើងដឹងថា លោក ឡុត បានរស់នៅក្នុងទីក្រុងដ៏អាក្រក់។ *ដ្បិតអ្នកសុចរិតនោះ ដែលនៅជាមួយនឹងគេ ក៏កើតទុក្ខក្នុងចិត្តសុចរិតរបស់លោករាល់តែថ្ងៃ ដោយបានឮ ហើយឃើញការទទឹងច្បាប់ ដែលគេប្រព្រឹត្តធ្វើ* តែគាត់ផ្ទាល់មិនអាក្រក់ទេ (២ពេត្រុស ២:៨)។ ជាមនុស្សសុចរិតម្នាក់នៅក្នុងក្រុងសូដុំម អាចដោយសារតែព្រះគុណនៃព្រះ។ បើគ្មានព្រះគុណនោះ វាមិនអាចទៅរួចបានឡើយ។

ខ) ភស្តុតាងមួយទៀតចំពោះចរិតលក្ខណៈរបស់គាត់គឺថា គាត់*កើតទុក្ខក្នុងចិត្តសុចរិតរបស់លោករាល់តែថ្ងៃ ដោយបានឮ ហើយឃើញការទទឹងច្បាប់ ដែលគេប្រព្រឹត្តធ្វើ* (២ពេត្រុស ២:៨)។ គាត់សោកសង្រេង គាត់ឈឺចាប់ដោយសារតែគាត់ឃើញពីអំពើបាប។ គ្មានអ្វីនឹងរាប់ការនេះ ក្រៅពីព្រះគុណនៃព្រះឡើយ។

គ) ភស្តុតាងមួយទៀតនៃចរិតលក្ខណៈរបស់គាត់គឺថា គាត់*មានចិត្តព្រួយលំបាកដោយព្រោះកិរិយាខូចអាក្រក់របស់មនុស្សទទឹងច្បាប់ទាំងនោះ* (២ពេត្រុស ២:៧)។ គាត់មិនបានស៊ាំនឹងឃើញអំពើបាបរាល់ថ្ងៃ ហើយគាត់បានចាប់ផ្តើមមិនព្រួយបារម្ភពីវា ដូចជាមនុស្សជាច្រើនបានធ្វើនោះទេ។ ជាថ្មីម្តងទៀត ការនេះអាចយកមកពន្យល់ដោយសារតែព្រះគុណនៃព្រះជាម្ចាស់នៅក្នុងលោក ឡុត តែប៉ុណ្ណោះ។ ដូច្នេះកុំភ្លេចថា លោក ឡុត ក៏ជាកូនរបស់ព្រះជាម្ចាស់ដែរ។

**២. តើពាក្យថា *គាត់នៅបង្អែបង្អង់* ប្រាប់យើងអ្វីខ្លះពីគាត់?**

គាត់បានយល់ពីភាពអសីលធម៌របស់ប្រជាជននៅក្នុងទីក្រុងដែលគាត់បានរស់នៅនោះ។ គាត់ដឹងថា ការជំនុំជំរះដ៏អាក្រក់ជិតធ្លាក់មកលើទីក្រុងនេះហើយ។ ហើយគាត់បានដឹងថា ព្រះជាម្ចាស់គឺជាព្រះដែលតែងតែរក្សានូវព្រះបន្ទូលជានិច្ច។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ លោក ឡុត បានបង្ហាញនូវការស្ទាក់ស្ទើរ។ គាត់បានជឿថាមានគ្រោះថ្នាក់ ដ្បិតគាត់បានយកបញ្ហាមកឯអនាគតកូនប្រសាររបស់គាត់ ហើយគាត់ដាស់តឿនឲ្យពួកគេរត់ចេញ។ *ចូរក្រោកឡើងចេញពីទីនេះទៅ ពីព្រោះព្រះយេហូវ៉ាហៀបនឹងបំផ្លាញទីក្រុងចោល* (លោកុប្បត្តិ ១៩:១៤)។ តែគាត់បានបង្អែបង្អង់!

គាត់យឺតពេលដែលគាត់គួរតែលឿន គាត់ថយក្រោយពេលដែលគាត់គួរតែទៅមុខ គាត់បង្អែបង្អង់ពេលដែលគាត់គួរប្រញាប់។ មានមនុស្សជាច្រើនហាក់ដូចជាបែបហ្នឹង ខ្ញុំខ្លាចថា មានគ្រីស្ទានជាច្រើនមានលក្ខណៈដូចជាលោក ឡុត។ មានកូនពិតប្រាកដរបស់ព្រះជាម្ចាស់ជាច្រើន ដែលដឹងច្រើនជាជាងរស់នៅជាក់ស្តែង ហើយយល់លើសពីការប្រព្រឹត្តិដោយស្មោះត្រង់។ ពួកគេជឿថាមានស្ថានសួគ៌ ប៉ុន្តែហាក់ដូចជាយកចិត្តទុកដាក់បន្តិចបន្តួចចំពោះការនេះ។ ពួកគេជឿថាមានស្ថាននរក ប៉ុន្តែពួកគេខ្លាចវាតែបន្តិចបន្តួចទៅវិញ។ ពួកគេស្អប់អារក្ស ប៉ុន្តែហាក់ដូចជាវាឲ្យមកល្បួងខ្លួនឯងជាញឹកញាប់។ តើយើងគួរហៅពួកគ្រីស្ទានបែបនេះថាយ៉ាងម៉េច? ហៅថា ជាបងប្អូនរបស់ឡុត!

ក) ទាំងនេះជាប្រភេទមនុស្សដែលហាក់ដូចជាគិតថា សេចក្តីបរិសុទ្ធពិតប្រាកដគឺជាអ្វីមួយដែលពួកគេទៅមិនដល់។ គេនឹងឯកភាពថា សេចក្តីបរិសុទ្ធគឺជាអ្វីមួយគួរជាទីស្រឡាញ់។ ពួកគេចូលចិត្តអានអំពីវា ហើយនិងមើលវាក្នុងជីវិតអ្នកដទៃទៀត។ ប៉ុន្តែពួកគេហាក់ដូចជាគិតក្នុងចិត្តថា ពួកគេមិនអាចទៅដល់ ទៅវិញ។

ខ) ទាំងនេះជាប្រភេទមនុស្សដែលមានគំនិតខុសឆ្គងអំពីសេចក្ដីស្រឡាញ់ ហើយខិតខំព្យាយាមផ្គាប់ចិត្តមនុស្ស តែមិនផ្គាប់ព្រះហឫទ័យព្រះ។ ពួកគេខ្លាចថា អ្នកដទៃគិតថាខ្លួនជាមនុស្សមានចិត្តចង្អៀតចង្អល់ បានជាពួកគេព្យាយាមធ្វើអោយអ្នកដទៃពេញចិត្ត ដោយភ្លេចថាពួកគេគួរផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ជាមុន។

គ) ទាំងនេះជាប្រភេទមនុស្សដែលរុញរាពីការលះកាត់ខ្លួនឯង ហើយមិនពេញចិត្តនឹងធ្វើការលះបង់ទេ។ ពួកគេហាក់ដូចជាមិនអាចទទួលបង្គាប់របស់ព្រះជាម្ចាស់ដែលថា *ផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ* (ម៉ាថាយ ១៦:២៤)។

ឃ) ទាំងនេះជាប្រភេទមនុស្សដែលស្ទាក់ស្ទើរក្នុងភាពម៉ឺងម៉ាត់ជាប់នឹងផ្លូវរបស់ព្រះជាម្ចាស់ ហើយមានអារម្មណ៍ថា ត្រូវតែរាប់អានបន្តិចបន្តួចជាមួយផ្លូវលោកិយដែលអាចធ្វើឲ្យលោកិយបានល្អ។ ប៉ុន្តែពួកគេមិនបានធ្វើល្អចំពោះលោកិយទេ ហើយធ្វើឲ្យតែខ្លួនឯងមានគ្រោះថ្នាក់ប៉ុណ្ណោះ។ មនុស្សដែលស្ទាក់ស្ទើរមិនមែនជាមនុស្សដ៏សប្បាយរីករាយទេ!

**៣. តើហេតុផលអ្វីខ្លះដែលអាចរាប់ថាជាការស្ទាក់ស្ទើររបស់លោក ឡុត?**

គាត់បានសម្រេចចិត្តខុសតាំងពីដំបូងក្នុងជីវិតរបស់គាត់មកម្ល៉េះ។ លោក អ័ប្រាហាំបានឲ្យឡុតនូវជម្រើសនៃទីកន្លែងដែលគាត់ត្រូវតាំងលំនៅជាមួយហ្វូងសត្វរបស់គាត់។ គាត់បានជ្រើសរើសដីដែលមើលទៅល្អបំផុតសម្រាប់សត្វរបស់គាត់ ជាទឹកដីដែលនៅជិតក្រុងសូដុំម។ គាត់មិនបានសូមដល់ព្រះថាអ្វីដែលគាត់កំពុងធ្វើនោះត្រឹមត្រូវឬយ៉ាងណា ដែលជ្រើសរើសកន្លែងនោះទេ។ គាត់ជ្រើសរើសដោយពឹងលើមូលដ្ឋាននៃប្រាជ្ញាខាងលោកិយ មិនពឹងលើមូលដ្ឋាននៃសេចក្ដីជំនឿដល់ព្រះជាម្ចាស់ឡើយ។

គាត់បានសេពគប់ជាមួយពួកមនុស្សទមិឡល្មើស នៅពេលដែលគ្មានការចាំបាច់ដែលត្រូវធ្វើយ៉ាងដូច្នោះ។ គាត់*ផ្លាស់ត្រសាលគាត់ទៅត្រឹមសូដុំម* (លោកុប្បត្តិ ១៣:១២)។ ហើយក្រោយមកយើងឮថាគាត់រស់នៅក្នុងក្រុងសូដុំមតែម្តង (លោកុប្បត្តិ ១៩:១២)។ ប្រសិនបើអ្នកជ្រើសរើសខុសនៅក្នុងជីវិត ដែលជាជម្រើសមិនតាមបទគម្ពីរ ហើយតាំងលំនៅក្នុងចំណោមមនុស្សទមិឡល្មើស នោះលទ្ធផលជាក់លាក់នឹងជាការខូចខាតដល់សេចក្តីខាងព្រលឹងវិញ្ញាណរបស់យើង។ នេះគឺជាផ្លូវដ៏ប្រាកដច្បាស់បំផុត ដែលធ្វើឲ្យអារម្មណ៍របស់យើងចាត់ទុកអំពើបាបមិនសូវធ្ងន់ធ្ងរ។ ចូរប្រុងប្រយ័ត្នក្នុងការដែលសេពគប់ដោយមិនមានការចាំបាច់ជាមួយមនុស្សទមិឡល្មើស។ ចូរប្រុងប្រយ័ត្នជម្រើសរបស់ឡុត!

ក) ចូរចងចាំការនេះ នៅពេលអ្នកកំពុងជ្រើសរើសកន្លែងដើម្បីរស់នៅ។ ចូរគិតផងដែរថា តើអ្វីខ្លះដែលនឹងមានប្រយោជន៍ដល់ជីវិតខាងព្រលឹងវិញ្ញាណរបស់អ្នក។ សូមសួរខ្លួនឯងថាតើ ព្រះបន្ទូលដំណឹងល្អត្រូវបានបង្រៀនដោយស្មោះត្រង់នៅកន្លែងដែលអ្នករស់នៅដែរឬទេ។ ចូរប្រុងប្រយ័ត្នជម្រើសរបស់ឡុត!

ខ) ចូរចងចាំការនេះ នៅពេលអ្នកកំពុងជ្រើសរើសការងារ។ ការទទួលប្រាក់ខែច្រើននោះ ឬមានឱកាសឡើងឋានៈនោះ វាមិនទាន់គ្រប់គ្រាន់ទេ។ ចូរសួរខ្លួនឯងថា តើការងារនោះនឹងជាឧបសគ្គ ឬក៏ជាជំនួយដល់ជីវិតខាងព្រលឹងវិញ្ញាណ។

គ) ចូរចងចាំការនេះ នៅពេលអ្នកកំពុងមានគម្រោងរៀបអាពាហ៍ពិពាហ៍។ តើដៃគូរដែលអ្នកជ្រើសរើសជាអ្នកជឿដែរឬទេ? តើដៃគូររបស់អ្នកទាញអ្នកឲ្យកាន់តែជិតព្រះគ្រីស្ទ ឬក៏កាន់តែជិតលោកិយដ៏គ្មានជំនឿនេះ? ត្រូវតែមានអ្វីម្យ៉ាងដែលលើសពីសេចក្តីស្រឡាញ់ និងមិត្តភាព អ្វីម្យ៉ាងដែលលើសពីលទ្ធភាពដែលនឹងមានទីលំនៅដ៏មានផាសុខភាព។ "ចូរគិត" ដូចជាអ្នកនិពន្ធចំណាស់ម្នាក់បាននិយាយថា

"ចូរគិតហើយគិតទៀត មុននឹងធ្វើការសម្រេចចិត្ត"។ ចូរប្រុងប្រយ័ត្នជម្រើសរបស់ឡុត!

អ្នកអាចនឹងគិតថា ការទាំងអស់នេះនឹងមិនជាបញ្ហាធំទេ ប្រសិនបើអ្នកជាអ្នកជឿដែលត្រូវបានរាប់ជាបរិសុទ្ធហើយនោះ គឺជារាស្ត្រម្នាក់របស់ព្រះគ្រីស្ទហើយ។ ប៉ុន្តែសូមឲ្យខ្ញុំដាស់តឿនអ្នកថា ព្រលឹងវិញ្ញាណរបស់អ្នកនឹងមិនដែលចម្រើនឡើងទេ ប្រសិនបើអ្នកជ្រើសរើសមិនត្រឹមត្រូវនៅពេលចាប់ផ្ដើមជីវិតរបស់អ្នក។ អ្នកជឿពិតប្រាកដនឹងមិនដែលវិនាសខាងព្រលឹងវិញ្ញាណនោះទេ ប៉ុន្តែជីវិតខាងព្រលឹងវិញ្ញាណរបស់ពួកគេនឹងមិនធំធាត់ ប្រសិនបើអ្នកតែងតែស្ទាក់ស្ទើរបង្អែបង្អង់ នៅពេលដែលអ្នកគួរធ្វើការសម្រេចចិត្ត។

## ៩. តើអ្វីជាលទ្ធផលនៃការបង្អែបង្អង់របស់លោក ឡុត?

អ្នកខ្លះអាចនឹងនិយាយថា "ទោះជាយ៉ាងណាលោក ឡុត នៅតែបានសង្គ្រោះដដែលហ្នឹង។ គាត់បានទទួលការរាប់ជាសុចរិត។ គាត់បានទៅនគរស្ថានសួគ៌ ហើយខ្ញុំក៏មិនត្រូវការអ្វីដែលលើសពីនេះដែរ"។ ខ្ញុំចង់បង្ហាញមួយឬពីរចំណុចនៅក្នុងរឿងរ៉ាវរបស់លោក ឡុត ដែលយើងគួរគិត ហើយបន្ទាប់មកអ្នកនឹងប្រហែលជាយល់ពីមូលហេតុថាហេតុអ្វីបានជាការខុសឆ្គងដែលមនុស្សខ្លះនិយាយបែបនោះ។

ក) លោក ឡុត មិនបានធ្វើល្អអ្វីដល់មនុស្សដែលនៅក្រុងសូដុំមទេ។ គាត់បានរស់នៅទីនោះជាច្រើនឆ្នាំ។ ពិតណាស់គាត់មានឱកាសជាច្រើននិយាយពីសេចក្ដីនៃព្រះ ហើយនិងមានឱកាសព្យាយាមទាញមនុស្សចេញពីអំពើបាបរបស់ពួកគេ។ ប៉ុន្តែគាត់ហាក់ដូចជាគ្មានឥទ្ធិពលអ្វីបន្តិចសោះ។ មនុស្សនៅក្នុងក្រុងសូដុំម នៅក្រៅរបងផ្ទះរបស់ឡុត គ្មានអ្នកណាមួយសុចរិតទាល់តែសោះ។

២) លោក ឡុត មិនបានជួយសាច់ញាតិណាម្នាក់ឲ្យបានទៅនគរស្ថានសួគ៌សោះ។ យើងដឹងថា គាត់មានប្រពន្ធ និងកូនស្រីពីរនាក់។ ប៉ុន្តែច្បាស់ណាស់ថា គ្មានអ្នកណាម្នាក់បានកោតខ្លាចព្រះទាល់តែសោះ។ ហើយនៅពេលដែលគាត់បានទៅដាស់តឿនពួកអនាគតកូនប្រសារបស់គាត់ តែពួកគេបែរជាសើចចំអកដាក់គាត់ទៅវិញ។ *ពួកកូនប្រសាគាត់ស្មានថា គាត់និយាយលេងទេ* (លោកុប្បត្តិ ១៩:១៤)។ ឡុត បានបង្ហាញយើងពីអ្វីដែលអ្នកមិនជឿគិតពីអ្នកជឿដែលបង្អែបង្អង់!

ប្រពន្ធរបស់លោក ឡុត បានចាកចេញពីទីក្រុងជាមួយគាត់ ប៉ុន្តែនាងមិនបានទៅឆ្ងាយទេ។ នាងមិនមានសេចក្តីជំនឿ ជឿពីអ្វីដែលព្រះមានបន្ទូលនោះទេ ឬក៏មើលឃើញពីភាពចាំបាច់ដែលត្រូវចាកចេញឲ្យលឿននោះដែរ។ នាងមិនបានអើពើចំពោះការបង្គាប់ដ៏ច្បាស់ថាមិនឲ្យក្រឡេកមើលក្រោយទេ ហើយនាងក៏បានត្រឡប់ទៅជាបង្គោលអំបិល(លោកុប្បត្តិ១៩:១៧)។កូនស្រីរបស់លោកបានចាកចេញជាមួយគាត់ដែរ តែនៅចុងបំផុតធ្វើឲ្យគាត់បានប្រព្រឹត្តិការដ៏អាក្រក់ (លោកុប្បត្តិ ១៩:៣៣-៣៦)។ វាជាការគួរឲ្យសោកស្តាយណាស់ដែលលោកឡុតមិនមែនជាមធ្យោបាយដែលធ្វើឲ្យអ្នកណាម្នាក់រួចពីស្ថាននរក។ ខ្ញុំមិនមែនកំពុងតែលើកឡើងថាអ្នកជឿដែលបង្អែបង្អង់ នឹងមិនជាមធ្យោបាយក្នុងការនាំព្រះពរដ៏ធំមកឯលោកិយនោះទេ។ ហើយខ្ញុំក៏មិនមែនកំពុងតែលើកឡើងថា អ្នកជឿដែលមិនបង្អែបង្អង់នឹងជាមធ្យោបាយនៃការផ្លាស់ប្រែនៃគ្រួសាររបស់ពួកគេនោះដែរ។ ប៉ុន្តែខ្ញុំចង់និយាយថា វាមិនអាចទៅរួចទេ ដែលមិនឃើញការទាក់ទងមួយរវាងជម្រើសអាក្រក់ និងការស្ទាក់ស្ទើររបស់គាត់ ហើយនិងការទាក់ទងរវាងការស្ទាក់ស្ទើររបស់គាត់ និងការឥតប្រយោជន៍ខាងវិញ្ញាណរបស់គាត់ចំពោះអ្នកដទៃនោះ។

គ) យើងដឹងតិចតួចណាស់អំពីលោក ឡុត បន្ទាប់ពីការរត់គេចពីក្រុងសូដុំម។ ការអង្វរសូមទៅក្រុងសូអារ ហើយនិងការចេញដំណើររបស់គាត់ក្រោយមកទៀត ព្រមទាំងឥរិយាបថរបស់គាត់នៅក្នុងរូងភ្នំ ទាំងអស់នេះសុទ្ធតែប្រាប់ពីសេចក្តីកម្សោយនៅក្នុងព្រះគុណ។ ហើយសណ្ឋានដ៏ទាបនៃព្រលឹងវិញ្ញាណរបស់គាត់ដែលគាត់ធ្លាក់ចូល។ យើងបានដឹងពីថ្ងៃចុងក្រោយរបស់ អ័ប្រាហាំ អ៊ីសាក យ៉ាកុប យ៉ូសែប និងស្តេចដាវីឌ ប៉ុន្តែយើងមិនបានដឹងពីចុងបញ្ចប់ដ៏កំសត់របស់ឡុតទេ។ ប្រសិនបើការនោះមិនប្រាប់យើងឲ្យដឹងនៅក្នុងកណ្ឌសញ្ញាថ្មី ដែលថាគាត់ជាមនុស្សយុត្តិធម៌និងសុចរិតទេ នោះយើងប្រហែលជាសង្ស័យថា គាត់ជាគ្រីស្ទានពិតប្រាកដឬយ៉ាងណាហើយ! យើងអាចត្រឹមតែគិតថា គំរូរបស់គាត់ ព្រះវិញ្ញាណនៃព្រះជាម្ចាស់មានបំណងព្រះហឫទ័យទុកជាការដាស់តឿនមួយដល់គ្រីស្ទានទាំងអស់។ ប្រសិនបើយើងចង់ធ្វើបង្ហាញតែខាងក្រៅនៃភាពជាគ្រីស្ទានរបស់យើង ចូរយើងមិនត្រូវបង្អែបង្អង់ធ្វើការខំប្រឹងប្រែងខាងព្រលឹងវិញ្ញាណឲ្យស្មើគ្នាដែរនៅក្នុងព្រលឹងវិញ្ញាណរបស់យើងនោះទេ។

ខ្ញុំមិនចង់ផ្តល់នូវទិដ្ឋភាពដ៏គួរសោកសង្រេងមួយដល់អ្នក អំពីអ្វីដែលត្រូវឲ្យក្លាយជាគ្រីស្ទានទេ។ គោលបំណងរបស់ខ្ញុំគឺដើម្បីផ្តល់ឲ្យអ្នកនូវការដាស់តឿនដ៏គួរឲ្យរាប់អានប៉ុណ្ណោះ។ ដ្បិតយើងកំពុងតែរស់នៅក្នុងសម័យមួយដែលជំនឿដ៏បង្អែបង្អង់ដូចលោក ឡុតកំពុងតែកើតឡើងទៅជាការធម្មតា។ អាចទៅរួចដែលធ្វើកិច្ចការជាច្រើនខាងជំនឿ តែតម្រូវឲ្យមានការលះបង់តែបន្តិចបន្តួច ឬក៏គ្មានការលះបង់សោះគឺពួកគេមិនពាក់ព័ន្ធអ្វីទាំងអស់ជាមួយនឹងឈើឆ្កាង។ ប៉ុន្តែដើម្បីដើរយ៉ាងជិតស្និតជាមួយនឹងព្រះ ដើម្បីយកចិត្តទុកដាក់ពិតប្រាកដនឹងសេចក្តីខាងព្រលឹងវិញ្ញាណ គឺត្រូវពោរពេញដោយសេចក្តីអធិស្ឋាន មិនអាត្មានិយម ស្ងៀមស្ងាត់ ងាយគាប់ចិត្ត

មានសេចក្តីស្រឡាញ់ អត់ធ្មត់ហើយស្លូតបូត ការទាំងអស់នេះនៅតែជាសេចក្តីកម្រ នៅឡើយទេ! ដូច្នេះ ខ្ញុំចង់ដាស់តឿនលោកអ្នកថា មិនត្រូវធ្វើអ្វីដែលមិនអាចធ្វើបាននោះទេ គឺបម្រើព្រះគ្រីស្ទផង និងចំណង់ចំណូលចិត្តខាងលោកិយផងនៅពេលតែមួយបានទេ។ តើអ្នកចង់ដឹងពីអ្វីដែលសម័យរបស់យើងទាមទារដែរឬទេ? ការរង្គោះរង្គើនៃប្រជាជាតិ ការរំលើងឫសនៃតម្លៃចាស់ ហើយនិងការរលកទំពើកនៃគំនិតរបស់មនុស្ស តើការទាំងអស់នេះសម្តែងពីអ្វី? ពួកវាកំពុងតែស្រែកថា " ឱគ្រីស្ទានអើយ កុំឲ្យបង្អែបង្អង់ឡើយ!”។

តើអ្នកចង់ត្រៀមខ្លួនរួចជាស្រេចដើម្បីជួបព្រះគ្រីស្ទពេលទ្រង់យាងមកវិញដែរឬទេ? ទីបន្ទាល់របស់អ្នកចែងចាំង ជីវិតខាងព្រលឹងវិញ្ញាណរបស់អ្នកសកម្ម សេចក្តីក្លាហានជាគ្រីស្ទានរបស់អ្នកខ្លាំងក្លា តើការទាំងអស់នេះពាក់ព័ន្ធអ្វីខ្លះ? គឺវាពាក់ព័ន្ធនឹងការបដិសេធមិនបង្អែបង្អង់!

តើអ្នកចង់មានសេចក្តីកម្សាន្តនឹអស្ចារ្យពីជំនឿរបស់អ្នកដែរឬទេ? ចូរមានទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធជាមួយនឹងវិញ្ញាណរបស់អ្នក ដើម្បីឲ្យដឹងប្រាកដថា អ្នកបានជឿហើយ អ្នកមិនមែនជាគ្រីស្ទានដែលក្រៀមក្រំ។ តើការនេះអាចទៅរួចដោយរបៀបណា? ចូរកុំបង្អែបង្អង់នឹងសេចក្តីខាងឯព្រលឹងវិញ្ញាណឲ្យសោះ!

តើអ្នកចង់ក្លាយជាមនុស្សមានប្រយោជន៍ចំពោះគ្រួសារ ហើយនិងអ្នកឯទៃទៀតដែលនៅជុំវិញអ្នកដែរឬទេ? ដើម្បីទាញមនុស្សប្រុសមនុស្សស្រីពីអំពើបាប ដើម្បីឲ្យជំនឿរបស់អ្នកកាន់តែគួរឲ្យចាប់អារម្មណ៍ ដើម្បីធ្វើឲ្យគ្រួសាររបស់អ្នកនិយាយថា "ពួកយើងនឹងទៅជាមួយដែរ" នោះអ្នកមិនត្រូវបង្អែបង្អង់នៅក្នុងការប្តេជ្ញាដើម្បីដើរតាមព្រះគ្រីស្ទឡើយ!

ចូរយើងចងចាំពីព្រលឹងនៃអ្នកដទៃ និងព្រលឹងរបស់យើងផ្ទាល់។ ប្រសិនបើយើងឃើញបងប្អូនគ្រីស្ទានណាកំពុងតែបង្អែបង្អង់ ចូរយើងលើកទឹកចិត្តពួកគេ។ ចូរយើងដាស់តឿនគ្នាទៅវិញទៅមកដោយព្រះបន្ទូលរបស់ទ្រង់៖ *តែចូរកំឡាចិត្តគ្នាទៅវិញទៅមកជារាល់ថ្ងៃវិញ ក្នុងកាលដែលនៅតែហៅថា ថ្ងៃនេះនៅឡើយ ក្រែងអ្នករាល់គ្នាណាមួយមានចិត្តរឹងរូស ដោយសេចក្ដីបញ្ឆោតរបស់អំពើបាប* (ហេព្រើរ ៣:១៣)។

# ជំពូក ១០

## ស្ត្រីម្នាក់ដែលគេត្រូវចងចាំ

*ចូរនឹកចាំពីប្រពន្ធលោកឡុត* (លូកា ១៧:៣២)។

ពាក្យនេះមានបន្ទូលដោយព្រះយេស៊ូវគ្រីស្ទ នៅពេលដែលទ្រង់កំពុងមានបន្ទូលពីការយាងមកជាលើកទីពីររបស់ទ្រង់ ហើយកំពុងពិពណ៌នាពីសណ្ឋានដ៏អាក្រក់របស់មនុស្សជាច្រើនដែលមិនបានត្រៀមខ្លួនដើម្បីទទួលទ្រង់។ ជារឿងធ្ងន់ធ្ងរ ដែលព្រះយេស៊ូវត្រូវតែមានបន្ទូលពីប្រពន្ធរបស់លោកឡុត នៅពេលដែលទ្រង់បានគិតពីព្រលឹងរបស់ពួកអ្នកដែលមិនបានត្រៀមខ្លួនជាស្រេចសម្រាប់ការយាងត្រឡប់មកវិញរបស់ទ្រង់។

អ្វីដែលព្រះយេស៊ូវមានបន្ទូលនោះគឺកាន់តែជាការដាស់តឿនថែមទៀត នៅពេលដែលយើងដឹងថា ទ្រង់មិនកំពុងតែមានបន្ទូលទៅកាន់ពួកអាចារ្យនិងពួកផារិស៊ីដែលស្អប់ទ្រង់ទេ ប៉ុន្តែទ្រង់កំពុងមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់វិញ! ចូរកត់សំគាល់ពាក្យថា "កុំធ្វើដូចជាប្រពន្ធឡុត"ឡើយ ប៉ុន្តែទ្រង់មានបន្ទូលថា "*ចូរនឹកចាំពីប្រពន្ធលោកឡុត*"។ ទ្រង់មានបន្ទូលហាក់បីដូចជាយើងកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់នៃការភ្លេចប្រធានបទនេះអ៊ីចឹង។ បន្ទូលនេះមិនគ្រាន់តែជាការរំលឹកដាស់តឿនប៉ុណ្ណោះទេ ថែមទាំងដាស់ស្មារតីខ្ជិលច្រអូសឲ្យងើបវិញផងដែរ! ខ្ញុំនឹងប្រើចំណងជើងបីដើម្បីជួយឲ្យមានគំនិតខ្លះក្នុងបញ្ហានេះ។

## ១. ឯកសិទ្ធិនៃជំនឿដែលប្រពន្ធឡុតបានរីករាយ

នៅក្នុងសម័យលោក អ័ប្រាហាំ ជំនឿពិតដែលបានសង្គ្រោះ កម្រមានណាស់។ មិនមានព្រះគម្ពីរ គ្មានព័ន្ធកិច្ច គ្មានពួកជំនុំ។ មានតែគ្រួសារមួយចំនួនប៉ុណ្ណោះដែលមានចំណេះដឹងអំពីព្រះ។ មនុស្សភាគច្រើននៃលោកិយនេះបានរស់នៅក្នុងសេចក្តីងងឹតខាងព្រលឹងវិញ្ញាណ ការមិនអើពើ ជំនឿលើភព្វសំណាង និងអំពើបាប។ ប្រៀបធៀបជាមួយពួកគេ ប្រពន្ធឡុតមានចំណុចល្អច្រើន។ គាត់មានមនុស្សដែលកោតខ្លាចព្រះជាប្តី។ នាងមានលោក អ័ប្រាហាំ ដែលជាឪពុកនៃជំនឿ ជាពូថ្លៃ។ ប្រពន្ធរបស់ឡុតគួរណាស់តែបានដឹងពីសេចក្តីជំនឿ ចំណេះដឹង និងសេចក្តីអធិស្ឋាននៃពួកស្មោះត្រង់ទាំងអស់នោះ។ ប្រហែលជានាងនៅទីនោះដែរនៅពេលដែលលោកអ័ប្រាហាំសង់អាសនានៅចន្លោះអៃយនិងបេតអែល (លោកុប្បត្តិ ១២:៨)។ នៅពេលឡុតត្រូវបានចាប់ជាចំណាប់ខ្មាំងដោយស្តេចកេដូឡោមើរ ហើយក្រោយមកលោកអ័ប្រាហាំបានរំដោះវិញ ក៏នាងនៅទីនោះ (លោកុប្បត្តិ ១៤:១២)។ នៅពេលពួកទេវតាមកក្រុងសូដុំមដើម្បីដាស់តឿនប្តីរបស់នាងឲ្យរត់ចេញ នាងក៏នៅទីនោះដែរ (លោកុប្បត្តិ ៩)។ នៅពេលពួកទេវតាបានទាញដៃពួកគ្រួសារនាងឲ្យប្រញាប់ចេញពីទីក្រុង នាងក៏នៅទីនោះ (លោកុប្បត្តិ ១៩:១៦)។

ក៏ប៉ុន្តែតើមានលទ្ធផលល្អអ្វីខ្លះពីឯកសិទ្ធិដែលនាងមានទាំងអស់នេះ? នាងអត់មានលទ្ធផលល្អអ្វីទាំងអស់! នាងបានស្លាប់ដោយមិនមានព្រះគុណ មិនមានព្រះជាម្ចាស់ មិនបានប្រែចិត្ត ហើយនិងមិនមានជំនឿ។ នៅក្នុងគ្រប់ទាំងលទ្ធភាពទាំងអស់ នាងបានធ្វើតាមតែខាងក្រៅតាមសាសនារបស់ប្តីនាងប៉ុណ្ណោះ ប៉ុន្តែនៅខាងក្នុងវិញ ចិត្តរបស់នាងខុសចំពោះព្រះនេត្រព្រះជាម្ចាស់ នាងមានតែសេចក្តី

ស្រឡាញ់ចំពោះរបស់លោកិយប៉ុណ្ណោះ។ មានការដែលត្រូវរៀនជាច្រើនពីការដែលយើងចាំពីប្រពន្ធឡុត!

ក) ការគ្រាន់តែមានឯកសិទ្ធិខាងសាសនា នឹងមិនជួយសង្គ្រោះព្រលឹងមនុស្សបានទេ ។ នេះហាក់ដូចជាសេចក្តីពិតដ៏លំបាកសម្រាប់អ្នកដែលមានអារម្មណ៍ថា ឯកសិទ្ធិខាងសាសនានឹងជួយឲ្យពួកគេក្លាយជាគ្រីស្ទានកាន់តែល្អ។ ប៉ុន្តែប្រពន្ធរបស់ឡុតបានបង្រៀនយើងថា វាតម្រូវឲ្យមានអ្វីម្យ៉ាងដែលលើសជាងឯកសិទ្ធិខាងសាសនាទៅទៀត ដើម្បីឲ្យបានសង្គ្រោះដល់ព្រលឹង។ យ៉ូអាប់ជាមេទ័ពរបស់ស្តេចដាវីឌ កេហាស៊ីជាបាវបម្រើរបស់លោក អេលីសេ ដេម៉ាស ជាគូរកនរបស់ប៉ុល យូដាស អេស្ការីយ៉ុតជាសាវករបស់ព្រះយេស៊ូវ មនុស្សទាំងអស់នេះសុទ្ធតែបានស្លាប់ក្នុងអំពើបាបរបស់ពួកគេ។ យើងត្រូវការអ្វីដែលលើសពីឯកសិទ្ធិ។ យើងត្រូវការព្រះគុណនៃព្រះវិញ្ញាណបរិសុទ្ធ។

ជាការត្រឹមត្រូវដែលឲ្យតម្លៃឯកសិទ្ធិខាងសាសនា ប៉ុន្តែយើងមិនត្រូវពឹងលើការនោះតែមួយនោះទេ។ ចូរយើងប្រើឯកសិទ្ធិដោយអរព្រះគុណ ប្រសិនបើឯកសិទ្ធិទាំងនោះបានប្រទានមកយើង។ ប្រសិនបើឯកសិទ្ធិទាំងនោះមិនធ្វើឲ្យយើងមានប្រយោជន៍ នោះវាអាចនឹងធ្វើឲ្យយើងមានគ្រោះថ្នាក់ធំទៅវិញ។ ដូចជាភ្លើងដែលធ្វើឲ្យក្រមួនរលាយ ហើយធ្វើឲ្យដីឥដ្ឋរឹង ដូចជាពន្លឺថ្ងៃដែលធ្វើឲ្យរុក្ខជាតិមួយមានជីវិតលូតលាស់ ហើយធ្វើឲ្យដើមឈើដែលស្លាប់កាន់តែស្ងួតក្រៀមក្រោះវិញ។ គ្មានអ្វីដែលធ្វើឲ្យចិត្តយើងរឹងរូស ដូចជាភាពគ្រាន់តែស្គាល់ការបរិសុទ្ធទាំងនេះនោះទេ។ យើងពិតជាត្រូវការលើសពីឯកសិទ្ធិខាងសាសនា!

ខ្ញុំសូមផ្តល់ការដាស់តឿន ដល់យុវជនយុវនារីដែលមានឪពុកម្តាយជាអ្នកគោរពប្រតិបត្តិដល់ព្រះ ជាឯកសិទ្ធិ។ អ្នកមិនអាចចូលនគរព្រះ ដោយការល្អនៃ

សាសនារបស់ឪពុកម្តាយអ្នកបានឡើយ។ អ្នកត្រូវតែមានទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តរបស់អ្នក។ អ្នកត្រូវតែមានការប្រែចិត្ត សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធផ្ទាល់ខ្លួន។

## ២. អ្វីជាអំពើបាបដែលប្រពន្ធឡុតបានប្រព្រឹត្តិ?

យើងបានអានហើយថា ឯប្រពន្ធឡុតក៏ងាកបែរមើលទៅក្រោយវិញ នោះស្រាប់តែទៅជាបង្គោលអំបិលទៅ (លោកុប្បត្តិ ១៩:២៦)។ នោះហាក់ដូចជាបាបតូចតាចមែនទេ? មនុស្សខ្លះអាចនឹងមានអារម្មណ៍យ៉ាងដូច្នេះ។ ប៉ុន្តែមានអ្វីច្រើនណាស់ ដែលលើសពីការក្រឡេកមើលនោះ។

ក) វាបង្ហាញពីចរិតលក្ខណៈពិតប្រាកដរបស់នាង។ ជាញឹកញាប់ ការបន្តិចបន្តួចបង្ហាញពីសណ្ឋាននៃចិត្តល្អជាងការធំ។ អាការៈបន្តិចបន្តួចអាចជាសញ្ញានៃជំងឺធ្ងន់។ ការក្រឡេកមើលមួយអាចបង្ហាញពីសណ្ឋាននៃចិត្តមនុស្សម្នាក់ (សូមមើលព្រះគម្ពីរម៉ាថាយ ៥:២៨)។

ខ) វាបង្ហាញពីការមិនស្តាប់បង្គាប់របស់នាង។ បង្គាប់របស់ទេវតាងាយយល់ណាស់។ កុំក្រឡេកមើលក្រោយ! ប្រពន្ធរបស់ឡុតមិនស្តាប់បង្គាប់។ នៅពេលព្រះជាម្ចាស់មានបន្ទូលដោយងាយយល់ដោយព្រះបន្ទូលទ្រង់នៅក្នុងបទគម្ពីរ នោះភារកិច្ចរបស់យើងក៏មានភាពច្បាស់លាស់ដែរ។

គ) វាបង្ហាញពីការមិនជឿដ៏មានអំនួត។ ប្រពន្ធរបស់ឡុតហាក់ដូចជាសង្ស័យថា តើព្រះជាម្ចាស់នឹងធ្វើអ្វីដែលទ្រង់បានមានបន្ទូលថាទ្រង់នឹងបំផ្លាញក្រុងសូដុំមឬយ៉ាងណា។ *បើឥតមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ* (ហេព្រើរ ១១:៦)។ នៅពេលអ្នកណាម្នាក់គិតថា គេដឹងច្បាស់ជាងព្រះ

ជាម្ចាស់ នោះព្រលឹងរបស់គេកំពុងតែស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ដ៏ធំ។ ប្រសិនបើយើងមិនអាចយល់ពីហេតុផលនៃការងារព្រះជាម្ចាស់ទេ នោះកាតព្វកិច្ចរបស់យើងគឺត្រូវតែស្ងាត់ហើយជឿ។

ឃ) វាបង្ហាញពីសេចក្តីស្រឡាញ់ដ៏អាថ៌កំបាំងមួយដល់សម្ភារៈនៃលោកិយនេះ។ នាងមិនអាចចាកចេញពីផ្ទះរបស់នាងដោយមិនងាកក្រោយនោះទេ។ សេចក្តីប្រាថ្នារបស់នាងនៅក្នុងក្រុងសូដុំម ទោះបីខ្លួននាងនៅខាងក្រៅទីក្រុងក៏ដោយ។ ភ្នែករបស់នាងបែរទៅរកកន្លែងដែលទ្រព្យសម្បត្តិរបស់នាងជានិច្ច ដូចជាត្រីវិស័យដែលចង្អុលតែទៅទិសខាងជើងយ៉ាងដូច្នោះដែរ។ *អ្នកណាដែលចូលចិត្តចង់ធ្វើជាមិត្រសំឡាញ់នឹងលោកីយ៍ នោះឈ្មោះថា បានតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ* (យ៉ាកុប ៤:៤)។ *បើអ្នកណាស្រឡាញ់លោកីយ៍ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ* (១យ៉ូហាន ២:១៥)។

ខ្ញុំជឿថា សព្វថ្ងៃនេះពួកគ្រីស្ទានត្រូវការសេចក្តីដាស់តឿនដើម្បីប្រឆាំងនឹងសេចក្តីស្រើបស្រាលខាងលោកិយដ៏ទុច្ចរិតនេះ ជាចាំបាច់ជាងសម័យណាទាំងអស់។ (លោក រ៉ាល ដែលបានទទួលមរណភាពនៅឆ្នាំ ១៩០០)។ ប្រពន្ធរបស់ឡុតមិនមែនជាអ្នកសម្លាប់គេទេ មិនមែនជាមនុស្សកំផិតទេ មិនមែនចោរទេ។ នាងហាក់ដូចជាមនុស្សដែលមានជំនឿ តែនាងបែរជាមើលក្រោយទៅវិញ! មានមនុស្សរាប់ពាន់អ្នកដែលហៅខ្លួនឯងថាជាគ្រីស្ទាន តែអ្នកទាំងនោះបែរជាអ្នករងគ្រោះចំពោះសេចក្តីស្រឡាញ់ខាងសម្ភារៈនិយមនៃលោកិយនេះទៅវិញ។ ខ្ញុំប្រាកដថា ដល់ពេលដែលយើងទាំងអស់គ្នាត្រូវចងចាំពីអំពើបាបរបស់ប្រពន្ធឡុតហើយ។

ក) ក្មេងៗក្នុងគ្រួសារអ្នកជឿជាច្រើនហាក់ដូចជាចាប់ផ្តើមបានល្អ ប៉ុន្តែនៅចុងបញ្ចប់បែរជាលែងកោតខ្លាចដល់ព្រះ! នៅក្នុងវ័យកុមារភាព ពួកគេហាក់ដូចជា

ពេញទៅដោយការកោតខ្លាចដល់ព្រះ។ ពេលក្មេងប្រុសម្នាក់បានក្លាយជាបុរសម្នាក់ គេមិនខ្វល់ខ្វាយអ្វីទាំងអស់ក្រៅពីការកម្សាន្តនិងកីឡា។ ពេលក្មេងស្រីម្នាក់បានក្លាយជាស្ត្រីម្នាក់ គេមិនខ្វល់ខ្វាយអ្វីទាំងអស់ក្រៅពីសម្លៀកបំពាក់និងមិត្តភក្តិដ៏សប្បាយរីករាយរបស់គេ។ ពួកគេប្រៀបដូចជាប្រពន្ធឡុតយ៉ាងដូច្នេះដែរ។

ខ) កំលោះក្រមុំជាច្រើនហាក់ដូចជាស្រឡាញ់សេចក្តីជំនឿនៅពេលដំបូង តែបន្ទាប់មក ម្តងបន្តិចៗ កិច្ចការនៃជីវិតនេះរុញច្រានគំនិតរបស់ពួកគេចេញពីកិច្ចការនៃជីវិតដែលត្រូវមកទៅវិញ។ ហើយមិនយូរប៉ុន្មាន ពួកគេមានអាកប្បកិរិយាដូចជាប្រពន្ធឡុតយ៉ាងដូច្នេះដែរ ។

គ) បុរសស្ត្រីជាច្រើនបានជាប់ក្នុងសេចក្តីជំនឿយ៉ាងល្អរហូតដល់កូនធំៗហើយចាកចេញទៅ ហើយបន្ទាប់មកពួកគេបែរជាដាច់ចេញពីសេចក្តីជំនឿ។ ដំបូងគេបានដើរតាមព្រះគ្រីស្ទដោយសេចក្តីឧស្សាហ៍ព្យាយាម។ ប៉ុន្តែការខូចខាតខាងព្រលឹងវិញ្ញាណបានមកលើពួកគេ នៅពេលដែលកូនរបស់ពួកគេធំឡើងហើយត្រូវចាប់ផ្តើមជីវិតជាមនុស្សពេញវ័យ។ វិញ្ញាណនៃលោកិយនេះហាក់ដូចជាចូលទៅក្នុងគ្រួសាររបស់ពួកគេ។ ពួកគេក៏បានចាប់ផ្តើមដើរតាមជំហានរបស់ប្រពន្ធឡុត។

ចូរប្រុងប្រយ័ត្នពីជំនឿដែលមានចិត្តតែពាក់កណ្តាល។ ចូរប្រុងប្រយ័ត្នក្នុងការដើរតាមព្រះគ្រីស្ទ កុំដោយព្រោះបំណងចិត្តដែលមិនសូវសំខាន់ដូចជា ដើម្បីផ្គាប់ចិត្តមិត្តភក្តិ ឬដើម្បីឲ្យបានការគោរពឡើយ។ ចូរដើរតាមទ្រង់ដោយព្រោះទ្រង់ផ្លាស់ឲ្យវិញ។ *អ្នកណាដែលដាក់ដៃកាន់នង្គ័ល ហើយងាកបែរទៅមើលក្រោយ អ្នកនោះមិនសមនឹងនគរព្រះទេ* (លូកា ៩:៦២)។

## ៣. ទណ្ឌកម្មដែលប្រពន្ធឡុតទទួលការឈឺចាប់

ព្រះគម្ពីរបានចែងថា *ប្រពន្ធរបស់ឡុតក៏ងាកបែរមើលទៅក្រោយវិញ នោះស្រាប់តែទៅជាបង្គោលអំបិលទៅ* (លោកុប្បត្តិ ១៩:២៦)។ ពីសាច់ឈាមដែលមានជីវិត នាងបានក្លាយជាបង្គោលអំបិល។ ការស្លាប់នៅក្នុងស្ថានភាពមួយដែលល្អបំផុត ហើយនូវអ្វីដែលគេអាចនឹងគិតថាជាពេលវេលាដ៏ល្អបំផុត នៅតែជាការដ៏សំខាន់មួយ។ ប៉ុន្តែការដែលស្លាប់ភ្លាមៗដោយសេចក្តីក្រោធរបស់ព្រះ ជាការស្លាប់ដែលមានទាំងមានសុខភាពល្អ និងកំលាំងពេញលេញ ការស្លាប់ដោយព្រោះសកម្មភាពនៃអំពើបាប គឺជាការមួយដ៏គួរឲ្យខ្លាចពិតប្រាកដមែន!

វាជាចុងបញ្ចប់ដ៏គ្មានសង្ឃឹមមួយដែលត្រូវមក។ មិនមានពេលវេលាសូម្បីតែសម្រាប់សេចក្តីអធិស្ឋានដ៏ខ្លីបំផុត។ ការបែបនោះគឺជាចុងបញ្ចប់របស់ប្រពន្ធឡុត។ តើយើងមិនត្រូវអើពើនឹងការដាស់តឿនអំពីទីបញ្ចប់របស់នាងទេឬអី? ចូរគិតពីមនុស្សប្រភេទនេះផ្សេងទៀតផងដែរ ដូចជា កូរេ ដាថាន អាប៊ីរ៉ាម ហូនី និងភីនាស សូល អាបាប អាប់សាឡូម បិលសាសើរ យូដាសអេស្ការីយ៉ុត អាណានាស និងសាភីរ៉ា! ពួកគេទាំងនេះត្រូវវិនាសតែមួយរំពេចដោយគ្មានឱកាសសម្រាប់នឹងធ្វើឲ្យស្ថានភាពបានល្អប្រសើរជាងមុនទេ។ នៅពេលពួកគេរស់នៅ គេបានបដិសេធព្រះបន្ទូលរបស់ព្រះ បានជាពួកគេត្រូវស្លាប់។ ពួកគេបានទៅជួបព្រះជាម្ចាស់ដោយមានគ្រប់ទាំងអំពើបាបរបស់ពួកគេនៅជាមួយ។

ក) ចូរយើងយល់ថា ព្រះគម្ពីរដដែលបានបង្រៀនថា ព្រះជាម្ចាស់ដែលមានពោរពេញទៅដោយសេចក្តីមេត្តាករុណា ទ្រង់បានចាត់ព្រះគ្រីស្ទឲ្យមកសុគតសម្រាប់មនុស្សមានបាប ហើយក៏បានបង្រៀនថា ព្រះជាម្ចាស់ស្អប់អំពើបាប។ ចេញពីនិស្ស័យរបស់ទ្រង់ ទ្រង់ត្រូវតែដាក់ទណ្ឌកម្មដល់អ្នកដែលតោងអំពើបាបហើយបានបដិសេធសេចក្តីសង្គ្រោះដែលទ្រង់បានប្រទានមក។ នៅក្នុងជំពូកដដែលបាន

ប្រកាសថា ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក ហើយក៏ប្រាប់ផងដែរថា *អ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្តីក្រោធរបស់ព្រះតែងនៅជាប់លើអ្នកនោះឯង* (យ៉ូហាន ៣:១៦, ៣៦) ។

ខ) ចូរយើងយល់ថា ភស្តុតាងលើភស្តុតាងក្នុងព្រះគម្ពីរដែលព្រះជាម្ចាស់នឹងដាក់ទណ្ឌកម្មដល់អស់អ្នកដែលមិនជឿ ហើយនឹងសំដែងសេចក្តីមេត្តាករុណាចំពោះអ្នកប្រែចិត្តវិញ។

គ) ចូរយើងយល់ថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានមានបន្ទូលយ៉ាងច្បាស់អំពីសេចក្តីពិត និងភាពអស់កល្បនៃស្ថាននរក។ គ្មានបបូរមាត់ណាបានប្រើប្រាស់ពាក្យជាច្រើនដើម្បីបង្ហាញពីភាពដ៏អាក្រក់នៃស្ថាននរក ដូចជាបបូរមាត់នៃអ្នកដែលបានមានបន្ទូលថា *មិនដែលមានអ្នកណានិយាយដូចអ្នកនោះទេ* (យ៉ូហាន ៧:៤៦)។

ឃ) ចូរយើងយល់ថា គំនិតដែលមានសេចក្តីកំសាន្តដែលព្រះគម្ពីរបានប្រទានមកយើងពីស្ថានសួគ៌មិនមានន័យពិតប្រាកដទេ ប្រសិនបើមិនមានស្ថាននរក។ ភាពអស់កល្បនៃស្ថាននរកត្រូវបានបង្រៀនយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរដូចពីភាពអស់កល្បនៃស្ថានសួគ៌ដែរ។ នៅពេលណាដែលគេនិយាយថា ស្ថាននរកមិនមានភាពអស់កល្ប នោះអ្នកក៏អាចនិយាយថាស្ថានសួគ៌និងព្រះជាម្ចាស់ក៏មិនមានភាពអស់កល្បដែរ។ ពាក្យដដែលជាភាសាក្រិកដែលគេប្រើនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដើម្បីបង្ហាញពីភាពអស់កល្បជានិច្ចនៃសេចក្តីទាំងពីរនេះ។

ប្រសិនបើអ្នកចង់ក្លាយជាគ្រីស្ទានដែលមានសុខភាពល្អនិងបរិសុទ្ធម្នាក់ ។ ខ្ញុំសូមឲ្យអ្នករក្សាសេចក្តីពិតអំពីភាពពិតប្រាកដនៃស្ថាននរកនៅក្នុងគំនិតរបស់អ្នក ។ ខ្ញុំសូមឲ្យអ្នកជៀសវាងនូវព័ន្ធកិច្ចទាំងឡាយណាដែលមិនបង្រៀនពីសេចក្តីពិតអំពីភាពអស់កល្បនៃស្ថាននរកឲ្យបានច្បាស់លាស់។ ខ្ញុំសូមឲ្យអ្នកពិចារណាឲ្យបានញឹ

កញ្ជាប់ពីអ្វីដែលជាចុងបញ្ចប់របស់អ្នក។ តើវាជាចុងបញ្ចប់ដែលគ្មានសង្ឃឹមដូចជាចុងបញ្ចប់របស់ប្រពន្ធឡុតឬ? ចូរឲ្យខ្ញុំទាញសេចក្តីសន្និដ្ឋានដោយសួរសំនួរខ្លះដើម្បីជួយឲ្យអ្នកគិតអំពីប្រធានបទនេះ ។

១) តើអ្នកធ្វេសប្រហែសចំពោះការយាងមកវិញជាលើកទីពីររបស់ព្រះគ្រីស្ទឬ? ពួកក្រុងសូដុំមបានធ្វេសប្រហែសចំពោះការដាស់តឿនពីព្រះជាម្ចាស់ដែលថាទីក្រុងរបស់ពួកគេនឹងត្រូវបំផ្លាញ។

២) តើអ្នកក្តៅមិនក្តៅត្រជាក់មិនត្រជាក់ និងត្រជាក់ចំពោះសេចក្តីជំនឿរបស់អ្នកឬ? តើអ្នកកំពុងតែស្ទាក់ស្ទើររវាងសេចក្តីស្រឡាញ់របស់លោកិយ និងសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទឬ?

៣) តើអ្នកកំពុងស្រឡាញ់អំពើបាបខ្លះដោយសម្ងាត់ដែលមិនអាចបញ្ឈប់បានឬ? តើអ្នកកំពុងគិតថាបាប"តូច" មិនសូវសំខាន់ឬ?

៤) តើអ្នកកំពុងតែពឹងលើការដែលមានឯកសិទ្ធិខ្លះខាងជំនឿឬ? តើអ្នកកំពុងទុកចិត្តនឹងចំណេះដឹងខាងជំនឿឬ?

៥) តើអ្នកកំពុងស្មានថាអ្នកនឹងមានពេលក្នុងការប្រែចិត្តនៅពេលក្រោយក្នុងជីវិតរបស់អ្នកឬ? ចូរចាំពីប្រពន្ធឡុតចុះ!

សូមព្រះបន្ទូលនៃព្រះគ្រីស្ទទាំងនេះបានប៉ះពាល់យើងយ៉ាងជ្រាលជ្រៅ។ សូមឲ្យព្រះបន្ទូលទាំងនេះធ្វើឲ្យយើងកាន់តែដើរលឿនឡើងៗ នៅពេលយើងកំពុងរាថយ ហើយសូមឲ្យព្រះបន្ទូលទាំងនោះកម្តៅយើងនៅពេលយើងកំពុងតែត្រជាក់ ។

# ជំពូក ១១

## ព្រះចេស្ដាដ៏អស្ចារ្យរបស់ព្រះគ្រីស្ទ

*រីឯចោរកំណាចម្នាក់ដែលជាប់ព្យួរ វាប្រមាថមើលងាយដល់ទ្រង់ថា បើឯងជាព្រះគ្រីស្ទពិត នោះចូរជួយសង្គ្រោះខ្លួនឯង ហើយនិងយើងផង ប៉ុន្តែ ម្នាក់ទៀតឆ្លើយបន្ទោសវាថា តើឯងមិនខ្លាចព្រះទេឬអី ដ្បិតឯងក៏ជាប់ទោសដូចគ្នា គេធ្វើទោសយើងត្រូវហើយ ដ្បិតយើងត្រូវទោសចំពោះការដែលយើងបានប្រព្រឹត្ត ប៉ុន្តែ ព្រះអង្គនេះមិនបានធ្វើខុសអ្វីសោះ រួចអ្នកនោះទូលព្រះយេស៊ូវថា ព្រះអម្ចាស់អើយ កាលណាចូលទៅក្នុងនគរទ្រង់ សូមនឹកចាំពីទូលបង្គំផង ព្រះយេស៊ូវមានព្រះបន្ទូលទៅថា ខ្ញុំប្រាប់អ្នកជាប្រាកដថា ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ* (លូកា ២៣:៣៩-៤៣)។

ខ្ញុំចង់ព្យាយាមនិយាយអ្វីមួយអំពីខទាំងនេះ ដែលបានប្រាប់យើងពីអ្នកទោសដែលបានប្រែចិត្តពីអំពើបាបរបស់គាត់នៅពេលដែលគាត់កំពុងតែជិតស្លាប់ ហើយភ្លាមនោះគាត់ត្រូវបានអត់ទោសបាបដោយសារព្រះអម្ចាស់យេស៊ូវ។ មានមេរៀនសំខាន់ខ្លះបានបង្ហាញនៅទីនេះ។

## ១. ការស្នេហ៍គ្រព្រះហឫទ័យនិងព្រះចេស្តារបស់ព្រះគ្រីស្ទក្នុងការសង្គ្រោះមនុស្សមានបាប

នេះជាការសំខាន់មួយដែលត្រូវរៀនពីមេរៀននេះគឺថា ព្រះយេស៊ូវគ្រីស្ទជា*អ្នកពូកែនឹងសង្គ្រោះ* (អេសាយ ៦៣:១)។ អ្នកទោសនេះជាមនុស្សអាក្រក់។ គាត់ជាមនុស្សជិតស្លាប់ម្នាក់ គាត់ជាមនុស្សដែលគ្មានជំនួយដែលបានគេដំដែកគោលជាប់នឹងឈើឆ្កាង។ ប៉ុន្តែចូរមើលពីអ្វីដែលបានកើតឡើងនៅពេលដែលគាត់បែរមករកព្រះអម្ចាស់នៅក្នុងសេចក្តីអធិស្ឋាន៖ *ព្រះអម្ចាស់អើយ កាលណាចូលទៅក្នុងនគរទ្រង់ សូមនឹកចាំពីទូលបង្គំផង*។

ព្រះអម្ចាស់របស់យើងបានឆ្លើយតបមកវិញភ្លាម! ទ្រង់មានបន្ទូលដោយក្តីសប្បុរសដល់បុរសនោះ។ ទ្រង់បានសំអាតអំពើបាបរបស់គាត់ ហើយទទួលគាត់ដោយក្តីទន់សន្តោស រាប់គាត់ជាសុចរិតដោយឥតគិតថ្លៃ ហើយប្រទានឲ្យគាត់បានចូលទៅក្នុងស្ថានបរមសុខផង។ នៅក្នុងបទគម្ពីរទាំងមូលគ្មានអ្នកណាម្នាក់ធ្លាប់បានទទួលការដឹងប្រាកដច្បាស់ ពីសេចក្តីសង្គ្រោះដ៏មានសិរីល្អដូចនេះទេ។ ហើយខ្ញុំជឿថា ព្រះអម្ចាស់យេស៊ូវ មិនដែលប្រទានភស្តុតាងពេញលេញនៃអំណាច និងការស្នេហ៍គ្រព្រះហឫទ័យរបស់ទ្រង់ក្នុងការសង្គ្រោះ ដូចជាទ្រង់បានប្រទាននៅក្នុងឱកាសនេះឡើយ។

នៅក្នុងពន្លឺនៃរឿងនេះ តើខ្ញុំមិនមានសិទ្ធិនឹងនិយាយថា ព្រះគ្រីស្ទនឹងទទួលអ្នកមានបាបណាដែលចូលមកឯទ្រង់ដោយសេចក្តីអធិស្ឋានដោយជំនឿ ទេឬអី? ប្រសិនបើធ្លាប់មានមនុស្សម្នាក់ដែលហាក់ដូចជាអាក្រក់ពេកមិនអាចទទួលសេចក្តីសង្គ្រោះបាន គឺជាបុរសនោះហើយ។ ប៉ុន្តែទ្រង់នៅតែបង្ហាញសេចក្តីមេត្តាករុណាដល់គាត់។

តើខ្ញុំមិនមានសិទ្ធិនឹងនិយាយថា សេចក្ដីសង្គ្រោះគឺដោយសារតែព្រះគុណរបស់ព្រះជាម្ចាស់ ហើយមិនមែនតាមរយៈការខិតខំប្រឹងប្រែងរបស់មនុស្ស ទេឬអី? មនុស្សមានបាបនេះមិនដែលទទួលពិធីបុណ្យជ្រមុជទឹកទេ គាត់មិនមែនជាសមាជិកពួកជំនុំណាមួយទេ គាត់មិនដែលទទួលពិធីលៀងព្រះអម្ចាស់ទេ ហើយគាត់មិនដែលធ្វើកិច្ចការអ្វីសម្រាប់ព្រះគ្រីស្ទដែរ គាត់មិនដែលដាក់ដង្វាយសម្រាប់ព័ន្ធកិច្ចដែរ ប៉ុន្តែគាត់មានសេចក្តីជំនឿ បានជាគាត់បានទទួលសេចក្តីសង្គ្រោះ។

ហេតុអ្វីបានជាគេអស់សង្ឃឹមចំពោះសេចក្តីសង្គ្រោះ ដោយយើងមានបទគម្ពីរមួយដូចជាបទគម្ពីរនេះហើយនោះ? ទោះអ្នកនៅក្នុងសណ្ឋានណាក៏ដោយ នៅតែមានសេចក្តីសង្ឃឹម។ ព្រះគ្រីស្ទអាចព្យាបាលអ្នកបាន។ ព្រះគ្រីស្ទអាចលើកអ្នកឡើងពីគ្រប់ទាំងជម្រៅទាំងអស់។ ស្ថានសួគ៌មិនដែលបិទមិនឲ្យអ្នកចូលនោះទេ។ ព្រះគ្រីស្ទនឹងនៅតែទទួលអ្នក ប្រសិនអ្នកថ្វាយវិញ្ញាណរបស់អ្នកទៅឯព្រះហស្តរបស់ទ្រង់ដោយការបន្ទាបខ្លួន។

ប្រសិនបើអ្នកមានអារម្មណ៍មិនច្បាស់ថា អំពើបាបរបស់អ្នកត្រូវបានអត់ទោសឲ្យ ចូរមកឯព្រះគ្រីស្ទហើយរស់នៅចុះ។ ព្រះយេស៊ូវពេញទៅដោយសេចក្តីមេត្តាករុណា។ ខ្ញុំសូមប្រាប់អ្នកថា ទ្រង់អាចធ្វើអ្វីៗទាំងអស់ដែលចាំបាច់ដើម្បីសង្គ្រោះព្រលឹងរបស់អ្នក។ ប្រសិនអ្នកជាអ្នកជឿ នោះកុំឲ្យយកកិត្តិយសសម្រាប់ខ្លួនឯងនោះឡើយ វាជាសិរីល្អរបស់ព្រះគ្រីស្ទទេ។ យើងមិនបានគិតឲ្យបានខ្ពស់គ្រប់គ្រាន់អំពីទ្រង់។ តើអ្នកធ្លាប់ព្យាយាមធ្វើល្អចំពោះអ្នកឯទៀតដែរឬទេ? អ៊ីចឹង ត្រូវប្រាកដថា អ្នកនឹងប្រាប់គេអំពីព្រះគ្រីស្ទ។ ចូរប្រាប់គេពីអ្វីដែលទ្រង់បានធ្វើសម្រាប់អ្នកទោសម្នាក់ដែលកំពុងតែជិតស្លាប់។ ចូរប្រាប់គេថា ទ្រង់អាចធ្វើបានដូចគ្នាសម្រាប់ពួកគេដែរ។

**២. យើងរៀនថា អ្នកខ្លះបានទទួលសេចក្តីសង្គ្រោះនៅពេលហៀបនឹងស្លាប់ ខណៈពេលអ្នកឯទៀតទៀតមិនបានទទួលសេចក្តីសង្គ្រោះ**

មានចោរពីរនាក់ត្រូវបានព្យួរជាមួយព្រះគ្រីស្ទ។ តើចោរម្នាក់ទៀតបានត្រឡប់ជាអ្វី? ហេតុអ្វីបានជាគាត់មិនបានបែរចេញពីអំពើបាបរបស់គាត់ហើយអធិស្ឋានទៅឯព្រះអម្ចាស់? គ្មានអ្វីដែលបង្ហាញថា គាត់អាក្រក់ជាងគូរកនរបស់គាត់ម្នាក់ទៀតឡើយ។ ទាំងពីរនាក់សុទ្ធតែជាមនុស្សអាក្រក់។ ទាំងពីរនាក់កំពុងតែទទួលទណ្ឌកម្មដោយយុត្តិធម៌។ ប៉ុន្តែម្នាក់ត្រូវបានទទួលយកទៅឯស្ថានបរមសុខ ហើយម្នាក់ទៀតមិនបានយកទៅទេ។

មានទាំងការព្រមាន និងសេចក្តីកំសាន្តនៅក្នុងរឿងនេះ។ ការព្រមាននេះប្រាប់ខ្ញុំថា ទោះជាអ្នកខ្លះអាចនឹងប្រែចិត្តហើយត្រឡប់ជាអ្នកជឿនៅលើគ្រែដែលដេកស្លាប់របស់ពួកគេ តែអ្នកខ្លះអាចនឹងមិនដូច្នោះទេ។ ការព្រមាននេះប្រាប់ខ្ញុំថា មនុស្សពីរនាក់អាចមានឱកាសដូចគ្នាសម្រាប់ការល្អដល់ព្រលឹងរបស់ពួកគេ ប៉ុន្តែមានតែមួយប៉ុណ្ណោះដែលអាចនឹងទទួលយកអត្ថប្រយោជន៍នៃឱកាសទាំងនេះបាន ។ ការព្រមាននេះប្រាប់ខ្ញុំថា ការប្រែចិត្តនិងសេចក្តីជំនឿជាអំណោយទានរបស់ព្រះ។ ប្រសិនបើអ្នកណាម្នាក់ជឿថាខ្លួនអាចប្រែចិត្តបាន ហើយជឿខ្លួនអាចមកឯព្រះអម្ចាស់នៅពេលណាក៏បានតាមតែចិត្ត ពួកគេអាចនឹងដឹងថា នៅទីបញ្ចប់ពួកគេចាញ់ការឆបោកដ៏ធំ។

ចូរកុំឲ្យស្មានថាព្រះជាម្ចាស់នៅតែមានសេចក្តីមេត្តាករុណាឲ្យសោះ។ ចូរកុំបន្តនៅក្នុងអំពើបាបហើយការធ្វេសប្រហែសអំពីទ្រង់ ហើយគិតថាអ្នកអាចប្រែចិត្តហើយបានទទួលសេចក្តីសង្គ្រោះនៅពេលណាក៏បានតាមតែអ្នកចូលចិត្តឲ្យ

សោះ។ ចូរកុំពន្យារពេលមួយថ្ងៃទៀតចំពោះអ្វីដែលសំខាន់ចំពោះសុខភាពខាងឯព្រលឹងវិញ្ញាណរបស់អ្នកឲ្យសោះ។ ចូរមើលពីប្រវត្តិរបស់មនុស្សនៅក្នុងព្រះគម្ពីរ។

សូលនិងដាវីឌបានរស់នៅសម័យជាមួយគ្នា ចេញពីភាពជាមនុស្សសាមញ្ញស្រដៀងគ្នានៅក្នុងជីវិត។ ហើយពួកគេទាំងពីរនាក់បានហៅមកឯឋានៈមួយដ៏ធំនៅក្នុងលោកិយ។ ពួកគេបានសោយរាជ្យអស់ជាច្រើនឆ្នាំ។ ទាំងពីរនាក់មានព័ន្ធកិច្ចរបស់ហោរាសាំយូអែលដូចគ្នា ប៉ុន្តែម្នាក់បានទទួលសេចក្តីសង្គ្រោះ តែម្នាក់ទៀតបានបាត់បង់វិញ។

តើអ្នកមានចិត្តចង់អធិស្ឋានដែរឬទេ? ត្រូវអនុវត្តវាភ្លាម! តើអ្នកចង់បម្រើព្រះគ្រីស្ទដែរឬទេ? ចូរស្វែងរកពីរបៀបធ្វើយ៉ាងដូច្នេះភ្លាម! តើអ្នកកំពុងចាប់ផ្តើមចូលចិត្តសេចក្តីពិតរបស់ព្រះគម្ពីរឬទេ? បើអ៊ីចឹង ចូររស់នៅតាមសេចក្តីពិតដែលអ្នកបានរៀននោះភ្លាមចុះ! អ្នកអាចនឹងចង់និយាយថា មិនដែលយឺតពេកក្នុងការប្រែចិត្តមិនបាននោះទេ។ ប៉ុន្តែប្រសិនបើអ្នកនៅតែពន្យារពេលក្នុងការប្រែចិត្ត អ្នកអាចនឹងមិនដែលប្រែចិត្តជារៀងរហូត។ អ្នកអាចនឹងនិយាយថា ហេតុអ្វីបានជាខ្ញុំត្រូវខ្លាច? ចោរដែលសារភាពបានទទួលសេចក្តីសង្គ្រោះ។ ប៉ុន្តែចូរក្រឡេកមើលរឿងនេះម្តងទៀត។ ចោរម្នាក់បានបាត់បង់វិញ!

## ៣. យើងរៀនថាព្រះវិញ្ញាណនាំព្រលឹងទៅឯសេចក្តីសង្គ្រោះនៅក្នុងរបៀបដូចគ្នា

ជាកំហុសមួយដែលគ្រាន់តែសំគាល់ថា ចោរដែលបានប្រែចិត្តនេះបានទទួលសេចក្តីសង្គ្រោះនៅពេលដែលគាត់ជិតស្លាប់។ មានការជាច្រើនទៀតដែលយើងត្រូវកត់សម្គាល់ ដូចជាភស្តុតាងនៃកិច្ចការរបស់ព្រះវិញ្ញាណនៅក្នុងចិត្តរបស់

មនុស្ស ។ ព្រះវិញ្ញាណនាំគាត់ទៅឯសេចក្ដីសង្គ្រោះនៅក្នុងរបៀបដូចគ្នាដែលទ្រង់នាំមនុស្សទាំងអស់ដែលកំពុងទទួលសេចក្ដីសង្គ្រោះ។

ក) ចូរសម្គាល់ពីសេចក្ដីជំនឿរបស់គាត់។ គាត់បានស្រែកហៅព្រះនាមព្រះយេស៊ូវ។ គាត់បានប្រកាសសេចក្ដីជំនឿរបស់គាត់ចំពោះនគររបស់ព្រះយេស៊ូវ។ គាត់ជឿថាព្រះយេស៊ូវគ្មានទោសទេ ប៉ុន្ដែគាត់មិនមានឱកាសរៀនការទាំងនេះដូចជាពួកសាវករបស់ទ្រង់។

តើគាត់បានបង្ហាញសេចក្ដីជំនឿបែបនេះនៅពេលណា? វាបានកើតឡើងនៅពេលដែលប្រជាជាតិទាំងមូលបានបដិសេធព្រះគ្រីស្ទនេះ! វាបានកើតឡើងនៅពេលដែលពួកសម្ដេចសង្ឃ និងពួកផារិស៊ីបានកាត់ទោសព្រះគ្រីស្ទ។ វាបានកើតឡើងនៅពេលដែលសាវកផ្ទាល់របស់ព្រះគ្រីស្ទបានរត់ចោលទ្រង់! ពិតមែនហើយសេចក្ដីជំនឿនេះជាសេចក្ដីជំនឿដ៏គួរកត់សម្គាល់។ តើអ្នកចង់ដឹងថាតើព្រះវិញ្ញាណកំពុងតែធ្វើការនៅក្នុងជីវិតរបស់អ្នកដែរឬទេ? អញ្ចឹងខ្ញុំសូមសួរថា ទោះបីជាមនុស្សដទៃទៀតបដិសេធទ្រង់ក៏ដោយ តើអ្នកមានសេចក្ដីជំនឿបែបនេះដែរឬទេ?

ខ) ចូរសម្គាល់ពីគំនិតត្រឹមត្រូវរបស់គាត់អំពីអំពើបាប។ គាត់បានទទួលស្គាល់ពីសេចក្ដីទមិឡល្មើសរបស់គាត់ហើយនិងពីភាពយុត្តិធម៌នៃការដាក់ទោស។ *គេធ្វើទោសយើងត្រូវហើយ ដ្បិតយើងត្រូវទោសចំពោះការដែលយើងបានប្រព្រឹត្ត។* គាត់មិនបានព្យាយាមដើម្បីរាប់ខ្លួនឯងជាត្រូវ ឬក៏ដោះសារសម្រាប់សេចក្ដីអាក្រក់របស់គាត់នោះទេ។ គាត់និយាយដូចជាមនុស្សដែលបន្ទាបខ្លួនដោយការចងចាំពីអំពើបាបកាលពីអតីតកាលរបស់គាត់អញ្ចឹង។ នេះគឺជាអ្វីដែលមនុស្សរបស់ព្រះជាម្ចាស់មានអារម្មណ៍។ តើអ្នកចង់ដឹងថាតើអ្នកមានព្រះវិញ្ញាណនៅក្នុងអ្នកដែរឬទេ?

ខ្ញុំសួរថា តើអ្នកមានអារម្មណ៍នឹងពីភាពពោរពេញទៅដោយអំពើបាបរបស់អ្នកដែរ ឬទេ?

គ) ចូរសម្គាល់ពីសេចក្តីស្រឡាញ់ដែលមានភាពជាបងប្អូនរបស់គាត់។ គាត់ព្យាយាមបញ្ឈប់គូកនរបស់គាត់កុំឲ្យតិះដៀលដល់ព្រះយេស៊ូវទៀត។ មិនមានសញ្ញាសម្គាល់ដ៏ច្បាស់ជាងនេះទៀតទេអំពីកិច្ចការរបស់ព្រះវិញ្ញាណនោះ។ គាត់អង្រួនយើងឲ្យចេញពីភាពអាត្មានិយមរបស់យើង ហើយធ្វើឲ្យយើងភ្ញាក់ដឹងពីព្រលឹងដែលនៅជុំវិញយើង។ នៅពេលដែលស្ត្រីសាសន៍សាម៉ារីបានក្លាយជាអ្នកជឿ (យ៉ូហាន ៤) នាងបានទុកក្អមទឹករបស់នាងចោលហើយរត់ចូលទៅក្នុងទីក្រុង ហើយនិយាយថា *ចូលមកមើល មានបុរសម្នាក់ដែលប្រាប់ខ្ញុំពីគ្រប់អំពើទាំងអស់ដែលខ្ញុំបានប្រព្រឹត្ត តើអ្នកនោះមិនមែនជាព្រះគ្រីស្ទទេឬអី?* តើអ្នកចង់ដឹងប្រាកដច្បាស់ថាតើអ្នកមានព្រះវិញ្ញាណនៅក្នុងអ្នកដែរឬទេ? អ៊ីចឹង ខ្ញុំសូមសួរថា តើអ្នកមានសេចក្តីស្រឡាញ់ចំពោះព្រលឹងដទៃទៀតយ៉ាងដូចម្តេច?

## ៤. យើងរៀនថា អ្នកជឿដល់ព្រះគ្រីស្ទនឹងនៅជាមួយព្រះអម្ចាស់នៅពេលដែលពួកគេស្លាប់ទៅ

ការនេះអ្នកអាចនឹងប្រមូលមកពីព្រះបន្ទូលរបស់ព្រះអម្ចាស់ថា *ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ*។ បន្ទាប់ពីស្លាប់ទៅ អ្នកជឿនឹងនៅជាមួយព្រះគ្រីស្ទ។ ខ្ញុំដឹងថា សុភមង្គលរបស់ពួកគេខ្វះមិនដល់អ្វីដែលនឹងត្រូវកើតឡើង នៅពេលដែលរូបកាយរបស់ពួកគេត្រូវបានប្រោសឲ្យរស់ឡើងវិញម្តងទៀត ពេលដែលព្រះយេស៊ូវបានយាងត្រឡប់មកផែនដីវិញ។ ប៉ុន្តែខ្ញុំដឹងថា ពួកគេពេញចិត្តនឹង

ការសម្រាក សេរីភាពពីការខំប្រឹងប្រែង ការឈឺចាប់និងអំពើបាប។ ពួកគេនៅជាមួយព្រះគ្រីស្ទ។

ខ្ញុំមិនអាចពិពណ៌នាថាស្ថានបរមសុខជាកន្លែងប្រភេទណានោះទេ ពីព្រោះខ្ញុំមិនអាចយល់ថាតើ វាមានលក្ខណៈយ៉ាងដូចម្ដេចនៅពេលដែលព្រលឹងបានចាកចេញពីរូបកាយ។ ប៉ុន្តែនៅពេលខ្ញុំដឹងថាព្រលឹងទាំងនោះនៅជាមួយព្រះគ្រីស្ទ នោះខ្ញុំយល់គ្រប់គ្រាន់ហើយ! ប្រសិនបើចៀមនៅជាមួយអ្នកគង្វាល អាវយវៈនៅជាមួយសិរសា កូនៗនៅជាមួយអ្នកដែលស្រឡាញ់គេហើយនោះ អ្វីគ្រប់យ៉ាងត្រូវតែល្អ អ្វីគ្រប់យ៉ាងត្រូវតែត្រឹមត្រូវ។

ប្រសិនបើអ្នកជាអ្នកជឿ ប្រសិនបើអ្នកភ័យញ័រចំពោះសេចក្ដីស្លាប់ ចូរឲ្យមានកំលាំងចិត្តដោយបទគម្ពីរត្រង់នេះចុះ។ អ្នកកំពុងតែធ្វើដំណើរទៅកាន់ស្ថានបរមសុខហើយ ហើយព្រះគ្រីស្ទនឹងនៅទីនោះ។

**៥. ជាចុងបញ្ចប់ យើងរៀនថា វាសនាដ៏អស់កល្បនៃអ្នកជឿនៅក្បែរនេះសោះ**

ព្រះអម្ចាស់របស់យើងមានបន្ទូលថា *ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ។* មិនមែននៅពេលណាមួយនៅពេលអនាគតឡើយ ប៉ុន្តែនៅថ្ងៃនេះតែម្ដង! ព្រះបន្ទូលនេះនាំវាសនាដ៏អស់កល្បមកអ្វីក៏ជិតម្ល៉េះ។ ដាវីឌបាននិយាយថា *ខ្ញុំនឹងសេចក្ដីស្លាប់នៅឃ្លាតតែមួយជំហានពីគ្នាទេ* (១សាំយ៉ូអែល ២០:៣)។ យើងអាចនឹងនិយាយថា មានតែមួយជំហានប៉ុណ្ណោះរវាងខ្លួនយើងនិងស្ថានបរមសុខ ឬក៏ស្ថាននរក។

យើងមិនដឹងរឿងនេះដូចដែលយើងគួរដឹងនោះទេ។ យើងមានទំនោរគិតថា ខ្លួនជាអ្នកជឿ ហើយសេចក្ដីស្លាប់នឹងចាប់ផ្ដើមនៅដំណើរវែងឆ្ងាយទៀត។ នោះគឺជាការខុសធ្ងន់ណាស់! នាទីដែលអ្នកជឿម្នាក់ស្លាប់ ពួកគេរស់នៅក្នុងស្ថានបរម

សុខភ្លាម។ ចូរកុំយល់ខុសឲ្យសោះ។ គ្មានគម្លាតពេលដ៏យូររវាងសេចក្តីស្លាប់និងសណ្ឋានដ៏អស់កល្បរបស់យើងនោះទេ។ នាទីដែលអ្នកជឿម្នាក់ស្លាប់ ពួកគេរស់នៅក្នុងស្ថានបរមសុខភ្លាម។ ប្រសិនបើអ្នកជាគ្រីស្ទានម្នាក់ អ្នកកំពុងនៅជិតនគរស្ថានសួគ៌ជាជាងដែលអ្នកគិត! ថ្ងៃនេះប្រសិនបើព្រះអម្ចាស់យកយើងទៅ យើងនឹងដឹងថាយើងបានទៅនៅក្នុងស្ថានបរមសុខភ្លាម។

## សេចក្តីសន្និដ្ឋាន

មានសេចក្តីលើកទឹកចិត្តនៅទីនេះសម្រាប់អ្នកមានបាបដែលមានចិត្តបន្ទាប។ ហេតុអ្វីបានជាអ្នកមិនធ្វើដូចជាចោរដែលបានប្រែចិត្តនោះទៅ? ចូរមើលពីរបៀបដែលគាត់បានស្រែកហៅព្រះអម្ចាស់យេស៊ូវ ហើយមើលពីចម្លើយដែលគាត់បានទទួលចុះ! ប៉ុន្តែប្រសិនបើអ្នកមានចិត្តអំនួតស្មានថាខ្លួនមិនមែនជាមនុស្សមានបាប នោះមានការព្រមានមួយនៅទីនេះសម្រាប់អ្នក។ ដ្បិតចោរដែលមិនបានប្រែចិត្តបានស្លាប់ដូចជាកាលដែលរស់នៅជាមនុស្សអាក្រក់យ៉ាងដូច្នេះដែរ។

តើអ្នកជាគ្រីស្ទានដែលមានតែឈ្មោះឬ? បន្ទាប់មកចូរប្រើសកម្មភាពរបស់ចោរដែលប្រែចិត្តជាតេស្តផ្ទាល់ខ្លួនមួយសម្រាប់អ្នក។ បើអ្នកឈ្លាសវៃ អ្នកនឹងធ្វើដូចជាគាត់បានធ្វើដែរ។

ប្រសិនបើមានការទុក្ខសោកចំពោះការបាត់បង់មិត្តភក្តិឬសាច់ញាតិគ្រីស្ទានម្នាក់ ចូរឲ្យបានសេចក្តីកំសាន្តចិត្តពីបទគម្ពីរនេះចុះ។ ពួកគេគ្មានអ្វីដែលល្អជាងនេះទៀតទេ! ហើយប្រសិនបើអ្នកជាគ្រីស្ទានដែលមានវ័យចំណាស់ហើយ នោះអ្នកជិតទៅដល់ផ្ទះហើយ! នៅពេលដែលស្តេចរបស់អ្នកហៅរកអ្នក នៅក្នុងនាទី

នោះសង្គ្រាមនឹងត្រូវបញ្ចប់ហើយអ្នកនឹងបាននៅជាមួយទ្រង់នៅក្នុងស្ថានបរមសុខ ។

# ជំពូក ១២

## ការស្គាល់ព្រះយេស៊ូវគ្រីស្ទ

*នោះកើតមានខ្យល់ព្យុះជាខ្លាំង ហើយរលកបោកចូលក្នុងទូក ដល់ម្លេះបានជាទូកពេញហើយ តែទ្រង់ផ្ទំលក់លើខ្នើយ នៅកន្សៃទូក ពួកសិស្សដាស់ទ្រង់ឡើងទូលថា លោកគ្រូអើយ យើងវិនាស ហើយលោកមិនរវល់ទេឬអី។ កាលតើនឡើង ទ្រង់កំហែងខ្យល់ ក៏បង្គាប់ទៅសមុទ្រថា ចូរស្ងៀមទៅ ហើយឈប់ចុះ នោះខ្យល់ក៏ស្ងប់ ហើយស្ងាត់ឈឹងសូន្យទាំងអស់ទៅ។ រួចទ្រង់មានព្រះបន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម្លេះ ម្តេចក៏គ្មានសេចក្តីជំនឿ* (ម៉ាកុស ៤:៣៧-៤០)។

ខ្ញុំចង់ឲ្យគ្រីស្ទានបានសិក្សាដំណឹងល្អទាំងបួនឲ្យបានច្រើនជាងមុន។ ខ្ញុំនិយាយរបៀបនេះពីព្រោះវាជាមធ្យោបាយតែមួយគត់ ដែលគេនឹងបានស្គាល់ព្រះយេស៊ូវ។ ជាការល្អដែលស្គាល់អំពីសេចក្តីជំនឿ និងព្រះគុណ ការរាប់ជាសុចរិតនិងការរាប់ជាបរិសុទ្ធ។ ប៉ុន្តែជាការដែលកាន់តែប្រសើរដែលយើងស្គាល់ព្រះអម្ចាស់របស់យើង ដ្បិតការស្គាល់ទ្រង់នាំទៅកាន់សេចក្តីបរិសុទ្ធ។ តើមធ្យោបាយប្រសើរណា ដែលឲ្យបានស្គាល់ទ្រង់ជាជាងសិក្សាសំណេរទាំងបួនអំពីព្រះជន្មរបស់ទ្រង់ដែលមាននៅក្នុងគម្ពីរដំណឹងល្អទាំងនេះនោះ?

ព្រះគ្រីស្ទជាថ្មដារខាងព្រលឹងវិញ្ញាណ ហើយយើងតាំងលំនៅលើថ្មដារនោះ។ ព្រះគ្រីស្ទជាដើមទំពាំងបាយជូរដ៏ពិតដែលយើងអាចស្រូបជីវជាតិសម្រាប់

ការធំធាត់ខាងព្រលឹងវិញ្ញាណរបស់យើង។ ព្រះគ្រីស្ទគឺជាបងប្រុសរបស់យើងដែលយើងអាចសូមក្តីអាណិតអាសូរនៅពេលត្រូវការ។ ព្រះគ្រីស្ទជាអ្នកសម្រួបសម្រួមរបស់យើងដែលទ្រង់ថ្វាយសេចក្តីអធិស្ឋានរបស់យើងនៅចំពោះព្រះ ។ ព្រះគ្រីស្ទគឺជាស្តេចដែលអ្នកជឿចំណាយពេលដ៏អស់កល្បនៅក្នុងនគររបស់ទ្រង់។ ដូច្នេះចូរយើងមើលអ្វីដែលអាចយល់អំពីទ្រង់ ពីរឿងរ៉ាវតាំងពីដើមនៃជំពូកនេះ។

## ១. យើងយល់ថា ការដើរតាមព្រះគ្រីស្ទនឹងមិនការពារយើងពីបញ្ហាប្រចាំថ្ងៃដោយស្វ័យប្រវត្តិនោះទេ

ពួកសាវកបានស្ថិតនៅក្នុងការថប់អារម្មណ៍ដ៏ខ្លាំង។ ទោះបីជាពួកគេជាសិស្សជ្រើសរើសដែលមានគ្នាតិចក៏ដោយ ព្រះយេស៊ូវអនុញ្ញាតឲ្យពួកគេមានការភ័យខ្លាច (នៅពេលដែលពួកសង្ឃ ពួកអាចារ្យ នឹងពួកផារិស៊ីមិនជឿដល់ទ្រង់)។ ប្រហែលជាពួកគេបានគិតថា ការបម្រើព្រះគ្រីស្ទមានន័យថា ពួកគេនឹងគេចចេញពីបញ្ហាធម្មតានៃជីវិតនេះបាន។ ប្រសិនបើទ្រង់ប្រោសជំងឺដល់អ្នកឈឺ ឲ្យចំណីដល់មនុស្សជាច្រើនដោយនំប៉័ងតែពីរបីដុំ ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ហើយនិងបណ្តេញអារក្ស ពិតណាស់ទ្រង់នឹងមិនដែលបណ្តោយឲ្យពួកសិស្សរបស់ទ្រង់ឈឺចាប់ទេ។ ប៉ុន្តែប្រសិនបើពួកគេគិតបែបនោះពួកគេពិតជាខុសហើយ។ ការបម្រើព្រះគ្រីស្ទមិនបានផ្តល់នូវការការពារអ្នកជឿមិនឲ្យមានបញ្ហាជីវិតនោះទេ។

ជាការដ៏ល្អដែលយល់ការនេះបានច្បាស់លាស់។ ខ្ញុំមានឯកសិទ្ធិជាបាវបម្រើរបស់ព្រះគ្រីស្ទម្នាក់ ហើយខ្ញុំអាចនិយាយពីអំណោយទាននៃជីវិតអស់កល្បជានិច្ចដល់បុរសស្ត្រីទាំងអស់ ឬកុមារដែលចង់មានជីវិតនោះ។ ប៉ុន្តែខ្ញុំមិនប៊ានផ្តល់ឲ្យដល់អ្នកណានូវភាពរុងរឿងនៃលោកិយនេះ ទុកជាផ្នែកមួយនៃអត្ថបទគ្រី

ស្ថានទេ។ ខ្ញុំមិនហ៊ាននិយាយពីជីវិតយើនយូរ ការរួចផុតពីការឈឺចាប់ ទ្រព្យសម្បត្តិស្តុកស្តម្ភទេ។ ខ្ញុំដឹងថាមនុស្សជាច្រើនចង់បានព្រះគ្រីស្ទនិងសុខភាពល្អ (ព្រះគ្រីស្ទនិងលុយច្រើន) ព្រះគ្រីស្ទនិងការរួចផុតពីគ្រប់ទាំងការព្រួយបារម្ភ។ ប្រសិនបើអ្នកគិតយ៉ាងដូច្នេះ អ្នកកំពុងតែខុសហើយ។ ចូរឲ្យខ្ញុំបង្ហាញអ្នកពីមូលហេតុដែលខ្ញុំនិយាយអ៊ីចឹង។

តើអ្នកអាចនឹងដឹងថាអ្នកជាគ្រីស្ទានពិតប្រាកដដោយរបៀបណា បើអ្នកគិតថាការដើរតាមព្រះគ្រីស្ទមានន័យថា អ្នកមិនដែលមានបញ្ហាសោះនោះ? តើអ្នកដឹងដោយរបៀបណាថា តើអ្នកកំពុងតែដើរតាមព្រះគ្រីស្ទដោយព្រោះទ្រង់ ឬដោយព្រោះភាពអាត្មានិយមរបស់អ្នក ប្រសិនបើការដើរតាមទ្រង់នាំឲ្យមានសុខភាពនិងទ្រព្យសម្បត្តិមែននោះ? តើកិច្ចការដ៏ធំនៃការញែកចេញជាបរិសុទ្ធនឹងបន្តនៅក្នុងអ្នកជឿដោយរបៀបណា ប្រសិនបើពួកគេមិនដែលទទួលសេចក្តីល្បងនោះ? សេចក្តីល្បងគឺជាភ្លើងតែមួយដែលបញ្ឆេះកាកសំណល់ដែលជាប់នឹងចិត្តរបស់យើង។ វាជាកាំបិតសម្រាប់ក្រៀវដែលកាត់មែកដែលស្លាប់ពីជីវិតរបស់យើងហើយធ្វើឲ្យយើងបង្កើតផលផ្លែខាងឯព្រលឹងវិញ្ញាណ។

ប្រសិនបើអ្នកចង់បម្រើព្រះគ្រីស្ទ នោះត្រូវធ្វើតាមទ្រង់។ ចូរទុកឲ្យទ្រង់សម្រេចនូវអ្វីដែលល្អបំផុតសម្រាប់អ្នក។ ត្រូវជឿប្រាកដថា ទ្រង់ធ្វើអ្វីគ្រប់យ៉ាងបានយ៉ាងល្អ។

## ២. ចូរយើងរៀនថា ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទជាមនុស្សដ៏ពិតប្រាកដហើយក៏ជាព្រះដ៏ពិតប្រាកដដែរ

យើងបានអានថា ព្រះយេស៊ូវបានផ្ទំលក់នៅលើខ្នើយ។ ទ្រង់ជាមនុស្ស ដែលចេះអស់កម្លាំងម្នាក់! បន្ទាប់ពីការអធិប្បាយនៅក្នុងទីវាលទៅកាន់ហ្វូងមនុស្ស ដ៏ធំពេញមួយថ្ងៃ ទ្រង់បានអស់កម្លាំង។ យើងដឹងថា នឹងគេងលក់ស្រួលយ៉ាងណា ហើយបន្ទាប់ពីអស់កម្លាំងនោះ ។ ហើយនៅទីនេះយើងបានអានអំពីទ្រង់ដែល បានរស់នៅក្នុងសិរីល្អជាមួយព្រះវរបិតា បានមកក្នុងផែនដីដើម្បីរស់នៅដូចជា មនុស្សម្នាក់ ។ ទ្រង់មានរូបកាយដូចជាយើងរាល់គ្នាដែរ។ ទ្រង់បានកើតពីស្ត្រីម្នាក់ ដែរ ។ ទ្រង់តែងតែឃ្លាន ស្រេក ហើយអស់កម្លាំងដែរ។ ទ្រង់បានបរិភោគ ផឹក ហើយគេងដូចជាយើងរាល់គ្នាដែរ។ ទ្រង់មានសេចក្តីសោកសង្រេងហើយយំ សោកដូចជាយើងដែរ។ ទ្រង់ជាអ្នកបង្កើតស្ថានសួគ៌ដែលបានយាងទៅមកក្នុង នាមជាមនុស្សកំសត់ម្នាក់នៅលើផែនដីនេះ!

ខ្ញុំមានសេចក្តីកំសាន្តពីសេចក្តីពិតដែលថា ព្រះយេស៊ូវជាមនុស្សគ្រប់ លក្ខណ៍ ។ ដោយព្រោះទ្រង់មិនត្រឹមតែជាសម្តេចសង្ឃដ៏ធំសម្រាប់ខ្ញុំប៉ុណ្ណោះនោះ ទេ ទ្រង់ក៏ជាសម្តេចសង្ឃដែលជ្រាបនូវអារម្មណ៍ដែលខ្ញុំមានទៀតផង។ មិនត្រឹមតែ ជាព្រះអង្គសង្គ្រោះដ៏មានព្រះចេស្តាប៉ុណ្ណោះនោះទេ ទ្រង់ថែមទាំងជាព្រះអង្គស ង្គ្រោះដ៏មានសេចក្តីមេត្តាករុណាទៀតផង។ មិនត្រឹមតែជាព្រះរាជបុត្រានៃព្រះដ៏មាន អំណាចប៉ុណ្ណោះទេ ទ្រង់ថែមទាំងជាកូនមនុស្សដែលជ្រាបគ្រប់ទាំងការទុក្ខព្រួយ របស់មនុស្សទៀតផង។

ខ្ញុំឃើញភស្តុតាងដ៏អស្ចារ្យមួយអំពីសេចក្តីស្រឡាញ់និងប្រាជ្ញាញាណ របស់ព្រះនៅក្នុងការរួមសបាភាពនៃនិស្ស័យពីរនៅក្នុងអង្គបុគ្គលរបស់ព្រះគ្រីស្ទ។ សេចក្តីស្រឡាញ់ដ៏អស្ចារ្យនៅក្នុងព្រះអង្គសង្គ្រោះរបស់យើង ដែលទ្រង់បាន ស្ម័គ្រព្រះទ័យដើម្បីទ្រាំទ្រសេចក្តីកម្សោយនិងភាពអាម៉ាស់ដោយព្រោះយើងដែល

ជាមនុស្សបះបោរ។ ប្រាជ្ញាញាណដ៏អស្ចារ្យដោយសម្របអង្គទ្រង់ដោយភាពជាមនុស្សរបស់ទ្រង់ដើម្បីធ្វើជាមិត្តសម្លាញ់ដ៏លើសអស់ទាំងមិត្តសម្លាញ់។ ទ្រង់អាចយល់គ្រប់ទាំងសេចក្តីកម្សោយនិងជំងឺរបស់ខ្ញុំហើយក៏ធ្វើគ្រប់ការទាំងអស់ដែលចាំបាច់សម្រាប់សេចក្តីសង្គ្រោះរបស់ខ្ញុំផងដែរ។ ប្រសិនបើទ្រង់គ្រាន់តែជាព្រះជាម្ចាស់របស់ខ្ញុំនោះ ខ្ញុំអាចនឹងទុកចិត្តដល់ទ្រង់ ប៉ុន្តែមិនអាចនឹងមកឯទ្រង់ដោយគ្មានការភ័យខ្លាចនោះឡើយ។ ប្រសិនបើទ្រង់គ្រាន់តែជាមនុស្ស ខ្ញុំអាចនឹងស្រឡាញ់ទ្រង់ ប៉ុន្តែនឹងមិនដែលមានអារម្មណ៍ប្រាកដថា ទ្រង់អាចធ្វើអ្វីៗដែលចាំបាច់សម្រាប់សេចក្តីសង្គ្រោះរបស់ខ្ញុំបានឡើយ។ សេចក្តីអាណិតអាសូរដ៏ជ្រាលជ្រៅបំផុត និងអំណាចព្រះចេស្តាដ៏ខ្លាំងពូកែបានជួបគ្នានៅក្នុងព្រះយេស៊ូវគ្រីស្ទ! ពិតមែនហើយអ្នកជឿគ្រប់រូបមានគ្រប់ហេតុផលដើម្បីនឹងទុកចិត្តទ្រង់។

ក) តើអ្នកជាមនុស្សក្រហើយត្រូវការមែនទេ? ព្រះយេស៊ូវក៏ជាមនុស្សយ៉ាងដូច្នេះដែរ។ ទ្រង់បានអធិប្បាយពីក្នុងទូកមួយដែលទ្រង់ខ្ចីគេ ហើយជិះសត្វលាដែលខ្ចីគេទៅកាន់ក្រុងយេរូសាឡឹម ហើយព្រមទាំងត្រូវបានបញ្ចុះនៅក្នុងផ្នូរដែលខ្ចីគេដែរ។ កញ្ជ្រោងវាមានរូងរបស់វា សត្វស្លាបវាមានសំបុករបស់វា ប៉ុន្តែទ្រង់បានមានបន្ទូលថា ទ្រង់មិនមានកន្លែងសម្រាប់នឹងកើយក្បាលផង។

ខ) តើអ្នកឯកោម្នាក់ឯងនៅក្នុងពិភពលោកនេះមែនទេ? ព្រះយេស៊ូវក៏យ៉ាងដូច្នេះដែរ។ ពីរបីនាក់ដែលដើរតាមទ្រង់ជាអ្នកនេសាទ ជាអ្នកប្រមូលពន្ធដែលគេស្អប់ ហើយនិងជាពួកមនុស្សមានបាប។ ហើយមនុស្សទាំងនេះបានរត់ចោលទ្រង់នៅពេលចុងក្រោយបំផុតរបស់ទ្រង់ទៀតផង។

គ) តើអ្នកត្រូវបានគេយល់ច្រឡំ និយាយបង្ខុស ហើយបៀតបៀនមែនទេ? ព្រះយេស៊ូវក៏អ៊ីចឹងដែរ។ គេចោទទ្រង់ថា ជាមិត្តភក្តិជាមួយនឹងមនុស្សដែលសង្គមមិន

ត្រូវការ ហើយថាជាមនុស្សអន់ចរិត។ សត្រូវរបស់ទ្រង់បាននិយាយថា ទ្រង់បានបរិភោគហើយផឹកច្រើនពេក។ ពួកគេបាននិយាយថា ទ្រង់ជាមនុស្សមានអារក្សចូល ហើយថាជាមនុស្សឆ្កួត។ ទ្រង់ត្រូវបានគេចោទទាំងបង្ខុស ហើយកាត់ទោសស្លាប់ដល់ទ្រង់ដោយអយុត្តិធម៌។

ឃ) តើអ្នកត្រូវល្បួងយ៉ាងធ្ងន់ធ្ងរមែនទេ? ព្រះយេស៊ូវក៏អ៊ីចឹងដែរ។ អ្នកអាចអានអំពីកន្លែងដែលទ្រង់ត្រូវល្បួងនៅក្នុងព្រះគម្ពីរដំណឹងល្អម៉ាថាយ ម៉ាកុស និងលូកា។ តើអ្នកធ្លាប់មានអារម្មណ៍ថា អារក្សសាតាំងប្រាប់ពីគំនិតអាក្រក់មកឯអ្នកដែរឬទេ? ព្រះយេស៊ូវក៏មានអារម្មណ៍អ៊ីចឹងដែរ។

ង) តើអ្នកធ្លាប់មានអារម្មណ៍ថាមានការឈឺចាប់ខ្លាំង និងគំនិតច្របូកច្របល់ដែរឬទេ? តើយើងធ្លាប់មានអារម្មណ៍ថា ព្រះជាម្ចាស់បានចាកចោលយើងដែរឬទេ? ព្រះយេស៊ូវក៏មានអារម្មណ៍អ៊ីចឹងដែរ។ តើអ្នកណានឹងអាចប្រាប់ពីទំហំនៃការឈឺចាប់របស់ទ្រង់នៅក្នុងសួនគេសេម៉ានីហើយនិងនៅលើឈើឆ្កាងបាន?

មិនអាចនឹងរកបានព្រះអង្គសង្គ្រោះមួយអង្គដែលស័ក្តិសមនឹងសេចក្តីត្រូវការនៃចិត្តរបស់យើងដូចជាព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើងទេ។ ចូរកុំស្តាប់ការលើកឡើងដែលថា នាងម៉ារាមាតាព្រះយេស៊ូវនិងពួកបរិសុទ្ធដទៃទៀតមានសេចក្តីអាណិតអាសូរលើសព្រះយេស៊ូវគ្រីស្ទនោះ។ ការលើកឡើងបែបនេះកើតឡើងពីការមិនយល់ដឹងអំពីអ្វីដែលព្រះគម្ពីរបានបង្រៀន និងអំពីនិស្ស័យពិតនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ អស់អ្នកណាដែលស្វែងរកសេចក្តីកំសាន្តនៅក្នុងព្រះជាម្ចាស់ឬកូនមនុស្សព្រះយេស៊ូវគ្រីស្ទ អ្នកមិនបាច់ត្រូវការសេចក្តីកំសាន្តពីពួកបរិសុទ្ធនិងពួកទេវតា ឬសូម្បីតែពីស្ត្រីព្រហ្មចារិនីម៉ារាក៏ដោយ!

**៣. ចូរយើងត្រូវយល់ដឹងថា ជួនកាលអាចនឹងមានសេចក្តីកម្សោយដ៏ធំនៃសេចក្តីជំនឿ សូម្បីតែនៅក្នុងគ្រីស្ទានដែលពិតប្រាកដក៏ដោយ**

តើយើងត្រូវការភស្តុតាងអ្វីទៀតជាជាងអាកប្បកិរិយារបស់ពួកសិស្សនៅពេលព្យុះដ៏ធំនោះ? ដោយសេចក្តីភ័យខ្លាច គេបានដាស់ព្រះយេស៊ូវ ដោយស្រែកឡើងថា "លោកគ្រូអើយ តើទ្រង់មិនខ្វល់ពីពួកយើងទេឬអី បើយើងលង់ទឹកស្លាប់នោះ?" ពួកគេមិនមានការអត់ធ្មត់ ពោលគឺពួកគេមិនអាចរង់ចាំដល់ទ្រង់តើនសិន។ ពួកគេមិនជឿ។ តើពួកគេត្រូវវិនាសដោយរបៀបណា បើមានព្រះយេស៊ូវនៅលើទូកជាមួយពួកគេហើយនោះ? ពួកគេមិនបានទុកចិត្ត។ គេស្រែកឡើងថា "តើទ្រង់មិនខ្វល់ពីពួកយើងទេឬអី?"

ពួកគេមិនគួរភ័យខ្លាចទេ។ តើពួកគេមិនបានឃើញពីគំរូនៃសេចក្តីស្រឡាញ់និងសេចក្តីសប្បុរសជាច្រើនចំពោះពួកគេទេឬអី? ការភ័យខ្លាចតែងធ្វើឲ្យយើងមានការចងចាំមិនល្អ។ ខ្ញុំប្រាកដថា មានគ្រីស្ទានជាច្រើនបានស្ថិតនៅក្នុងស្ថានភាពបែបនេះ។ ពួកគេគិតថា ពួកគេទុកចិត្តទាំងស្រុងដល់ព្រះគ្រីស្ទ។ ប៉ុន្តែនៅពេលដែលសេចក្តីល្បងលបានមកដល់ភ្លាម សេចក្តីភ័យខ្លាច ការសង្ស័យ និងសេចក្តីទុក្ខលំបាក បានមកបំបែកពួកគេដូចជាទឹកជំនន់អ៊ីចឹង។ ការពិតនោះគឺថា មិនមានគ្រីស្ទានគ្រប់លក្ខណ៍ទេឯរាបណាពួកគេកំពុងតែនៅក្នុងជីវិតនេះនៅឡើយ។ លោកអ័ប្រាហាំជាបិតានៃសេចក្តីស្មោះត្រង់។ ប៉ុន្តែដោយសារតែខ្លាចជនជាតិអេស៊ីព្ទ គាត់បានប្រាប់ឲ្យប្រពន្ធគាត់ប្រាប់គេថា ជាប្អូនស្រីរបស់គាត់វិញ។ ស្តេចដាវីឌមានជំនឿគ្រប់គ្រាន់ដើម្បីប្រឈមមុខនឹងយក្សកូលីយ៉ាត។ គាត់មានជំនឿថា ថ្ងៃមួយគាត់នឹងក្លាយជាស្តេចដែលបានចាក់ប្រេងតាំងរបស់ព្រះជាម្ចាស់នៃសាសន៍អ៊ីស្រាអែល ទោះបីស្តេចសូលតាមរកសម្លាប់គាត់ក៏ដោយ។ ប៉ុន្តែពេលមួយស្តេចដាវី

ឧងដែលនេះមានពេញដោយការភ័យខ្លាចហើយស្រែកឡើងថា *ថ្ងៃណាមួយអញនឹងស្លាប់ ដោយសារដៃសូលជាមិនខាន* (១សាំយ៉ូអែល ២៧:១)។

តើអ្នកជឿដែលមានសេចក្តីស្រឡាញ់និងការជឿជាក់បែបនេះនៅក្នុងព្រះគ្រីស្ទ មិនធ្លាប់គិតថាខ្លួននឹងមានបញ្ហាអ្វីណាមួយទេឬអី? ល្អណាស់។ ខ្ញុំរីករាយណាស់ដែលឮអ៊ីចឹង! ប៉ុន្តែខ្ញុំសូមសួរអ្នកថា តើអ្នកធ្លាប់ដាក់សេចក្តីជំនឿរបស់អ្នកចូលទៅក្នុងការល្បងលដែរឬទេ? មិនមែនជាការងាយស្រួលទេក្នុងការស្គាល់សេចក្តីកម្សោយរបស់ខ្លួនឯងដោយគ្មានការល្បងលនោះ។ ព្រះអម្ចាស់បានទុកស្តេចហេសេគាចោលដើម្បីនឹងបង្ហាញពីសេចក្តីកម្សោយរបស់គាត់ (២របាក្សត្រ ៣២:៣១)។ មានពរហើយអស់អ្នកណាដែល "ស្លៀកសេចក្តីបន្ទាបខ្លួន" នៅក្នុងបញ្ហានេះ។

ខ្ញុំសូមផ្តល់នូវពាក្យដាស់តឿននេះ ពីព្រោះខ្ញុំចង់ឲ្យគ្រីស្ទានក្មេងៗយល់ពីអ្វីដែលពួកគេនឹងស្គាល់ពីខ្លួនឯងផ្ទាល់។ ខ្ញុំចង់ការពារពួកគេមិនឲ្យមានការខកចិត្តនៅពេលដែលពួកគេប្រឆាំងនឹងសេចក្តីកម្សោយនៅក្នុងពួកគេ។ អ្នកជឿក្មេងៗត្រូវតែដឹងថា ពួកគេនឹងអាចមានសេចក្តីជំនឿនិងព្រះគុណពិតប្រាកដ ប៉ុន្តែជួនកាលពួកគេមានអារម្មណ៍ខ្លាចហើយសង្ស័យ។ ខ្ញុំចង់ឲ្យពួកគេមើលឲ្យច្បាស់ពីលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហាន ហើយដឹងថាពួកគេជាសាវ័កពិតប្រាកដ ហើយប៉ុន្តែមិនដែលពេញជាព្រះវិញ្ញាណ ដែលថាមិនខ្លាចនោះទេ។

សំខាន់បំផុតនោះ ខ្ញុំចង់ឲ្យគ្រីស្ទានដឹងពីអ្វីមួយដែលជួនកាលអ្នកឃើញនៅក្នុងអ្នកជឿឯទៃទៀត។ កុំធ្វើការវិនិច្ឆ័យលឿនពេក។ មានមាសជាច្រើនដុំដែលលាយទៅដោយដី ប៉ុន្តែតើអ្នកណាគិតថា មាសនោះគ្មានតម្លៃ? ពួកសិស្សនៅក្នុងទូកបានលះបង់អ្វីទាំងអស់ដើម្បីដើរតាមព្រះយេស៊ូវ។ ពួកគេជឿទ្រង់ហើយស្រឡាញ់

ទ្រង់។ ជាការដែលទៅរួចដែលមនុស្សម្នាក់ដែលលះបង់ទាំងអស់ដើម្បីព្រះគ្រីស្ទ ប៉ុន្តែពេលខ្លះអ្នកនោះត្រូវបានគ្រប់គ្រងដោយសេចក្តីភ័យខ្លាចនិងសេចក្តីសង្ស័យ។

## ៩. ចូរយើងយល់ដឹងពីអំណាចព្រះចេស្តារបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ

ទឹករលកបានបក់បោកលើទូកដែលព្រះយេស៊ូវកំពុងគង់។ ពួកសិស្សមានការភ័យខ្លាចជាខ្លាំង។ បន្ទាប់មកព្រះយេស៊ូវបានធ្វើការអស្ចារ្យ គឺជាការអស្ចារ្យដែលមានតែព្រះអាទិករប៉ុណ្ណោះដែលអាចធ្វើបាន! ជួនកាលអ្នកមានអារម្មណ៍ថាអ្នកកំពុងតែមានបទពិសោធន៍ជាមួយព្យុះដ៏គំហុកមួយ! អ៊ីចឹងជាការល្អណាស់ដែលយើងត្រូវមានការយល់ដឹងឲ្យបានច្បាស់លាស់អំពីអំណាចរបស់ព្រះយេស៊ូវ។ ចូរឲ្យអ្នកជឿគ្រប់រូបដឹងថា ព្រះអង្គសង្គ្រោះគឺជាព្រះដ៏មានអំណាចព្រះចេស្តាផងដែរ។ អ្នកប្រោសលោះនេះក៏ជាព្រះអម្ចាស់លើសអស់ទាំងព្រះអម្ចាស់ហើយជាស្តេចលើសអស់ទាំងស្តេចផងដែរ។ ចូរសិក្សាពីអំណាចរបស់ព្រះយេស៊ូវចុះ!

ក) ចូរសិក្សាអំណាចព្រះយេស៊ូវនៅក្នុងកិច្ចការនៃការបង្កើតរបស់ទ្រង់។ *គ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ* (យ៉ូហាន ១:៣)។ រាល់ការបង្កើត តាំងពីព្រះអាទិត្យដែលនៅទីដ៏ខ្ពស់រហូតដល់ដង្កូវដែលគួរឲ្យអាណិតដែលនៅខាងក្រោមដីសុទ្ធតែជាកិច្ចការរបស់ព្រះគ្រីស្ទ។ ទ្រង់បានបង្គាប់មក នោះអ្វីៗក៏មានឡើង។ តើនោះមិនមែនជាអំណាចព្រះចេស្តាដ៏អស្ចារ្យទេឬអី?

ខ) ចូរសិក្សាពីអំណាចព្រះយេស៊ូវនៅក្នុងកិច្ចការនៃការគ្រប់គ្រងរបស់ទ្រង់។ ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយនានា បន្តដំណើរការនៅក្នុងប្រព័ន្ធដ៏គ្រប់លក្ខណ៍ឥតខ្ចោះមួយ។ រដូវទាំងអស់បន្តពីរដូវមួយទៅរដូវមួយតាមដំណើរទៀងទាត់។ នគរនៃ

លោកិយនេះកើតឬថយ ធ្លាក់ចុះឬបាត់ទៅដោយសារតែបំណងព្រះហឫទ័យរបស់ព្រះដែលគ្រប់ការទាំងនេះមាននៅរួមគ្នាដោយសារទ្រង់ (កូល៉ុស ១:១៧)។

គ) ចូរសិក្សាពីប្រធានបទនៅក្នុងការអស្ចារ្យដែលធ្វើឡើង ដោយព្រះអម្ចាស់យេស៊ូវ។ ទ្រង់អាចប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញដោយទ្រង់មានបន្ទូលតែមួយម៉ាត់។ ទ្រង់អាចប្រទានការមើលឃើញដល់មនុស្សខ្វាក់ ការឮដល់មនុស្សដែលថ្លង់ ការនិយាយដល់មនុស្សគ ហើយជាពិសេសបំផុតទ្រង់ធ្វើឲ្យមនុស្សមានបាបឃើញ ហើយចូលទៅក្នុងនគររបស់ព្រះ! ចូរមើលម្តងទៀតទៅអត្ថបទដែលនៅខាងដើមនៃជំពូកនេះ ហើយរៀនថា ព្រះយេស៊ូវអាចមានបន្ទូលទៅកាន់ចិត្តរបស់អ្នក អ្វីក៏ដោយដែលអាចជាសេចក្តីភ័យខ្លាចនិងការថប់បារម្ភ "ចូរនៅស្ងៀមស្ងាត់ចុះ!"

ប្រសិនបើអ្នកចង់បានសេចក្តីមេត្រី ចូរស្រែកទៅឯព្រះយេស៊ូវដូចជាពួកសិស្សបានធ្វើអ៊ីចឹងដែរ។ បើសិនអ្នកមានសេចក្តីមេត្រីជាមួយនឹងព្រះជាម្ចាស់ ប៉ុន្តែចិត្តរបស់អ្នកត្រូវបានសង្កត់ដោយភាពក្រីក្រ ការឈឺចាប់ វ័យចាស់ ឬក៏មរណភាពនៃអ្នកជាទីស្រឡាញ់ ព្រះយេស៊ូវអាចមានបន្ទូលទៅកាន់ចិត្តរបស់យើងថា "ចូរនៅស្ងៀមស្ងាត់ចុះ!"។ ចូរយើងយល់ដឹងពីអំណាចព្រះចេស្តារបស់ព្រះគ្រីស្ទ។ សង្ស័យអ្វីក៏សង្ស័យទៅចុះ តែមិនត្រូវសង្ស័យពីអំណាចព្រះចេស្តារបស់ព្រះគ្រីស្ទឡើយ។ មានការមួយដែលមិនត្រូវសង្ស័យសោះ ការនោះគឺ ព្រះគ្រីស្ទ*អាចនឹងជួយសង្គ្រោះសព្វគ្រប់បាន ដល់មនុស្សទាំងអស់ដែលចូលទៅឯព្រះដោយសារទ្រង់* (ហេព្រើរ ៧:២៥)។

## ៥. ចូរយើងយល់ដឹងពីរបៀបដែលព្រះយេស៊ូវមានបន្ទូលដោយអត់ធ្មត់ជាមួយនឹងអ្នកជឿនៅក្នុងសេចក្តីកម្សោយរបស់ពួកគេ

មានសេចក្ដីក្រោធនៅក្នុងការឆ្លើយតបរបស់ព្រះអម្ចាស់ចំពោះពួកសិស្សដែលភ័យខ្លាចរបស់ទ្រង់។ *ហេតុអ្វីបានជាអ្នកខ្លាច? តើអ្នកនៅតែមិនមានជំនឿឬអី?* មិនមែនជាការស្ដីបន្ទោសខ្លាំងៗទេ គ្រាន់តែជាសំនួរធម្មតាពីរបានចោលពន្លឺដ៏ស្រស់ស្អាត លើសេចក្ដីអាណិតអាសូររបស់ព្រះអម្ចាស់។ ជាការពិតណាស់ឥរិយាបថរបស់ទ្រង់ចំពោះសិស្សរបស់ទ្រង់គួរយកមកសិក្សាឲ្យបានម៉ត់ចត់។

គ្មានពេលណាមួយដែលពួកសាវកហាក់ដូចជាយល់ទាំងស្រុង អំពីការបង្រៀនរបស់ទ្រង់ទេ។ ពាក្យដ៏ងាយយល់ហើយច្បាស់បំផុតនៃអ្វីដែលនឹងកើតឡើងចំពោះគ្រូរបស់ពួកគេ ហាក់ដូចជាចូលទៅក្នុងរបស់គំនិតគេតិចណាស់។ ជួនកាលពួកគេប្រកែកគ្នានៅក្នុងចំណោមពួកគេថា អ្នកណានឹងធំជាងគេនៅក្នុងនគរស្ថានសួគ៌។ ជួនកាលពីរនាក់ក្នុងចំណោមពួកគេសូមឲ្យភ្លើងធ្លាក់ពីលើមេឃមកលើភូមិដែលបដិសេធព្រះគ្រីស្ទ។ នៅពេលទ្រង់ត្រូវបានចាប់ខ្លួន ពួកគេបានរត់ចោលទ្រង់ ហើយពេត្រុសបានបដិសេធមិនស្គាល់ព្រះអម្ចាស់បីដង!

ដូច្នេះតើព្រះយេស៊ូវបានមានប្រតិកម្មយ៉ាងដូចម្ដេចចំពោះអាកប្បកិរិយាទាំងអស់នេះ? ទ្រង់មិនបានបន្ទោសគេថាជាមនុស្សល្ងង់ឬបដិសេធពួកគេថាកំសាកនោះទេ។ រាល់ពេល ទ្រង់បានដឹកនាំពួកគេដោយសុភាព ទ្រង់បង្រៀនពួកគេបន្តិចម្តងៗនូវអ្វីដែលពួកគេអាចចាប់បាន។ សេចក្ដីបង្រៀនរបស់ទ្រង់តែងតែមានព្រះហឫទ័យសប្បុរស សេចក្ដីកំសាន្ត និងសមហេតុផល។ មិនមានអ្វីទាំងអស់ក្រៅពីសេចក្ដីសប្បុរស សេចក្ដីសុភាពរាបសា សេចក្ដីអត់ធ្មត់ ហើយនិងសេចក្ដីស្រឡាញ់នៅក្នុងការទាក់ទងរបស់ទ្រង់ជាមួយពួកគេ។ ខ្ញុំប្រាថ្នាចង់ឲ្យលោកិយ

ទាំងមូលបានដឹងថា ព្រះអម្ចាស់ព្រះគ្រីស្ទមានពេញដោយសេចក្តីអាណិតអាសូរ។ ទ្រង់បានថែរក្សាសិស្សដែលខ្សោយជាងគេនិងសិស្សដែលខ្លាំងជាងគេ។ អ្នកជឿទាំងអស់ត្រូវបានប្រទានមកទ្រង់ដោយព្រះវរបិតា។ ដោយមិនគិតពីសេចក្តីកម្សោយរបស់ពួកគេ ទ្រង់បានសន្យានឹងនាំគ្រប់គ្នាទៅនគរស្ថានសួគ៌ដោយសុវត្ថិភាព។

ពាក្យចុងក្រោយរបស់ខ្ញុំនៅក្នុងជំពូកនេះដូចនៅជំពូកទីមួយដែរ។ ខ្ញុំចង់ឲ្យអ្នកអានរបស់ខ្ញុំយកចិត្តទុកដាក់ឲ្យបានច្រើនចំពោះដំណឹងល្អហើយនិងចំពោះផ្នែកទាំងប្រាំនៃជំពូកនេះ។ ខ្ញុំចង់ឲ្យមនុស្សទាំងអស់ស្គាល់ព្រះគ្រីស្ទ ហើយស្គាល់ទ្រង់កាន់តែច្បាស់ឡើង ដើម្បីឲ្យពួកគេបានទទួលជីវិតអស់កល្បតាមរយៈទ្រង់! សេចក្តីបរិសុទ្ធគឺជាការដែលស្គាល់ព្រះគ្រីស្ទកាន់តែច្បាស់ឡើង។

# ជំពូក ១៣

## ពួកជំនុំពិតប្រាកដរបស់ព្រះគ្រីស្ទ

*ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ* (ម៉ាថាយ ១៦:១៨)។

តើអ្នកជាសមាជិកពួកជំនុំដែលបានសង់នៅលើថ្មដាមួយដែរឬទេ? តើអ្នកជាសមាជិកម្នាក់នៃពួកជំនុំពិតតែមួយឬទេ? ទាំងនេះជាសំណួរដ៏មុឺងម៉ាត់! មានប្រាំចំណុចនៅក្នុងខនេះដែលទាមទារការយកចិត្តទុកដាក់របស់អ្នក:

១. អគារមួយ - ពួកជំនុំរបស់ខ្ញុំ

២. អ្នកសង់ម្នាក់- ព្រះគ្រីស្ទមានបន្ទូលថា "ខ្ញុំនឹងសង់ព្រះវិហាររបស់ខ្ញុំ"។

៣. គ្រឹះ - នៅលើថ្មដានេះ

៤. កន្លែងវិនាស- ទ្វារស្ថានឃុំមនុស្សស្លាប់

៥. សុវត្ថិភាពដែលត្រូវបានធានា - ទ្វារស្ថានឃុំមនុស្សស្លាប់នឹងមិនយកឈ្នះវាបានឡើយ

### ១. ការសាងសង់

ពួកជំនុំនេះ មិនមែនជាអគារមួយឡើយ។ មិនមែនព្រះវិហារអ៊ីស្ទើន មិនមែនព្រះវិហារអ៊ែងគ្លីកិន មិនមែនព្រះវិហារបាទីស្ទ ហើយក៏មិនមែនព្រះវិហាររ៉ូមដែ

រ។ នៅពេលដែលព្រះយេស៊ូវមានបន្ទូលពី "ព្រះវិហាររបស់ខ្ញុំ" គឺទ្រង់សំដៅលើអ្នកជឿពិតប្រាកដទាំងអស់នៅក្នុងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ គឺជាពួកដែលបានផ្លាស់ប្រែហើយជារាស្ត្រដ៏បរិសុទ្ធវិញ។ ទ្រង់សំដៅលើមនុស្សដែលបានកើតជាថ្មីជាអ្នកដែលបានប្រែចិត្តពីអំពើបាប ហើយកំពុងតែទទួលការរាប់ជាបរិសុទ្ធដោយព្រះវិញ្ញាណបរិសុទ្ធ។ សរុបសេចក្តីមក គ្រប់ជាតិសាសន៍ គ្រប់មនុស្ស គ្រប់ភាសា គ្រប់កុលសម្ព័ន្ធ និងគ្រប់ជាន់ថ្នាក់ បង្កើតបានជាព្រះវិហារដ៏ពិតប្រាកដរបស់ព្រះគ្រីស្ទ។

សមាជិកនៃពួកជំនុំនេះមិនថ្វាយបង្គំព្រះជាម្ចាស់នៅក្នុងរបៀបតែមួយនោះទេ ប៉ុន្តែពួកគេទាំងអស់គ្នាថ្វាយបង្គំនិងបម្រើទ្រង់ដោយសេចក្តីស្រឡាញ់ខាងវិញ្ញាណតែមួយវិញ។ ពួកគេទាំងអស់គ្នាត្រូវបានដឹកនាំដោយព្រះវិញ្ញាណតែមួយ។ ពួកគេទាំងអស់គ្នាកំពុងតែតាមស្វែងរកសេចក្តីបរិសុទ្ធតែមួយដូចគ្នា។ ក្រៅពីព្រះវិហារនេះ មិនអាចមានសេចក្តីសង្គ្រោះបានឡើយ។

## ២. អ្នកសង់

ព្រះវិហារដ៏ពិតនេះត្រូវបានថែរក្សាយ៉ាងថ្នាក់ថ្នមដោយអង្គទាំងបីនៃព្រះត្រៃឯក។ នៅក្នុងផែនការនៃសេចក្តីសង្គ្រោះដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរ យើងឃើញថា ព្រះវរបិតាជ្រើសរើស ព្រះរាជបុត្រាប្រោសលោះ ហើយព្រះវិញ្ញាណបរិសុទ្ធរាប់គ្រប់សមាជិកនៃពួកជំនុំនេះជាបរិសុទ្ធ។ ប៉ុន្តែជាព្រះគ្រីស្ទដែលត្រូវបានគេគិតថាជាអ្នកប្រោសលោះដល់ពួកជំនុំ។

អ្នកជឿត្រូវបានហៅថា ជា*ពួកដែលព្រះយេស៊ូវគ្រីស្ទទ្រង់បានហៅ* (រ៉ូម ១: ៦)។ *ព្រះរាជបុត្រានឹងប្រោសដល់អ្នកណាដែលទ្រង់សព្វព្រះហឫទ័យ* (យ៉ូហាន ៥: ២១)។ ដូច្នេះព្រះយេស៊ូវជាអ្នកសង់ពួកជំនុំ។

ក) ព្រះគ្រីស្ទ បង្ហាញពីប្រាជ្ញាញាណដ៏អស្ចារ្យ នៅក្នុងការសាងសង់ពួកជំនុំរបស់ទ្រង់។ អ្វីគ្រប់យ៉ាងត្រូវសម្រេចជោគជ័យនៅពេលសមស្ួន ហើយក្នុងរបៀបដែលត្រឹមត្រូវ។ ជួនកាលនៅក្នុងកិច្ចការសាងសង់ (ការប្រមូលសមាជិកមកឯក្រុមជំនុំរបស់ទ្រង់) កើនឡើងយ៉ាងឆាប់រហ័ស ហើយជួនកាលយឺតៗបន្តិចម្តងៗ។ ព្រះគ្រីស្ទមិនដែលមានកំហុសទេ។

ខ) ទ្រង់បង្ហាញពី ភាពល្អផាច់គេ និងសេចក្តីមេត្តាករុណាក្នុងនាមជាអ្នកសាងសង់ពួកជំនុំ។ ជួនកាលទ្រង់បានជ្រើសរើសមនុស្សដែលមិនទំនងជាងគេ ឲ្យបានក្លាយជាមនុស្សដែលបរិសុទ្ធ។ ជាញឹកញាប់ ទ្រង់យកមនុស្សដែលទមិឡល្មើសបំផុត ហើយធ្វើឲ្យពួកគេក្លាយទៅជាមនុស្សថ្មី។ ហើយជារឿយៗ ទ្រង់ប្រើបាវបម្រើដែលបន្ទាបខ្លួនជាបាវបម្រើដើម្បីរួមចំណែកក្នុងកិច្ចការរបស់ទ្រង់។

គ) ព្រះគ្រីស្ទបានប្រើអំណាចដ៏អស្ចារ្យនៅក្នុងការសាងសង់ពួកជំនុំរបស់ទ្រង់។ ទ្រង់បន្តធ្វើការងាររបស់ទ្រង់ ទោះបីជាមានការប្រឆាំង និងការបៀតបៀនដល់មនុស្សរបស់ទ្រង់ដ៏ដោយ។ ក្នុងពេលមានទុក្ខលំបាកនិងក្នុងពេលសុខសប្បាយ ទ្រង់នៅតែបន្តការងារសាងសង់របស់ទ្រង់ដោយមិនមានអ្វីរារាំងឡើយ។ យើងគួរតែអរព្រះគុណដល់ព្រះដែលការងារសាងសង់ក្រុមជំនុំរបស់ទ្រង់នៅក្នុងសាកលលោកនេះ ស្ថិតនៅក្នុងព្រះហស្តរបស់ព្រះមួយអង្គដែលមានពេញទៅដោយអំណាចព្រះចេស្តា សេចក្តីមេត្តាករុណា និងប្រាជ្ញាញាណ!

**៣. គ្រឹះ**

តើព្រះអម្ចាស់យេស៊ូវគ្រីស្ទចង់សំដៅលើអ្វី នៅពេលទ្រង់បានមានបន្ទូលពីគ្រឹះនេះ? តើទ្រង់សំដៅលើសាវកពេត្រុសដែលទ្រង់កំពុងតែមានបន្ទូលជាមួយថាជាគ្រឹះនេះឬ? ខ្ញុំគិតថាមិនយ៉ាងដូច្នេះទេ។ ប្រសិនបើទ្រង់សំដៅថា ពេត្រុសជាគ្រឹះនៃពួកជំនុំ នោះទ្រង់អាចនឹងមានបន្ទូលថា "ខ្ញុំនឹងសង់ពួកជំនុំនៅលើឯង" ហើយ។ ទ្រង់មានបន្ទូលទៀតថា "ខ្ញុំនឹងឲ្យសោអ្នក (ខ ១៩)។ ដូច្នេះគ្មានមូលហេតុដែលគួរឲ្យទ្រង់មានបន្ទូលថា ទ្រង់នឹងសង់ក្រុមជំនុំរបស់ទ្រង់លើពេត្រុសឡើយ ប្រសិនបើនោះជាអ្វីដែលទ្រង់បានមានបន្ទូលសំដៅ។

ទេ សាវកពេត្រុសមិនមែនជាបុគ្គលដែលទ្រង់ចង់សំដៅនោះទេ ប៉ុន្តែនោះជាសម្ដីដែលព្រះបណ្ដាលមក ថាព្រះអម្ចាស់ទ្រង់ជាគ្រឹះនៃពួកជំនុំវិញ *"ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់"* (ម៉ាថាយ ១៦:១៦)។ នេះជាសេចក្ដីពិតអំពីព្រះយេស៊ូវគ្រីស្ទដែលទ្រង់គឺជាថ្មដាដែលពួកជំនុំត្រូវបានសង់ពីលើ។ សមាជិកគ្រប់រូបនៃពួកជំនុំពិតរបស់ព្រះគ្រីស្ទបានជាប់ទៅនឹងគ្រឹះដែលជាព្រះគ្រីស្ទនិងអ្វីដែលទ្រង់បានធ្វើ។ បើគ្មានគ្រឹះនេះទេ យើងនឹងមិនដែលអាចឈរនៅថ្ងៃជំនុំជំរះបានឡើយ។ ការដាក់សេចក្ដីសង្គ្រោះរបស់អ្នកលើគ្រឹះណាផ្សេងទៀតនោះគឺជាការដែលយើងសង់នៅលើដីខ្សាច់វិញ។

## ៤. កន្លែងវិនាស

ព្រះយេស៊ូវមានបន្ទូលពីទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់។ ដោយការនេះ ទ្រង់សំដៅពីអំណាចនៃសាតាំង។ ប្រវត្តិសាស្ត្រនៃពួកជំនុំតែងតែមានទំនាស់ជានិច្ច ពីព្រោះសាតាំងស្អប់ព្រះគ្រីស្ទហើយនិងអ្វីៗដែលពាក់ព័ន្ធទៅនឹងទ្រង់។ សមរភូមិនោះមិនដែលបញ្ចប់នៅក្នុងពិភពលោកនេះឡើយ។ ហើយសង្គ្រាម

ជាមួយដែលមានអំណាចនៃស្ថាននរកគឺជាបទពិសោធន៍របស់សមាជិកគ្រប់រូបនៃពួកជំនុំពិតរបស់ព្រះគ្រីស្ទ។ សមាជិកម្នាក់ៗត្រូវតែច្បាំង។ ទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់តែងតែវាយប្រហាររាស្ត្ររបស់ព្រះគ្រីស្ទឥតឈប់ឈរ។

ក) យើងមិនត្រូវភ្ញាក់ផ្អើលពីភាពជាសត្រូវនៃសាតាំងឡើយ។ ប្រសិនបើយើងជារបស់លោកិយ លោកិយនឹងស្រឡាញ់យើង (យ៉ូហាន ១៥:១៩)។ ដរាបណាលោកិយដ៏មិនជឿនេះប្រឆាំងនឹងព្រះគ្រីស្ទ វានឹងនៅតែប្រឆាំងនឹងរាស្ត្ររបស់ទ្រង់ជានិច្ច។ ដូចជា ម៉ាធិន លូសេុីរ បាននិយាយនៅពេលមួយថា "កាអុីននៅតែបន្តការធ្វើឃាតអេបិល នោះពួកជំនុំដែលនៅលើផែនដីទាំងមូលក៏ដូចជាអេបិលដែរ"។

ខ) យើងត្រូវតែពាក់គ្រឿងសឹកទាំងអស់របស់ព្រះ ហើយចូរឲ្យយើងប្រុងប្រៀបជាស្រេចចំពោះអារក្ស (អេភេសូរ ៦:១០-១៨)។ គ្រឿងសឹកទាំងនោះត្រូវបានប្រើប្រាស់ដោយអ្នកជឿដូចយើងរាប់លានអ្នក ហើយមិនដែលស្គាល់ថាបរាជ័យទេ។

គ) យើងត្រូវតែអត់ធ្មត់ក្រោមការវាយប្រហាររបស់អារក្ស។ បទពិសោធន៍នៃការវាយប្រហារទាំងនេះនឹងជួយឲ្យយើងបន្ទាបខ្លួន ហើយកាន់តែបានបរិសុទ្ធឡើង។ វានឹងរុញច្រានយើងឲ្យកាន់តែទៅជិតព្រះអម្ចាស់ ហើយច្រានយើងឲ្យចេញពីលោកិយនេះ។

ឃ) យើងមិនត្រូវព្រួយលំបាកដោយការវាយប្រហារនៃអំណាចរបស់ស្ថាននរកឡើយ។ ការតស៊ូដែលកូនពិតប្រាកដរបស់ព្រះមានជាមួយនឹងអំណាចនៃសេចក្ដីអាក្រក់គឺជាការដៅចំណាំមួយនៃព្រះគុណរបស់ព្រះនៅក្នុងពួកគេ ហើយនិងសេចក្ដីសុខសាន្តខាងក្នុងដែលពួកគេមានពេលខ្លះ។ ប្រសិនបើមិនមានចម្បាំងខាងវិញ្ញាណនៅក្នុងជីវិតរបស់យើងទេ យើងអាចនឹងសង្ស័យថាតើយើងជារបស់ពួកជំនុំដែលនៅលើថ្មដាឬយ៉ាងណា!

## ៥. សុវត្ថិភាពដែលត្រូវបានធានា

ព្រះយេស៊ូវបានប្រទានព្រះបន្ទូលរបស់ទ្រង់មកថា ទោះបីជាមានគ្រប់ទាំងការវាយប្រហារនៃទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ក៏ដោយ ក៏ពួកជំនុំពិតរបស់ទ្រង់នៅតែបន្តធន់នៅ។ ពួកជំនុំនេះមិនដែលចាញ់ឡើយ។ នគរផែនដីដ៏ធំបានងើបឡើងហើយបានដួលចុះ ទីក្រុងដ៏ធំបានធ្លាក់ទៅក្នុងការខូចខាត ប៉ុន្តែពួកជំនុំពិតរបស់ព្រះគ្រីស្ទបានស្ថិតស្ថេរនៅវិញ។ ទោះបីពួកជំនុំកាលពីដើមដំបូងកន្លងបាត់ទៅប៉ុន្តែពួកជំនុំដទៃទៀតក៏កើតមានឡើង។ ពួកជំនុំពិតបន្តរស់នៅគ្រប់សម័យកាល។ ទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលបំផ្លាញពួកជំនុំនេះទាំងស្រុងឡើយ ដ្បិតវាមានជីវិតខាងឯព្រលឹងវិញ្ញាណរបស់ព្រះគ្រីស្ទ មានន័យថាពួកជំនុំនេះជារូបកាយរបស់ទ្រង់នៅលើផែនដីនេះ។

សមាជិកខ្លះនៃពួកជំនុំនេះអាចនឹងរងទុក្ខដោយព្រោះតែអំណាចនៃអ្នកមិនជឿ។ ពួកគេសូម្បីតែអាចនឹងត្រូវគេសម្លាប់ទៀតផង។ ប៉ុន្តែមិនមែនគ្រប់ទាំងអំណាចរបស់សាតាំងអាចបោះអ្នកជឿម្នាក់ឲ្យចេញពីពួកជំនុំពិតរបស់ព្រះគ្រីស្ទបានទេ។ ព្រះអង្គដែលពួកអ្នកជឿបានថ្វាយព្រលឹងវិញ្ញាណ មានគ្រប់ទាំងអំណាចនៅស្ថានសួគ៌និងនៅផែនដី។ សាច់ញាតិអាចនឹងប្រឆាំងនឹងអ្នក អ្នកជិតខាងអាចនឹងចំអកឡកឡឺយនូវអ្វីដែលយើងធ្វើ លោកិយអាចនឹងសើចចំអកពីសេចក្តីជំនឿរបស់យើង ប៉ុន្តែការទាំងអស់នេះនឹងមិនមានអំណាចប្រឆាំងនឹងសេចក្តីសង្គ្រោះនៃព្រលឹងរបស់អ្នកឡើយ។ អ្វីគ្រប់យ៉ាងកំពុងតែដំណើរការល្អ ទោះជាភ្នែករបស់យើងមើលមិនទាន់ឃើញក៏ដោយ។

ដូច្នេះចូរខំព្យាយាមដើម្បីរស់នៅជាជីវិតដ៏បរិសុទ្ធទោះជាមានលទ្ធផលអ្វីក៏ដោយ។ ចូរដើរឲ្យសមជាសមាជិកនៃពួកជំនុំពិតប្រាកដរបស់ព្រះចុះ។ ឬប្រសិនបើ

អ្នកមិនមានភាពប្រាកដច្បាស់មួយទេ នោះខ្ញុំសូមឲ្យមកចូលរួមជាមួយពួកជំនុំពិតប្រាកដចុះ។ ចូរឲ្យខ្លួនអ្នកបានមកហើយចូលរួមជាមួយព្រះអម្ចាស់យេស៊ូវគ្រីស្ទដោយសេចក្តីជំនឿដោយមិនពន្យារពេលចុះ។ មានពរហើយអ្នកណាដែលជាសមាជិកពួកជំនុំដែលនៅលើថ្មដារ!

# ជំពូក ១៤

## ព្រះគ្រីស្ទទាមទារឲ្យពួកជំនុំបានបរិសុទ្ធ

*អ្នកណាដែលមានត្រចៀក ឲ្យអ្នកនោះស្តាប់សេចក្តីដែលព្រះវិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មានចុះ* (វិវរណៈ ២:៧)។

ទោះជាពួកជំនុំរបស់អ្នកមានឈ្មោះអ្វីក៏ដោយ ខ្ញុំសូមអញ្ជើញអ្នកយកចិត្តទុកដាក់ជាពិសេសចំពោះខគម្ពីរខាងលើនេះ។ ប្រសិនបើអ្នកចូលរួមការថ្វាយបង្គំនៅក្នុងពួកជំនុំគ្រីស្ទានណាមួយក៏ដោយ ពាក្យទាំងអស់នេះគឺសម្រាប់អ្នក។ ពាក្យទាំងអស់នេះគឺសម្រាប់អស់អ្នកណាដែលហៅខ្លួនឯងថាគ្រីស្ទាន។

ពាក្យទាំងនេះត្រូវបាននិយាយដដែលៗរហូតដល់៧ដងនៅក្នុងជំពូកទី២ និងទី៣នៃកណ្ឌគម្ពីរវិវរណៈ។ ព្រះយេស៊ូវបានផ្ញើសំបុត្រ៧ផ្សេងគ្នាតាមរយៈសាវកយ៉ូហាន ទៅកាន់ពួកជំនុំ៧នៅស្រុកអាស៊ី។ ហើយសំបុត្រនិមួយៗបានបញ្ចប់ដោយពាក្យទាំងនេះ។

អ្វីៗដែលព្រះជាម្ចាស់បានធ្វើ គឺទ្រង់បានធ្វើដោយគ្រប់លក្ខណ៍គឺថា ទ្រង់មិនដែលធ្វើអ្វីមួយដោយគ្មានគោលបំណងនោះទេ។ ដូច្នេះនេះបង្ហាញយ៉ាងច្បាស់ថា គ្មានផ្នែកណាមួយដែលនៅក្នុងព្រះគម្ពីរកើតឡើងដោយចៃដន្យនោះទេ។ មានគោលបំណងនិងគម្រោងការដែលខគម្ពីរមួយត្រូវបាននិយាយម្តងហើយម្តងទៀត។ នេះជាហេតុផលដែលត្រូវនិយាយពាក្យទាំងនេះរហូតដល់៧ដង ដូច្នេះហើយ

យើងគួរយកចិត្តទុកដាក់ចំពោះពាក្យទាំងនេះ។ យ៉ាងនេះសូមឲ្យខ្ញុំបង្ហាញពីសេចក្តីពិតសំខាន់ៗ ដែលត្រូវបានបង្រៀននៅក្នុងសំបុត្រទាំង៧នេះ។ ទាំងនោះជាសេចក្តីពិតសម្រាប់សម័យកាលដែលយើងរស់នៅ ហើយជាសេចក្តីពិតដែលល្អសម្រាប់យើងទាំងអស់គ្នាបានស្គាល់។

## ១. នៅក្នុងសំបុត្រទាំង៧ យើងមិនអាចរកឃើញអ្វីទាំងអស់ក្រៅពីសេចក្តីអំពីគោលលទ្ធិ របស់គ្រីស្ទាន អាកប្បកិរិយា ការព្រមាន និងសេចក្តីសន្យា។

ព្រះយេស៊ូវបានប្រទាននូវការដាស់តឿនដ៏ម៉ឺងម៉ាត់មួយនៅពេលដែលទ្រង់បានទតឃើញគោលលទ្ធិក្លែងក្លាយហើយនិងអាកប្បកិរិយាទមិឡល្មើស។ សេចក្តីសរសើរបានប្រទានមកសម្រាប់សេចក្តីជំនឿ កិច្ចការល្អ និងសេចក្តីខ្ជាប់ខ្ជួន។ ការប្រែចិត្តនិងការបែរទៅរកព្រះតែងតែត្រូវបានលើកទឹកចិត្ត។

ប៉ុន្តែខ្ញុំចង់ឲ្យអ្នកកត់សម្គាល់ថា មិនមានចែងអំពីរបៀបដែលត្រូវគ្រប់គ្រងពួកជំនុំទេ ឬក៏ចែងពិធី ឬទម្រង់នៃការថ្វាយបង្គំដែលពួកគេអាចប្រើនោះទេ។ ទ្រង់មិនបានបង្រៀនលោក យ៉ូហានឲ្យសរសេរអំពីពិធីបុណ្យជ្រមុជទឹក ឬពិធីលៀងព្រះអម្ចាស់ទេ។ សូមកុំឲ្យយល់ច្រឡំអ្វីដែលខ្ញុំនិយាយនេះ ខ្ញុំមិននិយាយថាការទាំងនេះមិនសំខាន់នោះទេ។ តែសេចក្តីទាំងអស់នេះមិនអាចប្រៀបស្មើនឹងសេចក្តីជំនឿ ការប្រែចិត្ត និងសេចក្តីបរិសុទ្ធបានឡើយ។ សេចក្តីទាំងនេះជាទីមួយ ហើយសំខាន់បំផុត។ ខ្ញុំជឿថា បើមិនមានសេចក្តីខាងព្រលឹងវិញ្ញាណទាំងនេះទេ គ្មានអ្នកណាម្នាក់អាចបានទទួលសេចក្តីសង្គ្រោះបានឡើយ។

នេះជាហេតុផលមួយដែលជាញឹកញាប់ខ្ញុំបានដាស់តឿនមនុស្សមិនត្រូវឲ្យស្កប់ចិត្តនឹងអ្វីដែលគ្រាន់តែផ្នែកខាងក្រៅនៃជំនឿឡើយ។ ពួកគេមិនមែនជាគ្រីស្ទា

នឡើយ បើគ្រាន់តែមានលក្ខណៈខាងក្រៅ។ ត្រូវតែមានការបង្កើតថ្មីដោយព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តវិញ។ ជំនឿពិតគឺជាសេចក្ដីផ្ទាល់ខ្លួនទាំងស្រុងរវាងព្រះគ្រីស្ទនិងខ្លួនអ្នក។

## ២. ឃ្លាមួយទៀតដែលមាននៅក្នុងគ្រប់សំបុត្រទាំងនោះគឺ *ខ្ញុំស្គាល់ការប្រព្រឹត្តិរបស់អ្នកហើយ*

មិនឥតប្រយោជន៍ទេដែលយើងអានពាក្យទាំងនេះ៧ដងនោះ! ព្រះយេស៊ូវមិនបានមានបន្ទូលថា "អញស្គាល់ពីបំណងរបស់ឯងហើយ" ឬក៏ "អញស្គាល់ពីការសម្រេចចិត្តរបស់ឯងហើយ" ឬក៏ "អញបានស្គាល់អ្វីដែលឯងបានទូលប្រាប់ហើយ" នោះទេ។ ទ្រង់បានមានបន្ទូលថា "អញស្គាល់អស់ទាំងការដែលឯងធ្វើ"។ ជាការពិតដែលការប្រព្រឹត្តិមិនអាចសង្គ្រោះព្រលឹងរបស់អ្នកបាន ប៉ុន្តែវាមានសារៈសំខាន់ណាស់។ ការប្រព្រឹត្តិមិនអាចរាប់យើងជាសុចរិតបានទេ ឬសំអាតបាបរបស់យើងបានទេ ប៉ុន្តែជាភស្តុតាងដ៏ល្អមួយនៃសណ្ឋាននៃចិត្តរបស់យើង។ មិនមានតម្លៃទេដែលយើងនិយាយថា យើងស្គាល់ព្រះជាម្ចាស់នោះ ប្រសិនបើអាកប្បកិរិយាយើងបដិសេធអ្វីដែលយើងនិយាយនោះ ដូចជាពួកអ្នកដែលសាវកប៉ុលបានពិពណ៌នានៅក្នុងព្រះគម្ពីរទីតុស ១:១៦។ អាកប្បកិរិយារបស់យើងជាភស្តុតាងនៃជំនឿរបស់យើង។

ក) ព្រះអម្ចាស់ព្រះយេស៊ូវជ្រាបពីការប្រព្រឹត្តិរបស់អ្នកមិនជឿ ហើយថ្ងៃមួយទ្រង់នឹងដាក់ទណ្ឌកម្មដល់គេ។ ការប្រព្រឹត្តិទាំងនេះអាចនឹងត្រូវបានគេបំភ្លេចនៅលើផែនដី ប៉ុន្តែនឹងមិនត្រូវបានបំភ្លេចនៅនគរស្ថានសួគ៌ឡើយ។

ខ) ព្រះអម្ចាស់ព្រះយេស៊ូវជ្រាបពីការប្រព្រឹត្តិនៃរាស្ត្រដែលចេះកោតខ្លាចរបស់ទ្រង់ ហើយទ្រង់វាស់ថ្លឹងគេ។ ទ្រង់ជ្រាបពីមូលហេតុដែលអ្នកជឿធ្វើនូវអ្វីដែលពួកគេធ្វើគឺថា ពួកគេធ្វើសម្រាប់ការសរសើរផ្ទាល់ខ្លួនរបស់ពួកគេច្រើនប៉ុណ្ណា ហើយធ្វើសម្រាប់ទ្រង់ច្រើនប៉ុណ្ណា!

គ) ព្រះអម្ចាស់ព្រះយេស៊ូវជ្រាបពីការប្រព្រឹត្តិនៃរាស្ត្ររបស់ផងទ្រង់ផ្ទាល់ ហើយថ្ងៃមួយទ្រង់នឹងប្រទានរង្វាន់ដល់គេ។ ទ្រង់មិនដែលទតរំលងអ្វីដែលធ្វើឡើងនៅក្នុងព្រះនាមទ្រង់នោះទេ។ លោកិយអាចនឹងមិនដឹងពីអ្វីមួយដែលយើងធ្វើ ឬមូលហេតុដែលយើងធ្វើ ប៉ុន្តែព្រះយេស៊ូវទតឃើញហើយជ្រាបគ្រប់ការទាំងអស់វិញ។ មិនការព្រមានដ៏មុឹងម៉ាត់មួយនៅក្នុងការទាំងអស់នេះទេ។ អ្នកអាចនឹងបោកបញ្ឆោតអ្នកដទៃ ឬសូម្បីតែខ្លួនឯង អំពីអ្វីដែលអ្នកធ្វើ និងមូលហេតុដែលអ្នកធ្វើវា។ ប៉ុន្តែអ្នកមិនអាចបោកបញ្ឆោតព្រះគ្រីស្ទបានឡើយ។ ប៉ុន្តែចូរគិតពីការលើកទឹកចិត្តដែលមាននៅក្នុងការទាំងអស់នេះផងដែរ។ អ្នកអាចនឹងមិនមានអារម្មណ៍ថាអ្នកបានធ្វើច្រើនសម្រាប់ទ្រង់។ គ្រប់ទាំងការដែលអ្នកធ្វើហាក់ដូចជាមិនគ្រប់លក្ខណ៍ មិនបានល្អដូចដែលអ្នកចង់បាន។ ប៉ុន្តែព្រះគ្រីស្ទមិនបានភ្លេចពីអ្វីដែលអ្នកបានធ្វើដោយចេញពីសេចក្ដីស្រឡាញ់សម្រាប់ទ្រង់ឡើយ ទោះជាលោកិយ ហើយសូម្បីតែខ្លួនអ្នកគិតវាតិចតួចក៏ដោយ!

## ៣. មានឃ្លាមួយទៀតដែលបាននិយាយដដែលនៅក្នុងសំបុត្រទាំង៧ គឺជាសេចក្តីសន្យាមួយចំពោះអស់អ្នកណាដែលឈ្នះ។

ប្រាំពីរដងដែលព្រះអម្ចាស់ប្រទានសេចក្តីសន្យាដ៏សំខាន់ដល់ពួកជំនុំ។ សេចក្តីសន្យានិមួយៗគឺផ្សេងៗពីគ្នា។ សេចក្តីសន្យានិមួយៗមានពេញដោយ

សេចក្ដីលើកទឹកចិត្ត ប៉ុន្តែសេចក្ដីសន្យានិមួយៗសំដៅតែចំពោះ "អស់អ្នកណាដែលឈ្នះ"ប៉ុណ្ណោះ។

គ្រីស្ទានពិតគ្រប់រូបត្រូវតែប្រឈមមុខនឹងខ្មាំងសត្រូវ ដើម្បីទៅកាន់ជីវិតខាងព្រលឹងវិញ្ញាណ ហើយត្រូវតែប្រយុទ្ធដើម្បីយកឈ្នះពួកគេ។ ខ្ញុំសូមនិយាយម្តងទៀតចំពោះអ្វីដែលខ្ញុំបាននិយាយនៅក្នុងជំពូក៤។ គំនិតសំខាន់ដែលខ្ញុំចង់និយាយនៅពេលឥឡូវនេះគឺថា អ្នកជឿពិតមិនត្រឹមតែជាទាហានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាទាហានដ៏មានជ័យជំនះទៀតផង។ ភាពជោគជ័យគឺជាភស្តុតាងដែលធ្វើឲ្យពេញចិត្តតែមួយគត់ដែលថាអ្នកជឿមានជំនឿដែលនាំឲ្យបានសេចក្ដីសង្គ្រោះដ៏ពិត។

ក) *លោក*(ម៉ូសេ)*ស៊ូរងទុក្ខលំបាកជាមួយនឹងរាស្ត្ររបស់ព្រះ ជាជាងមានសេចក្ដីអំណរខាងអំពើបាបដែលនៅតែមួយភ្លែតនោះវិញ* (ហេព្រើរ ១១:២៥)។ ការនេះកំពុងតែឈ្នះសេចក្ដីស្រឡាញ់នៃសេចក្ដីរីករាយខាងឯសេចក្ដីទមិឡល្មើស។

ខ) លោក មីកាយ៉ា បដិសេធមិនព្រមទាយល្អដល់ស្តេចអ័ហាប់ ទោះជាគាត់ដឹងក៏ដោយថា គាត់នឹងត្រូវទទួលការបៀតបៀន ប្រសិនបើគាត់និយាយពីសេចក្ដីពិត។ ការនេះកំពុងឈ្នះសេចក្ដីស្រឡាញ់ខាងសេចក្ដីស្រណុកសុខស្រួល (១ពង្សាវតាក្សត្រ ២២)។

គ) លោក ដានីយ៉ែល បដិសេធមិនបោះបង់ចោលការអធិស្ឋាន ទោះជាគាត់បានដឹងថារូងសឹង្ហត្រូវបានរៀបចំសម្រាប់គាត់ក៏ដោយ។ គាត់បានយកឈ្នះការខ្លាចសេចក្ដីស្លាប់ (ដានីយ៉ែល ៦)។

ឃ) លោក ម៉ាថាយ បានចាកចេញពីតុអ្នកប្រមូលពន្ធហើយដើរតាមការត្រាស់ហៅរបស់ព្រះយេស៊ូវ។ គាត់លះចោលអ្វីៗទាំងអស់ហើយដើរតាមទ្រង់។ អ្នកអាចនិយាយថា គាត់កំពុងឈ្នះការស្រឡាញ់ប្រាក់ (ម៉ាថាយ ៩:៩)។

ង) លោក ពេត្រុស និងលោក យ៉ូហាន បានបដិសេធមិនបញ្ឈប់ការប្រកាសដំណឹងល្អអំពីព្រះគ្រីស្ទហើយនិងសេចក្តីរស់ឡើងវិញរបស់ទ្រង់ ទោះជាពួកគេកំពុងត្រូវបានគំរាមកំហែងដោយក្រុមប្រឹក្សាជនជាតិយូដាក៏ដោយ។ នោះជារបៀបដែលពួកគេឈ្នះការភ័យខ្លាចនៃពួកមន្ត្រីដែលមិនជឿ (កិច្ចការ ៤:១៩, ២០)។

ច) សុល ជាផារិស៊ី បានបោះបង់ចោលលទ្ធភាពនៃការឡើងដំណែងនិងមានមុខមាត់ខ្ពង់ខ្ពស់ក្នុងចំណោមពួកយូដា ហើយបានទៅគ្រប់ទីកន្លែងដើម្បីប្រកាសពីព្រះយេស៊ូវ ដែលពីមុនគាត់ជាមនុស្សដែលព្យាយាមបៀតបៀនគេ។ ការនេះកំពុងឈ្នះលើការស្រឡាញ់ការសរសើរពីមនុស្ស (ភីលីព ៣:៤-៩)។

មេរៀននេះច្បាស់ស្រួលយល់សម្រាប់យើង។ ប្រសិនបើអ្នកចង់ដឹងប្រាកដច្បាស់ថា អ្នកជាអ្នកជឿពិតប្រាកដ អ្នកក៏ត្រូវតែត្រៀមខ្លួនជាស្រេចសម្រាប់ការតស៊ូខាងព្រលឹងវិញ្ញាណនៅក្នុងបុព្វហេតុរបស់ព្រះជាម្ចាស់ ហើយយកឈ្នះចុះ!

ចូរយើងប្រុងប្រយ័ត្នពីការលះចោលសេចក្តីស្រឡាញ់ដើមដូចជាពួកជំនុំអេភេសូរ ពីការត្រឡប់ជាក្តៅមិនក្តៅត្រជាក់មិនត្រជាក់ដូចជាពួកជំនុំឡាអូឌីគា ការគាំទ្រដល់ប្រពៃណីខុសឆ្គងដូចជាពួកជំនុំភើកាមិម ការគាំទ្រគោលលទ្ធិខុសឆ្គងដូចជាពួកជំនុំយ៉ាធីរ៉ា ឬក៏ដូចមនុស្សស្លាប់ពាក់កណ្តាលដូចជាពួកអ្នកសាឌិស។ ចូរយើងបាញ់ឆ្ពោះទៅសេចក្តីបរិសុទ្ធដូចជាពួកជំនុំស្មឺណា និងពួកជំនុំភីឡាដាភា។ ចូរយើងធ្វើជាគ្រីស្ទានដ៏ពិតប្រាកដ! ចូរយើងធ្វើជារាស្ត្របរិសុទ្ធដ៏ពិតប្រាកដ! យ៉ាង

នោះបានជាព្រះយេស៊ូវងាស់តឿនយើងរាល់គ្នាឲ្យបានស្តាប់ នូវអ្វីដែលព្រះវិញ្ញាណបានមានបន្ទូលទៅកាន់ពួកជំនុំ។

# ជំពូក ១៥

## ការស្រឡាញ់ដល់ព្រះគ្រីស្ទ គឺជាផ្នែកនៃភាពបរិសុទ្ធ

*តើស្រឡាញ់ខ្ញុំឬអី?* (យ៉ូហាន ២១:១៦) ។

អារម្មណ៍នៃសេចក្តីស្រឡាញ់ចំពោះអ្នកណាម្នាក់គឺជាអារម្មណ៍សាមញ្ញមួយនៃធម្មជាតិរបស់មនុស្ស។ គួរឲ្យសោកស្តាយ ជួនកាលមនុស្សបានដាក់សេចក្តីស្រឡាញ់របស់គេចំពោះវត្ថុដែលមិនសក្តិសមទៅវិញ។ ខ្ញុំចង់ប្រកាសពីម្នាក់ដែលសក្តិសមជាងគេបំផុតសម្រាប់សេចក្តីស្រឡាញ់របស់យើងរាល់គ្នាគឺ ព្រះយេស៊ូវគ្រីស្ទ! នេះមិនមែនជាអ្វីមួយដែលមានតែពួកអ្នកជឿធ្វើប៉ុណ្ណោះនោះទេ តែអ្នកជឿអាចនឹងរីករាយជាមួយសេចក្តីសង្គ្រោះដែលព្រះគ្រីស្ទបានធ្វើវិញផងដែរ។ អញ្ចឹងតើអ្នកជឿអាចនឹងមិនស្រឡាញ់ទ្រង់ដោយរបៀបណាបាន? សេចក្តីបរិសុទ្ធមិនអាចមានដោយគ្មានសេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ទបានទេ។

មានចំនុចពីរដែលខ្ញុំចង់និយាយអំពីប្រធានបទនេះ។ ទីមួយគឺ៖

### ១. គ្រីស្ទានពិតមានអារម្មណ៍ពិសេសនៃសេចក្តីស្រឡាញ់មួយចំពោះព្រះគ្រីស្ទ

មានការជាច្រើនដែលពួកគ្រីស្ទានជឿហើយធ្វើនៅក្នុងដំណើរនៃជីវិតជាគ្រីស្ទានរបស់ពួកគេ។ ប៉ុន្តែការដែលគួរឲ្យកត់សម្គាល់ជាងគេបំផុតចំពោះអ្នកជឿពិត

គឺជាសេចក្តីស្រឡាញ់ចំពោះព្រះអម្ចាស់របស់ពួកគេ។ ចំណេះដឹងខាងព្រះគម្ពីរ សេចក្តីជំនឿ សេចក្តីសង្ឃឹម ការគោរព និងការស្តាប់បង្គាប់ចំពោះព្រះជាម្ចាស់ គឺជាអ្វីៗត្រូវបានសំដែងឲ្យឃើញនៅក្នុងជីវិតរបស់ពួកអ្នកជឿ។ ប៉ុន្តែអ្នកជឿពិតប្រាកដទៅលើស ពីការនេះទៀត គឺពួកគេស្រឡាញ់ព្រះគ្រីស្ទ។ មនុស្សម្នាក់អាចនឹងខ្វះចំណេះដឹងច្បាស់លាស់អាចនឹងមិនមានសេចក្តីក្លាហាន ឬធ្លាក់ទៅក្នុងអំពើបាប។ ប៉ុន្តែការទាំងអស់នេះនឹងមិននាំឲ្យធ្លាក់ទៅក្នុងសេចក្តីវិនាសអស់កល្បឡើយ ប្រសិនបើអ្នកស្រឡាញ់ព្រះគ្រីស្ទ។

ការមិនជឿនិងការមិនស្រឡាញ់ គឺជាជំហានទៅកាន់សេចក្តីវិនាសអស់កល្បជានិច្ច។ *បើអ្នកណាមិនស្រឡាញ់ព្រះអម្ចាស់យេស៊ូវ គ្រីស្ទ ឲ្យអ្នកនោះត្រូវបណ្តាសាចុះ* (១កូរិនថូស ១៦:២២)។ ព្រះយេស៊ូវបានមានបន្ទូលដោយផ្ទាល់ទៅកាន់ពួកយូដាថា *បើព្រះជាព្រះវរបិតានៃអ្នករាល់គ្នាមែន នោះអ្នកនឹងបានស្រឡាញ់ខ្ញុំ* (យ៉ូហាន ៨:៤២)។ ហើយបន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ព្រះយេស៊ូវបានសួរសំនួរនេះបីដងដល់លោកពេត្រុសជាសិស្សរបស់ទ្រង់។ *តើស្រឡាញ់ខ្ញុំឬអី?* (យ៉ូហាន ២១:១៥, ១៦, ១៧)។ ព្រះបន្ទូលត្រង់នេះសួរពីភាពពិតនៃសេចក្តីជំនឿរបស់យើង។ ជាព្រះបន្ទូលងាយយល់ ហើយគេស្វែងរកច្រើនបំផុត។

ប្រសិនបើអ្នកចង់ដឹងពីសេចក្តីអាថ៌កំបាំងនៃអារម្មណ៍នេះចំពោះព្រះគ្រីស្ទ សាវក យ៉ូហានប្រាប់យើងថា *យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន* (១យ៉ូហាន ៤:១៩)។ យើងស្រឡាញ់ទ្រង់ពីព្រោះទ្រង់បានធ្វើការគ្រប់ទាំងអស់សម្រាប់យើង។ ហើយយើងស្រឡាញ់ទ្រង់ព្រោះទ្រង់កំពុងតែធ្វើការសម្រាប់យើងនៅពេលឥឡូវនេះ។ អ្នកជឿត្រូវបានប្រោសឲ្យរួចពីទោសកំហុសដែលជាអំណាចនិងលទ្ធផលនៃអំពើបាបរបស់ពួកគេ។ ហើយជារៀងរាល់ថ្ងៃពួក

គេបានទទួលជីវិតនិងកម្លាំងខាងព្រលឹងវិញ្ញាណពីព្រះគ្រីស្ទ ខណៈពេលដែលទ្រង់អធិស្ឋានសម្រាប់ពួកគេនៅនគរស្ថានសួគ៌។

តើអ្នកជំពាក់បំណុលម្នាក់ ស្រឡាញ់មិត្តភក្តិដែលបានសងបំណុលជំនួសខ្លួនទាំងអស់ដែរឬទេ? តើអ្នកលង់ទឹកម្នាក់ ស្រឡាញ់អ្នកដែលហក់ចូលទៅក្នុងទឹកសមុទ្រហើយជួយសង្គ្រោះគាត់ដែរឬទេ? តើអ្នកដែលជាប់នៅក្នុងផ្ទះដែលកំពុងតែឆេះម្នាក់ ស្រឡាញ់អ្នកដែលប្រថុយជីវិតខ្លួនរត់ចូលទៅក្នុងអណ្តាតភ្លើងហើយជួយសង្គ្រោះគាត់ដែរឬទេ? សូម្បីតែកូនក្មេងក៏អាចឆ្លើយនឹងសំនួរទាំងនេះបានដែរ! នេះជារបៀបដូចគ្នានិងហេតុផលស្រដៀងគ្នា ដែលអ្នកជឿពិតស្រឡាញ់ព្រះគ្រីស្ទ។

ក) សេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ទនេះ គឺជាដៃគូរនៃសេចក្តីជំនឿដែលនាំឲ្យបានសង្គ្រោះនៅក្នុងព្រះគ្រីស្ទ។ ប្រសិនបើមនុស្សម្នាក់មិនមានសេចក្តីស្រឡាញ់សម្រាប់ព្រះគ្រីស្ទ អ្នកអាចនឹងប្រាកដថា ពួកគេមិនមានសេចក្តីជំនឿពិតនៅក្នុងព្រះគ្រីស្ទទេ។

ខ) សេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ទ ជាកម្លាំងជំរុញដ៏ប្រសើរបំផុតសម្រាប់គ្រប់ទាំងកិច្ចការសម្រាប់ព្រះអម្ចាស់។ មានភាពខុសគ្នាដ៏ធំមួយរវាងគ្រូពេទ្យដែលកំពុងថែរក្សាក្មេងដែលមានជំងឺ និងម្តាយម្នាក់ដែលកំពុងថែរក្សាកូនដែលមានជំងឺ។ ម្នាក់ធ្វើដោយសារកាតព្វកិច្ច ហើយម្នាក់ទៀតធ្វើដោយចេញពីសេចក្តីស្រឡាញ់។ មនុស្សបម្រើគេ ពីព្រោះគេឲ្យប្រាក់ខែ។ ម្នាក់ទៀតធ្វើអ្វីដែលនាងធ្វើដោយព្រោះចិត្តស្រឡាញ់ដល់កូនរបស់នាង។ ដូចគ្នាទៅនឹងការបម្រើរបស់ព្រះគ្រីស្ទដែរ។ អ្នកធ្វើការដ៏អស្ចារ្យនៅក្នុងពួកជំនុំគ្រប់សម័យកាលសុទ្ធតែជាអ្នកស្រឡាញ់ដល់ព្រះគ្រីស្ទ។

គ) សេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ទគឺជាអ្វីដែលយើងគួរបង្រៀន ជាពិសេសដល់ក្មេងៗ។ មានសេចក្តីជាច្រើននៅក្នុងសេចក្តីពិតរបស់គ្រីស្ទានដែលក្មេងៗពិបាកនឹងយល់។ ប៉ុន្តែសេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ទ គឺជាអ្វីម្យ៉ាងដែលមានច្រើននៅក្នុងការយល់ដឹងរបស់ពួកគេ។

ឃ) សេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ទ គឺជាចំណុចដែលគ្រីស្ទានគ្រប់រូប ពីគ្រប់និកាយក្រុមជំនុំគ្រីស្ទាន អាចរួបរួមមកតែមួយ ទោះជាមានភាពខុសគ្នានៅផ្នែកដទៃណាទៀតក៏ដោយ។ បុរសដែលពុំសូវបានរៀនសូត្រម្នាក់បាននិយាយថា "ខ្ញុំមិនអាចនិយាយបានច្រើនសម្រាប់ព្រះគ្រីស្ទទេ។ ទោះជាខ្ញុំមិនអាចនិយាយបានច្រើនសម្រាប់ទ្រង់ក៏ដោយ ប៉ុន្តែខ្ញុំអាចស្លាប់សម្រាប់ទ្រង់បាន!"

## ២. តើយើងអាចនឹងកត់សម្គាល់ពីសេចក្តីស្រឡាញ់មួយសម្រាប់ព្រះគ្រីស្ទដោយរបៀបណា?

នេះជាសំនួរដ៏សំខាន់បំផុត ព្រោះមិនមានសេចក្តីសង្គ្រោះដោយគ្មានសេចក្តីស្រឡាញ់ទេ។ ប៉ុន្តែវានៅតែជាសំនួរដ៏ពិបាកឆ្លើយ។ តើយើងដឹងថា យើងស្រឡាញ់អ្នកណាម្នាក់ដោយរបៀបណា? ចូរឲ្យខ្ញុំបង្ហាញអ្នកពីសេចក្តីស្រឡាញ់សម្រាប់ព្រះគ្រីស្ទនៅក្នុងរបៀបដែលស្រដៀងគ្នាក្នុងការបង្ហាញពីសេចក្តីស្រឡាញ់របស់យើងចំពោះមិត្តភក្តិនិងសាច់ញាតិចុះ។

ក) ប្រសិនបើយើងស្រឡាញ់អ្នកណាម្នាក់ យើងចូលចិត្តគិតពីអ្នកនោះ។ យើងមិនភ្លេចគេ ឬត្រូវការរំលឹកឲ្យនឹកចាំពីពួកគេនោះទេ។ យើងគិតពីគេជាញយដងក្នុងមួយថ្ងៃ។ ក្នុងរបៀបដូចគ្នានេះដែរ បើយើងស្រឡាញ់ព្រះគ្រីស្ទ នោះដោយព្រះវិញ្ញាណបរិសុទ្ធ *ព្រះគ្រីស្ទបានសណ្ឋិតនៅក្នុងចិត្តអ្នករាល់គ្នា* (អេភេសូរ ៣:១៧)។

ខ) ប្រសិនបើយើងស្រឡាញ់អ្នកណាម្នាក់ យើងចូលចិត្តឮពីអ្នកនោះ។ យើងនឹងយកចិត្តទុកដាក់នៅពេលឮគេនិយាយពីឈ្មោះអ្នកនោះ។ អស់អ្នកដែលមិនស្គាល់អ្នកជាទីស្រឡាញ់របស់យើង គេនឹងមិនសូវកត់សម្គាល់ទេ នៅពេលគេនិយាយពីអ្នកទាំងនោះ។ នោះជាសេចក្តីស្រឡាញ់ដែលជាអាថ៌កំបាំងនៃអនុស្សាវរីយ៍ដ៏ល្អ មិនថានៅក្នុងចំណោមមិត្តភក្តិជាមនុស្សដូចគ្នា ឬមិនថារវាងអ្នកជឿនិងព្រះគ្រីស្ទនោះទេ!

គ) ប្រសិនបើយើងស្រឡាញ់អ្នកណាម្នាក់ យើងចូលចិត្តអានអំពីពួកគេដើម្បីឲ្យដឹងថាពួកគេកំពុងធ្វើអ្វី។ សេចក្តីរីករាយជាច្រើនចេញពីសំបុត្រដែលផ្ញើមកពីអ្នកជាទីស្រឡាញ់របស់អ្នក។ នេះគឺដូចគ្នារវាងគ្រីស្ទាននិងព្រះគ្រីស្ទ។ អ្នកជឿពិតរីករាយនឹងការអានបទគម្ពីរ ពីព្រោះនៅក្នុងអំណាននោះ ពួកគេអានអំពីព្រះអង្គសង្គ្រោះរបស់ពួកគេ។

ឃ) ប្រសិនបើយើងស្រឡាញ់អ្នកណាម្នាក់ យើងចូលចិត្តផ្គាប់ចិត្តអ្នកនោះ។ យើងព្យាយាមស្វែងយល់ថាពួកគេចូលចិត្តអ្វីនិងអ្វីដែលពួកគេមិនចូលចិត្ត ហើយយើងព្យាយាមធ្វើទៅតាមនោះ។ ដូចជាគ្រីស្ទានខំព្យាយាមផ្គាប់ចិត្តដល់ព្រះគ្រីស្ទយ៉ាងដូច្នេះដែរ។ ពួកគេស្វែងយល់នៅក្នុងព្រះគម្ពីរនូវអ្វីដែលជាបំណងព្រះហឫទ័យរបស់ព្រះ ហើយបន្ទាប់មកខំព្យាយាមដើម្បីធ្វើតាមបំណងព្រះហឫទ័យនោះ។

ង) ប្រសិនបើយើងស្រឡាញ់អ្នកណាម្នាក់ យើងក៏ចូលចិត្តមិត្តភក្តិរបស់អ្នកនោះដែរ។ នៅពេលយើងបានជួបមិត្តភក្តិរបស់អ្នកនោះ យើងមិនមានអារម្មណ៍ថា យើងជាអ្នកដទៃសុទ្ធសាធនោះទេ។ ដូច្នេះក្នុងនាមយើងជាគ្រីស្ទាន មិត្តភក្តិទាំងអស់របស់ព្រះគ្រីស្ទក៏ជាមិត្តភក្តិរបស់យើងដែរ។ យើងស្រឡាញ់ព្រះអង្គសង្គ្រោះតែមួយដូចជាពួកគេដែរ។

ច) ប្រសិនបើយើងស្រឡាញ់អ្នកណាម្នាក់ យើងនឹងការពារអ្នកនោះ។ យើងមិនចូលចិត្តឲ្យអ្នកណានិយាយអាក្រក់ប្រឆាំងនឹងអ្នកនោះទេ ហើយយើងនឹងការពារពួកគេភ្លាម។ ក្នុងនាមជាគ្រីស្ទាន យើងនឹងមានការឈឺចាប់ នៅពេលដែលយើងឮអ្នកណាម្នាក់កំពុងនិយាយប្រឆាំងអាក្រក់នឹងព្រះគ្រីស្ទ ហើយយើងចង់និយាយជំនួសទ្រង់។

ឆ) ប្រសិនបើយើងស្រឡាញ់អ្នកណាម្នាក់ យើងនឹងចូលចិត្តចំណាយពេលជាមួយអ្នកនោះ ជជែកជាមួយអ្នកនោះ ស្តាប់អ្នកនោះ ឬក៏មានភាពស្និទ្ធស្នាលជាមួយអ្នកនោះ។ ទោះបីជាយើងអៀនហើយនៅស្ងៀមចំពោះគ្នាទៅវិញទៅមកដ៏ដោយ យើងហាក់ដូចជាមិនមានការលំបាកក្នុងការដែលនៅជាមួយគ្នាហើយនិងជជែកគ្នាជាមួយមិត្តជិតស្និតនោះទេ។ ដូច្នេះពួកគ្រីស្ទានពិតក៏មិនហាក់ដូចជាលំបាកក្នុងការជជែកជាមួយព្រះគ្រីស្ទដែរ។

ទាំងនេះជាសញ្ញាសម្គាល់ដែលគេអាចរកឃើញសេចក្តីស្រឡាញ់ពិតប្រាកដបាន។ សញ្ញាសម្គាល់ទាំងនេះសុទ្ធតែច្បាស់ហើយងាយស្រួលយល់។ ចូរប្រើសញ្ញាសម្គាល់ដោយស្មោះត្រង់ទាំងនេះដើម្បីពិនិត្យមើលខ្លួនអ្នក ហើយអ្នកនឹងដឹងថាតើអ្នកមានសេចក្តីស្រឡាញ់សម្រាប់ព្រះគ្រីស្ទដែរឬទេ។ ចូរដាក់ខ្លួនអ្នកនៅក្នុងសំនួរដែលព្រះអម្ចាស់បានសួរលោក ពេត្រុស។ តើអ្នកពិតជាស្រឡាញ់ខ្ញុំទេ?

បើអ្នកប្រាប់ខ្ញុំថា អ្នកចេះគ្រប់ទាំងគោលលទ្ធិគ្រីស្ទាន នោះមិនមែនជាចម្លើយទេ។ ព្រះគម្ពីរបានបង្រៀនថា អាចជាមិនមែនជាជំនឿគ្រីស្ទានពិត បើគ្មានអារម្មណ៍ណាមួយស្រឡាញ់ដល់ព្រះគ្រីស្ទ។ មិនមែនជាចម្លើយទេ បើអ្នកប្រាប់ខ្ញុំថាអ្នកមិនគាំទ្រជំនឿនៃអារម្មណ៍នោះ។ ប្រសិនបើជំនឿនោះមិនមានអ្វីសោះ ប៉ុន្តែ

មានអារម្មណ៍តែម្យ៉ាង នោះខ្ញុំនឹងឯកភាពជាមួយអ្នក។ ប៉ុន្តែប្រសិនបើអ្នកបិទអារម្មណ៍ទាំងអស់ នោះអ្នកស្គាល់តិចតួចណាស់ពីជំនឿគ្រីស្ទាន។

ប្រសិនបើអ្នកស្រឡាញ់ព្រះគ្រីស្ទ ពីព្រោះតែអ្នកមានអារម្មណ៍ថាអ្នកមិនជំពាក់អ្វីដល់ទ្រង់ នោះគ្មានកាតព្វកិច្ចចំពោះទ្រង់ឡើយ។ មានតែវិធីព្យាបាលតែម្យ៉ាងប៉ុណ្ណោះសម្រាប់ការនេះ។ អ្នកត្រូវការចំណេះដឹងដ៏ប្រសើរមួយអំពីខ្លួនអ្នកតាមរយៈការបង្រៀនរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អ្នកអាចស្វែងរកនិស្ស័យពិតរបស់អ្នក។ អ្នកត្រូវតែស្វែងរកទោសកំហុសហើយភាពគ្មានអ្វីសោះនៅចំពោះព្រះនេត្រនៃព្រះជាម្ចាស់។ អ្នកត្រូវតែអង្វរព្រះជាម្ចាស់អំពីព្រលឹងរបស់អ្នក។ ចូរអានពីរបៀបដែលប៉ុលពិពណ៌នាពីនិស្ស័យមនុស្សនៅក្នុងជំពូក ១ ដល់ជំពូក ២ នៃសំបុត្ររបស់គាត់ទៅកាន់ទីក្រុងរ៉ូម។ ចូរសិក្សាអត្ថបទបែបនេះរួមជាមួយសេចក្ដីអធិស្ឋានដើម្បីសូមការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ហើយមិនយូរប៉ុន្មានអ្នកនឹងបានយល់ពីអ្វីដែលខ្ញុំចង់និយាយអំពីអ្នកជាប់បំណុលរបស់ព្រះគ្រីស្ទ ហើយកំពុងត្រូវការជំនួយពីព្រះជាម្ចាស់។

ការស្គាល់សេចក្ដីត្រូវការពីព្រះគ្រីស្ទ គឺជាជំហានដំបូងដែលឆ្ពោះទៅកាន់សេចក្ដីស្រឡាញ់ដល់ទ្រង់។ ការមិនស្រឡាញ់ដល់ទ្រង់គឺគ្រោះថ្នាក់នៃសេចក្ដីវិនាសដ៏នៅអស់កល្ប ដែលនឹងត្រូវមក។ សូមកុំឲ្យមានចិត្តអំនួតពេកក្នុងការទទួលយកដំបូន្មានរបស់ខ្ញុំឲ្យសោះ។ ចូរទទួលវា ហើយបានសង្គ្រោះចុះ!

មានមនុស្សដែលគេប្រាកដនឹងខ្លួនឯងថា ពួកគេស្រលាញ់ដល់ព្រះគ្រីស្ទ។ ចំពោះអ្នកទាំងនោះខ្ញុំនិយាយថា សេចក្ដីស្រឡាញ់របស់អ្នកជាភស្តុតាងនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រីស្ទចំពោះអ្នកហើយ។ អ្នកនឹងមិនស្រឡាញ់ព្រះគ្រីស្ទបានទេ ប្រសិនបើទ្រង់មិនបានធ្វើអ្វីសោះសម្រាប់អ្នកទេនោះ។

ដូច្នេះមិនត្រូវខ្មាសក្នុងការដែលឲ្យអ្នកដទៃបានឃើញពីសេចក្តីស្រឡាញ់របស់អ្នកចំពោះទ្រង់ឡើយ។ ចូរនិយាយពីទ្រង់ រស់សម្រាប់ទ្រង់ ហើយធ្វើការសម្រាប់ទ្រង់ចុះ។

# ជំពូក ១៦

## ការដាច់ចេញពីព្រះគ្រីស្ទ

*អ្នករាល់គ្នានៅទីទៃពីព្រះគ្រីស្ទ* (អេភេសូរ ២:១២)

នៅពេលដែលប៉ុលបានសរសេរសំបុត្ររបស់គាត់ទៅកាន់ពួកជំនុំអេភេសូរ គាត់បានរំលឹកដល់ពួកគេថា មុនពេលដែលពួកគេបានត្រឡប់ជាគ្រីស្ទានពួកគេក៏នៅក្នុងចំណោមសេចក្តីដទៃទៀតដែរគឺ បាននៅទីទៃពីព្រះគ្រីស្ទ។ ប៉ុន្តែពាក្យដដែលបានពិពណ៌នាថា អស់អ្នកដែលមិនបានប្រែចិត្តមកឯព្រះជាម្ចាស់ហើយត្រឡប់ជាអ្នកជឿដល់ព្រះគ្រីស្ទ អ្នកទាំងនោះក៏ដាច់ចេញពីព្រះគ្រីស្ទដែរ។ បើយើងមិនមានលុយកាក់ ឬមិនមានមិត្តភក្តិ ឬមិនមានសុខភាពល្អ នោះជាការមិនល្អ ។ ប៉ុន្តែវាកាន់តែអាក្រក់ជាងនេះទៅទៀតក្នុងការដែលយើងដាច់ចេញពីព្រះគ្រីស្ទ។

### ១. តើមនុស្សម្នាក់ដាច់ចេញពីព្រះគ្រីស្ទនៅពេលណា?

នេះមិនមែនជាស្ថានភាពដែលខ្ញុំបានបង្កើតឡើងនោះទេ។ នោះជាឃ្លាដែលសាវក ប៉ុល បានប្រើជាលើកដំបូង។ គ្មានអ្វីគួរឲ្យឆ្ងល់ទេដែលពួកជំនុំក្រុងអេភេសូរជាច្រើនជាអ្នកថ្វាយបង្គំនៃព្រះស្រី**ដាយអេណា**នោះ។ ប៉ុន្តែសាវក ប៉ុល មិនបានគិតអ្វីទាំងអស់ពីការនោះ។ តែគាត់ពិពណ៌នាមនុស្សទាំងនោះថាជាពួកដែលគ្មានព្រះគ្រីស្ទវិញ ។

ក) មនុស្សម្នាក់ដែលគ្មានព្រះគ្រីស្ទ គឺនៅពេលណាអ្នកនោះគ្មានចំណេះដឹងអំពីទ្រង់។ គ្មានអ្វីដែលគួរឲ្យសង្ស័យទាំងអស់ ព្រោះមនុស្សរាប់លាននាក់ស្ថិតនៅក្នុងស្ថានភាពនេះ ដ្បិតពួកគេមិនដែលបានឮពីទ្រង់សោះ។ មានមនុស្សរាប់ពាន់នាក់នៅក្នុងប្រទេសអង់គ្លេសស្គាល់ព្រះគ្រីស្ទមិនលើសជាងពួកអ្នកដែលនៅប្រទេសដទៃទៀតដែលមិនធ្លាប់ឮពីទ្រង់នោះទេ។ ការមិនស្គាល់ព្រះគ្រីស្ទ មានន័យថា យើងមិនស្គាល់ព្រះអង្គសង្គ្រោះដែរ។

ខ) មនុស្សគ្មានព្រះគ្រីស្ទគឺនៅពេលណាពួកគេមិនមានសេចក្តីជំនឿដល់ទ្រង់ ទោះជាពួកគេមានចំណេះបន្តិចបន្តួចអំពីព្រះគ្រីស្ទក៏ដោយ។ អាចនឹងមានមនុស្សជាច្រើនមានចំណេះដឹងខ្លះពីព្រះគ្រីស្ទ តែពួកគេមិនបានប្រើប្រាស់ចំណេះដឹងនោះជាប្រយោជន៍ទេ។ គេបានដាក់ការជឿជាក់របស់គេនៅក្នុងអ្វីផ្សេងទៀតទៅវិញ។ គេអាចនឹងសង្ឃឹមថានឹងបានទៅដល់ស្ថានសួគ៌ដោយព្រោះអត្តចរិតល្អរបស់ពួកគេ ឬដោយព្រោះពេលខ្លះពួកគេបានអធិស្ឋាន ឬក៏ពួកគេបានទៅព្រះវិហារ។ ប៉ុន្តែពួកគេខ្វះសេចក្តីជំនឿដែលសកម្មនិងទុកចិត្តដល់ព្រះគ្រីស្ទ។ ពួកគេដាច់ចេញពីទ្រង់ហើយ។

គ) មនុស្សដែលដាច់ចេញពីព្រះគ្រីស្ទ នៅពេលណាគេមិនអាចមើលឃើញពីកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់ពួកគេ។ *បើអ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ* (រ៉ូម ៨:៩)។ ដើម្បីឲ្យបានចូលរួមជាមួយនឹងព្រះគ្រីស្ទ នោះចំណេះដឹង សេចក្តីជំនឿ និងសេចក្តីទន់សណ្តោសនៃព្រះវិញ្ញាណបរិសុទ្ធ ពិតជាសំខាន់ណាស់។ អស់អ្នកដែលខ្វះសេចក្តីទាំងអស់នេះច្បាស់ជាដាច់ចេញពីព្រះគ្រីស្ទហើយ។

ខ្ញុំចង់ឲ្យអ្នកគិតពីចំណុចទាំង៣ដែលខ្ញុំទើបបាននិយាយខាងលើនេះ។ មនុស្សជាច្រើនមិនដឹងពីសេចក្តីទាំងអស់នេះទេ។ មនុស្សជាច្រើនបានស្កប់ចិត្តថា ពួកគេបានមានចិត្តសប្បុរសដល់"មនុស្សគ្រប់រូបហើយ" ឬថា ពួកគេ "បានបំពេញកាតព្វកិច្ចរបស់ពួកគេហើយ"។ ពួកគេនិយាយតែពី "ការធ្វើ" ហើយមិនដែលនិយាយពី "ការជឿ" ទេ។ ប្រសិនបើអ្នកគិតថាការនិយាយរបស់ខ្ញុំនេះពិបាកហើយធ្ងន់ធ្ងរពេក ខ្ញុំត្រូវតែប្រាប់អ្នកថា ពាក្យទាំងនោះគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនមែនជារបស់ខ្ញុំទេ។ *អ្នកណាដែលមិនព្រមជឿ នោះនឹងត្រូវទោសវិញ* (ម៉ាកុស ១៦:១៦)។ ដូច្នេះខ្ញុំត្រូវតែប្រាប់អ្នកពីការទាំងអស់នេះ ខ្ញុំចង់ប្រាប់មនុស្សគ្រប់គ្នាខ្លាំងណាស់អំពីសេចក្តីមេត្តាករុណា និងសេចក្តីសប្បុរសនៃព្រះដែលមានសំរាប់អស់អ្នកណាដែលស្វែងរកវា ដ្បិតខ្ញុំមិនអាចរកឃើញនៅកន្លែងណាមួយនៅក្នុងព្រះគម្ពីរដែលចែងថា ការមិនស្គាល់ ឬការមិនផ្លាស់ប្រែ ឬការមិនជឿ ជាអ្វីម្យ៉ាងនោះទេ ក្រៅពីការដាច់ចេញពីព្រះគ្រីស្ទនោះ។

## ២. តើអ្វីជាស្ថានភាពពិតនៃអ្នកដាច់ចេញពីព្រះគ្រីស្ទ?

ឧបមាថាមានម្នាក់និយាយថា "ប្រសិនបើខ្ញុំដាច់ចេញពីព្រះគ្រីស្ទ ខ្ញុំក៏មិនអាក្រក់ជាងមនុស្សឯទៀតដែរ។ ខ្ញុំសង្ឃឹមថា ព្រះជាម្ចាស់នឹងមានសេចក្តីមេត្តាករុណា ហើយថាអ្វីៗនឹងមិនអីទេនៅទីបញ្ចប់"។ ខ្ញុំចង់ព្យាយាម បង្ហាញដល់មនុស្សបែបនោះថា ពួកគេត្រូវបានទទួលការបោកបញ្ឆោតដ៏គួរឲ្យអាណិតណាស់។

ក) ការដាច់ចេញពីព្រះគ្រីស្ទមានន័យថា ជាការដាច់ចេញពីព្រះជាម្ចាស់ ដ្បិតព្រះគ្រីស្ទគឺជាបុគ្គលតែមួយដែលអាចណែនាំមនុស្សមានបាបហើយនិងមនុស្សល្ងង់ខ្លៅដែលបានបែរខ្នងដាក់ព្រះអាទិកររបស់ខ្លួន ទៅឯព្រះជាម្ចាស់។ និស្ស័យបរិសុទ្ធនៃ

ព្រះជាម្ចាស់ត្រូវបានពិពណ៌នា ថាជា "ភ្លើងដ៏សន្ធោសន្ធៅមួយ" ចំពោះអស់អ្នកណាដែលដាច់ចេញពីព្រះគ្រីស្ទ។ បើយើងនៅតែបន្តឲ្យខ្លួនយើងដាច់ចេញពីព្រះគ្រីស្ទ នោះយើងមិនអាចមកជិតព្រះបានទេ។ ព្រះយេស៊ូវផ្ទាល់បានមានបន្ទូលថា *ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ។ បើអ្នករាល់គ្នាបានស្គាល់ខ្ញុំ នោះបានស្គាល់ព្រះវរបិតាដែរ* (យ៉ូហាន ១៤: ៦-៧)។

២) បើគ្មានព្រះគ្រីស្ទ នោះក៏គ្មានសេចក្តីសុខសាន្តបានដែរ។ មនុស្សគ្រប់រូបសុទ្ធតែមានបញ្ហាចិត្តនៅក្នុងពួកគេម្នាក់ៗ ដែលត្រូវតែស្កប់ចិត្ត បើពួកគេមានសេចក្តីសុខសាន្ត។ នៅក្នុងមនុស្សមួយចំនួន បញ្ហាចិត្តអាចនឹងស្លាប់ពាក់កណ្តាល ឬដេកលក់ករណីនេះមិនបណ្តាលឲ្យពួកគេមានទុក្ខព្រួយច្រើនទេ។ ប៉ុន្តែនៅពេលដែលបញ្ហាចិត្តបានភ្ញាក់ឡើង ហើយដឹងពីកំហុស និងការជំនុំជំរះនៅអនាគតខាងមុខ អ្នកនោះនឹងស្វែងរកអ្វីមួយដែលខ្លួនត្រូវការដើម្បីឲ្យបានសេចក្តីសម្រាកខាងព្រលឹងវិញ្ញាណ។

មានតែសេចក្តីមួយប៉ុណ្ណោះដែលអាចផ្តល់ឲ្យមានសេចក្តីសុខសាន្តនៅក្នុងបញ្ហាចិត្តដែលមានការលំបាក គឺជាការយល់ដឹងច្បាស់ថា ការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង គឺជាការសងពេញថ្លៃមួយសំរាប់អំពើបាបរបស់យើង ហើយសេចក្តីល្អនៃការសុគតនោះត្រូវបានប្រទានមកយើងនៅពេលយើងជឿ នោះគឺជាមហាអាថ៌កំបាំងនៃសេចក្តីសុខសាន្តខាងព្រលឹងវិញ្ញាណហើយ! *ដែលយើងរាល់គ្នាបានរាប់ជាសុចរិតដោយការជឿ នោះឈ្មោះថា យើងបានមេត្រីនឹងព្រះដោយសារព្រះយេស៊ូវគ្រីស្ទ ជាអម្ចាស់នៃយើងរាល់គ្នាហើយ* (រ៉ូម ៥:១)។

គ) បើគ្មានព្រះគ្រីស្ទ នោះក៏គ្មានសេចក្តីសង្ឃឹមដែរ។ មនុស្សជាច្រើនមានសេចក្តីសង្ឃឹមម្យ៉ាងសំរាប់ខ្លួនឯងនៅក្នុងជីវិតមួយនៅពេលខាងមុខ។ ប៉ុន្តែមនុស្សតិចតួចណាស់ដែលអាចផ្តល់ហេតុផលមួយសំរាប់សេចក្តីសង្ឃឹមដែលពួកគេមាន (១ ពេត្រុស ៣:១៥)។ សេចក្តីសង្ឃឹមមិនច្បាស់នេះ នឹងមិនអាចជាប្រយោជន៍នៅពេលដែលត្រូវការបំផុតទេ គឺនៅពេលស្លាប់។ សេចក្តីសង្ឃឹមដែលសមនឹងមាន គឺជាសេចក្តីសង្ឃឹមដែលពឹងផ្អែកលើព្រះគ្រីស្ទនិងអ្វីដែលទ្រង់បានធ្វើក្នុងនាមជាព្រះអង្គសង្គ្រោះ។ សេចក្តីសង្ឃឹមបែបនេះនឹងមិនដាច់ចេញពីព្រះគ្រីស្ទឡើយ។

ឃ) ដូចជាអ្វីដែលខ្ញុំបាននិយាយរួចមកហើយថា ការដាច់ចេញពីព្រះគ្រីស្ទ គឺជាការដែលដាច់ចេញពីនគរស្ថានសួគ៌! ខ្ញុំមិនសំដៅត្រឹមតែថា គ្មានព្រះគ្រីស្ទ អ្នកមិនអាចចូលទៅក្នុងនគរស្ថានសួគ៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថា អ្នកនឹងមិនសប្បាយរីករាយទេ បើអ្នកបានចូលក្នុងនគរស្ថានសួគ៌មែននោះ។ សេចក្តីអំណរនៃនគរស្ថានសួគ៌ គឺជាការដែលនៅជាមួយនិងព្រះគ្រីស្ទ។ តើគេអាចនឹងសុបិន្តចង់បានស្ថានសួគ៌ដោយគ្មានព្រះគ្រីស្ទដោយរបៀបណាបាន? នៅក្នុងគ្រប់ទាំងការពិពណ៌នាអំពីស្ថានសួគ៌ដែលព្រះគម្ពីរផ្តល់ឲ្យយើង វត្តមានរបស់ព្រះគ្រីស្ទគឺជាលក្ខណៈដ៏សំខាន់មួយ។ ស្ថានសួគ៌ដែលគ្មានព្រះគ្រីស្ទ មិនមែនជាស្ថានសួគ៌ដែលបានចែងនៅក្នុងព្រះគម្ពីរទេ។

ខ្ញុំអាចនឹងនិយាយបន្ថែមចំពោះការទាំងនេះដោយងាយស្រួលបាន។ ខ្ញុំអាចប្រាប់អ្នកថា បើគ្មានព្រះគ្រីស្ទ នោះក៏គ្មានជីវិត គ្មានកម្លាំង គ្មានសុវត្ថិភាព គ្មានគោលបំណងនៅក្នុងជីវិតហើយក៏គ្មានមូលដ្ឋាននៃជីវិតដែរ។ ពួកអ្នកដែលគ្មានព្រះគ្រីស្ទ គឺមានន័យថាពួកគេកំពុងតែស្ថិតក្នុងស្ថានភាពដ៏កាន់តែអាក្រក់ហើយ! ឫសសំខាន់ចំពោះមែក ខ្យល់សំខាន់ចំពោះសួតរបស់យើង អាហារនិងទឹកចំពោះរូបកាយរបស់

យើងយ៉ាងណា  នោះព្រះគ្រីស្ទសំខាន់ចំពោះយើងលើសពីនោះទៅទៀត។  គ្មានអ្វីដែលគួរឲ្យអាណិតដូចជាអ្នកដែលគ្មានទ្រង់នោះទេ!

# ជំពូក ១៧

## ការស្រេកត្រូវបានពន្លត់

*នៅថ្ងៃក្រោយបង្អស់ ជាថ្ងៃបុណ្យយ៉ាងសំខាន់ នោះព្រះយេស៊ូវទ្រង់ឈរបន្លឺឧទានប្រកាសឡើងថា បើអ្នកណាស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ។ អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងមានទន្លេទឹករស់ហូរចេញពីពោះខ្លួនមក ដូចជាគម្ពីរសំដែងហើយ តែសេចក្តីនេះ គឺទ្រង់មានព្រះបន្ទូលពីព្រះវិញ្ញាណ ដែលអស់អ្នកជឿដល់ទ្រង់នឹងត្រូវទទួល ដ្បិតព្រះវិញ្ញាណបរិសុទ្ធមិនទាន់យាងមក ដោយព្រោះព្រះយេស៊ូវមិនទាន់បានដំកើងឡើងនៅឡើយ* (យ៉ូហាន ៧:៣៧-៣៨)។

ដើម្បីឲ្យតម្លៃដល់ព្រះបន្ទូលទាំងនេះ អ្នកត្រូវការនឹកចាំពីទីកន្លែង ឱកាសនិងពេលវេលានៅដែលព្រះយេស៊ូវមានបន្ទូលពាក្យទាំងនេះ។ ដ្បិតកត្តាទាំងអស់នេះហើយដែលបានឯងព្រះបន្ទូលទាំងនេះពីព្រះអម្ចាស់។

ទីកន្លែងគឺក្រុងយេរូសាឡឹម ជាមជ្ឈមណ្ឌលនៃសាសនាយូដា ហើយជាទីមាំមួនរបស់ពួកផារិស៊ី និងសាឌូស៊ី។ ពេលនោះជាឱកាសនៃពិធីបុណ្យបារាំ ជាបុណ្យប្រចាំឆ្នាំដ៏ធំមួយរបស់សាសន៍យូដាដែលខំប្រឹងប្រែងឲ្យបានមានវត្តមាននៅក្នុងក្រុងយេរូសាឡឹមនៅពេលនោះ។ ពេលវេលាគឺនៅថ្ងៃចុងក្រោយនៃពិធីបុណ្យនោះ។ យោងទៅតាមប្រពៃណីទំនៀមទម្លាប់ នោះជាពេលដែលគេឯងទឹកពីស្រះស៊ីឡោម ហើយចាក់ទឹកនោះលើអាសនាព្រះវិហារ។

ប្រហែលជាព្រះយេស៊ូវមានអារម្មណ៍ខកព្រះទ័យចំពោះពួកបណ្ដាជន ខណៈពេលដែលពួកគេរៀបចំខ្លួនត្រឡប់ទៅផ្ទះវិញ។ ទ្រង់ពិតជាបានជ្រាបយ៉ាងប្រាកដថា គ្រប់ទាំងពិធីបុណ្យទាំងអស់នោះសុទ្ធតែជាទំនៀមទម្លាប់ឥតប្រយោជន៍ទទេ។ ទ្រង់បានទតហើយមានព្រះហឫទ័យអាណិតដល់ពួកគេ នោះទ្រង់ក៏បានមានបន្ទូលយ៉ាងខ្លាំងថា *បើអ្នកណាស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ!*

ចូរកត់សម្គាល់ពីភាសារបស់ព្រះយេស៊ូវដែលទ្រង់មានបន្ទូលថា *មកឯខ្ញុំ*។ សូមឲ្យខ្ញុំរំលឹកអ្នកថា គ្មានអ្នកដឹកនាំសាសនាដ៏អស្ចារ្យណាធ្លាប់ប្រើភាសាផ្ទាល់យ៉ាងនេះទេ! នោះជាព្រះបន្ទូលដ៏វិជ្ជមានមួយដែលបង្ហាញថា ព្រះយេស៊ូវផ្ទាល់បានជ្រាបថា ទ្រង់ជាព្រះម៉ែស៊ីដែលបានសន្យាទុក ជាព្រះអង្គសង្គ្រោះនៃលោកិយ។ មានបីចំនុចនៅក្នុងព្រះបន្ទូលដ៏អស្ចារ្យនេះ ដែលនិយាយពីព្រះអម្ចាស់ដែលយើងគួរពិនិត្យមើល៖

| | |
|---|---|
| ១. បញ្ហា | - បើអ្នកណាស្រេក |
| ២. ដំណោះស្រាយ | - ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ |
| ៣. លទ្ធផលសន្យា | - អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងមានទន្លេទឹករស់ហូរចេញពីខាងក្នុងមក |

## ១. បញ្ហា- បើអ្នកណាស្រេក

មនុស្សគ្រប់រូបក្រៅពីព្រះយេស៊ូវ នឹងបានស្គាល់អ្វីម្យ៉ាងអំពីការឈឺចាប់នៃការស្រេកខាងរូបកាយ។ ប៉ុន្តែការស្រេកខាងព្រលឹងវិញ្ញាណកាន់តែឈឺចាប់ជាងនេះទៅទៀត! ការឈឺចាប់ខាងរូបកាយគឺជាការមួយ ប៉ុន្តែការឈឺចាប់ខាងចិត្តគំនិតគឺកាន់តែខ្លាំងទៅទៀត។ មានបញ្ហាចិត្តពេញដោយការទុក្ខសោក ការដែលដឹងថាយើងមិនបានត្រៀមខ្លួនជាស្រេចសំរាប់ព្រះ ការមិនស្គាល់ទោសកំហុសនិងអំពើបាបរបស់ខ្លួន

ឯង នោះគឺជាកំរិតខ្ពស់បំផុតនៃការឈឺចាប់។ នេះហើយជាការស្រេកដែលព្រះយេស៊ូវកំពុងតែមានបន្ទូលអំពី។ វាគឺជាការស្រេករកការអភ័យទោស ការអត់ទោសបាប និងសេចក្តីមេត្រីជាមួយនឹងព្រះជាម្ចាស់។ នេះគឺជាការស្រេកដែលពួកសាសន៍យូដាស្រេករក បន្ទាប់ពីពេត្រុសបានប្រកាសដល់ពួកគេនៅថ្ងៃបុណ្យទី៥០ (កិច្ចការ ២:៣៧)។ វាជាការស្រេកឃ្លានដែលអ្នកឆ្មាំគុកស្រេក នៅពេលភ្ញាក់ដឹងខ្លួនពីការគ្រោះថ្នាក់ខាងព្រលឹងវិញ្ញាណរបស់គាត់ (កិច្ចការ ១៦:៣០)។

នេះជាការស្រេកដែលអ្នកបម្រើព្រះដ៏អស្ចារ្យជាច្រើនបានស្រេក នៅពេលដែលពន្លឺនៃការយល់ដឹងខាងព្រលឹងវិញ្ញាណបានចែងចាំងមកលើពួកគេ។ ហើយជាការពិតណាស់ វាមិនច្រើនពេកទេដែលយើងនិយាយថា យើងរាល់គ្នាគួរយល់ដឹងពីអ្វីមួយអំពីការស្រេកនេះ។ ការខ្វះអារម្មណ៍នៃអវយវៈណាមួយនៃរូបកាយខាងសាច់ឈាមរបស់យើង គឺជាសញ្ញាដ៏ពិតប្រាកដមួយនៃវត្តមានរបស់សេចក្តីស្លាប់នៅក្នុងអវយវៈនោះ។ គ្មានអ្វីមួយអាចផ្តល់ភស្តុតាងដ៏ពិតប្រាកដមួយពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណនៃចិត្តគំនិតរបស់មនុស្សប្រុសស្រី ជាជាងការខ្វះសេចក្តីស្រេករកសេចក្តីមេត្រីជាមួយព្រះជាម្ចាស់នោះទេ។ ដូច្នេះហើយបានជាបទគម្ពីរពិពណ៌នាថា អ្នកមិនជឿ គឺជាមនុស្សស្លាប់ខាងព្រលឹងវិញ្ញាណ ពោលគឺមិនមានអារម្មណ៍ស្រេករកព្រះជាម្ចាស់ទាល់តែសោះ។ អ្វីដែលជាការដ៏អាក្រក់នោះគឺនៅពេលព្រះយេស៊ូវបានមានបន្ទូលចំពោះវិញ្ញាណមួយថា *ឯងមិនដឹងថា ឯងវេទនា លំបាក ទ័លក្រ ខ្វាក់ភ្នែក ហើយអាក្រាតវិញនោះទេ* (វិវរណៈ ៣:១៧)។ ការមានអារម្មណ៍ស្គាល់ពីអំពើបាប ការមានទោស ហើយក្រីក្រខាងវិញ្ញាណ គឺជាការដែលយើងត្រូវអរព្រះគុណព្រះជាម្ចាស់! នោះជាសញ្ញាដំបូងនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតមួយហើយ។ មិនមែនយើងចាប់ផ្តើមមានអារម្មណ៍ល្អ

ទេ ប៉ុន្តែជាអារម្មណ៍មិនល្អវិញ នៅពេលដែលយើងកំពុងឃានជំហានដំបូងឆ្ពោះទៅកាន់នគរស្ថានសួគ៌នោះ។ នោះហើយជាការចាប់ផ្តើមជំនឿគ្រីស្ទានដ៏ពិតប្រាកដ។

**២. ដំណោះស្រាយ--*មកឯខ្ញុំ ហើយផឹកចុះ***

ភាពងាយស្រួលយល់នៃប្រយោគនេះ គេត្រូវតែគោរពហើយយល់ព្រម។ នេះហើយជាចម្លើយរបស់មនុស្សគ្រប់គ្នាចំពោះបញ្ហាអំពីរបៀបដែលគេអាចមានមេត្រីភាពជាមួយព្រះជាម្ចាស់នោះ។ គេគួរចងចាំប្រយោគនេះជាមួយនឹងព្រះបន្ទូលរបស់ព្រះយេស៊ូវប្រាំមួយផ្សេងទៀតនៅក្នុងចិត្ត ។ *ខ្ញុំជានំប៉័ងជីវិត។ អ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ។ ខ្ញុំជាពន្លឺលោកីយ៍។ ខ្ញុំជាទ្វារ។ ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត។ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក។* (យ៉ូហាន ៦:៣៥, ៦:៣៧, ៨:១២, ១០:៩, ១៤:៦, ម៉ាថាយ ១១:២៨)។ ចូរចងចាំព្រះបន្ទូលទាំងប្រាំមួយនេះជាមួយនឹងព្រះបន្ទូលមួយទៀតខាងលើផង។ ចូរឲ្យព្រះបន្ទូលទាំងប្រាំពីរនេះបានជាប់នៅក្នុងគំនិតរបស់អ្នកជានិច្ច កុំឲ្យភ្លេចឡើយ! នៅពេលត្រូវការណាមួយ អ្នកអាចរកបានព្រះបន្ទូលនៃសេចក្តីកំសាន្តចិត្តដ៏កាត់ថ្លៃពុំបាននេះ!

តើព្រះបន្ទូលទាំងអស់នេះមានន័យយ៉ាងដូចម្តេច? នោះមានន័យថា ព្រះគ្រីស្ទជាប្រភពនៃ "ទឹករស់" ខាងព្រលឹងវិញ្ញាណដែលព្រះជាម្ចាស់បានប្រទានមកសំរាប់វិញ្ញាណដែលស្រេក។ ជាព្រះអង្គសង្គ្រោះនិងជាអ្នកជំនួសដែលត្រូវបានឆ្កាងសំរាប់អំពើបាបរបស់យើងហើយទ្រង់បានមានព្រះជន្មរស់ឡើងវិញសំរាប់ការរាប់ជាបរិសុទ្ធរបស់យើង នៅក្នុងព្រះគ្រីស្ទមានការផ្គត់ផ្គង់ដែលមិនចេះអស់នៃគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណដែលយើងត្រូវការដូចជា ការអភ័យទោស ការ

អត់ទោស សេចក្ដីមេត្តាករុណា សេចក្ដីមេត្រី ការសម្រាក សេចក្ដីកំសាន្តចិត្តនិង សេចក្ដីសង្ឃឹម។ ដូច្នេះបើអ្នកណាម្នាក់ដឹងថាខ្លួនកំពុងតែស្រេកខាងព្រលឹងវិញ្ញាណ ចូរឲ្យគេមកឯព្រះគ្រីស្ទហើយផឹកចុះ!

ថ្នាំរបស់គ្រូពេទ្យនឹងជួយយើងឬយ៉ាងណា នោះអាស្រ័យលើថាតើយើង គោរពតាមការណែនាំដ៏ត្រឹមត្រូវក្នុងការប្រើប្រាស់វាដែរឬអត់។ ចូរឲ្យខ្ញុំបានបង្ហាញ អ្នកពីរបៀបត្រឹមត្រូវដើម្បីឲ្យបានផឹកពីព្រះគ្រីស្ទចុះ។

ក) អស់អ្នកដែលចង់ឲ្យការស្រេកខាងព្រលឹងវិញ្ញាណរបស់ខ្លួនបានឈប់ស្រេក ទៀត ត្រូវតែមកឯព្រះគ្រីស្ទផ្ទាល់។ ពួកគេមិនត្រូវស្កប់ចិត្តដោយគ្រាន់តែទៅចូលរួម ការប្រជុំគ្នារបស់ពួកគ្រីស្ទាននោះឡើយឬចូលរួមការថ្វាយបង្គំ ឬបានបំពេញពិធី ខាងសាសនានោះឡើយ។ ប្រសិនបើគេស្កប់ចិត្តនឹងសេចក្ដីទាំងនោះ មនុស្សនោះ នឹងស្រេកម្ដងទៀត។ យើងត្រូវតែដោះស្រាយដោយផ្ទាល់ជាមួយព្រះគ្រីស្ទ។

ខ) អស់អ្នកណាដែលស្រេកហើយចង់មកឯព្រះគ្រីស្ទ គឺត្រូវតែមកឯទ្រង់តែម្ដង។ មិនគ្រប់គ្រាន់ទេ ដោយគ្រាន់តែប្រាថ្នាចង់ និយាយ មានបំណងដើម្បីដោះស្រាយ ឬមានសង្ឃឹម។ យើងត្រូវតែថ្វាយខ្លួនយើងផ្ទាល់ដាច់ដល់ព្រះគ្រីស្ទ។

គ) អស់អ្នកណាដែលស្រេកត្រូវចងចាំថា សេចក្ដីជំនឿធម្មតាតែមួយប៉ុណ្ណោះដែល តម្រូវឲ្យមាន នៅពេលមកឯព្រះគ្រីស្ទ។ ត្រូវមកដោយការសោកសង្រេងនិងការ ប្រែចិត្តពីអំពើបាបដែលខ្លួនបានប្រព្រឹត្ត។ ប៉ុន្តែមិនគ្រប់គ្រាន់ទេបើគ្រាន់តែពឹងលើ ការសោកសង្រេងតែម្យ៉ាងដើម្បីឲ្យបានទទួលការទទួលស្គាល់ជាមួយនឹងទ្រង់ នោះ។ យើងក៏ត្រូវតែថ្វាយខ្លួនយើងផ្ទាល់ទៅឯទ្រង់ដោយសេចក្ដីជំនឿផងដែរ។ ដើម្បីឲ្យបានផឹកពីទ្រង់ គឺត្រូវទុកចិត្តឯល់ទ្រង់ ពឹងឯល់ទ្រង់ មិនពឹងលើអ្វីផ្សេង ទៀតក្រៅពីទ្រង់ដើម្បីឲ្យបានសេចក្ដីសង្គ្រោះឡើយ។ ប៉ុន្តែ មធ្យោបាយដោះ

ស្រាយដ៏សាមញ្ញសំរាប់ការស្រេកខាងព្រលឹងវិញ្ញាណនេះ ម៉េចក៏ពិបាកបញ្ចុះបញ្ចូលមនុស្សម្លេះ! អរព្រះគុណដល់ព្រះជាម្ចាស់ប្រសិនបើអ្នកបានរកឃើញមធ្យោបាយនេះសំរាប់ខ្លួនឯង។

### ៣. លទ្ធផលដែលបានសន្យាទុក-ទន្លេទឹករស់នឹងហូរពីខាងក្នុង

គ្រីស្ទានតិចណាស់ដែលដឹងពីចំនួននៃសេចក្តីសន្យានានាដែលមាននៅក្នុងព្រះគម្ពីរ ត្បិតវាជាអត្ថប្រយោជន៍របស់អស់អ្នកណាដែលប្រើសេចក្តីសន្យាទាំងនោះ។ សេចក្តីសន្យាស្ទើរតែជាផ្នែកនៃ ជីវិតប្រចាំថ្ងៃរបស់យើងយ៉ាងណា នោះសេចក្តីសន្យាក៏ជាផ្លូវគួរឲ្យស្រឡាញ់មួយដែលព្រះជាម្ចាស់យាងមកឯមនុស្សប្រុសស្រីដែរ ។ ប៉ុន្តែមានភាពផ្សេងគ្នាដ៏ធំមួយរវាងការសន្យារបស់មនុស្សនិងការសន្យារបស់ព្រះ។ សេចក្តីសន្យារបស់មនុស្សអាចនឹងមិនរក្សាបាន ប៉ុន្តែសេចក្តីសន្យារបស់ព្រះជាម្ចាស់តែងតែសម្រេចជានិច្ច។

សេចក្តីសន្យារបស់មនុស្សជាច្រើនគឺសំរាប់អត្ថប្រយោជន៏នៃបុគ្គលដែលធ្វើកិច្ចសន្យានោះ។ ប៉ុន្តែសេចក្តីសន្យាដែលបានដកស្រង់នៅខាងលើនេះហាក់ដូចជាសំដៅទៅមនុស្សជាច្រើនថែមទៀតនិងអស់អ្នកដែលទ្រង់បានមានបន្ទូលទៅកាន់ផងដែរ ។ និយាយពីទឹករស់ហូរពីខាងក្នុង ខ្ញុំជឿថា ព្រះអម្ចាស់របស់យើងមានបំណងឲ្យយើងយល់ថា យើងមិនត្រឹមតែមានការផ្គត់ផ្គង់ដ៏ច្រើនបរិបូរនៃព្រះពរខាងព្រលឹងវិញ្ញាណដែលយើងត្រូវការប៉ុណ្ណោះទេ យើងក៏ជាប្រភពនៃព្រះពរខាងព្រលឹងវិញ្ញាណដល់អ្នកដែលនៅជុំវិញខ្លួនយើងទៀតផង។

ក) អ្នកជឿមួយចំនួនជាប្រភពនៃព្រះពរដល់អ្នកដទៃខណៈពេលពួកគេនៅរស់។ ពាក្យសម្តីរបស់ពួកគេ គំរូរបស់ពួកគេ ការបង្រៀនរបស់ពួកគេ គឺជាមធ្យោបាយដែល មានអត្ថប្រយោជន៍ខាងព្រលឹងវិញ្ញាណហូរដល់អ្នកដទៃទៀត។ ដូចគ្នាដែរ

អ្នកប្រកាសដំណឹងល្អនិងគ្រូបង្រៀនអស្ចារ្យជាច្រើនជាទីបញ្ចេញពរដល់មនុស្សរាប់ពាន់អ្នកនៅពេលពួកគេនៅរស់ ។

ខ) មនុស្សខ្លះជាទន្លេទឹករស់ដល់មនុស្សជាច្រើននៅពេលដែលពួកគេស្លាប់! នោះគឺជាពួកអ្នកដែលយើងបានអាននៅក្នុងប្រវត្តិសាស្ត្រនៃពួកជំនុំគ្រីស្ទាន។ កិច្ចការដែលពួកគេបានធ្វើដោយការស្មោះត្រង់ចំពោះការស្លាប់ គឺលើសជាជាងពីអ្វីដែលពួកគេបានធ្វើកាលនៅរស់ផង!

គ) អ្នកជឿខ្លះជាប្រភពនៃព្រះពរដល់អ្នកដទៃទៀតបន្ទាប់ពីពួកគេបានស្លាប់យូរទៅហើយក្តី។ ពួកគេនៅតែធ្វើល្អដោយសៀវភៅរបស់ពួកគេនិងសំណេរដទៃទៀតដែលបន្សល់ទុកឲ្យ។ ហើយម្តងទៀត កិច្ចការល្អដែលពួកគេធ្វើដោយសំណេររបស់ពួកគេនៅពេលបច្ចុប្បន្ននេះ អាចនឹងលើសជាងកាលពួកគេនៅរស់ផង។

គ្មានពួកយើងណាម្នាក់ ក្លាយជាអ្នកជឿសំរាប់តែខ្លួនឯងម្នាក់នោះទេ។ ជាញឹកញាប់ការផ្លាស់ប្រែរបស់មនុស្សប្រុសឬស្រីម្នាក់នៅតែបន្តទៅមុខទៀត នៅក្នុងគោលបំណងរបស់ព្រះជាម្ចាស់ ទៅឯការផ្លាស់ប្រែនៃអ្នកដទៃទៀត។ ខ្ញុំមានការសង្ស័យបើមានអ្នកជឿណាមិនដែលក្លាយជាទន្លេទឹករស់ដល់អ្នកដទៃទៀតសោះនោះ។

ហើយខ្ញុំជឿថា ព្រឹកនៃសេចក្តីរស់ឡើងវិញនឹងបង្ហាញពីអត្ថន័យពេលពេញនៃសេចក្តីសន្យានេះ ហើយមនុស្សជាច្រើននឹងភ្ញាក់ផ្អើលដោយមិនដឹងថា ពួកគេគឺជាមធ្យោបាយនៃការបញ្ចេញពរមួយដល់អ្នកដទៃទៀត!

# ជំពូក ១៨

## ទ្រព្យសម្បត្តិដ៏ប្រមាណមិនបាន

*ទ្រង់បានប្រទានព្រះគុណនេះ គឺជាសម្បត្តិរបស់ព្រះគ្រីស្ទដ៏ប្រមាណមិនបានមកខ្ញុំ ដែលជាអ្នកតូចជាងគេបំផុតក្នុងពួកបរិសុទ្ធទាំងអស់ ឲ្យខ្ញុំបានផ្សាយដំណឹងល្អក្នុងពួកសាសន៍ដទៃ* (អេភេសូរ ៣:៨)

ទាំងនេះជាព្រះបន្ទូលដ៏អស្ចារ្យ នៅពេលណាអ្នកគិតពីអ្នកសរសេរព្រះបន្ទូលនេះ។ អ្នកនិពន្ធគឺគ្មានអ្នកណាទៀតក្រៅពីសាវក ប៉ុលឡើយ គឺជាអ្នកដឹកនាំម្នាក់របស់ពួកគ្រីស្ទានសាសន៍យូដាកាលពីម្ភៃសតវត្សមុនដែលបានធ្វើឲ្យពិភពលោកក្រឡាប់ចាក់ដោយសារព្រះបន្ទូលដែលពួកគេបានប្រកាស និងដោយសារភាពបរិសុទ្ធនៃជីវិតរបស់ពួកគេ! ព្រះបន្ទូលនេះគឺមកពីពួកមនុស្សទាំងនេះ ទាមទារការយកចិត្តទុកដាក់របស់យើង!

នៅត្រង់នេះមានបីចំនុចដែលសំខាន់សំរាប់កត់សម្គាល់៖

១. អ្វីដែលសាវក ប៉ុលនិយាយពីខ្លួនគាត់ផ្ទាល់--*ជាអ្នកតូចជាងគេបំផុតក្នុងពួកបរិសុទ្ធទាំងអស់*

២. អ្វីដែលសាវក ប៉ុលនិយាយពីអំណាចក្នុងការប្រកាស--*ទ្រង់បានប្រទានព្រះគុណនេះ*

៣. អ្វីដែលសាវក ប៉ុលប្រកាសអំពី--*សម្បត្តិរបស់ព្រះគ្រីស្ទដ៏ប្រមាណមិនបាន*

## ១. អ្វីដែលសាវក ប៉ុលនិយាយពីខ្លួនគាត់ផ្ទាល់

គាត់គឺជាអ្នកដាំក្រុមជំនុំជាច្រើន ជាអ្នកសរសេរសំបុត្រដែលព្រះវិញ្ញាណបណ្តាលចំនួនដប់បួន ជាអ្នកបម្រើនៃការអស្ចារ្យ ជាមនុស្សដែលរងទុក្ខដោយត្រូវគេវាយដំ ចោលនឹងដុំថ្ម លិចសំពៅ ហើយនិងការគ្រោះថ្នាក់ជាច្រើនដទៃទៀតដោយព្រោះព្រះគ្រីស្ទ-- ប៉ុន្តែតើប៉ុលនិយាយពីខ្លួនគាត់ដែរឬទេ? "ខ្ញុំជា*អ្នកតូចជាងគេបំផុតក្នុងពួកបរិសុទ្ធទាំងអស់*"។ ជាការដែលអន់មែនទែនដែលមនុស្សម្នាក់តូចទាបជាងគេបំផុត ប៉ុន្តែសាវក ប៉ុល គិតថាខ្លួនគាត់កាន់តែតូចជាងអ្នកនោះទៅទៀត!

ការបន្ទាបខ្លួននេះគឺលើសពីការគិតរបស់មនុស្សជាច្រើនដែលហៅខ្លួនឯងថាគ្រីស្ទាន ជាអ្នកដែលគ្មានបទពិសោធន៍គ្រីស្ទានពិតប្រាកដ។ ពួកគេមិនអាចយល់ពីជម្លោះ ការភ័យខ្លាច សេចក្តីសង្ឃឹម និងសេចក្តីសោកសង្រេងនៃគ្រីស្ទានពិតប្រាកដ។ ដែលមនុស្សខ្វាក់មិនអាចឲ្យតម្លៃស្នាដៃសិល្បៈ ហើយមនុស្សថ្លង់មិនអាចរីករាយជាមួយនឹងតន្ត្រីជាយ៉ាងណា មនុស្សដែលមិនទាន់បានក្លាយជាគ្រីស្ទានពិតប្រាកដក៏យ៉ាងនោះដែរ។ ទោះជាប្រកាសថាខ្លួនជាគ្រីស្ទានឬយ៉ាងណាក៏ដោយ ក៏មិនអាចយល់ពីការបន្ទាបខ្លួនខាងឯព្រលឹងវិញ្ញាណនេះបានដែរ។

ប៉ុន្តែសាវក ប៉ុល និយាយសំដៅពីអ្វីដែលគាត់បានសរសេរ។ នៅកន្លែងផ្សេងទៀតគាត់បានសរសេរ កាន់តែគួរឲ្យកត់សម្គាល់ទៅទៀតគឺថា *មនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ* (១ធីម៉ូថេ ១:១៥)។ *វេទនាណាស់ខ្ញុំ តើអ្នកណានឹងជួយឲ្យខ្ញុំរួច ពីតួសេចក្តីស្លាប់នេះទៅបាន* (រ៉ូម ៧:២៤)។ ដោយសេចក្តី

បង្រៀននៃព្រះវិញ្ញាណបរិសុទ្ធ សាវក ប៉ុល បានឃើញការមិនត្រឹមត្រូវនៅក្នុងជីវិតគាត់ ដែលគ្រីស្ទានមិនពិតប្រាកដមិនអាចមើលឃើញនៅក្នុងជីវិតរបស់ពួកគេ។

ហើយការបន្ទាបខ្លួនខាងព្រលឹងវិញ្ញាណនេះគឺជាអារម្មណ៍មួយដែលអ្នកជឿពិតប្រាកដទាំងអស់មាន។ ការស្គាល់ព្រះកាន់តែច្រើនឡើង មនុស្សកាន់តែដឹងថាខ្លួនឯងមានបាបគ្រប់គ្នា។ ការយល់ដឹងពីសេចក្ដីបរិសុទ្ធរបស់ព្រះកាន់តែច្រើន គេកាន់តែដឹងថាខ្លួនមិនបរិសុទ្ធ ហើយគិតថាខ្លួនឯងមិនបានបរិសុទ្ធ។ នេះឯងជាការបន្ទាបខ្លួនដែលយើងត្រូវស្វែងរក!

តើមានអ្វីដែលយើងត្រូវមានអំនួតនៅក្នុងខ្លួនយើង? គ្រប់ទាំងការបង្កើតរបស់ព្រះ គ្មានអ្វីណាមួយដែលពឹងលើខ្លួនវានោះទេ រីឯមនុស្សក៏ដូច្នោះដែរ។ នៅផ្នែកខាងរូបកាយ តើមានអ្នកណាដែលត្រូវការការថែរក្សានិងការយកចិត្តទុកដាក់យ៉ាងខ្លាំងដូចជាពួកយើងនោះ? រីឯខាងចិត្តគំនិតវិញ តើមានអ្វីដែលល្ងង់ខ្លៅដូចមនុស្សជាតិ ហើយជាការដឹកំសត់ដែលយើងធ្វើសំរាប់ខ្លួនឯងដោយសេចក្ដីសេចក្ដីល្ងីល្ងើរបស់យើងនោះ! ពិតមែនហើយយើងគួរតែជាអ្នកដែលបន្ទាបខ្លួនបំផុតនៅក្នុងចំណោមការបង្កើតទាំងអស់នៅលើផែនដីនេះ។ កាលណាយើងមានការបន្ទាបខ្លួនកាន់តែច្រើន យើងមានលក្ខណៈដូចព្រះគ្រីស្ទកាន់តែច្រើន ដ្បិតទ្រង់ *ទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្ដីស្មើនឹងព្រះនោះ ទុកជាសេចក្ដីដែលគួរកាន់ខ្ជាប់ឡើយ...នោះក៏បន្ទាបព្រះអង្គទ្រង់* (ភីលីព ២:៦-៨)។

ខ្ញុំគិតថា ស្ថានសួគ៌នឹងបង្រៀនយើងបានពេញលេញពីរបៀបដែលយើងគួរបន្ទាបខ្លួន។ នៅពេលណាយើងយល់កាន់តែច្បាស់ពីរបៀបដែលយើងបានទទួលសេចក្ដីសង្គ្រោះ ហើយបាននាំផ្លូវពេញមួយជីវិត ហើយត្រូវបានលើកទៅក្នុងសិរីល្អនៃនគរស្ថានសួគ៌ យើងនឹងដឹងយ៉ាងពេញលេញពីការអស្ចារ្យនៃអ្វីដែលព្រះ

បានធ្វើដោយសេចក្តីទន់សន្តោសសំរាប់យើងដែលជាស្ត្រីដែលមានសេចក្តីជំនឿរបស់ទ្រង់។ ហើយនៅពេលនោះ ការបន្ទាបខ្លួនដែលសាវក ប៉ុល បានបង្ហាញយើងនឹងហាក់ដូចជាត្រឹមត្រូវណាស់!

## ២. អ្វីដែលសាវក ប៉ុលនិយាយពីអំណាចក្នុងការប្រកាស

មានភស្តុតាងដែលសាវក ប៉ុល ចាត់ទុកថាជាកិច្ចការដ៏ចម្បងរបស់ពួកសាវក គឺជាការបញ្ជូនដំណឹងល្អនៃព្រះរាជសារដោយការប្រកាសដំណឹងល្អ។ គាត់បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសំណេរនានារបស់គាត់ដូចជា *ទ្រង់បានតាំងខ្ញុំ ឲ្យធ្វើជាអ្នកប្រកាសប្រាប់* (១ធីម៉ូថេ ២:៧)។ *ទ្រង់បានតាំងខ្ញុំ ឲ្យធ្វើជាអ្នកប្រកាសប្រាប់ដំណឹងល្អ* (២ធីម៉ូថេ ១:១១)។ ហើយនៅក្នុងសំណេរផ្សេងទៀតគាត់និយាយថា *ព្រះគ្រីស្ទមិនបានចាត់ខ្ញុំ ឲ្យមកធ្វើបុណ្យជ្រមុជទឹកទេ គឺឲ្យមកផ្សាយដំណឹងល្អប៉ុណ្ណោះ* (១កូរិនថូស ១:១៧)។

ខ្ញុំជឿថាសាវក ប៉ុល បានយល់ថា ការងារដ៏ចម្បងរបស់អ្នកបម្រើព្រះគ្រីស្ទ គឺជាការធ្វើជាអ្នកប្រកាសដំណឹងល្អ។ គ្មានកន្លែងណាមួយគាត់លើកឡើងថា អ្នកបម្រើព្រះគ្រីស្ទត្រូវធ្វើជាសង្ឃជារៀងរហូតនោះទេ។ ពិតមែនហើយ គ្មានកន្លែងណាមួយនៅក្នុងគម្ពីរសញ្ញាថ្មី ដែលនិយាយថា អ្នកបម្រើរបស់ព្រះគ្រីស្ទ ជាសង្ឃដែលបានញែកជាបរិសុទ្ធ ដូចជាពួករ៉ូម៉ាំងកាតូលិក ដែលតម្រូវឲ្យអ្នកបម្រើព្រះសំរាប់ការថ្វាយយញ្ញបូជានៃពិធីបុណ្យម៉ាសនោះទេ។ ការទូន្មានចុងក្រោយរបស់សាវក ប៉ុលចំពោះធីម៉ូថេ ជាអ្នកដែលគាត់បានផ្ទុកផ្តាក់ទំនួលខុសត្រូវនៃការងារពួកជំនុំឲ្យ គឺថា “ *ចូរឲ្យផ្សាយព្រះបន្ទូលចុះ!*” (២ធីម៉ូថេ ៤:២) ។

ក) ចូរយើងយល់ឲ្យច្បាស់នៅក្នុងចិត្តថា អ្នកបម្រើព្រះត្រូវតែចែកចាយព្រះបន្ទូលទៅតាមការបង្គាប់របស់ព្រះគម្ពីរ។ ការនេះបញ្ជាក់យ៉ាងច្បាស់ពីបទគម្ពីរដែលយើងបានធ្វើការកត់សម្គាល់រួចមកហើយ។ គ្មានអ្នកអានសំបុត្រដែលផ្ញើទៅកាន់លោកធីម៉ូថេ និងលោក ទីតុស ណាបានសន្និដ្ឋានថាជាការអ្វីមួយ ជាជាងថាការប្រកាសដំណឹងល្អ គឺជាការអនុវត្តន៍តាមបទគម្ពីរនោះទេ។

ខ) ចូរយើងយល់ឲ្យច្បាស់នៅក្នុងចិត្តថា អ្នកបម្រើព្រះគឺជាអំណោយទានដ៏មានប្រយោជន៍ ដែលព្រះទ្រង់បានប្រទានមកយើងប្រកបដោយបញ្ញាញាណ។ ព្រះជាម្ចាស់ជាព្រះនៃសណ្តាប់ធ្នាប់ ដែលទ្រង់ធ្វើការដោយប្រើមធ្យោបាយមនុស្ស យើងមិនមានសិទ្ធចង់ឲ្យទ្រង់ធ្វើការដោយការភ្លាមៗនៃការអស្ចារ្យនោះទេ។ គ្មានផែនការណាដែលល្អជាងផែនការក្នុងការប្រកាសដំណឹងល្អពីសេចក្តីពិតរបស់ព្រះ និងការរក្សាការទាមទាររបស់ព្រះនៅក្នុងពួកជំនុំ ជាជាងអ្នកដែលបង្កើតឲ្យមានពួកអ្នកបម្រើដែលស្មោះត្រង់នោះឡើយ។

គ) ចូរយើងយល់ឲ្យច្បាស់នៅក្នុងចិត្តថា ការធ្វើជាអ្នកបម្រើព្រះម្នាក់ គឺជាឯកសិទ្ធិដ៏ធំ ហើយក៏ជាទំនួលខុសត្រូវដ៏មឺុងម៉ាត់មួយ។ ជាកិត្តិយសមួយដែលមនុស្សម្នាក់ធ្វើជារាជទូតរបស់ស្តេច ចំនែកការធ្វើជារាជទូតរបស់ស្តេចលើសអស់ទាំងស្តេចនោះកាន់តែមានកិត្តិយសជាងអម្បាលម៉ានទៅទៀត! វាក៏ជាទំនួលខុសត្រូវដ៏មឺុងម៉ាត់មួយចំពោះម្នាក់ដែលពួកគេតំណាងឲ្យផងដែរ។ ការមិនស្មោះត្រង់ ការចែកចាយតិចជាងសេចក្តីពិតនៃព្រះរាជសារ ទាំងនោះជាកំហុសដែលនាំមកនូវការអាម៉ាស់ដល់ទូតនោះ។ *ហេតុនោះ អញក៏បានធ្វើឲ្យឯងរាល់គ្នាជាទីមើលងាយ នៅចំពោះមុខជនទាំងឡាយដែរ ពីព្រោះឯងរាល់គ្នាមិនបានកាន់តាមអស់ទាំងផ្លូវរបស់*

*អញ* នេះជាព្រះបន្ទូលដ៏ក្រៀមក្រំ ដែលព្រះត្រូវតែមានបន្ទូលមកអ្នកដឹកនាំមួយចំនួននៅក្នុងប្រទេសអ៊ីស្រាអែល (ម៉ាឡាគី ២:៩)។

យើងត្រូវអធិស្ឋានឲ្យអស់ពីចិត្តសំរាប់អស់អ្នកអធិប្បាយដំណឹងល្អ ដើម្បីឲ្យពួកគាត់បានស្មោះត្រង់ចំពោះព្រះបន្ទូលព្រះ។ ហើយជាញឹកញាប់យើងគួរតែអង្វរដល់ព្រះ សូមឲ្យទ្រង់បានតាំងឲ្យមានអ្នកដឹកនាំស្មោះត្រង់កាន់តែច្រើនថែមទៀត!

## ៣. អ្វីដែលសាវក ប៉ុលប្រកាស

សាវក ប៉ុល ប្រកាសអំពីព្រះគ្រីស្ទគឺមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលនោះទេ ដ្បិតជាព្រះគ្រីស្ទនៅក្នុងគ្រប់ទាំងសិរីល្អរបស់ទ្រង់ ដែលគាត់បានជួបនៅតាមផ្លូវទៅកាន់ក្រុងដាម៉ាស (កិច្ចការ ៩:៣, ៩)។ បន្ទាប់ពីហ្នឹងមក សាវក ប៉ុល មិនដែលខ្ជះខ្ជាយពេលវេលានិយាយពីអ្វីផ្សេងទៀតទេ! ប៉ុន្តែ មានន័យយ៉ាងដូចម្តេចនៅពេលដែលគាត់បាននិយាយអំពី “*ទ្រព្យសម្បត្តិដ៏ប្រមាណមិនបាននៃព្រះគ្រីស្ទនោះ*”?

ក) មានទ្រព្យសម្បត្តិដ៏ប្រមាណមិនបាននៅក្នុងអង្គបុគ្គលរបស់ព្រះគ្រីស្ទ ដ្បិតទ្រង់ជាព្រះផងនិងជាមនុស្សផង។ ពិតមែនហើយ នេះជាអាថ៌កំបាំងដ៏ធំ។ ប៉ុន្តែគ្រីស្ទានដែលចេះគិតពិចារណានឹងមិនដែលមានសេចក្តីខ្មាស់ទេ ដែលជឿថាព្រះគ្រីស្ទជាមនុស្សផងជាព្រះផងនោះ។ ប្រសិនបើទ្រង់គ្រាន់តែជាមនុស្ស នោះទ្រង់មិនអាចនឹងជួយសង្គ្រោះយើងពីអំពើបាបបានទេ។ ប្រសិនបើទ្រង់គ្រាន់តែជាព្រះ នោះទ្រង់មិនអាចនឹងមានបទពិសោធន៍នឹងសេចក្តីល្បួងនិងសេចក្តីកម្សោយរបស់យើងបានទេ។ ជាព្រះ ទ្រង់មានអំណាចព្រះចេស្តាក្នុងការសង្គ្រោះ ជាមនុស្ស ទ្រង់សមជាអ្នកតំណាងរបស់យើងបំផុត។ ដែលព្រះគ្រីស្ទជាព្រះផងនិងជាមនុស្សផង មិន

ត្រឹមតែជាសេចក្តីពិតដែលមិនចេះសាបសូន្យប៉ុណ្ណោះទេ ក៏ជាសេចក្តីពិតដ៏មានតម្លៃផងដែរ។

ខ) អ្វីដែលព្រះគ្រីស្ទបានធ្វើសំរាប់យើងដោយសារការសុគត ការរស់ឡើងវិញ និងការយាងទៅស្ថានសួគ៌របស់ទ្រង់ គឺជាការដែលប្រមាណមិនបាន។ ទ្រង់បានបញ្ចប់កិច្ចការដែលព្រះវរបិតាប្រទានឲ្យទ្រង់ធ្វើ (យ៉ូហាន ១៧:៤) គឺជាកិច្ចការនៃការធ្វើឲ្យធួននឹងបាប ការសង្រ្គោះ ការប្រោសលោះ ការជំនួស ជា "មនុស្សសុចរិតសំរាប់មនុស្សទុច្ចរិត" ហើយនិងការធ្វើឲ្យស្កប់ព្រះទ័យពេញលេញនៃការទាមទារដ៏សុចរិតរបស់ព្រះជាម្ចាស់ពីយើងរាល់គ្នា។ ពាក្យទាំងអស់នេះជាពាក្យពោរពេញទៅដោយអត្ថន័យខ្លឹមសារណាស់!

គ) មានទ្រព្យសម្បត្តិដ៏ប្រមាណមិនបាននៅក្នុងព័ន្ធកិច្ចផ្សេងៗដែលព្រះគ្រីស្ទបានធ្វើសម្រេចសំរាប់រាស្ត្ររបស់ទ្រង់។ ទ្រង់ជាអ្នកសង្រ្គោះរបស់ពួកគេ ជាអ្នកនិយាយគាំទ្រជំនួសរបស់ពួកគេ ជាសម្តេចសង្ឃរបស់ពួកគេ ជាអ្នកគង្វាលរបស់ពួកគេ ជាគ្រូពេទ្យរបស់ពួកគេ ជាមេបញ្ជាការរបស់ពួកគេ ជាស្តេចរបស់ពួកគេ ជាគ្រូរបស់ពួកគេ ជាសិរសាររបស់ពួកគេ ជាអ្នកទុកគំរូដល់ពួកគេ ជាបងប្រុសរបស់ពួកគេ! ទាំងអស់នេះគឺជាទ្រព្យសម្បត្តិដ៏ប្រមាណមិនបាន ចំពោះពួកអ្នកជឿដែលតស៊ូរស់នៅជាជីវិតនៃសេចក្តីជំនឿ!

ឃ) មានទ្រព្យសម្បត្តិដ៏ប្រមាណមិនបាននៅក្នុងព្រះនាមនិងងាររបស់ព្រះគ្រីស្ទ។ ខ្ញុំមិនអាចជូនជាបញ្ជីនាមនិងងារទាំងអស់នោះនៅទីនេះបានទេ ប៉ុន្តែអ្នកអានបទគម្ពីរដែលយកចិត្តទុកដាក់នឹងរកបាននាមនិងងារទាំងនោះនៅពេលអាន ដូចជាកូនចៀមនៃព្រះជាម្ចាស់ នំប៉័ងជីវិត ទ្វារ ផ្លូវនិងជាសេចក្តីពិតហើយជាជីវិត ដើម

ទំពាំងបាយជូរ ថ្មដារ ថ្មជ្រុង។ ចំពោះអ្នកមិនជឿ ទាំងនេះជាពាក្យដែលគ្មានន័យ ប៉ុន្តែចំពោះអ្នកជឿវិញពាក្យទាំងនេះជាទ្រព្យសម្បត្តិដ៏ប្រមាណមិនបានវិញ!

ង) អ្វីដែលព្រះគ្រីស្ទមានបំណងសំរាប់រាស្ត្ររបស់ទ្រង់ គឺជាអ្វីម្យ៉ាងនៃទ្រព្យសម្បត្តិដ៏ប្រមាណមិនបាន។ មានទ្រព្យសម្បត្តិនៃអំណាចដើម្បីលើកលែង អត់ទោស សំអាត ហើយជាទ្រព្យសម្បត្តិនៃការអត់ធ្មត់ ការអាណិតអាសូរ កំលាំងនិងសិរីល្អដែលត្រូវមក។ អ្នកជឿនឹងដឹងថា គ្មានទ្រព្យសម្បត្តិណាស្មើនឹងការទាំងនេះនៅក្នុងបុគ្គលណាមួយជាជាងនៅក្នុងព្រះគ្រីស្ទឡើយ។

ហើយទ្រព្យសម្បត្តិទាំងនេះ គឺរកប្រមាណមិនបានទេ--ទាំងអស់នោះតែងប្រៀបដូចជាកំណប់ថ្មីដែលគេទើបរកឃើញអញ្ចឹង។ អ្នកជឿស្គាល់ព្រះអង្គសង្គ្រោះនេះតែបន្តិចបន្តួចប៉ុណ្ណោះ។ ប៉ុន្តែដើម្បីឲ្យបានស្គាល់អ្វីមួយអំពីព្រះគ្រីស្ទ គឺជាជីវិតអស់កល្បជានិច្ច។ *អស់អ្នកដែលមានព្រះរាជបុត្រានៃព្រះ មានជីវិត តែអស់អ្នកដែលមិនមានព្រះរាជបុត្រានៃព្រះ មិនមានជីវិតទេ* (១យ៉ូហាន ៥:១២)។ នៅពេលយើងមកឯសិរីល្អ យើងនឹងមានការភ្ញាក់ផ្អើលពីរបៀបដែលយើងមិនបានដឹងថា ទ្រព្យសម្បត្តិដ៏ប្រមាណមិនបានរបស់ព្រះគ្រីស្ទទាំងនេះអស្ចារ្យយ៉ាងណា ហើយដឹងថាយើងបានស្រឡាញ់ទ្រង់តែបន្តិចបន្តួចប៉ុណ្ណោះ។ ដូច្នេះ ឥឡូវនេះចូរយើងខំស្វែងរកឲ្យបានស្គាល់ទ្រង់ថែមទៀត ដ្បិតនេះជាផ្លូវទៅកាន់សេចក្ដីបរិសុទ្ធ។

# ជំពូក ១៩

## អ្វីដែលសម័យរបស់យើងទាមទារពីយើងក្នុងនាមជាគ្រីស្ទាន

*មនុស្សដែលស្គាល់សម័យ* (១របាក្សត្រ ១២:៣២)

មានពេលមួយនៅក្នុងសម័យសញ្ញាចាស់នៃប្រទេសអ៊ីស្រាអែល នៅពេលដែលពួកកុលសម្ព័ន្ធបានបែងចែកសេចក្តីស្មោះត្រង់របស់ពួកគេរវាងគ្រួសារស្តេចសូល (បន្ទាប់ពីពេលដែលទ្រង់ត្រូវបានសម្លាប់នៅក្នុងសមរភូមិ) ហើយនិងដាវីឌ ជាអ្នកដែលព្រះបានចាក់ប្រេងតាំងជាស្តេចបន្ទាប់។ ប៉ុន្តែ កុលសម្ព័ន្ធមួយក្នុងចំណោមនោះគឺកុលសម្ព័ន្ធអ៊ីសាខារបានមកដោយសេចក្តីក្លាហានហើយគាំទ្រដល់ស្តេចដាវីឌ។ ហើយពួកទាំងនោះបានទទួលពាក្យសរសើរមួយដែលនិយាយថា *មនុស្សដែលស្គាល់សម័យ*។

ខ្ញុំសូមលើកឡើងដូចជាពួកគេដែរថា ជាការមានសារៈសំខាន់ណាស់សំរាប់យើងក្នុងការស្គាល់និងយល់ពីសម័យដែលយើងរស់នៅ។ ការដែលអង្គុយនៅក្នុងស្ថានភាពឯកជនផ្ទាល់ខ្លួនដោយមិនអើពើពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងពួកជំនុំគ្រីស្ទាននិងនៅក្នុងលោកិយនេះ គឺជាប្រភេទគ្រីស្ទានដែលខ្សោយ។ ក្រៅពីព្រះគម្ពីរនិងចិត្តគំនិតរបស់យើង ព្រះអម្ចាស់របស់យើងក៏ឲ្យយើងសិក្សាពីសម័យរបស់យើងផងដែរ។

នៅព្រះគម្ពីរសញ្ញាថ្មី ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទបានបន្ទោសដល់ពួកសាសន៍យូដានៅសម័យទ្រង់ថា ជាពួកដែលមិនស្គាល់ពេលវេលា (ម៉ាថាយ ១៦: ១៣, លូកា ១៩:៤៤)។ គ្រប់សម័យកាលសុទ្ធតែមានការគ្រោះថ្នាក់សំរាប់ពួកគ្រីស្ទាន ហើយសម័យនិមួយៗសុទ្ធតែត្រូវការឲ្យពួកគ្រីស្ទានចេះកត់សម្គាល់ការគ្រោះថ្នាក់ទាំងអស់នោះ។ ដត្រែ ក៏ដូចគ្នា បើឮសូរមិនច្បាស់ នោះតើនឹងមានអ្នកណាប្រុងប្រៀបខ្លួនទៅច្បាំងបាន (១កូរិនថូស ១៤:៨)។

## ១. សម័យដែលយើងរស់នៅនេះតម្រូវឲ្យយើងរក្សាសេចក្តីពិតនៃជំនឿគ្រីស្ទាន និងអំណាចនៃព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

ពាក្យសម្តីរបស់គ្រូគង្វាលដ៏ល្បីម្នាក់ដែលបានសរសេរនៅឆ្នាំ១៧៣៦ នៅតែជាការពិតដ៏គួរឲ្យកត់សម្គាល់នៅពេលបច្ចុប្បន្ននេះ គឺថា៖

> *មានពេលមួយមនុស្សជាច្រើនមិនមានការយកចិត្តទុកដាក់ គឺថាជំនឿគ្រីស្ទាននឹងមិនមែនជាប្រធានបទមួយសំរាប់គេចង់ដឹងទៀតទេ។ ប៉ុន្តែអស់រយៈពេលយ៉ាងយូរ នៅបច្ចុប្បន្ននេះគេគិតថាជារឿងប្រឌិតទៅវិញ។ មិនតែប៉ុណ្ណោះ នៅសម័យនេះពួកគេប្រព្រឹត្តនឹងវាប្រៀបដូចជាចំនុចឯកភាពមួយក្នុងចំណោមមនុស្សដែលចេះវិនិច្ឆ័យ ហើយគ្មានអ្វីសល់នៅទាំងអស់ ក្រៅពីធ្វើឲ្យមានប្រធានបទនៃរឿងព្រេងកថា និងរឿងអស់សំណើច ហើយសេចក្តីជំនឿនោះប្រៀបដូចទណ្ឌកម្មដោយព្រោះវាមានការរំខានដល់សេចក្តីស្រើបស្រាលខាងលោកិយរបស់ពួកគេ។ (ដកស្រង់ពីសេចក្តីផ្តើមនៃសៀវភៅ Analogy of Religion របស់គ្រូគង្វាល Butler)។*

នៅក្នុងសារព័ត៌មាន ទស្សនាវដ្ដី សៀវភៅ ការបង្រៀន និងពេលខ្លះសូម្បីតែនៅក្នុងសេចក្ដីអធិប្បាយ អ្នកនិពន្ធនិងអ្នកអធិប្បាយនៅតែបង្កើតសង្គ្រាមប្រឆាំងនឹងមូលដ្ឋានគ្រឹះនៃជំនឿគ្រីស្ទាន។ ជារឿយៗ ទស្សនៈវិទូ ហើយនិងអ្នកវិទ្យាសាស្រ្តប្រាប់យើងថា មនុស្សគ្មានការអប់រំមិនអាចជឿជំនឿសាសនាដ៏អស្ចារ្យមួយ ឬព្រះគម្ពីរ ឬភាពដែលអាចកើតឡើងនៃការអស្ចារ្យបានឡើយ។ សេចក្ដីពិតដូចជា ព្រះត្រៃឯក ភាពជាព្រះនៃព្រះគ្រីស្ទ បុគ្គលិកលក្ខណៈនៃព្រះវិញ្ញាណបរិសុទ្ធ និងវត្តមានរបស់អារក្ស ហើយនិងភាពពិតនៃនគរស្ថានសួគ៌និងស្ថាននរក មនុស្សជាច្រើនគិតថាការទាំងអស់នេះសុទ្ធតែរឿងគួរឲ្យអស់សំណើចប៉ុណ្ណោះ។ ហើយការនេះធ្វើឡើងយ៉ាងឆ្លាតវៃណាស់បានជាគ្រីស្ទានខ្សោយៗអាចនឹងរងឥទ្ធិពលរបស់វា។

ការមិនជឿបែបនោះមិនគួរណានឹងធ្វើឲ្យយើងភ្ញាក់ផ្អើលនោះទេ។ តាំងពីសម័យលោកអ័ដាមនិងនាងអេវ៉ាមក អារក្សសាតាំងបានធ្វើការឥតឈប់ឈរដើម្បីល្បួងមនុស្សមិនឲ្យជឿដល់ព្រះជាម្ចាស់ (លូកា ១៨:៨; ២ធីម៉ូថេ ៣:១៣; ២ពេត្រុស ៣:៣)។ ប៉ុន្តែដូចជាខ្ញុំបានប្រាប់អ្នកអញ្ចើង ថាកុំឲ្យភ្ញាក់ផ្អើលចំពោះការមិនជឿបែបនោះឡើយ ខ្ញុំសូមទូន្មានអ្នកថា កុំឲ្យភ័យញ័រនៅក្នុងចិត្តគំនិតដោយការនោះឲ្យសោះ។ ជំនឿគ្រីស្ទាននឹងរស់នៅ ទោះជាមានការវាយប្រហារដោយពួកអ្នកមិនជឿដ៏ឆ្លាតវៃក៏ដោយ។ នៅពេលពួកអ្នកសង្ស័យទាំងអស់នេះបានធ្វើអ្វីៗទាំងអស់តាមតែពួកគេអាចធ្វើបាន យើងមិនត្រូវភ្លេចសេចក្ដីពិតដ៏អស្ចារ្យបីដែលគេមិនអាចពន្យល់បាន។

ក) ទីមួយគឺសេចក្ដីពិតអំពីព្រះយេស៊ូវគ្រីស្ទផ្ទាល់។ ប្រសិនបើជំនឿគ្រីស្ទានមិនពិតហើយវាមិនមកពីព្រះជាម្ចាស់ តើពួកអ្នកសង្ស័យទាំងអស់នេះពន្យល់ពីព្រះយេស៊ូវគ្រីស្ទដោយរបៀបណា? តើពួកគេពន្យល់ពីលក្ខណៈរបស់ទ្រង់នៅក្នុងប្រវត្តិសាស្រ្ត

មនុស្សដោយរបៀបណា? ដោយមិនមានការបង្ខិតបង្ខំ និងសំណូកសូកប៉ាន់ តើពួកគេពន្យល់ដោយរបៀបណា ថាទ្រង់បានទុកឲ្យមានការកំណត់សម្គាល់ដ៏អស្ចារ្យមួយនៅក្នុងពិភពលោកនេះ។ ដោយរបៀបណាបានជាគ្មានមនុស្សណាម្នាក់ដូចជាទ្រង់សោះតាំងពីដើមដំបូងនៃប្រវត្តិសាស្ត្រមនុស្សមក? គ្មានអ្វីអាចពន្យល់ពីទ្រង់បានសោះ លើកលែងតែអ្វីដែលព្រះគម្ពីរបានចែងអំពីទ្រង់ប៉ុណ្ណោះ។

ខ) ការពិតទីពីរគឺជាព្រះគម្ពីរផ្ទាល់តែម្តង។ តើសៀវភៅនេះមានលក្ខណៈយ៉ាងដូចម្តេច? តើដោយរបៀបណាដែលសៀវភៅមួយក្បាលសរសេរដោយពួកយូដាមួយចំនួនដែលនៅកន្លែងឆ្ងាយៗពីគ្នាក្នុងពិភពលោក នៅសម័យកាលផ្សេងៗគ្នានៃប្រវត្តិសាស្ត្រ ហើយពួកគេមិនដែលស្គាល់គ្នាសោះ។ តើសៀវភៅព្រះគម្ពីរនេះនៅតែមានវត្តមានដោយព្រោះសេចក្តីល្អរបស់វាដោយរបៀបណា? តើវាជាសៀវភៅដ៏ជ្រាលជ្រៅ ជាសៀវភៅដ៏សាមញ្ញ និងដ៏ប្រកបដោយប្រាជ្ញា ត្រឹមត្រូវឥតកំហុសយ៉ាងដូចម្តេចបាន? គេអាចពន្យល់ការនេះបានដោយព្រោះសៀវភៅនេះមានលក្ខណៈអធិធម្មជាតិហើយមកពីព្រះជាម្ចាស់ប៉ុណ្ណោះ។

គ) សេចក្តីពិតទីបីគឺជាឥទ្ធិពលដែលជំនឿគ្រីស្ទានបានជះដល់លោកិយ។ ប្រសិនបើជំនឿគ្រីស្ទានគ្រាន់តែជាការបង្កើតរបស់មនុស្ស មិនមែនជាព្រះបន្ទូលរបស់ព្រះ ចុះធ្វើដូចម្តេចបានជាវាធ្វើឲ្យមានភាពផ្សេងគ្នាចំពោះសណ្ឋានរបស់មនុស្សមានបាប? តើមានអ្វីទៀតដែលពួកអ្នកសង្ស័យអាចពន្យល់ពីភាពផ្សេងគ្នាខាងសីលធម៌ដែលជាលទ្ធផលនៃសេចក្តីជំនឿចំពោះមនុស្ស មុនពេល ជឿ និងក្រោយពេលជឿ? តើយើងអាចពន្យល់ដោយរបៀបណា ពីភាពខុសគ្នារវាងប្រទេសនានាដែលមានវត្តមានជំនឿគ្រីស្ទាន ហើយនិងប្រទេសនានាដែលគ្មាន វត្តមានសេចក្តីជំនឿគ្រីស្ទាន? ជាការពិតណាស់ ជំនឿគ្រីស្ទាននាំមកឯចំណេះដឹងនៃសេចក្តីពិតនិងសេចក្តី

បរិសុទ្ធរបស់ព្រះដល់យើង នោះទើបអាចពន្យល់ពីឥទ្ធិពលរបស់វាចំពោះលោកិយបាន។

## ២. សម័យដែលយើងរស់នៅតម្រូវឲ្យយើងមានគំនិតរឹងមាំច្បាស់លាស់ពីគោលលទ្ធិគ្រីស្ទាន

ខ្ញុំមិនអាចនៅស្ងៀមស្ងាត់បានទេ ខ្ញុំខ្លាចក្រែងគោលលទ្ធិនៃជំនឿរបស់យើងត្រូវបំផ្លាញដោយការធ្វេសប្រហែសនៅក្នុងពួកជំនុំ ក៏ដូចជាពួកដេញដោលនិងពួកអ្នកមិនជឿនៅក្រៅក្រុមជំនុំផង។ មនុស្សជាច្រើនដែលថាខ្លួនជាគ្រីស្ទានហាក់ដូចជាមិនប្រាកដអំពីគោលលទ្ធិត្រឹមត្រូវនិងគោលលទ្ធិខុសឆ្គងសោះ។ ពួកគេងាយនឹងរងឥទ្ធិពលពីពួកអ្នកអធិប្បាយឆ្លាតវៃឬដោយគំនិតថ្មីនិងគំនិតដ៏គួរឲ្យចាប់អារម្មណ៍។ ការប្រាកដមួយអំពីមនុស្សបែបនេះ គឺថាពួកគេមិនចូលចិត្តស្គាល់សេចក្តីពិតនៃព្រះគម្ពីរឲ្យបានច្បាស់ទេ!

មនុស្សទាំងនេះកំពុងតែរស់នៅក្នុងភាពស្រអាប់ខាងព្រលឹងវិញ្ញាណ បានជាពួកគេមិនអាចមើលច្បាស់បាន។ ការគ្រោះថ្នាក់នោះគឺ ពួកគេនឹងដាច់ចេញហើយចូលទៅក្នុងផ្ទះរបស់ពួកគេដោយមិនមានសេចក្តីកំសាន្តចិត្តឬសេចក្តីសង្ឃឹមអ្វីទាំងអស់ពីសេចក្តីជំនឿរបស់ពួកគេ។ ហើយការពន្យល់នៅក្នុងកាលៈទេសៈបែបនេះ មិនពិបាករកនោះទេ។ ក្នុងនិស្ស័យសាច់ឈាម ចិត្តរបស់មនុស្សខ្វាក់មើលមិនឃើញសេចក្តីលំអនៃសេចក្តីជំនឿខាងព្រលឹងវិញ្ញាណនោះទេ ហើយក៏មិនចាប់អារម្មណ៍ក្នុងការស្វែងរកសេចក្តីពិតខាងសេចក្តីជំនឿនោះផង។ យើងចូលចិត្តឲ្យគេគិតថាយើងជាមនុស្សពូកែអត់ធ្មត់និងរួសរាយរាក់ទាក់។ ហើយជាលទ្ធ

ផលគឺថា យើងជាមនុស្សដែលមានទំនោរមិនចង់យល់ច្បាស់នៅក្នុងសេចក្តីជំនឿរបស់យើង។

ខ្ញុំសូមអង្វរអស់អ្នកដែលបានអានសៀវភៅនេះថា ចូរឲ្យភ្ញាក់ដឹងខ្លួនពីសណ្ឋានចិត្តដែលមិនប្រាកដនេះឡើង។ ជ័យជំនះនៃជំនឿគ្រីស្ទានតែងតែត្រូវបានយកឈ្នះដោយការសិក្សាវិជ្ជាព្រះគម្ពីរអំពីគោលលទ្ធិច្បាស់លាស់។ យើងត្រូវបង្រៀនមនុស្សឲ្យបានច្បាស់លាស់ពីការសុគតរបស់ព្រះគ្រីស្ទនិងពីអត្ថន័យរបស់វា។ យើងត្រូវតែបង្រៀនអំពីនិស្ស័យដ៏ខូចអាក្រក់នៃអំពើបាប អំពីការរាប់ជាសុចរិតដោយសារសេចក្តីជំនឿ អំពីការកើតជាថ្មីដោយព្រះវិញ្ញាណ អំពីភាពចាំបាច់នៃការប្រែចិត្តនិងការថ្វាយខ្លួនទៅចំពោះព្រះគ្រីស្ទ។ នេះជាសេចក្តីបង្រៀនដ៏ច្បាស់លាស់ដែលព្រះជាម្ចាស់ប្រទានកិត្តិយសដល់ភាពជោគជ័យអស់រយៈពេលជាច្រើនសតវត្សមកនេះ។

## ៣. សម័យដែលយើងរស់នៅនេះតម្រូវឲ្យយើងមានខ្នាតនៃសេចក្តីបរិសុទ្ធផ្ទាល់ខ្លួនខ្ពស់ជាងមុនហើយនិងការយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះការប្រើជាប្រយោជន៍នៃសេចក្តីជំនឿនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង

តាំងពីសម័យកែទម្រង់មក ពុំសូវមានការបរាជ័យខ្លាំងចំពោះការប្រដេញតាមខ្នាតនៃការរស់នៅរបស់គ្រីស្ទានដូចជាបច្ចុប្បន្ននេះទេ។ ផ្លូវទៅកាន់ខ្នាតនៃសេចក្តីបរិសុទ្ធមិនពិបាករកនោះទេ។ អ្នកខ្លះអាចនឹងញញឹមដាក់ការពន្យល់ដ៏សាមញ្ញរបស់ខ្ញុំនេះ។ យើងត្រូវពិនិត្យឲ្យបានច្បាស់ចំពោះក្រឹត្យវិន័យទាំង១០ប្រការរបស់ព្រះ។ យើងក៏ត្រូវការពិនិត្យកាន់តែច្រើនចំពោះសេចក្តីអធិប្បាយរបស់

ព្រះយេស៊ូវនៅលើភ្នំ ។ ហើយត្រូវតែអានដោយយកចិត្តទុកដាក់ចំពោះពាក់កណ្តាលចុងក្រោយនៃសំបុត្រភាគច្រើនរបស់សាវកប៉ុលផងដែរ។

អ្វីដែលមនុស្សត្អូញត្អែរច្រើននៅបច្ចុប្បន្ននេះគឺថា ពួកគេខ្វះអំណាចនៅក្នុងជំនឿគ្រីស្ទានបែបទំនើប។ ខ្ញុំជឿថាហេតុផលសំរាប់ការនេះគឺព្រោះតែខ្វាតទាបនៃជីវិតដែលតែងតែមាននៅក្នុងចំណោមអ្នកជឿដែលជាគ្រីស្ទាន។ ព្រះវិញ្ញាណបរិសុទ្ធទតឃើញនិងមានព្រះហឫទ័យព្រួយ រីឯលោកិយដែលនៅជុំវិញយើងឃើញខ្នាតនៃជីវិតនោះ ហើយក៏ស្អប់យើង។ យើងពិតជាត្រូវការឲ្យមានមនុស្សប្រុសស្រីដែលដើរជាមួយព្រះជាម្ចាស់ដូចជាពួកបរិសុទ្ធនៅក្នុងសម័យព្រះគម្ពីរថែមទៀត! តើការលះកាត់ខ្លួនឯងរបស់យើងនៅឯណា? តើការញែកចេញពីរបស់លោកិយរបស់យើងនៅឯណា? តើការបដិសេធនូវការស្រណុកសុខស្រួលរបស់យើងនៅឯណា? ចូរយើងមានខ្នាតនៃជីវិតបរិសុទ្ធឲ្យបានខ្ពស់ជាងមុនចុះ។

## ៤. សម័យដែលយើងរស់នៅនេះតម្រូវឲ្យយើងមានសេចក្តីខ្ជាប់ខ្ជួននៅក្នុងការទទួលសេចក្តីល្អសំរាប់ព្រលឹងរបស់យើង

ចូរយើងកុំភ្លេចឲ្យសោះនូវសកម្មភាពទាំងឡាយខាងសេចក្តីជំនឿរបស់យើងដែលយើងធ្វើជាសាធារណៈ ត្រូវតែស៊ីសង្វាក់គ្នានឹងការអនុវត្តន៍សេចក្តីជំនឿនៅក្នុងភាពឯកជនផងដែរ។ មិនមែនមានន័យថា ខ្ញុំចង់ឃើញការធ្លាក់ចុះសកម្មភាពនៃសេចក្តីជំនឿដែលធ្វើជាសាធារណៈនោះទេ ប៉ុន្តែខ្ញុំពិតជាចង់ឃើញពីការកើនឡើងនៃសេចក្តីជំនឿក្នុងភាពឯកជនផងដែរ គឺជាសកម្មភាពជំនឿរវាងអ្នកជឿម្នាក់និងព្រះជាម្ចាស់។ សម័យកាលតម្រូវឲ្យយើងរាល់គ្នាយកចិត្តទុកដាក់ថែមទៀតចំពោះការប្រកបផ្ទាល់ខ្លួនរបស់យើងម្នាក់ៗជាមួយនឹងព្រះជាម្ចាស់។

ក) ចូរយើងអធិស្ឋានកាន់តែស្មោះត្រង់ឡើងដោយផ្ទាល់ខ្លួនម្នាក់ៗ។ នៅពេលដែលអ្នកជឿមិនមានលក្ខណៈដូចជាព្រះគ្រីស្ទជាសាធារណៈ ពីព្រោះតែពួកគេមានការធ្វេសប្រហែសចំពោះការប្រកបផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗជាមួយនឹងព្រះជាម្ចាស់ ជាយូរមកហើយ។

ខ) ចូរយើងកាន់តែយកចិត្តទុកដាក់ឡើងនៅក្នុងការអានព្រះគម្ពីរ។ ការមិនអើពើចំពោះបទគម្ពីរនៃសេចក្តីពិត នឹងនាំទៅកាន់កំហុសជាច្រើននៅក្នុងការគិត ហើយធ្វើឲ្យខ្លួនយើងក្លាយជារំពាដ៏ងាយស្រួលរបស់អារក្ស។

គ) ចូរយើងថែររក្សាទម្លាប់នៃការសញ្ជឹងគិតផ្ទាល់ខ្លួនរបស់យើង។ យើងត្រូវការពេលវេលាដើម្បីអង្គុយដោយស្ងៀមស្ងាត់ ហើយពិចារណាដោយយកចិត្តទុកដាក់ពីស្ថានភាពខាងព្រលឹងវិញ្ញាណរបស់យើង ដើម្បីឲ្យយើងមានសេចក្តីប្រកបជាមួយព្រះជាម្ចាស់និងសេចក្តីពិតនៃព្រះគម្ពីរ។ សេចក្តីខាងព្រលឹងវិញ្ញាណរបស់យើង ពឹងជាចំបងលើការប្រកបផ្ទាល់ខ្លួនរបស់យើងម្នាក់ៗជាមួយនឹងព្រះជាម្ចាស់។ *ត្រូវឲ្យចូលទៅក្នុងបន្ទប់ ហើយបិទទ្វារ* គឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែលត្រូវបានគេធ្វេសប្រហែសយ៉ាងខ្លាំងនៅសម័យនេះ (ម៉ាថាយ ៦:៦)។

តើខ្ញុំអាចទុកសំនួរមួយចំនួនសំរាប់អ្នកបានទេ? ឧទាហរណ៍៖ តើអ្នកមើលឃើញពីគ្រោះថ្នាក់ជាក់លាក់ណាខ្លះនៅក្នុងសម័យដែលអ្នករស់នៅនេះដែរឬទេ? ហើយនៅក្នុងពន្លឺនៃការគ្រោះថ្នាក់ទាំងអស់នោះ តើអ្នកប្រាកដច្បាស់ឬទេដែលអ្នកធ្វើការទាំងនោះសំរាប់ជាសេចក្តីល្អដល់ព្រលឹងរបស់អ្នក? ចូរភ្ញាក់រលើកពីភាពមិនច្បាស់អំពីសេចក្តីពិតនៅក្នុងនាមជាសេចក្តីសប្បុរសនិងការអត់ធ្មត់ចុះ។ *បងប្អូនអើយ គួរឲ្យអ្នករាល់គ្នាមានចិត្តឧស្សាហ៍វិញ ដើម្បីនឹងធ្វើឲ្យដំណើរដែលទ្រង់ហៅ ហើយរើសតាំងអ្នករាល់គ្នា បានពិតប្រាកដឡើង* គឺជាដំបូន្មាន ដែលសាវក ពេត្រុសទូន្មាន

ដល់អ្នកជឿដែលរស់នៅក្នុងសម័យមួយដែលមានគ្រូបង្រៀនក្លែងក្លាយជាច្រើន ដែលបង្កបញ្ហាដល់ពួកជំនុំ (២ពេត្រុស ១:១០)។

នៅចុងបញ្ចប់ នៅក្នុងគំនិតនៃគ្រោះថ្នាក់ខាងព្រលឹងវិញ្ញាណនៃសម័យដែលយើងកំពុងរស់នៅនេះ តើយើងកំពុងតែខំធ្វើគ្រប់ការល្អខាងវិញ្ញាណដល់ព្រលឹងអ្នកដទៃដែរឬទេ? មានការដែលត្រូវធ្វើច្រើនណាស់ ដូច្នេះត្រូវប្រើគ្រប់ឱកាសដែលអ្នកអាច ដើម្បីប្រកាសដំណឹងល្អដល់អ្នកដទៃទៀត។ ចូរចាំថា ជាញឹកញាប់ ព្រះជាម្ចាស់ធ្វើការជាមួយការដ៏តូចទាបបំផុតនៃអ្នកបម្រើរបស់ទ្រង់។ ចូរប្តេជ្ញាចិត្តថា កុំទៅនគរស្ថានសួគ៌តែម្នាក់ឯងឲ្យសោះ!

# ជំពូក ២០

## ព្រះគ្រីស្ទ ទ្រង់ជាគ្រប់ទាំងអស់

*ព្រះគ្រីស្ទ ទ្រង់ជាគ្រប់ទាំងអស់...ហើយទ្រង់ក៏គង់នៅក្នុងគ្រប់ទាំងអស់ផង* (កូល៉ុស ៣:១១)។

ព្រះបន្ទូលបែបនេះមានតិចណាស់ ព្រមទាំងខ្លីទៀត។ ប៉ុន្តែព្រះបន្ទូលនេះពោរពេញដោយអត្ថន័យសំរាប់អ្នកជឿពិតប្រាកដ។ ព្រះបន្ទូលទាំងនេះជាខ្លឹមសារ និងអត្ថន័យដ៏សំខាន់បំផុតនៃជំនឿគ្រីស្ទាន។ ប្រសិនបើយើងយល់ពាក្យទាំងនេះនៅក្នុងចិត្ត នោះយើងអាចនឹងមានទំនុកចិត្តថា សេចក្តីជំនឿរបស់យើងកំពុងតែនាំយើងតាមទិសដៅដែលត្រឹមត្រូវ។ នោះជាមូលហេតុដោយខ្ញុំមានបំណងចង់បញ្ចប់សៀវភៅនេះដោយជំពូកអំពីព្រះបន្ទូលដ៏គួរឲ្យកត់សម្គាល់នេះ។ អស់អ្នកណាដែលប្រដេញតាមសេចក្តីបរិសុទ្ធ នឹងមិនរីកចំរើនបានទេ លុះត្រាតែពួកគេបានដាក់ព្រះគ្រីស្ទនៅក្នុងការគិតរបស់ពួកគេម្នាក់ៗ។

### ១. ចូរយើងយល់ថា ព្រះគ្រីស្ទ ទ្រង់ជាគ្រប់ទាំងអស់ គ្រប់ទាំងអស់នៃគំនិតរបស់ព្រះ គឺអំពីមនុស្សជាតិ

ក) មានសម័យមួយដែលលោកិយនេះមិនធ្លាប់មាន។ ពេលនោះមិនទាន់មានភ្នំ សមុទ្រ ផ្កាយ ឬអ្វីណាមួយបានកើតឡើងនៅឡើយទេ គឺមិនមានជីវិតអ្វីណាមួយ ក៏មិនមានមនុស្សជាតិណាសោះ។ តើពេលនោះព្រះគ្រីស្ទគង់នៅឯណា? សូម្បីតែនៅពេលនោះ ព្រះគ្រីស្ទបានគង់នៅជាមួយនឹងព្រះ ហើយទ្រង់នោះឯងជាព្រះ ហើយទ្រង់ស្មើជាមួយនឹងព្រះ (យ៉ូហាន ១:១; ភីលីព ២:៦)។ ព្រះយេស៊ូវបានមានបន្ទូលពីសិរីល្អដែលទ្រង់មាន មុនពេលលោកិយនេះ៖ *ឱព្រះវរបិតាអើយ សូមដំកើងទូលបង្គំឡើងជាមួយនឹងទ្រង់ផង ដោយសិរីល្អដែលទូលបង្គំមានជាមួយនឹងទ្រង់ក្នុងកាលដែលលោកីយ៍មិនទាន់បានកើតនៅឡើយ* (យ៉ូហាន ១៧:៥)។ ហើយសូម្បីតែនៅពេលនោះ ព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះ។ សាវក ពេត្រុស បានសរសេរថា យើងរាល់គ្នាបានទទួលការប្រោសលោះ *ដោយសារព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទវិញ ទុកដូចជាឈាមនៃកូនចៀមឥតខ្ចោះ ឥតស្លាកស្នាម* (១ពេត្រុស ១:១៩, ២០)។

ខ) មានសម័យមួយ ដែលពិភពលោកត្រូវបានបង្កើតនៅក្នុងទំរង់បច្ចុប្បន្នរបស់វា។ ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយ សមុទ្រ ដី ហើយនិងគ្រប់ជីវិតទាំងអស់ត្រូវបានបង្កើតមក។ ហើយនៅក្រោយបំផុត លោក អ័ដាម ដែលជាមនុស្សដំបូងគេ ត្រូវបានបង្កើតមកពីធូលីដី។ តើព្រះគ្រីស្ទគង់នៅឯណា? ចូរអានពីអ្វីដែលព្រះគម្ពីរចែង៖ គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ (យ៉ូហាន ១:៣)។ ហើយក្រោយមកសាវក ប៉ុល បានសរសេរថា *ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី* (កូល៉ុស ១:១៦)។ យើងអាចអាននៅក្នុងព្រះគម្ពីរហេព្រើរ ១:១០ ថា *ឱព្រះអម្ចាស់អើយ កាលដើមដំបូង ទ្រង់បាន*

*បង្កបូសផែនដី ហើយផ្ទៃមេឃក៏ជាការដែលព្រះហស្តទ្រង់ធ្វើដែរ*។ ដូច្នេះ តើអ្នកភ្ញាក់ផ្អើលឬទេ ដែលព្រះអម្ចាស់របស់យើងតែងតែបង្រៀនមេរៀនដែលយកចេញពីពិភពលោកនេះ? នៅពេលដែលទ្រង់មានបន្ទូលពីចៀម ពីត្រី ពីសត្វស្លាប ពីពោត ពីដើមល្វា ហើយនិងដើមទំពាំងបាយជូរ គឺទ្រង់កំពុងតែមានបន្ទូលអំពីរបស់ដែលទ្រង់ផ្ទាល់បានបង្កើតមក!

គ) មានសម័យមួយដែលអំពើបាបបានចូលមកក្នុងលោកិយនេះតាមរយៈការមិនស្តាប់បង្គាប់របស់អ័ដាម និងនាងអេវ៉ា។ ពួកគាត់បាត់បង់នូវនិស្ស័យបរិសុទ្ធដែលពួកគាត់មាន នៅសម័យនៃការបង្កើតរបស់ពួកគេ។ ពួកគេបាត់បង់មិត្តភាព និងការសព្វព្រះទ័យរបស់ព្រះ ហើយបានក្លាយជាមនុស្សមានបាបដ៏ពុករលួយហើយគ្មានទីពឹង។ អំពើបាបរបស់ពួកគេបានក្លាយជារនាំងរវាងពួកគេ និងព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់ពួកគេ។ ប្រសិនបើទ្រង់ចាត់ការពួកគេតាមការដែលពួកគេសមទទួល នោះនឹងគ្មានសង្ឃឹមអ្វីសោះសំរាប់អ្នកដែលកើតមកពីពួកគេ ក្រៅពីសេចក្តីស្លាប់និងស្ថាននរកដ៏នៅអស់កល្ប។ តើពេលនោះ ព្រះគ្រីស្ទទ្រង់គង់នៅឯណា?

ថ្ងៃដែលព្រះគ្រីស្ទបានបើកសំដែងអង្គទ្រង់ឲ្យបានស្គាល់ គឺជាសេចក្តីសង្ឃឹមតែមួយគត់នៃសេចក្តីសង្គ្រោះរបស់មនុស្សមានបាប។ ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់សត្វពស់ថា *អញនឹងធ្វើឲ្យឯង ហើយនិងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ* (លោកុប្បត្តិ ៣:១៥)។ និយាយឲ្យស្រួលស្តាប់ទៅ គឺមានព្រះអង្គសង្គ្រោះមួយអង្គដែលប្រសូតពីស្ត្រីនឹងយកឈ្នះអារក្ស។ មិនដែលមាននាមឈ្មោះណាដែលគេស្គាល់ អាចធ្វើការនេះបាន ក្រៅពីព្រះនាមព្រះយេស៊ូវគ្រីស្ទឡើយ។

ឃ) មានពេលមួយដែលប្រជាជាតិនៅផែនដីបានកើតមកអត់ស្គាល់ព្រះជាម្ចាស់។ ជនជាតិអេស៊ីព ជនជាតិអាស៊ីរី ជនជាតិពើស៊ី ជនជាតិក្រិក ជនជាតិរ៉ូម សុទ្ធតែបានកើតមកជ្រមុជក្នុងជំនឿលើជោគវាសនានិងការថ្វាយបង្គំរូបព្រះ។ កវី អ្នកប្រវត្តិសាស្ត្រ និងទស្សនវិទូ សុទ្ធតែបង្ហាញឲ្យឃើញថា ពួកគេមិនអាចស្វែងរកព្រះជាម្ចាស់ឃើញដោយកំលាំងបញ្ញារបស់ពួកគេបានទេ។ *ដ្បិតដោយព្រោះព្រះទ្រង់បានសំរេចតាមប្រាជ្ញានៃទ្រង់ថា មនុស្សលោកនឹងរកស្គាល់ព្រះដោយអាងប្រាជ្ញាខ្លួនមិនបានទេ* (១កូរិនថូស ១:២១)។ ក្រៅពីជនជាតិយូដាមួយចំនួន មនុស្សនៅក្នុងលោកិយទាំងមូលបានស្លាប់ខាងព្រលឹងវិញ្ញាណនៅក្នុងការមិនយល់និងអំពើបាប។ តើពេលនោះព្រះគ្រីស្ទបានធ្វើអ្វី?

ទ្រង់បានលះចោលសិរីល្អដ៏អស់កល្បដែលទ្រង់មានជាមួយព្រះជាម្ចាស់ដ៏ជាព្រះវរបិតា ហើយបានយាងមកក្នុងលោកិយដ៏ទមិឡល្មើសនេះ ដើម្បីប្រទានផ្លូវសង្គ្រោះមួយសំរាប់មនុស្សមានបាបទាំងអស់នោះ។ ទ្រង់បានយកនិស្ស័យជាមនុស្សរបស់យើង ហើយបានកើតមកជាមនុស្សម្នាក់។ ជាមនុស្សម្នាក់ ទ្រង់បានធ្វើតាមបំណងព្រះហឫទ័យព្រះវរបិតាយ៉ាងគ្រប់លក្ខណ៍ ដែលពួកយើងរាល់គ្នាគួរធ្វើដូចទ្រង់ដែរ តែយើងអត់បានធ្វើ ដោយព្រោះអំពើបាបរបស់យើង។ នៅលើឈើឆ្កាងទ្រង់បានទទួលរងសេចក្តីក្រោធរបស់ព្រះ ដែលយើងរាល់គ្នាគួរទទួល។ ដូច្នេះហើយបានជាទ្រង់យកសេចក្តីសុចរិតរបស់ទ្រង់ផ្ទាល់ចូលមកក្នុងលោកិយនេះ ដោយសេចក្តីសុចរិតនោះ ទ្រង់បានប្រោសលោះមនុស្សមានបាប។ *ដែលទ្រង់ត្រូវគេបញ្ជូនទៅឲ្យមានទោស ដោយព្រោះអំពើរំលងរបស់យើងរាល់គ្នា ហើយបានប្រោសឲ្យមានព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឲ្យយើងរាល់គ្នាបានរាប់ជាសុចរិត* (រ៉ូម ៤:២៥)។ ទ្រង់បានយាងត្រឡប់ទៅស្ថានសួគ៌ទៅគង់ជាមួយព្រះវរបិតាវិញ

ហើយឥឡូវនេះទ្រង់បានប្រទានសេចក្ដីសង្គ្រោះដល់អស់អ្នកដែលមកឯទ្រង់ដោយគ្រាន់តែជឿទុកចិត្ត។

ង) ពេលមួយនឹងមក ដែលអំពើបាបនឹងបាត់ពីលោកិយនេះទៅ។ នឹងមានស្ថានសួគ៌ថ្មីនិងផែនដីថ្មី។ *វារាល់គ្នានឹងមិនធ្វើទុក្ខ ឬបំផ្លាញគ្នា នៅគ្រប់លើភ្នំបរិសុទ្ធរបស់អញ ដ្បិតគ្រប់ទាំងអស់នឹងស្គាល់ព្រះយេហូវ៉ា នៅពេញពាសលើផែនដី ដូចជាទឹកនៅពេញពាសក្នុងសមុទ្រដែរ* (អេសាយ ១១:៩)។ ហើយពេលនោះ តើព្រះយេស៊ូវនឹងធ្វើអ្វី? តើទ្រង់នឹងធ្វើអ្វី? ទ្រង់នឹងធ្វើជាស្ដេច! ទ្រង់នឹងយាងមកម្ដងទៀតប្រកបដោយអំណាចអស្ចារ្យនិងសិរីល្អ ហើយពិភពលោកនេះនឹងត្រឡប់ជានគររបស់ទ្រង់។ គ្រប់ទាំងជង្គង់នឹងលុតចុះនៅចំពោះទ្រង់ ហើយគ្រប់ទាំងអណ្ដាតនឹងថ្លែងថា ទ្រង់គឺជាព្រះអម្ចាស់។ នគររបស់ទ្រង់នឹងជានគរដែលស្ថិតស្ថេរអស់កល្ប មិនដែលបាត់ទៅ ឬត្រូវបំផ្លាញឡើយ។ ផែនដីទាំងមូលនឹងជារបស់ទ្រង់! ចូរមើលពីអ្វីដែលព្រះគម្ពីរបាននិយាយអំពីពេលវេលាដ៏ល្អអស្ចារ្យនេះ។ នៅក្នុងព្រះគម្ពីរទំនុកដំកើង ២:៨, ដានីយ៉ែល ៧:១៤, ម៉ាថាយ ២៤:៣០, ភីលីព ២:១០, ១១ និងវិវរណៈ ១១:១៥។

ច) នឹងមានថ្ងៃមួយមកដល់ ដែលមនុស្សគ្រប់រូបនឹងទទួលការជំនុំជំរះ។ សមុទ្រនឹងប្រគល់មនុស្សស្លាប់នៅក្នុងសមុទ្រមកវិញ សេចក្ដីស្លាប់និងស្ថាននរកនឹងប្រគល់មនុស្សស្លាប់មក គ្រប់គ្នានឹងទទួលការជំនុំជំរះទៅតាមរបៀបដែលពួកគេបានរស់នៅជាយ៉ាងណា។ ហើយនៅពេលនោះព្រះគ្រីស្ទនឹងគង់នៅឯណា? ព្រះគ្រីស្ទផ្ទាល់គឺជាចៅក្រម! *ដ្បិតយើងទាំងអស់គ្នាត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រីស្ទ ដើម្បីឲ្យគ្រប់គ្នាបានទទួលតាមការដែលបានធ្វើ ពីកាលនៅក្នុងរូបកាយរៀងខ្លួន ទោះល្អឬអាក្រក់ក្ដី* (២កូរិនថូស ៥:១០)។

ពិតមែនហើយ យើងគួរគិតឲ្យបានល្អអំពីការទាំងនេះ។ អស់អ្នកណាដែលគិតតែបន្តិចបន្តួចពីព្រះគ្រីស្ទ អ្នកនោះគិតខុសពីព្រះវរបិតា! គ្រប់ទាំងគំនិតរបស់ព្រះអំពីការងារក្នុងលោកិយនេះហើយនិងមនុស្សរបស់លោកិយនេះ ព្រះគ្រីស្ទត្រូវបានប្រទាននូវកន្លែងកិត្តិយស។ ការគិតតែបន្តិចបន្តួចអំពីទ្រង់ គឺជាការស្អប់ដល់ម្នាក់ដែលព្រះជាម្ចាស់គិតថាខ្ពស់បំផុត។ ច្បាស់ណាស់នៅពេលដែលយើងអានថា *អ្នកណាដែលមិនគោរពប្រតិបត្តិដល់ព្រះរាជបុត្រា នោះក៏មិនគោរពប្រតិបត្តិដល់ព្រះវរបិតា ដែលចាត់ឲ្យទ្រង់មកដែរ* (យ៉ូហាន ៥:២៣)។

## ២. ចូរយើងយល់ថា ព្រះគ្រីស្ទគង់នៅគ្រប់កណ្ឌនៃព្រះគម្ពីរទាំងមូល

គេអាចរកឃើញព្រះគ្រីស្ទនៅគ្រប់ទាំងកណ្ឌគម្ពីរសញ្ញាចាស់និងកណ្ឌគម្ពីរសញ្ញាថ្មី។ គេមើលមិនសូវឃើញច្បាស់នៅកណ្ឌគម្ពីរនៅខាងដើម ប៉ុន្តែគេឃើញយ៉ាងច្បាស់ជាងនៅកណ្ឌកណ្ដាលនិងកាន់តែច្បាស់ខាងចុងនៃព្រះគម្ពីរ។ ប៉ុន្តែតាមពិតទៅ ទ្រង់គង់នៅគ្រប់ទីកន្លែង។ យញ្ញបូជារបស់ព្រះគ្រីស្ទនៅលើឈើឆ្កាងហើយនិងនគររបស់ទ្រង់គឺជាអ្វីដែលយើងត្រូវចាំនៅក្នុងចិត្ត នៅពេលយើងអានផ្នែកណាក៏ដោយនៃបទគម្ពីរ។ ទ្រង់ជាគន្លឹះនៃការយល់ដឹងនូវផ្នែកពិបាកយល់ជាច្រើនក្នុងបទគម្ពីរ។ ចូរឲ្យខ្ញុំបង្ហាញនូវអ្វីដែលខ្ញុំចង់និយាយ៖

ក) គឺជាឈាមនិងការឆ្កាងនៃព្រះគ្រីស្ទ ដែលបានបង្ហាញឲ្យឃើញនៅក្នុងឈាមសត្វនៃព្រះគម្ពីរសញ្ញាចាស់។ ឈាមទាំងនោះបានបង្ហាញពីរបៀបដែលឈាមនៃអ្នកជំនួសមួយសំរាប់មនុស្សមានបាប អាចដកអំពើបាបចេញដោយការកំចាយឈាម។ (ហេព្រើរ៩:២២)។ ចូរចងចាំព្រះបន្ទូលដ៏សំខាន់របស់ព្រះយេស៊ូវផងដែរថា៖ នេះជាឈាមខ្ញុំ (ម៉ាថាយ ២៦:២៨)។

ខ)	ជាដង្វាយនៃព្រះគ្រីស្ទដែលអេបិលបានបង្ហាញពេលគាត់បានថ្វាយដង្វាយដែលល្អជាង
ដង្វាយរបស់កាអ៊ីនដែលជាបងប្រុសរបស់គាត់ (លោកុប្បត្តិ ៤)។ នៅក្នុងការថ្វាយសត្វមួយពីហ្វូងសត្វរបស់គាត់ ជាអ្នកជំនួសគាត់ អេបិលបានបង្ហាញថា គាត់បានយល់ថា បើគ្មានការចំចាយឈាម នោះក៏គ្មានការអត់ទោសដែរ។

គ) នោះគឺជាព្រះគ្រីស្ទដែលអេណុកបានទាយក្នុងសម័យដ៏អាក្រក់ហួសល្បត់របស់មនុស្សប្រុសស្រីមុនទឹកជំនន់សម័យលោកណូអេ។ នៅពេលនោះគាត់បាននិយាយថា៖ *ដើម្បីនឹងកាត់ទោសដល់គ្រប់មនុស្សទាំងឡាយ ហើយនិងរំឭកពួកទមិលល្មើសទាំងអម្បាលម៉ាន ឲ្យដឹងខ្លួនពីគ្រប់ទាំងការទមិលល្មើស ដែលគេបានប្រព្រឹត្តធ្វើ ដោយចិត្តល្មើស ហើយពីអស់ទាំងសេចក្ដីរឹងទទឹងទាំងប៉ុន្មាន ដែលអស់ពួកទមិលល្មើសដ៏មានបាបទាំងនោះ បានពោលទាស់នឹងទ្រង់*(យូដាស ១:១៥)។

ឃ) គឺជាព្រះគ្រីស្ទ ដែលអ័ប្រាហាំកំពុងតែគិតអំពី នៅពេលដែលគាត់បានជឿដល់សេចក្ដីសន្យារបស់ព្រះដែលថា តាមរយៈម្នាក់នៃពូជរបស់លោក គ្រប់ប្រជាជាតិនឹងបានទទួលព្រះពរ។ នៅពេលព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកសាសន៍យូដាថា *លោកអ័ប្រាហាំ ជាឰយុកោអ្នករាល់គ្នា លោកបានត្រេកអរដោយឃើញគ្រាខ្ញុំ លោកក៏បានឃើញមែន ហើយមានសេចក្ដីរីករាយ*(យ៉ូហាន ៨:៥៦)។

ង) គឺជាព្រះគ្រីស្ទដែលលោកយ៉ាកុបបាននិយាយទៅកាន់កូនប្រុសៗរបស់គាត់ នៅពេលគាត់ហៀមនឹងស្លាប់ថា *ដំបងរាជ្យនឹងមិនដែលឃ្លាតពីយូដា ឬអំណាច*

*គ្រប់គ្រងពីជើងវាឡើយ ដរាបដល់ស៊ីឡូរបានមកដល់ នោះបណ្ដាជនទាំងឡាយនឹងចុះចូលចំពោះទ្រង់*(លោកុប្បត្តិ ៤៩:១០)។

ច) គ្រប់ទាំងពិធីនៃច្បាប់ដែលព្រះជាម្ចាស់បានប្រទានដល់រាស្ត្រអ៊ីស្រាអែល គឺបានតាំងឡើងដើម្បីបង្រៀនពួកគេពីកិច្ចការរបស់ព្រះគ្រីស្ទ ជាព្រះម៉ែស៊ីដែលត្រូវមក។ ដង្វាយពេលព្រឹកនិងដង្វាយពេលល្ងាច ការកំចាយឈាមឥតឈប់ឈរ គ្រឿងសង្ហារិមនៃរោងឧបោសថ សម្ដេចសង្ឃ ពិធីបុណ្យរំលង ថ្ងៃធួននឹងបាបពពែត្រូវបានបណ្ដេញចេញ ទាំងអស់នេះសុទ្ធតែជាគំរូនៃព្រះគ្រីស្ទនិងកិច្ចការរបស់ទ្រង់។

ឆ) គ្រប់ទាំងការអស្ចារ្យដែលកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងវត្តមាននៃប្រជាជនអ៊ីស្រាអែលនៅក្នុងទីហោស្ថាន នៅខណៈពេលដែលពួកគេបានចាកចេញពីប្រទេសអេស៊ីប សុទ្ធតែជាការបង្ហាញពីកិច្ចការរបស់ព្រះគ្រីស្ទ។ បង្គោលពពកនិងបង្គោលភ្លើងនាំផ្លូវ នំម៉ាណាពីស្ថានសួគ៌ ទឹកចេញពីថ្ម ពស់លង្ហិនដែលបណ្ដាជនក្រឡេកមើលដើម្បីគេចពីសេចក្ដីស្លាប់ដែលពស់មានពិសខាំ ទាំងអស់នេះនិងការដទៃទៀតសុទ្ធតែដើម្បីបង្រៀនពីនិស្ស័យនៃបេសកកម្មរបស់ព្រះគ្រីស្ទ (១កូរិនថូស ១០:៤)។

ជ) គ្រប់ទាំងពួកចៅហ្វាយជាគំរូពីព្រះគ្រីស្ទ នៅពេលពួកគេត្រូវបានតាំងឲ្យធ្វើជាអ្នកសង្គ្រោះនៃពួកអ្នកដែលមានសេចក្ដីរងទុក្ខ។

ឈ) ស្ដេចដាវីឌជាគំរូពីព្រះគ្រីស្ទ។ គាត់ត្រូវបានជ្រើសរើសឲ្យធ្វើជាស្ដេច នៅពេលដែលមានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលផ្ដល់កិត្តិយសនិងគោរព។ គាត់ត្រូវបានគេស្អប់និងបៀតបៀនពីសំណាក់មនុស្សរបស់គាត់ជាច្រើន ប៉ុន្តែនៅទី

បញ្ចប់គាត់គឺជាស្តេចដ៏មានជ័យជំនះ ។ ទាំងអស់នេះសុទ្ធតែរំលឹកដល់យើងអំពីព្រះគ្រីស្ទ ។

៣) គឺជាព្រះគ្រីស្ទហើយដែលពួកហោរ៉ា ចាប់តាំងពីហោរ៉ាអេសាយរហូតដល់ហោរ៉ាម៉ាឡាគី បាននិយាយអំពី។ ជួនកាលគេនិយាយពីការរងទុក្ខរបស់ទ្រង់ ជួនកាលគេនិយាយអំពីសិរីល្អរបស់ទ្រង់។ ជួនកាលពួកគេត្រូវបានបណ្តាលឲ្យនិយាយពីកា រយាងមក លើកទីមួយដ៏ប្រកបដោយការបន្ទាបខ្លួនរបស់ទ្រង់ ជួនកាលនិយាយពីសិរីល្អនៃការយាងមកលើកទីពីររបស់ទ្រង់។ ជួនកាលពួកគេបានឃើញការយាងមកទាំងពីរលើក ហើយនិយាយពីការយាងទាំងពីរលើនោះ ហាក់បីដូចជាការយាងមកទាំងពីរលើករបស់ទ្រង់នោះ គឺតែមួយ ប៉ុន្តែនោះគឺជាព្រះគ្រីស្ទ ដែលទ្រង់តែងតែស្ថិតក្នុងគំនិតរបស់ពួកគេ ។

ង) ព្រះគម្ពីរសញ្ញាថ្មីមានពេញដោយព្រះគ្រីស្ទ ។ ព្រះគម្ពីរដំណឹងល្អនិយាយពីការរស់នៅរបស់ទ្រង់ក្នុងចំណោមរាស្ត្ររបស់ទ្រង់ ព្រះគម្ពីរកិច្ចការគឺជាព្រះគ្រីស្ទដែលត្រូវបានប្រកាសដោយអ្នកជឿដំបូង ។ ព្រះគម្ពីរសំបុត្រផ្តល់នូវសេចក្តីពន្យល់ដ៏មានការប្រុងប្រយ័ត្នពីសេចក្តីបង្រៀនរបស់ព្រះគ្រីស្ទ ព្រះគម្ពីរវិវរណៈពិពណ៌នាពីចុងបញ្ចប់ដែលព្រះគ្រីស្ទនឹងនាំគ្រប់ការទាំងអស់ទៅកាន់ ។

នៅពេលណាក៏ដោយយើងសិក្សាព្រះគម្ពីរ។ ខ្ញុំសូម ទូន្មានដល់បងប្អូនឲ្យចងចាំថាព្រះគ្រីស្ទគឺជាទាំងអស់ក្នុងទាំងអស់។

## ៣. ចូរយើងយល់ថា ព្រះគ្រីស្ទគឺអ្វីៗគ្រប់ទាំងអស់នៅក្នុងបទពិសោធន៍ខាងសេចក្តីជំនឿនៃគ្រីស្ទានគ្រប់រូប

ការនិយាយបែបនេះ មិនមានន័យថា សេចក្តីពិតនៃបទគម្ពីរ ដូចជាគោលលទ្ធិ អំពីព្រះត្រៃឯក ឬក៏គោលលទ្ធិអំពីការជ្រើសរើសរាស្ត្ររបស់ព្រះជាម្ចាស់នឹងជាព្រះវរបិតា គោលលទ្ធិនៃព្រះវិញ្ញាណបរិសុទ្ធដែលឲ្យមនុស្សទាំងនោះបានបរិសុទ្ធ មិនសូវសំខាន់នោះទេ។ ខ្ញុំជឿថា អ្នកជឿអំពីការទៅដល់ស្ថានសួគ៌ នឹងសរសើរដល់ព្រះត្រៃឯកដែលប្រកបដោយព្រះពរ គឺព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាបរិសុទ្ធ ។

ប៉ុន្តែខ្ញុំឃើញភស្តុតាងដ៏ច្បាស់នៅក្នុងបទគម្ពីរ ដែលនោះគឺជាបំណងព្រះបហុទ័យព្រះគឺថា ព្រះគ្រីស្ទគួរតែជាតួសំខាន់ពិសេសនៅក្នុងកិច្ចការសង្គ្រោះដល់ព្រលឹង។ កំណើតនិងការសុគតរបស់ទ្រង់គឺជាមូលដ្ឋាននៃគ្រប់សេចក្តីសង្គ្រោះ។ ព្រះគ្រីស្ទគឺជាផ្លូវ និងជាទ្វារ ហើយតាមរយៈនេះ អ្នកជឿគ្រប់រូបត្រូវតែមកឯព្រះជាម្ចាស់។ សាវក ប៉ុល បានសរសេរទៅកាន់អ្នកជឿមួយចំនួនថា *ព្រះបានសព្វព្រះហឫទ័យ ឲ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់(ព្រះគ្រីស្ទ)* (កូល៉ុស ១:១៩)។ ដូចជាព្រះអាទិត្យចំពោះមេឃយ៉ាងណា ព្រះគ្រីស្ទក៏យ៉ាងនោះដែរចំពោះសេចក្តីជំនឿគ្រីស្ទាន។

ក) ព្រះគ្រីស្ទគឺជាអ្វីៗគ្រប់យ៉ាងទាំងអស់នៅក្នុងការរាប់ជាសុចរិតនៃមនុស្សមានបាបនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់។ តើយើងរាល់គ្នាត្រូវបានទទួលស្គាល់នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ដោយរបៀបណា? នោះមិនមែនដោយការណាមួយដែលយើងបានធ្វើឡើយ! យើងរាល់គ្នាសុទ្ធតែមានទោសដោយព្រោះការល្មើសនឹងច្បាប់របស់ព្រះជាម្ចាស់។ ដូច្នេះតើយើងអាចចូលទៅចំពោះព្រះជាម្ចាស់ដោយរបៀបណា? យើងមិនអាចចូលមកចំពោះព្រះជាម្ចាស់តាមផ្លូវណាទៀតក្រៅពីតាមក្នុងព្រះនាមនៃព្រះយេស៊ូវឡើយ។ ទ្រង់បានសុគតជំនួសមនុស្សទមិឡល្មើស

ហើយយើងអាចទុកចិត្តដល់ទ្រង់បាន។ មានតែព្រះនាមទ្រង់តែមួយប៉ុណ្ណោះជាសេចក្តីល្អ ដែលតាមរយៈសេចក្តីល្អនោះទើបគ្រប់គ្នាអាចរកបាននគរស្ថានសួគ៌។

ចូរយើងកុំភ្លេចថា ព្រះគ្រីស្ទត្រូវតែជាអ្វីៗគ្រប់យ៉ាងដល់អស់អ្នកដែលប្រាថ្នាចង់បានឲ្យបានរាប់ជាសុចរិតនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់។ ចង់ឬមិនចង់យ៉ាងណា យើងត្រូវតែចូលទៅក្នុងនគរស្ថានសួគ៌ក្នុងនាមជាអ្នកសុំទានខាងឯវិញ្ញាណ ដោយពឹងដល់ព្រះគុណនៃព្រះជាម្ចាស់និងអំណោយនៃសេចក្តីសង្គ្រោះចំពោះអស់អ្នកដែលមានសេចក្តីជំនឿលើព្រះគ្រីស្ទតែមួយប៉ុណ្ណោះ។

ខ) ព្រះគ្រីស្ទគឺជាអ្វីៗទាំងអស់នៅក្នុងការញែកជាបរិសុទ្ធរបស់អ្នកជឿ។ សូមកុំយល់ច្រឡំឲ្យសោះ នៅពេលខ្ញុំនិយាយអញ្ចឹង។ ខ្ញុំមិនមានបំណងដើម្បីធ្វើឲ្យកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងអ្នកជឿ មិនសូវសំខាន់នោះទេ។ ប៉ុន្តែអ្វីដែលខ្ញុំកំពុងនិយាយគឺថា គ្មានអ្នកម្នាក់បានបរិសុទ្ធបានឡើយ លុះត្រាណាតែពួកគេមកឯព្រះគ្រីស្ទហើយរួមសហភាពជាមួយនឹងទ្រង់ដោយសេចក្តីជំនឿ។ ព្រះយេស៊ូវផ្ទាល់បានមានបន្ទូលថា *បើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ* (យ៉ូហាន ១៥:៥)។ គ្មានអ្នករីកចំរើនខាងឯសេចក្តីបរិសុទ្ធបានឡើយ លុះត្រាណាតែពួកគេរួមមកជាមួយព្រះគ្រីស្ទ។

គ) ព្រះគ្រីស្ទជាអ្វីៗគ្រប់ទាំងអស់នៅក្នុងសេចក្តីកម្សាន្តនៃអ្នកជឿនៅក្នុងជីវិតនេះ។ អ្នកជឿក៏មានសេចក្តីសោកសង្រេងដូចជាអ្នកជឿឯទៃទៀតដែរ។ ពួកគេមានរូបកាយដែលខ្សោយដូចជាអ្នកឯទៃទៀតដែរ។ ពួកគេមាននិស្ស័យងាយបាក់បែកប្រហែលជាជាងអ្នកឯទៃជាច្រើនផងក៏ថាបាន។ ពួកគេមានសេចក្តីសោកសង្រេងដោយមានការបាត់បង់អ្នកជាទីស្រឡាញ់របស់ពួកគេ ពួកគេមានគំនិតសាច់ឈាមក្នុងការប្រឆាំង និងមានជីវិតដែលគ្រប់លក្ខណ៍ដែលពួកគេត្រូវរស់នៅ។ ជួនកាល

ពួកគេត្រូវទទួលការបៀតបៀន ហើយនិងដូចជាមនុស្សដទៃផ្សេងទៀតដែរ គឺពួកគេនឹងត្រូវស្លាប់។ ប៉ុន្តែគ្រីស្ទានបែបនោះមានការលើកទឹកចិត្តដ៏ធំមួយ ពួកគេមានការលើកទឹកចិត្តពីការដែលពួកគេរួមសហភាពជាមួយព្រះគ្រីស្ទ (ភីលីព ២:១)។ ព្រះគ្រីស្ទគឺជាមិត្តសម្លាញ់ដែលជិតស្និតជាងបងប្អូនទៅទៀត។ ទ្រង់តែមួយអង្គអាចកំសាន្តចិត្តគ្រប់គ្រាន់ដល់រាស្ត្ររបស់ទ្រង់។ របៀបដែលអ្នកជឿម្នាក់ស៊ូទ្រាំនឹងបញ្ហានៃជីវិត ហាក់ដូចជាអស្ចារ្យណាស់ ប៉ុន្តែហេតុផលគឺថាព្រះគ្រីស្ទបានប្រទានឲ្យពួកគេនូវការកំសាន្តចិត្តដ៏អស្ចារ្យវិញ។

ឃ) ព្រះគ្រីស្ទគឺជាអ្វីៗទាំងអស់នៅក្នុងសេចក្តីសង្ឃឹមរបស់គ្រីស្ទានសំរាប់ពេលអនាគត។ មនុស្សស្ទើរតែគ្រប់រូបសុទ្ធតែមានសេចក្តីសង្ឃឹមសំរាប់ពេលអនាគត។ ប៉ុន្តែសេចក្តីសង្ឃឹមភាគច្រើននៃសេចក្តីសង្ឃឹមទាំងនោះមិនមានមូលដ្ឋានរឹងមាំទេ។ អ្នកមិនជឿមិនមានភាពប្រាកដច្បាស់អំពីសេចក្តីសង្ឃឹមសំរាប់អនាគតទេ។ សេចក្តីជំនឿសំរាប់អនាគតរបស់គ្រីស្ទានមានមូលដ្ឋានលើសេចក្តីពិតដែលថា ព្រះយេស៊ូវគ្រីស្ទកំពុងយាងមកម្តងទៀត គឺយាងមកដើម្បីប្រមូលសមាជិកគ្រួសារទាំងអស់របស់ទ្រង់ទៅនៅជាមួយទ្រង់អស់កល្បជានិច្ច។ ដូច្នេះអ្នកជឿអាចរង់ចាំដោយអត់ធ្មត់សំរាប់ពេលអនាគត។ ពួកគេអាចទ្រាំទ្រជាមួយសេចក្តីលំបាកលំបិនដោយមិនរអ៊ូរទាំ ពីព្រោះពួកគេកំពុងរង់ចាំដោយដឹងប្រាកដពីការយាងមកវិញរបស់ព្រះអម្ចាស់របស់ពួកគេ។

អ្នកជឿអាចនៅតែល្ហមនៅក្នុងគ្រប់ការទាំងអស់នៅពេលឥឡូវនេះ ពីព្រោះពួកគេដឹងថាទ្រព្យសម្បត្តិរបស់ពួកគេនៅឯនគរស្ថានសួគ៌ឯណោះ សេចក្តីល្អរបស់ពួកគេមិនទាន់មកនៅឡើយទេ! លោកិយនេះមិនមែនជាទីសំរាករបស់យើងទេ ប៉ុន្តែគ្រាន់តែជាសណ្ឋាគារប៉ុណ្ណោះ។ សណ្ឋាគារមិនមែនជាផ្ទះទេ។ ព្រះគ្រីស្ទនឹងមក

នគរស្ថានសួគ៌នឹងមក។ តែប៉ុណ្ណឹងវាបានហើយ។ *ព្រលឹងខ្ញុំអើយ ចូរនៅស្ងៀមចាំតែព្រះចុះ ដ្បិតសេចក្តីសង្ឃឹមរបស់ខ្ញុំ នោះមកតែពីទ្រង់ទេ* (ទំនុកដំកើង ៦២:៥)។

## ៩. ចូរយើងយល់ថា ព្រះគ្រីស្ទនឹងជាអ្វីៗគ្រប់ទាំងអស់នៅនគរស្ថានសួគ៌

មិនមែនជាការងាយស្រួលទេក្នុងការនិយាយអំពីចំនុចនេះ ដ្បិតខ្ញុំមិនអាចនិយាយច្រើនអំពីពិភពមួយដែលគេមិនដែលឃើញនិងមិនដែលស្គាល់ ដូចជានគរស្ថានសួគ៌នេះឯង! ប៉ុន្តែការនេះ ខ្ញុំដឹងថា មនុស្សប្រុសស្រីដែលទៅដល់ស្ថានសួគ៌ទាំងអស់នឹងដឹងថាសូម្បីតែនៅទីនោះក៏មានព្រះគ្រីស្ទនៅក្នុងគ្រប់ទាំងអស់ផងដែរ។

ដូចជាអាសនានៅក្នុងរោងឧបោសថនិងព្រះវិហារនៃសម័យសញ្ញាចាស់ផងដែរ ស្នាមរបួសនៃព្រះគ្រីស្ទដែលធ្លាប់ត្រូវបានគេឆ្កាង នឹងក្លាយជារបស់ដ៏អស្ចារ្យមួយនៃសេចក្តីសរសើរនៅនគរស្ថានសួគ៌។ នៅកណ្តាលបល្ល័ង្កនៃព្រះ នឹងមានព្រះមួយអង្គដែលមើលទៅដូចជា *កូនចៀម១ ដែលមើលទៅដូចជាបានសំឡាប់ហើយ* (វិវរណៈ ៥:៦)។ បទចម្រៀងនៃពួកអ្នកដែលរស់នៅនគរស្ថានសួគ៌នឹងបន្លឺសំឡេងឡើងថា *កូនចៀមដែលគេបានសំឡាប់ នោះគួរនឹងបានព្រះចេស្តា ទ្រព្យសម្បត្តិ ប្រាជ្ញា ឥទ្ធិឫទ្ធិ កិត្តិនាម សិរីល្អ និងព្រះពរ* (វិវរណៈ ៥:១២)។

វត្តមាននៃព្រះគ្រីស្ទនឹងនៅក្នុងគ្រប់ទាំងអស់នៅនគរស្ថានសួគ៌។ យើងនឹងឃើញព្រះភ័ក្ត្រទ្រង់ ឮព្រះសូរសៀងរបស់ទ្រង់ហើយនិងនិយាយជាមួយទ្រង់ដូចជាមិត្តសំឡាញ់និយាយគ្នា។ វត្តមានរបស់ទ្រង់នឹងធ្វើឲ្យសេចក្តីត្រូវការរបស់យើងរាល់គ្នាបានស្កប់ស្កល់ចិត្ត។ ការថ្វាយបង្គំដល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទនឹងជាការងារឥតឈប់ឈររបស់ពួកអ្នកដែលរស់នៅនគរស្ថានសួគ៌។ នៅទីបំផុត អ្នកជឿនឹងអាចធ្វើការសំរាប់ទ្រង់ដោយគ្មានការរំខាន ហើយនិងបំរើទ្រង់ដោយមិនមានការហត់នឿយ។

នគរស្ថានសួគ៌នឹងជាកន្លែងដ៏ផ្អែមល្ហែមនិងប្រកបដោយសិរីរុងរឿងយ៉ាងណាហ្ន៎ សំរាប់ពួកអ្នកដែលស្រឡាញ់ព្រះអម្ចាស់យេស៊ូវនៅពេលពួកគេរស់នៅលើផែនដីនេះ។ ប៉ុន្តែគួរឲ្យសោកស្តាយ មនុស្សជាច្រើនដែលនិយាយពីការទៅនគរស្ថានសួគ៌នៅពេលគេស្លាប់ គេបែរជាមិនមានការស្គាល់គ្នាពិតប្រាកដជាមួយនឹងព្រះគ្រីស្ទទៅវិញ។ នៅក្នុងជីវិតនេះនៅឡើយគេមិនបានគោរពប្រតិបត្តិដល់ទ្រង់ទេ ដូច្នេះតើពួកគេនឹងធ្វើអ្វីនៅឯនគរស្ថានសួគ៌? ពួកគេមិនមានការប្រកបគ្នាជាមួយទ្រង់នៅលើផែនដីនេះ ដូច្នេះតើពួកគេនឹងធ្វើអ្វីនៅឯនគរស្ថានសួគ៌? ពួកគេមិនចូលចិត្តសេចក្តីខាងវិញ្ញាណនៅលើផែនដីនេះទេ ដូច្នេះតើពួកគេនឹងរកបានសេចក្តីអំណរនៅនគរស្ថានសួគ៌បានដោយរបៀបណា?

ខ្ញុំសង្ឃឹមថា ខ្ញុំបានចាប់ផ្តើមបង្ហាញបងប្អូនពីអ្វីដែលមានន័យជ្រាលជ្រៅនៅក្នុងឃ្លាថា ព្រះគ្រីស្ទគឺគ្រប់ទាំងអស់។ មានការជាច្រើនទៀតដែលខ្ញុំអាចនឹងនិយាយ។ ឧទាហរណ៍៖ ព្រះគ្រីស្ទគួរតែជាអ្វីទាំងអស់នៅក្នុងជីវិតនិងការថ្វាយបង្គំរបស់ពួកជំនុំគ្រីស្ទានទាំងអស់។ ពិធីដ៏ស្រស់បំព្រង អាគារដ៏ស្រស់ស្អាត ក្រុមផ្សាយដំណឹងល្អដ៏មានជំនាញ ប៉ុន្តែទាំងអស់នេះឥតប្រយោជន៍ទទេប្រសិនបើពួកគេមិនបានថ្វាយសិរីល្អដល់ព្រះគ្រីស្ទឲ្យខ្ពស់បំផុត។ ពួកជំនុំដែលព្រះគ្រីស្ទមិនមែនជាអ្វីៗគ្រប់ទាំងអស់ នោះគឺគ្រាន់តែជារូបកាយដែលស្លាប់មួយប៉ុណ្ណោះ។

ខ្ញុំក៏អាចនិយាយបានថា ព្រះគ្រីស្ទគួរតែជាគ្រប់ការទាំងអស់នៅក្នុងការបង្រៀននៃគ្រប់ព័ន្ធកិច្ចគ្រីស្ទាន។ គ្រូអធិប្បាយនិងគ្រូបង្រៀនគ្រីស្ទត្រូវតែធ្វើជាទូតដើម្បីយកព្រះរាជសារផ្សាយទៅកាន់លោកិយដែលមិនជឿអំពីព្រះរាជបុត្រារបស់មហាក្សត្រនោះ។ ហើយប្រសិនបើពួកគេបង្រៀនមនុស្សគិតអ្វីផ្សេងទៀតច្រើនជាងនេះ នោះពួកគេមិនសមនឹងធ្វើជាគ្រូប្រកាសដំណឹងល្អនិងគ្រូបង្រៀនគ្រីស្ទានឡើយ។ ព្រះជាម្ចាស់មិនដែលផ្តល់កិត្តិយសដល់ព័ន្ធកិច្ចដែលមិនបង្រៀនថា ព្រះគ្រីស្ទជាគ្រប់ទាំងអស់ឡើយ។

ខ្ញុំអាចនឹងបង្ហាញអ្នកដែរថា ព្រះគម្ពីរហាក់ដូចជាប្រើភាសាឲ្យអស់ពីលទ្ធភាពក្នុងការពិពណ៌នាពីព័ន្ធកិច្ចផ្សេងៗរបស់ព្រះអម្ចាស់យេស៊ូវ។ សម្ដេចសង្ឃ អ្នកសង្រ្គោះ អ្នកប្រោសលោះ ព្រះអង្គសង្គ្រោះ អ្នកមុនគេ អ្នកទទួលជំនួស មេក្រុម ជាអាម៉ែន ឫទ្ធានុភាព ជាព្រះដ៏មានឫទ្ធានុភាព ជាផ្ដល់ប្រឹក្សា ទាំងអស់នេះហើយនិងមានឈ្មោះជាច្រើនទៀតដែលបានប្រទានដល់ព្រះគ្រីស្ទនៅក្នុងបទគម្ពីរ។ របៀបដែលគេពិពណ៌នាពីភាពពោរពេញនៃព្រះគ្រីស្ទហាក់ដូចជាមិនចេះចប់ទេ!

តើព្រះគ្រីស្ទជាគ្រប់ទាំងអស់ដល់អ្នកអានរបស់ខ្ញុំដែរឬទេ? ប្រសិនបើមិនទេ នោះត្រូវរៀនពីអ្វីដែលខ្ញុំបាននិយាយនៅទីនេះចុះ គឺការឥតប្រយោជន៍នៃការខិតខំបន្ថែមលើអ្វីដែលព្រះគ្រីស្ទបានធ្វើសំរេចហើយនៅក្នុងការសង្គ្រោះដល់មនុស្សមានបាប។ អ្នកមិនត្រូវគិតថា សេចក្ដីសង្គ្រោះបានមកដោយព្រះគ្រីស្ទនិងអ្វីមួយដែលអ្នកបានធ្វើឲ្យសោះ។ បែបនោះមានន័យថា អ្នកផ្លាស់ប្ដូរផែនការសង្គ្រោះរបស់ព្រះជាម្ចាស់ ដែលព្រះគ្រីស្ទទ្រង់ជាទាំងអស់ហើយ។

តើព្រះគ្រីស្ទជាទាំងអស់ចំពោះអ្នកឬទេ? ប្រសិនបើមិនទេ នោះចូរអនុវត្តជាប្រយោជន៍ផ្ទាល់ចំពោះព្រះគ្រីស្ទនៅពេលឥឡូវនេះចុះ។ មិនមែនជាការមើលទៅទូកសង្គ្រោះមួយនឹងជួយសង្គ្រោះពួកនាវិកនៃកប៉ាល់ដែលលេចបាននោះទេ ប៉ុន្តែតាមពិតទៅត្រូវចូលទៅក្នុងទូកសង្គ្រោះនោះវិញ។ មិនមែនការដែលមើលទៅនំប៉័ងនឹងជួយដល់មនុស្សឃ្លាននោះទេ ប៉ុន្តែត្រូវញ៉ាំវាវិញ។ ដូច្នេះមិនមែនការស្គាល់ព្រះគ្រីស្ទ ឬសូម្បីតែជឿថាទ្រង់ជាព្រះអង្គសង្គ្រោះ នឹងសង្គ្រោះអ្នកនោះទេ លុះត្រាណាមានទំនាក់ទំនងពិតប្រាកដរវាងអ្នកផ្ទាល់និងទ្រង់ គឺការប្ដេជ្ញាដោយស្ម័គ្រពីចិត្តរបស់អ្នកចំពោះទ្រង់។ អ្នកត្រូវតែនិយាយថា “ព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ខ្ញុំពីព្រោះខ្ញុំបានមកឯទ្រង់ដោយទុកចិត្តនិងដោយជំនឿ ហើយខ្ញុំបានទទួលទ្រង់ទុកជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ”។

លោក ម៉ាទិន លូសើ បាននិយាយថា “សេចក្ដីជំនឿ ធ្វើឲ្យយើងអាចប្រើសព្វនាមកម្មសិទ្ធ។ សូមទទួលយកពីទូលបង្គំនូវពាក្យថា **របស់ទូលបង្គំ** ហើយព្រះ

អង្គុយកពីទូលបង្គំនូវពាក្យថា **ព្រះរបស់ទូលបង្គំ**ចុះ!ចូរយើងរស់នៅពឹងព្រះគ្រីស្ទ។ ចូរយើងរស់នៅជាមួយព្រះគ្រីស្ទ។ ចូរយើងរស់នៅដើម្បីព្រះគ្រីស្ទ។ យ៉ាងនោះ យើងនឹងទទួលបាននូវសេចក្តីមេត្រីដ៏ធំ ហើយបង្ហាញថា *បើអ្នកណាគ្មានសេចក្តីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ* (ហេព្រើរ ១២:១៤)៕